
មហាគ្រោះជាតិខ្មែរ
The Great Danger of Khmer Nation
Composed by a victim :
TIENG-NARITH
In 2012
លុយជំនួយ
លុយខ្ចីបរទេស
លុយចំណូលថវិកាជាតិ
លុយលក់ធនធានធម្មជាតិខ្មែរ
លុយរបរម៉ាហ្វីយ៉ា
រដ្ឋប្រហារ ៥-៦ កក្កដា ១៩៩៧
ភេរវកម្មបោកគ្រាប់បែក ៣០ មីនា ១៩៩៧
សម្លាប់បង្ក្រាបបាតុកម្មខែកញ្ញា ១៩៩៨
ឃាតកម្ម លួចឆក់ប្លន់ ជំរិត ជួញ ដូរគ្រឿងញៀន
ជួញដូរមនុស្ស លក់ដីសម្លប់រាស្ត្រ អភិវឌ្ឍន៍សេដ្ឋកិច្ចយួន
ចិញ្ចឹមជនជាតិយួន យកខ្មែរម្ចាស់ស្រុកធ្វើជាទាសករ
រៀបរៀងដោយ ទៀង ណារិទ្ធ
Khmer Language
ឆ្នាំ 2012

# មហាគ្រោះជាតិខ្មែរ

# *The Great Danger of Khmer Nation*

មាតិការរឿង ទំព័រ

អារម្ភកថា ........................................................................................................ ៣

១-អង្គការឧក្រិដ្ឋជនសំងាត់បាក់គី (Secret Criminal Organization of Backy),........ ៦

២-អង្គការយុវជនពិសេស អេស-អូ-វ៉ាយ (S.O.Y = Special Organization of Youths),. ១៨

៣- អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ Death Squads,...................... ៦៧

៤-អង្គការឧក្រិដ្ឋជនស្របច្បាប់របស់រដ្ឋាភិបាលអាយ៉ងតឹកងកំលាំងប្រដាប់អាវុធ,.............. ៩៤

៥-រចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា:,.................................... ១០១

៦-មូលហេតុអ្វីបានជា ហ៊ុន-សែន គ្រប់គ្រងក្រុមឃាតករយ៉ាងណែនក្នុងដៃយ៉ាងនេះ? ១២១

៧-ល្បិចកាប់ដើមដុតគល់រំលើងរឹសដើម្បីសំរេចបេសកកម្មរំលាយជាតិសាសន៍ខ្មែរ ១៣៣

៨-តើអំណាចផ្តាច់ការផ្តាច់មុខរបស់គណៈបក្សប្រជាជនបានមកពីណា? ១៤១

៩-យុទ្ធសាស្រ្តក្ស័យប្រល័យមរណៈឆ្លងគ្រោះរំដោះមហាគ្រោះរបស់ប្រជាជាតិខ្មែរ: ១៤៣

១០-សន្និដ្ឋាន ១៥៤

១១- កំណត់ហេតុឯកសារ (Notes): ១៥៦

# អារម្ភកថា

ជំរាបមហាគ្រោះរបស់ជាតិខ្មែរគ្រាន់តែជាជ្រុងដ៏សែនតូចមួយនៃបេសកកម្មរំលាយជាតិជាតិសាសន៍ខ្មែររបស់ក្រុងហាណូយតាមរយៈគណៈបក្សប្រជាជនកម្ពុជា បន្ទាប់ពីយួនកុំមុយនីស្ត៍ឈ្លានពានខ្មែរ និងលេបទឹកដីខ្មែរបានសំរេចជាស្ថាពរហើយនោះ នៅមានបញ្ហាសេសសល់គឺជាតិសាសន៍ដែលរស់នៅលើដីកំណើតខ្លួនអាចធ្វើបដិវត្តន៍រើបំរះនៅថ្ងៃណាមួយ ប្រសិនបើជនជាតិខ្មែរមានចំនួនច្រើនយ៉ាងនេះ ដូច្នេះចាំបាច់ត្រូវតែបន្តគោលនយោបាយរំលាយជាតិសាសន៍ខ្មែរ ធ្វើអោយជនជាតិខ្មែរមានចំនួនតិចទៅៗរហូតដល់សេសសល់ត្រឹមតែមួយក្តាប់តូចទុកគ្រាន់លម្ហមតាំងពិពណ៍ដូចជនជាតិចម្ប៉ា ជនជាតិឡាវ និងជនជាតិខ្មែរកម្ពុជាក្រោម ហើយជំនួសដោយនយោបាយសមានកម្ម និងនយោបាយឆ្មុងសាច់ឈាមយួន-ខ្មែរ ចិន-ខ្មែរ ចិន-យួន លាយចំរុះពូជសាសន៍ ដោយយកជនជាតិជាតិខ្មែរធ្វើជាទាសកររបស់យួន របស់ចិននៅលើទឹកដីកំណើតរបស់ខ្លួន។ក្រុងហាណូយអនុវត្តយុទ្ធសាស្ត្រថ្មីដែលហៅថា "**យុទ្ធសាស្រ្តជំហ៊ានតឹង្គក់**" នៅក្នុងការរំលាយពូជសាសន៍ខ្មែរ ដោយបង្កើតបណ្តូញអង្គការឧក្រិដ្ឋជនសំងាត់បន្តកន្ទុយគ្នាជាបណ្តូញខ្សែសង្វាក់ប្រទាក់ក្រឡាចាក់ច្រែះគ្នាយ៉ាងស្មុគស្មាញដូចជា អង្គការឧក្រិដ្ឋជនសំងាត់បាក់គី អេស-អូ-វ៉ាយ និងអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ រួមជាមួយក្រុងកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយ ហ៊ុន-សែន ធ្វើការសំលាប់រង្គាលប្រជារាស្ត្រតាម "យុទ្ធសាស្រ្តជំហ៊ានតឹង្គក់ " គឺសំលាប់តិចៗ សំលាប់តក់ៗ សំលាប់ រយៈយូរ សំលាប់ច្រើនករណីផ្សេងៗគ្នាគឺសំលាប់បានច្រើន ហើយអាចលាក់បាំងភ្នែកសហគមន៍អន្តជាតិ បានយ៉ាងងាយស្រួល។ គណៈបក្សប្រជាជនកម្ពុជាមានប្រភពដើមកំណើតចេញមកពីយួនកុំមុយនីស្ត៍ដែលជាអ្នកបង្កើត និងបន្ទុបពួកគេ ឱ្យស្ថិតនៅលើបល្ល័ងអំណាចដែលសោយអំណាចរហូតដល់បច្ចុប្បន្ននេះ ហើយពួកគេបានយកព្រះមហាក្សត្រធ្វើជាទ្រនាប់ជើងរបស់ពួកគេដើម្បីឈរលើអំណាច ទាត់ធាក់វ៉ាយ ប្រហារសំលាប់ប្រជារាស្ត្រខ្មែរស្រេចតែក្បាលចិត្តដោយគ្រាន់តែយកលេសថាអនុវត្តតាមព្រះហត្ថលេខារបស់ព្រះមហាក្សត្រ ឬធ្វើតាមព្រះរាជតំរិះព្រះមហាក្សត្រតែប៉ុណ្ណោះ។ ទោះបីជាពួកថ្នាក់ដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជាចេញប្រភពមកពីពួកចោរលួចចោរប្លន់ក្មេងពាលក្មេងអាណាថា មិនបានរៀនសូត្រជ្រៅជ្រះក៏ដោយ ប៉ុន្តែពួកគេទទួល

ការហ្វឹកហាត់សិល្បៈសង្គ្រាមពីចៅហ្វាយយួនរបស់ពួកគេ ហើយ ពួកគេមានជំនាញប៉ិនប្រសព្វណាស់ចំពោះខាងរឿងសំលាប់ឃាតកម្ម ការធ្វើភេរវកម្ម ការគំរាមកំហែង ការបំបាក់ស្មារតីប្រជារាស្ត្រខ្មែរអោយភ័យរន្ធត់ខ្លាចបាក់ស្បាត ការប្រើឃាតករក្នុងបណ្តាញខ្សែសង្វាក់ចុច អន្ទាក់ គឺជាជំនាញរបស់ពួកគេនៅក្នុងការក្តោបអំណាច ហើយ **"ចំណុចខ្លាំងរបស់ពួកកុំមុយនីស្ត៍គឺប្រើ ប្រាស់ឃាតកម្ម ទារុណកម្ម និងភេរវកម្ម ធ្វើជាឧបករណ៍តែមួយគត់សំរាប់គ្រប់គ្រងប្រទេស និងត្រួត ត្រាក្តោបក្តាប់ប្រជាជនខ្មែរបានយ៉ាងណែននៅក្នុងដៃ ហើយ ចំណុចខ្សោយរបស់ពួកកុំមុយនីស្តគឺសេដ្ឋកិច្ច តែបើពួកវាមានសេដ្ឋកិច្ចហើយ គឺប្រៀបបីដូចជាសត្វខ្លាដុះស្លាប ធ្វើអ្វីក៏បាន"** ។ ទោះបីជាពួកថ្នាក់ដឹកនាំ កុំមុយនីស្ត៍កំពូល១ របស់គណៈបក្ស ប្រជាជនកម្ពុជាបានសំលាប់ប្រជារាស្ត្រខ្មែររាប់មិនអស់ក៏ដោយ ក៏ពួក គេប៉ិនប្រសព្វធ្វើអោយពិភពខាងក្រៅដូចជា សហគមន៍អន្តរជាតិ មហាអំណាចពិភពសេរីមានសហរដ្ឋអាមេរិកជាមេខ្លោងជាដើម នៅតែយល់ច្រលំស្មានមិនដល់និងភន្ត័ច្រលំថាពួកគេកំពុងតែអនុវត្តលទ្ធិប្រជាធិបតេយ្យ ដោយគ្រាន់ទុកឱ្យមានគណៈបក្សប្រឆាំងធ្វើអ្វីមិនកើតមានតួនាទីត្រឹមតែក្តាន់ក្តអោយគណៈបក្សប្រជាជននោមតែប៉ុណ្ណោះ ហើយគណៈបក្សប្រជាជនកម្ពុជាដែលជាស្ថានិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅកម្ពុជា បានផ្តល់កៅអីុតែបន្តិចបន្តួចដល់ពួកគណៈបក្សប្រឆាំងដើម្បីបិទផ្លាកថា ពួកគេអនុវត្តលិទ្ធិប្រជាធិបតេយ្យព្រោះមានគណៈបក្សប្រឆាំងនៅក្នុងរដ្ឋាភិបាល ហើយយកពាក្យលទ្ធិប្រជាធិបតេយ្យនេះធ្វើជាឧបករណ៍ ធ្វើជានុយបញ្ឆោត ទៅស្ទូចលុយធំ ជារន្ទា ជាឈ្នាន់ សំរាប់អោយគណៈប្រជាជនកម្ពុជាយកទៅបោកប្រាស់ពួកសហគមន៍អន្តរជាតិ អង្គការអន្តរជាតិ និងបណ្តាប្រទេសមហាអំណាចនានាមានសហរដ្ឋអាមេរិកជាមេក្លោង ទៅស្ទូចយកលុយជំនួយអន្តរជាតិ និង លុយកំម្ចីបរទេសរាប់រយពាន់លានដុល្លាសហរដ្ឋអាមេរិក ទៅចាក់បញ្ចូលក្នុងមាត់បិសាចកុំមុយនីស្ត៍ ជាហេតុធ្វើអោយពួកកុំមុយនីស្ត៍មានកំលាំងខ្លាំងក្លាមហិមារ ដោយយកលុយជំនួយបរទេសលុយកម្ចីបរទេស លុយចំណូល ថវិការជាតិ លុយលក់ធនធានធម្មជាតិ និងលុយរបរម៉ាហ្វីយ៉ាអស់ទាំងនោះទៅពង្រឹង និងពង្រីកបណ្តាញអង្គការឧក្រិដ្ឋជនសំងាត់ បណ្តាញឃាតករភេរវករ បណ្តាញចោរលួចឆក់ប្លន់ជីវិត ជួញដូរគ្រឿងញៀនជួញដូរមនុស្ស និង យកទៅបំពាក់ឧបករណ៍ចារកម្មអសន្សាណ្វូទំនើប រួមទាំង

ពង្រីកប្រព័ន្ធចារជនទាំង៥ ទៅបំផ្លាញជាតិខ្មែរ កំទេចរាល់សរសរទ្រូងខ្មែរ បោសសំអាតពួកវរៈជនខ្មែរ គាស់រំលើងពួកអ្នកជាតិនិយមខ្មែរដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ហើយរដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយគណៈបក្សប្រជាជនកម្ពុជា និង ហ៊ុន-សែន ស្អីគេនោះ បានព្យាយាមបង្កើតកលយុទ្ធនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ដីសែនស្មុគស្មាញ ប្រទាក់ក្រឡាចាក់ច្រែះគ្នាជាមួយកងកំលាំងប្រដាប់អាវុធ និងប្រពន្ធ័ចារកម្មចំរុះយួន-ខ្មែរ អនុវត្តយុទ្ធសាស្រ្ត"**ជំហ៊ានតឹង្គក់**"ដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ដោយធ្វើការលួចឆក់បួន់ជិវិត ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន បង្កើតបរិយាកាសបំពុលសង្គមខ្មែរ ធ្វើការកាប់សំលាប់ បាញ់ប្រហារ ចាប់ចងវាយដំធ្វើទារុណកម្ម ដាក់គុកធ្វើទារុណកម្មដូចសត្វធាតុ ប៉ុន្តែសហគមន៏អន្តរជាតិ អង្គការអន្តរជាតិ និងបណ្តាប្រទេសមហាអំណាចលោកសេរីដែលមានសហរដ្ឋអាមេរិកជាមេក្លោង បែរជាពុតធ្វើមិនដឹងមិនឮ មិនធ្វើអន្តរាគមន៏អ្វីទាំងអស់ដើម្បីជួយស្រោយស្រង់ប្រជាជាតិខ្មែរអោយចេញពីរណ្តៅគ្រោះមរណៈរបស់យួន ថែមទាំងនាំគ្នាផ្តល់លុយជំនួយ និងលុយកំចីបរទេសទៅអោយរដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយ ហ៊ុន-សែន ដើម្បីដូរយកផលប្រយោជន៏វិនិយោគទុន ធនធានធម្មជាតិខ្មែរ និងប្រយោជន៏ដែលមើលលមិនឃើញទៅវិញ ចំណែកឯអង្គការសហប្រជាជាតិ មិនត្រឹមតែមិនចាប់ ហ៊ុន-សែន និង ពួកមេដឹកនាំគណៈបក្សប្រជាជនឯទៀតៗយកទៅកាត់ទោសប៉ុណ្ណោះនោះទេ តែបែរជាឃុបឃិតសមគំនិតជា មួយពួកមេឧក្រិដ្ឋករ មេឃាតករ មេភេរវករ ហ៊ុន-សែន ហើយបង្កើតតុលាការសាលាក្តីខ្មែរក្រហមលាងសំអាតបទឧក្រិដ្ឋកម្មប្រល័យមនុស្សជាតិរបស់យួន និងអំពើឈ្លានពានលេបទឹកដីខ្មែររបស់យួនឱ្យក្លាយទៅជាអំពើស្របច្បាប់ទៅវិញ។ បច្ចុប្បន្នប្រជាជាតិខ្មែរកំពុងតែរស់នៅដីសែនវេទនាឈឺចាប់នៅក្នុងចង្កូមបិសាចនៃជំរៅមហាគ្រោះ ត្រូវបានបង្កើតឡើងដោយ រដ្ឋាភិបាលអាយ៉ងក្រោមខ្សែញាក់នៃរដ្ឋាភិបាលក្រុងហាណូយនោះ។ http://hengpov.wordpress.com/

**តើក្នុងនាមជាប្រជាជាតិខ្មែរទាំងអស់គ្នាគួរតែរកច្រកចេញពីក្រញាំបិសាចយួនកំមុយនីស្តដោយរបៀបណា?**

http://www.youtube.com/watch?v=sb7cawCPp2c

http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html

## ១-អង្គការឧក្រិដ្ឋជនសំងាត់បាក់គី (Secret Criminal Organization of Backy):



លោក **ហុក ឡុងឌី** គឺជាអគ្គស្នងការនគរបាលជាតិ ជាឧត្តមសេនីយឯកផ្កាយមាស៤ ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់បាក់គី (១៩៩១-១៩៩៧) ជាអ្នកចូលរួមធ្វើរដ្ឋប្រហារថ្ងៃ ៥-៦ កក្កដា ១៩៩៧ ដោយបានសំលាប់ឥស្សរៈជនជាច្រើនរបស់គណៈបក្សហ្វុនស៊ិនប៉ិច ជាអ្នកចូលរួមស្ថាបនាអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ជាមួយ ហ៊ុន-សែន និង ជា-ស៊ីម (១៩៩៧-២០០៣) ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅឈុតខ្មៅ ជាមួយ ហ៊ុន-សែន (១៩៩៧-២០០៨) គឺជាវិរៈបុរសរបស់យួនដែលបានសំរេចស្នាដៃដឹមហិមារនៅក្នុងបេសកកម្មរំលាយជាតិសាសន៏ខ្មែររបស់ក្រុងហាណូយបន្ទាប់ពីយួនកំមុយនីស្ដ៏ឈ្លានពានលេបត្របាក់ទឹកដីខ្មែររួចស្រេចហើយ ។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីគឺត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលក្រុងហាណូយ នៅក្នុងឆ្នាំ១៩៩១ ដើម្បីធ្វើភេរវកម្ម បង្កើតអសន្តិសុខ ចលាចលសង្គម អស្ថេរភាពនៅក្នុងសង្គមខ្មែរ និងរកចំណូលអោយគណៈបក្សប្រជាជនកម្ពុជា ព្រមទាំងបំរើផលប្រយោជន៏នយោបាយនៃរដ្ឋាភិបាលអាយ៉ងយួន(CPP) ដើម្បីពន្លឿនល្បឿនលេបទឹកដីខ្មែរយ៉ាងឆាប់បំផុត ។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះ ត្រូវបានប្រើប្រាស់ និងបញ្ជាដោយលោក ហុង ឡង់ឌី រហ័សនាមហៅថា កាពីរ (K-2 ជាឧត្តមសេនីយផ្កាយមាស៤ ជាអគ្គស្នងការនគរបាលជាតិនៅក្នុងប្រទេសកម្ពុជា និងជាឧត្តមសេនីយទោផ្កាយ២នៅប្រទេស វៀតណាម មានឈ្មោះថា ខៀវវ៉ាន់ឌី នេះបើតាមប្រភពលោកអ៊ុំ នូសារុន CFF នៅខេត្តស្វាយរៀង ដែលបានបញ្ជាក់ប្រាប់ខ្ញុំនៅបរិវេនខាងក្រោយអាគារសេ C នៃគុកព្រៃសនាឆ្នាំ ២០០៧ ហើយបើតាម លោក វេង វុទ្ធី បាន បញ្ជាក់ថាឪចិញ្ចឹមរបស់លោក ហុក-ឡង់ឌី ឈ្មោះតាវ៉ា នៅបាវិតនាខេត្ត ស្វាយរៀង) ។ បន្ទាប់ពីកិច្ចព្រមព្រៀងក្រុងប៉ារីសនាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលក្រុងហាណូយមានការព្រួយបារម្ភខ្លាចបាត់អំណាចត្រួតត្រាលើកម្ពុជា ក៏បានកែណ្ឌប្រមូលអតីតយុទ្ធជនវៀតណាម និងពួកចោរជើងចាស់ និង

ឈ្មួញជួញដូរមនុស្ស ជួញដូរគ្រឿងញៀនវៀតណាម រួមទាំងក្រុមជនអន្ធពាលវៀតណាមផងដែរ ត្រូវបានគេបញ្ចូលជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គី។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីមួយចំនួនធំ គឺបានចេញប្រភពមកពីអតីតយុទ្ធជនវៀតណាមដែលជាពួកចារជនផ្នែកខាងទាហ៊ាននៃជួរកងទ័ពវៀតណាម ដែលពូកែខាងស៊ើបការណ៍យកពត៏មាន និងឃោសនាបំផុសបំផុលផ្នែកនយោបាយ និងធ្លាប់រៀនសូត្រខាងវិជ្ជាដាកកុង និនច្ចារ ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងក្រុមនេះ។ សមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានបញ្ជូនទៅប្រទេសកម្ពុជាសំរាប់ជួយជ្រោងជ្រែងលោក ហុកឡង់ឌី នៅក្នុងការសំលាប់ផ្តាច់ពូជជនជាតិខ្មែរបែបរបៀបថ្មី មានន័យថាសំលាប់ខុសពីលោកអ៊ីត្លែ និងលោកប៉ុលពត គឺយកលេសប្លន់ជិវិតបងធំបងតូចសំលាប់រាស្ត្រខ្មែរជាចំហរ សំលាប់តិចៗ សំលាប់តក់ៗ តែរយៈយូរគឺសំលាប់បានច្រើន អន្តរជាតិមិនដឹង មិនសង្ស័យហើយ ចាប់ភស្តុតាងមិនបាន ថ្កោលទោសក៏មិនបាន។ លោក ហុកឡង់ឌី ប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះ ដើម្បីសំលាប់ពួកអ្នកស្នេហាជាតិខ្មែរ ឥស្សរៈជនខ្មែរ វរៈជនខ្មែរ វីរះជនខ្មែរ ពួកគណៈបក្សប្រឆាំង និងរាស្ត្រសាមញ្ញ និងបង្ករអសន្តិសុខ អស្ថេរភាពសង្គមរីករាលដាលរចលាចល ដើម្បីងាយស្រួលប្រើអំណាចផ្តាច់ការ សំលាប់ប្រជារាស្ត្រខ្មែរ បង្កើនអំណាចរបស់គណៈបក្សប្រជាជន ជាពិសេសដើម្បីពង្រឹងកំលាំងអំណាចផ្តាច់មុខរបស់លោក ហុកឡង់ឌី នៅក្នុងប្រទេសកម្ពុជា។ ក្នុងការបំភាន់ភ្នែកអន្តរជាតិមិនអោយមើលឃើញ ឬ យល់ដឹងនៅអាថ៏កំបាំងឧក្រិដ្ឋកម្មសំងាត់ ឃាតកម្មសំងាត់របស់ខ្លួន ប្រព្រឹត្តិលើប្រជារាស្ត្រខ្មែរស្លូតត្រង់ លោក ហុក ឡង់ឌី បានប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់បាក់គីដូចស្រដៀងគ្នាទៅនឹង អង្គការអាល់ខៃដា របស់លោកអូសាម៉ា ប៊ិនឡាឌិន ប៉ុន្តែពាក់ផ្លាកនយោបាយទៅលើ គណៈបក្សដៈទៃៗ ជាពិសេសលើពួកខ្មែរក្រហម ដូចករណីដាក់បន្ទុះគ្រាប់បែកដៃចងកៅស៊ូទុក ក្នុងកំប៉ុងប្រេកកាតដាក់បង្កប់តាមហាងកាហ្វេយួនទា ឆ្នាំ ១៩៩២ ១៩៩៣,,,,,,ភេរវកម្ម បាញ់ប្រហារ ឃាតកម្មចំឡែកៗជាដើម។

## គោលបំណង និង គោលដៅនៃអង្គការឧក្រិដ្ឋជនសំងាត់បាក់គី

**(១)-ស៊ើបការណ៍ យកពត៏មាន ប្រមូលពត៏មាន តាមដានយកការណ៍** អំពីពួកគណៈបក្សប្រឆាំង នឹងពួកវីរៈជន វរៈជន ឥស្សរៈជនខ្មែរ ពួកបញ្ញាជនខ្មែរ និងពួកអ្នកជាតិនិយមខ្មែរ ព្រមទាំងស៊ើបអង្កេតរាល់

សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរ ជីវភាពរបស់ប្រជាជនខ្មែរដែលមានទំនាក់ទំនងប្រក្រតី ឬក៏ខុសប្រក្រតីជាមួយបណ្តាពួកមន្ត្រី ថ្នាក់ដឹកនាំរដ្ឋាភិបាលអាយ៉ង ពួកបក្សប្រឆាំង និងតាមដានផងដែរ នៅរាល់សកម្មភាពគ្រប់យ៉ាងរបស់ពួកមន្ត្រីរដ្ឋាភិបាលអាយ៉ងគ្រប់ស្រទាប់ចាប់តាំងពីពួកមន្ត្រីទាហ៊ាន យោធា មន្ត្រីនគរបាល មន្ត្រីស៊ីវិល ប្រធានភូមិ ប្រធានឃុំ ចៅហ្វាយស្រុក អភិបាលខណ្ឌ អភិបាលខេត្ត រហូតដល់រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី សភាតំណាងរាស្ត្រ មន្ត្រីជាន់ទាបជាន់ខ្ពស់ក្នុងជួរតុលាការ ព្រមទាំងធ្វើជាទាហ៊ានចារកិច្ច ប៉ូលីសស៊ើបការណ៍របស់ពួករដ្ឋាភិបាលអាយ៉ងផងដែរ ហើយប្រសិនបើលទ្ធផល ពត៌មានសបង្ហាញថា ពួកទាំងនោះខុសប្រក្រតី វេចវេរ រកកលចង់ក្បត់បក្ស ឬ ជាជនក្បត់បក្ស និងរាល់ពួកដែលដើរខុសពីបន្ទាត់គោលនយោបាយយួនកុំមុយនីស្ត៍ ពួកអស់ទាំងនេះ ត្រូវបានក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី នាំបញ្ជូនឈ្មោះទៅកាន់លោក ហុក ឡង់ឌី ឬទៅថ្នាក់លើជាអ្នកសំរេច ថាតើត្រូវ ចាប់ខ្លួនដាក់គុក ត្រូវកសាង អប់រំកែប្រែ ឬក៏ត្រូវសំលាប់ចោល (សូមបញ្ជាក់ថា ពាក្យថ្នាក់លើ គឺមាន ន័យថារដ្ឋាភិបាលក្រុងហាណូយ យួនកុំមុយនីស្ត៍នេះឯង ហើយទំលាប់វិន័យរបស់ពួកគេគឺថា បើគ្មាន បញ្ជារពីថ្នាក់លើទេ គឺមិនហ៊ានធ្វើ មិនហ៊ានសំលាប់ឬចាប់ចងអ្វីឡើយ =បើមានបញ្ជាពីថ្នាក់លើ ពួកគេធ្វើ តែបើគ្មានបញ្ជាគឺពួកគេមិនធ្វើ)។

**(២)-ផ្សព្វផ្សាយពត៌មាន បំភ្លៃពត៌មាន បំភ្លើសពត៌មាន និងសាបព្រួសពត៌មាន**បំបាក់ស្មារតីប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់វណ្ណៈអោយភ័យខ្លាចបាក់ស្បាតមិនហ៊ានងើបឡើងតតាំងប្រឆាំងតវ៉ា ឬនិយាយស្តីអំពីគ្រប់រាល់អំពើពុករលួយ លក់ជាតិទឹកដីរបស់រដ្ឋាភិបាលអាយ៉ងយួន រាល់គ្រប់ទង្វើរខុសប្រក្រតី និងរាល់សកម្មភាពទន្ទ្រានវាតទីត្របាក់លេបទឹកដីព្រំដែនខ្មែរ ព្រំប្រទល់ស៊ីម៉ាខ្មែរ-យួន ឬសកម្មភាព សំលាប់ភ្នែកស្រស់ឡើយ ផ្ទុយទៅវិញប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់វណ្ណៈបែរជាភ័យខ្លាចមហាគ្រោះថ្នាក់ ចំពោះមុខដែលកើតមានប្រចាំថ្ងៃទៅវិញ ហើយព្យាយាមសម្ងំសុខ ដោយសង្ឃឹមថា ដាំដើមគរជាប្រភព នៃភាពសុខក្សេមក្សាន្តគ្រប់យ៉ាង ប៉ុន្តែធាតុពិតគឺផ្ទុយស្រឡះពីអ្វីដែលប្រជារាស្ត្រខ្មែររំពឹងទុក ព្រោះថាពួកកុំមុយនីស្ត៍តែងតែប្រកាន់ខ្ជាប់នៅគោលការណ៍ដែលថា "**បញ្ជាគឺបញ្ជា ផែនការគឺផែនការ** "។ រាល់គ្រប់ផែនការងងឹត ល្បិចខ្មៅក្រខ្វក់ទាំងឡាយរបស់រដ្ឋាភិបាលក្រុងហាណូយ ត្រូវបានក្រុមពួកក្រុមអង្គការ

ឧក្រិដ្ឋជនសំងាត់បាក់គី យកទៅផ្សព្វផ្សាយសាបព្រួសនៅក្នុងសង្គមខ្មែរដើម្បីញុះញុងបំបែកបំបាក់ ប្រជារាស្ត្រខ្មែរ ប្រជាជាតិខ្មែរអោយបែកបាក់គ្នាជាបំណែក១គ្រប់ស្រទាប់វណ្ណៈ។ ពួកបាក់គីក្រៅពីលួច ឆក់ប្លន់ជីវិត និងសំលាប់ ឃាតកម្មនយោបាយស្អីគេនោះ ពួកវាពូកែ និងប្រសព្វផងដែរខាងឃោសនា បញ្ចុះបញ្ចូល ផ្លាស់ប្តូរទឹកចិត្តប្រជាករខ្មែរតាមជនបទស្រែចំការ ឬតាមក្រុមប្រជាជនទីក្រុងដែលពុំមានការ រៀនសូត្រ ចេះដឹង អោយទទួលយកអ្វីដែលពួកវារនិយាយល្បួងលួងលោម បញ្ឆោតបញ្ឆោរលើកជើង រាស្ត្រខ្មែរល្ងង់ខ្លៅ អោយជឿពាក្យផ្អែមល្ហែមរបស់ពួកវា ហើយយល់ព្រមផ្តល់ពត៌មាន រាយការណ៍អោយ ពួកវាដោយមិនដឹងខ្លួន ព្រោះពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះគឺ ពូកែខាងប្រើមនុស្សទៅតាមទីកន្លែង តាមស្ថានភាព ជាក់ស្តែង បើទីតាំងគោលដៅជាមនុស្សមានសំបុរស្បែកខ្មៅ ពួកវាចាត់មនុស្ស ដែលមានស្បែកសំបុរខ្មៅទៅទីនោះដើម្បីស្ទាបស្ទង់ស្ថានភាពចិត្តសាស្ត្រ សិក្សាភូមិសាស្ត្រជាក់ប្រាកដ មុនបើកយុទ្ធនាការលើទីតាំង គោលដៅនោះ ហើយពួកមនុស្សដែលស៊ីនុយពួកវានោះ ក្លាយខ្លួនជាអ្នកផ្តល់ ពត៌មានរាយការណ៍អោយ ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ពេលចូលអន្ទាក់ ក៏ដកខ្លួនពុំរួច ហើយ លង់កាន់តែជ្រៅ ទីបំផុតស្ថិតក្នុងការគំរៀមកំហែងរបស់ពួកវា ប្រៀបបីដូចជាសមាជិករបស់ក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដែរ គ្រាន់តែបណ្តោះអាសន្ន មិនអចិន្ត្រៃយ៍ទេ ហើយការយល់ដឹង ពីពួកបាក់គីគឺតិចតួចបំផុត ព្រោះពួកនេះ បន្សល់ដានតិចណាស់មុនផ្លាស់ប្តូរទៅចាប់គោលដៅថ្មីនោះ។ ក្រៅពីនេះ ពួកវាតែងតែដើរផ្សាយបំផុសនៅ ពត៌មានប្រឌិតក្លែងក្លាយ បំផ្លែងពត៌មាន បំភ្លៃពត៌មានផ្លាស់ប្តូររឿងរ៉ាវហេតុការណ៍ពីអាក្រក់ទៅល្អ ពីល្អទៅអាក្រក់ ពីពិតទៅមិនពិត ពីមិនពិតទៅពិត ដោយបង្វែរសាច់ រឿងតាមគោលដៅដែលថ្នាក់លើ ចង់បាន ដោយមានការសហការពីរដ្ឋអំណាចមូលដ្ឋានជួយជ្រោងជ្រែងសព្វ បែបយ៉ាងដើម្បីសំរេចបញ្ជូរថ្នាក់លើអោយខាងតែបាន ដូចជារឿងឃាតកម្មនយោបាយ ពួកវាប្រែទៅជារឿងឈ្លោះគ្នា រឿងគំនុំផ្ទាល់ខ្លួន ឬរឿងគ្រួសារទំនាស់ផ្ទៃក្នុងទៅវិញ ចំណែករឿងចោរកម្មលួចឆក់ប្លន់នោះ ពួកវាបែរជាដើរតួជាអ្នកគំរៀមកំហែងជឹកសួររកភស្តុតាងតឹកតាង "ចេះតែថាហើយ ប្រយត្ន័អត់ភស្តុតាងច្បាស់លាស់ គេប្តឹងបកវិញ,,,,,,កុំនាំរឿងដាក់ខ្លួន,,,,,,កុំយកជីវភ្លៅបៀតភ្លៀក,,,,,, ប្រយត្ន័ងាប់ដូចខ្មោចឆ្កែរ ,,,,,,បើមិន

អញ្ចឹងទេ ពួកវាប្រែរូបទៅជាសាក្សីក្នុងសាច់រឿងនោះតែម្តង ដូចជាករណីរឿងឃាតកម្ម ឬជារឿងគ្រោះថ្នាក់ផ្សេងៗនោះ ពួកសមាជិកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីបែរជាដើរតួថា ពួកវាបាន នៅកន្លែងកើតហេតុនោះដែរ ពួកវាបានឃើញ,,,,,,,បានឮ,,,,,ថែមទាំង ពន្យល់សាច់រឿងយ៉ាងក្បោះក្បាយ ទៀតផង ហើយធ្វើការផ្សព្វផ្សាយសព្វទីកន្លែង ដោយមានប្រព័ន្ធឃោសនារបស់រដ្ឋាភិបាលមានវិទ្យុ សារពត៌មាន កាសែតទស្សនាវដ្តី ទូរទស្សន៍ និងបណ្តាញឃោសនាផ្សេងៗទៀតចូលរួមផងដែរដើម្បីបង្វែរ សាច់រឿង ចំណែកកងកំលាំងប៉ូលីស ទាហ៊ាន កងរាជអាវុធហត្ថ ជួយបំភ្លឺក្នុងរឿងនេះ ហើយថែម ទាំងគំរាមកំហែងនៅរាល់ជនណាដែលមិនជឿពួកគេបកស្រាយពន្យល់ ឬសំលាប់បំបិទមាត់នៅរាល់ ជនណា ដែលដឹងសាច់រឿងយ៉ាងជាក់ច្បាស់ប្រាកដ ។ រីឯបើរឿងចោរកម្ម ប្លន់សំលាប់ ឬ ការសំលាប់យ៉ាង ឃោរឃៅសាហាវព្រៃផ្សៃនោះ ពួកវាបែរជាបង្វែរទៅជារឿងផ្សេងទៅវិញ ពេលខ្លះជារឿងគំនុំ រឿងសង សឹក រឿងផិតក្បត់ រឿង សាហាយស្មន់,,,,,រឿងគ្រោះ ថ្នាក់ចរាចរ,,,,,,,រឿងយល់ស្រឡំ,,,,, រឿងទាស់សំដីគ្នា,,,,,ឬក៏ពួកវាផ្សាយថា ចោរ ឃាតករ ចាប់បាន ហើយ ចោរឃាតករបាញ់ចោលហើយ កប់ចោលហើយ,,,,, ។ល។ និង ។ល។ សរុបពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី និងកងកំលាំង រដ្ឋាភិបាលអាយ៉ង ហាក់បីដូចជាធ្វើរឿងតែមួយ ធ្វើកិច្ចការតែមួយយ៉ាងស៊ីសង្វាក់គ្នាដើម្បីបំរើឆន្ទះ គោលបំណងរបស់ក្រុងហាណូយ ធ្វើអោយមានភាពស្របច្បាប់អន្តរជាតិនៅរាល់បទឧក្រិដ្ឋដែលពួកគេ ប្រព្រឹត្តិ និងធ្វើអោយមានប្រតិមតិក្នុងខួរក្បាលរាស្ត្រខ្មែរ ទទួលយក ឬសង្ស័យនៅរាល់រឿងពិតទាំងឡាយ ទៅតាមបំណងដែលយួនចង់បាន គឺយល់ស្របជឿជាក់ទាំងបង្ខំចិត្តនៅរាល់គ្រប់ការបំផុសពត៌មានមិនពិត ការបំភ្លៃនិងបំផ្លែងពត៌មាន ការសាបព្រុសមនោគមវិជ្ជាក្បត់ជាតិដល់ប្រជារាស្ត្រខ្មែរ គំរាមកំហែង បំបាក់ស្មារតីប្រជាពលរដ្ឋខ្មែរ អោយខ្លាចបាក់ស្បាតមិន ហ៊ានក្រោកឡើងប្រឆាំងពួកវា មិនហ៊ានមាន និន្នាការចូលរួមក្នុងបក្សប្រឆាំង ហើយភ័យខ្លាចមានគ្រោះថ្នាក់ដល់ខ្លួន និងជឿជាក់ងថា **"ជីវិតរស់ ស្លាប់ គឺអាស្រ័យបក្សប្រជាជន ជាអ្នកសំរេច** "ហើយមានតែបង្ខំចិត្តជឿ និងអនុវត្តន៏តាមបញ្ជាផែនការទិសដៅ របស់រដ្ឋាភិបាលអាយ៉ងយួនគឺគណ:បក្សប្រជាជនកម្ពុជាទេ ព្រោះគ្មានជំរើសហើយបើប្រជាជនខ្មែរទៅពឹងលើ

ច្បាប់អន្តរជាតិ ឬក៏អង្គការសហប្រជាជាតិ គឺប្រៀបបីដូចកាប់បំពង់រងចាំទឹកភ្លៀងដូចរងចាំផ្កាយធ្លាក់ពីលើមេឃព្រោះកម្ពុជាមិនមែនអ៊ីរ៉ាក់ ឬអាហ្គានីស្ថាន ដែលសំបូរទៅដោយប្រេងកាតធនធានធម្មជាតិជាទីស្រេកឃ្លានត្រេកត្រអាលរបស់មហាអំណាចនោះទេ។

**(៣)-បង្កើនភាពច្របូកច្របល់ វឹកវរចលាចរ អស្ថេរភាព និងអសន្តិសុខនៅក្នុងសង្គមខ្មែរ** ហើយយកលេសនេះដើម្បីបង្ហាញឬទ្ធានុភាពនៃកងកំលាំងប្រដាប់អាវុធដ៏សាហាវឃោរឃៅដែលស្ទាត់ជំនាញខាងប្រហារ និងប្រល័យប្រជាជនខ្មែរស្លូតត្រង់ដែលគ្មានដឹងល្បិចឃាតកម្ម ឧក្រិដ្ឋកម្មកំបាំងមុខរបស់រដ្ឋាភិបាលអាយ៉ងយួនដែលតែងតែប្រើលេសឃាតកម្ម ភេរវកម្ម លួចឆក់ប្លន់ជីវិតសំលាប់ និងអស្ថេរភពសង្គម អសន្តិសុខសង្គម និងការពារសុវត្តិភាពសង្គម ការពារសន្តិសុខសង្គម ការពារស្ថេរភាពសង្គម ដើម្បីបង្កើននៅភាពច្របូលច្របល់ភ័យខ្លាចដល់ប្រជារាស្ត្រខ្មែរ និង ដើម្បីបំភាន់ភ្នែកសហគមន៍អន្តរជាតិថា កងកំលាំងរដ្ឋាភិបាលពួកវាកំពុង តែប្រឹងប្រែងធ្វើការដើម្បីបុព្វហេតុសន្តិសុខជាតិតែប៉ុណ្ណោះ រួចហើយវាយកកំលាំងតាមតំបន់គោលដៅដោយប្រើអំណាចផ្តាច់ការតាមអំពើចិត្តក្នុងការចាប់ចងចាប់ដាក់គុក វាយដំសំលាប់ កាប់សំលាប់បាញ់បោះ បាញ់ប្រហារជនស្លូតត្រង់ខ្មែរតាមអំពើចិត្ត ហើយបិទផ្លាកថាបង្ក្រាបចោរ បង្ក្រាបក្មេងពាលបងតូចបងធំ ឬបង្ក្រាបក្មេងទំរើសទំយើរស្ទីគេនោះ ប៉ុន្តែធាតុពិតគឺរដ្ឋាភិបាលអាយ៉ងប្រើល្បិចប្រើលេសនេះលេសនោះ ហើយប្រើប្រាស់ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី និងកងកំលាំងប្រដាប់អាវុធរបស់ពួកវាដើម្បីបំរើផលប្រយោជន៍រដ្ឋាភិបាលក្រុងហាណូយ និងអនុវត្តន៍តាមបញ្ជាសំងាត់របស់ចៅហ្វាយយួនតែប៉ុណ្ណោះ ហើយ **ពួកវាចាត់ទុកសហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗគ្រាន់តែជាទឹងម៉ោងចាំចាប មិនដឹងខ្យល់អ្វី ក្រៅពីផ្តល់ជំនួយ** និងទទួលផលពីជំនួយនោះវិញ តាមរយៈការដោះដូរនឹងអ្វីផ្សេងទៀតដែលស្មានមិនដល់ ដូចជា ធនធានរ៉ែ ធនធានធម្មជាតិ សិទ្ធិវិនិយោគ ប្រាក់កំរៃជើងសារ ឬលុយសំណូកដែលរដ្ឋាភិបាលអាយ៉ងអោយ ដើម្បីបិទភ្នែកធ្វើមិនដឹងមិនឮលើគំនរឈាម និងទឹកភ្នែករបស់ប្រជារាស្ត្រខ្មែរ (សហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗជាស្ថាប័នប៉ុន្តែមនុស្សដែលបំរើអោយស្ថាប័នទាំងនោះគឺគ្រាន់តែជាបុគ្គលមនុស្ស ដែលទទួលផលប្រយោជន៍យ៉ាង

មហិមារ គ្រាន់តែធ្វើមិនដឹងមិនឮ នៅរាល់ហេតុការណ៍ពិតកើតមានក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ខ្ញុំសុំទោស នេះជាឧទាហរណ៏ទេណា សុំអស់លោកអង្គការកុំប្រកាន់ខ្ញុំអ្វី ដូចជាករណីលោក វ៉ាំង-គីមូន ទៅទស្សនកិច្ចនៅកម្ពុជា ប្រសិនបើអា ហ៊ុន-សែន អោយ ១០០០ លានដុល្លាសហរដ្ឋអាមេរិក ហើយ គ្រាន់តែធ្វើមិនដឹងមិនឮរឿងឧក្រិដ្ឋកម្មឃាតកម្ម ភេរវកម្ម បោកគ្រាប់បែក និងការរំលោភសិទ្ធមនុស្សរបស់អា ហ៊ុន-សែន ហើយយកលេសថាសំណុំរឿងពិភពលោកច្រើនពេករវល់ជាប់ តើលោក វ៉ាំង-គីមូន គិតយ៉ាងម៉េចដែរ ព្រោះខ្ញុំឆ្ងល់ណាស់ អា ហ៊ុន-សែន សំលាប់ជនជាតិខ្មែររាប់មិនអស់ រួមទាំង ភេរវកម្មបោកគ្រាប់បែកមុខរដ្ឋសភាថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ ទៀតផង ប៉ុន្តែអង្គការ សហប្រជាជាតិមិនចាប់ ហ៊ុន-សែន កាត់ទោស បែរជារួមដៃជាមួយអា ហ៊ុន-សែន បង្កើតតុលា ការសាលាក្តីខ្មែរក្រហមលាងកំហុសអោយយួនឈ្លានពានខ្មែរទៅវិញ មិនដឹងថាហេតុអ្វីបានទៅជាយ៉ាងនេះ? រួមទាំងសហរដ្ឋអាមេរិកទៀតដែលបានដឹងរឿងអា ហ៊ុន-សែន ច្បាស់ តែបែរជាសម្ងំអោយអា ហ៊ុន-សែន បន្តអំពើឧក្រិដ្ឋកម្មថែមទៀត តើសហរដ្ឋអាមេរិកបានទទួលផលប្រយោជន៍អ្វីពីអា ហ៊ុន-សែន ហើយពាក្យ ថា **លិទ្ធិប្រជាធិបតេយ្យ តំលៃមនុស្សជាតិ និងសិទ្ធិមនុស្សនៅឯណា**? គ្រាន់តែសួរលេងៗទេ បើយល់ថា ប៉ះពាល់ដល់ផលប្រយោជន៍អស់លោក សូមមេត្តាប្រហារជីវិតខ្ញុំថែមម្នាក់ទៀតក៏មិនអ្វីដែរ ក៏គ្រាន់បើជាង ខ្ញុំស្លាប់នៅក្រោមដៃអា ហ៊ុន-សែន ដែរ)។

**(៤)-រកលុយ រកចំណូលអោយគណៈបក្សប្រជាជនកម្ពុជា** និងអោយលោក ហុក ឡង់ឌី ដូចដែលជនរួម ជាតិខ្មែរបានជ្រួតជ្រាបហើយថា "រដ្ឋាភិបាលអាយ៉ងយួនកុំមុយនីស្តបានក្តោបអំណាចនយោបាយទាំងប្រាំក្នុង ដៃគឺ អំណាចនិតិបញ្ញត្តិ អំណាចនិតិប្រតិបត្តិ អំណាចតុលាការ អំណាចប្រព័ន្ធឃោសនា និងអំណាច ម៉ាហ្វីយ៉ា (ជាអំណាចប្រើក្នុងផ្លូវងងឹតដើម្បីបំភាន់ភ្នែកមហាអំណាច សហគមន៍អន្តរជាតិតែប៉ុណ្ណោះ អំណាច ម៉ាហ្វីយ៉ា មានដូចជាក្រុមបងធំបងតូចក្រុមចោរលួច ចោរប្លន់ ចោរចាប់ជំរិត ពួកឆបោក ពួករកស៊ីគ្រឿង ញៀន ពួករកស៊ីជួញដូរអាវុធ ពួកមេបនរកស៊ីជួញដូរមនុស្ស និងពួកឃាតករស៊ីឈ្នួល ព្រមទាំងពួក ភេរវករ សំរាប់ធ្វើភេរវកម្ម និងធ្វើឃាតកម្មនយោបាយតែប៉ុណ្ណោះ) និងកាន់អំណាចសេដ្ឋកិច្ចប្រាំក្នុងដៃ

ទៀតគឺ ចំណូលដែលបានមកពីពន្ធដារពន្ធគយ ចំណូលបានមកពីជំនួយបរទេស ចំណូលដែលបានមកពីកំម្ចីបរទេស ចំណូលដែលបានមកពីការលក់ដូរធនធានធម្មជាតិខ្មែរមានដូចជាព្រៃឈើដីភ្នំស្ទឹងបឹងបួរសមុទ្ររ៉ែ ជីវចំរុះ,,,,,,,, ។ល។ និង ។ល។,,,,,,, និង ចំណូលដែលបានមកអំពីសេដ្ឋម៉ាហ្វីយ៉ា (លុយដែលបានមកអំពីអំពើពុករលួយលួចលុយចំណូលជាតិ លួចកេងកីបលុយកំម្ចីបរទេស លួចលុយជំនួយបរទេសធ្វើជាលុយរបស់ខ្លួន និងរបស់បក្សខ្លួន លុយចំណូលដែលបានមកអំពីពួកក្រុមពួកបងធំបងតូច ក្រុមពួកចោរលួចចោរប្លន់ក្រុមចោរចាប់ជំរិត ពួកឆបោក ការរកស៊ីគ្រឿងញៀន រកស៊ីជួញដូរអាវុធ រកស៊ី ជួញដូរមនុស្ស និងឃាតកម្មស៊ីឈ្នួល ការចងការប្រាក់ ការរកស៊ីកាងបាញ់បោះ,,,,,,,,,,,មុខរបរទាំងអស់នេះ មានលក្ខណៈជាឯកជនត្រូវបានកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលជាអ្នកការពារសំរួលអោយមានភាពរលូនដោយយកកំរៃ និងឈ្នួលការពារ ហើយជាជាលក្ខណៈរដ្ឋអំណាចដែលគណៈបក្សប្រជាជនខ្លួនឯងជាអ្នករកស៊ីផ្ទាល់ជាទ្រង់ទ្រាយធំ) គណៈប្រជាជនជាអ្នករៀបចំឆាកល្ខោនអោយមានលក្ខណៈជាបណ្តាញខ្សែសង្វាក់ ជាអង្គការចាត់តាំងមានរចនាសម្ពន្ធ័ច្បាស់លាស់ក្នុងបណ្តាញចោរលួចចោរប្លន់ ចោរចាប់ជំរិត ក្រុមឃាតករស៊ីឈ្នួល និងក្រុមរកស៊ីជួញដូរគ្រឿងញៀន ជួញដូរមនុស្ស,,,,,, ។ល។ និង ។ល។,,,,,នៃអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដែលស្ថិតនៅក្នុងការគ្រប់គ្រងផ្ទាល់របស់លោក ហ៊ុក-ឡង់ឌី និងក្រោមការជួយជ្រោមជ្រែងផងដែរពីកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ង។ ពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដែលដើរតួនាទីជាអង្គរក្សរបស់ លោក ហ៊ុក-ឡង់ឌី និងជាក្រុមពួកអន្តរពាល ជាឃាតករ ជាកងកំលាំងប្រដាប់អាវុធ និងជាចារជនពិសេសរបស់យួនផងដែរនោះ លើសពីនេះទៅទៀត ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដើរតួនាទីជាអ្នករកចំណូលតាមរយៈការរកស៊ីប្លន់ជំរិតលួចឆក់ ឃាតកម្មស៊ីឈ្នួល និងកាងទីតាំងរកស៊ី ធ្វើអោយលុយចំណូល បានហូរចូលយ៉ាងក្រាស់ក្រែទៀតផង ហើយបើតាមពួកអ្នកដែលធ្លាប់បានចេញចូលផ្ទះលោក ហ៊ុក-ឡង់ឌី ជិតបុរីកីឡាបានអោយដឹងថា ចាប់ពីពាក់កណ្តាលខែរហូតដល់ចុងខែ លុយចំណូលរបស់លោក ហ៊ុក-ឡង់ឌី ត្រូវបានយកមកចាក់គរពេញបន្ទប់ដែលប្រពន្ធកូនគាត់មិនដែលរវីរវល់ទៅរាប់លុយនោះទេគ្រាន់តែចាត់ពួកអ្នកបំរើចូលបន្ទប់រាប់លុយ និងរៀបលុយតាមរបៀប ដុំដោយដុំ រាយដោយរាយ ដុល្លាដោយ

ដុល្លា លុយរៀលដោយរៀល(Source[C1]),....,។ល។ និង ។ល។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះរកចំណូលបានយ៉ាងច្រើនក្រាស់ក្រែល បន្ថែមលើជំនួយពន្ធដារពន្ធគយ ព្រោះថាកាលពីគ្រានោះ មិនទាន់មានជំនួយបរទេស ឬក៏មានកម្ចីបរទេសដែលប្រភពចំណូលយ៉ាសន្ធឹកសន្ធាប់ដូចក្រោយពេលនៃការបោះឆ្នោតឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្នទេ ហើយកំលាំងឃាតកអាចកំបាំងក៏មិនខ្លាំងក្លាដូចបច្ចុប្បន្ននេះដែរ ដោយសារហេតុនេះហើយ ទើបសព្វថ្ងៃនេះ **ទោះបីគណៈបក្សប្រជាជនកម្ពុជាបានស្ថាបនា និងក្តោបក្តាប់គ្រប់គ្រងក្បាលម៉ាស៊ីនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅប្រទេសកម្ពុជាយ៉ាងណែននៅក្នុងដៃរបស់ពួកវាក៏ដោយ ក៏ពួកវាបង្ខំចិត្តផ្តល់កៅអីខ្លះអោយទៅលោក សម-រង្ស៊ី និង លោក គឹម-សុខា ដើម្បីអោយកាន់ក្តអោយគណៈបក្សប្រជាជននោម ព្រោះពួកវាអាចទាញយកចំណូលយ៉ាងសន្ធឹកសន្ធាប់ពីជំនួយបរទេស និងលុយកម្ចីបរទេស ដោយគ្រាន់តែពាក់ផ្លាកថា "មានគណៈបក្សប្រឆាំង គឺមានលិទ្ធិប្រជាធិបតេយ្យ"។**

**(៥)-ការពារជនជាតិយួន ជនបង្កប់យួន និងឈ្មួញទុច្ចរិតយួន**ដូចជាក្រុមពួករកស៊ីខុសច្បាប់ជួញដូរមនុស្សគ្រឿងញៀន ជួញដូរអាវុធ និងទំនិញខុសច្បាប់ ទំនិញគេចពន្ធជាដើម,.....,។ល។ និង ។ល។ ជនជាតិយួនបានដើរតួនាទីជាជនបង្កប់យួន ត្រូវបានវាយសព្វទីកន្លែង មានន័យថាទីកន្លែងណាដែលមានប្រជាជនយួនរស់នៅ ទីកន្លែងនោះនឹងប្រែជាទីតាំងដែនរដ្ឋបាលយួនដែលមានអង្គការចាត់តាំងយួននៅទីនោះប្រៀបបីដូចជារដ្ឋាភិបាលទី២របស់យួន ដែលប្រជាជនយួនទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់សុទ្ធតែជាចារជនសុទ្ធតែជាសមាជិកនៃអង្គការចាត់តាំងរដ្ឋបាលយួនស្ថិតនៅក្រោមការការពារ និងជួយជ្រោមជ្រែងរបស់ពួកសមាជិកសកម្មនៃអង្គការឧក្រិដ្ឋជនសំងាត់បាក់គី។ **ជនជាតិយួនរាប់លាននាក់ត្រូវបានបង្ហូរចូលស្រុកខ្មែរគឺប្រៀបបីដូចទឹកជ្រោះធ្លាក់ពីលើកំពូលភ្នំចុះមកក្រោម ចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ដើម្បីសំរេចនៅគោលនយោបាយលេបទឹកដីខ្មែរតាមរយៈនយោបាយសមានកម្ម និងនយោបាយឆុងសាច់ឈាម ប្រែជាតិខ្មែរអោយទៅជាយួនដូចស្រដៀងនឹងនយោបាយសហពន្ធ័ឥណ្ឌូចិនរបស់លោក ហូ-ជីមិញ ដែលយកកម្ពុជាឡាវ និងយួនក្លាយជាប្រទេសតែមួយឈ្មោះថា សហពន្ធ័ឥណ្ឌូចិន ស្ថិតក្រោមការត្រួតត្រាគ្រប់គ្រងផ្តាច់មុខរបស់យួន** ចំណែកឯសមាជិកខ្មែរ និងឡាវមានតួនាទីត្រឹមតែធ្វើអាយ៉ងយួន មិនចេះ មិនដឹងខ្យល់អ្វីទាំង

អស់ គឺចេះតែប្រមូលលុយអោយយួនតាមរយៈសេដ្ឋកិច្ច៥ និងសំលាប់តែរាស្ត្រខ្លួនឯងតែប៉ុណ្ណោះដើម្បីយកចិត្តយកថ្លើមចៅហ្វាយយួន ដូចជាករណីអា ហ៊ុន សែន បានធ្វើ និងកំពុងធ្វើលើប្រជារាស្ត្រខ្មែរចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ននេះយ៉ាងជាក់ស្តែងស្រាប់។ ជនជាតិយួនដែលមករស់នៅស្រុកខ្មែរមិនត្រឹមតែដើរតួនាទីជាជនជាតិខ្មែរស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើជាចៅហ្វាយរបស់ខ្មែរទៀតផង។

**(៦)-ផ្តល់ពត៏មានដល់ក្រុងហាណូយទាន់ហេតុការណ៏ និងបោសសំអាតភាពក្រខ្វក់ក្នុងកែវភ្នែកយួន ឬហៅថាខ្មាំងរបស់ក្រុងហាណូយ** (ក្រុងហាណូយចាត់ទុកជាខ្មាំង ជាឧបសគ្គដ៏ធំរបស់ពួកវានោះ គឺសំដៅទៅលើពួកបញ្ញាជនខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកអ្នកជាតិនិយមខ្មែរ វីរៈជនខ្មែរ ឥស្សរៈជនខ្មែរ ប្រជាជាតិខ្មែរដែលគាំទ្របុព្វហេតុជាតិទឹកដី និងពួកអ្នកដែលមិនជឿលើមនោគមន៏វិជ្ជាបោកប្រាស់របស់យួន អ្នកដែលហ៊ានតវ៉ាប្រឆាំងនៅអ្វីដែលមិនសមហេតុផល ឬហ៊ានអះអាងនៅរាល់ការពិត ព្រមទាំងពួកមន្ត្រីអាយ៉ងយួនដែលរារែកចិត្តក្នុងការអនុត្តន៏ឧបាយកលសំងាត់របស់យួន) ចេញអោយអស់ពីរដ្ឋាភិបាលអាយ៉ងយួន។ ពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានដាក់ពង្រាយស្ទើរតែពាសពេញប្រទេសកម្ពុជាតាំងពីទីក្រុងរហូតដល់ជនបទ ទោះបីកំលាំងពួកនេះមិនច្រើនក៏ដោយ ក៏ពួកវាមានការជួយជ្រោងជ្រែងពីប្រជាជនយួន បណ្តាញសំងាត់យួន ជនអន្តោប្រវេសយួនដែលទើបតែមករស់នៅស្រុកខ្មែរនិយាយខ្មែរមិនទាន់ទាំងច្បាស់ផង ឱ្យរឹងមាំទោះបីពួកគេមានសញ្ជាតិខ្មែរភ្លាមៗគ្រាន់តែចាប់ផ្តើមចូលស្រុកខ្មែរក៏ដោយ ហើយពួកគេដើរតួជាជំនួយដ៏សំខាន់សំរាប់ជួយពួកឧក្រិដ្ឋជនសំងាត់បាក់គី ដើម្បីបោសសំអាតខ្មាំងផ្ទៃក្នុង និងផ្ទៃក្រៅ ដោយផ្តល់ពត៌មានសំខាន់ៗដោយបែងចែកប្រភេទពួកអ្នកដែលត្រូវបានគេបោសសំអាត ថាជាមនុស្សរបៀបណា ហើយត្រូវបានរៀបចំផែនការអោយស្លាប់របៀបណាទៅលើមនុស្សដែលត្រូវបានចាត់ទុកជាបន្លានៅក្នុងកែវភ្នែករបស់ក្រុងហាណូយ ឬក៏ជាឧបសគ្គរាំងស្ទះដល់ផែនការរបស់ពួកគេនោះ? ត្រូវសំលាប់ដោយរបៀបណាជាមួយរឿងហេតុទាំងឡាយអោយសមហេតុសមផលនោះ ឬក៏ត្រូវអោយជាប់គុកក្នុងករណីណាមួយដែលពួកអាយ៉ងរារែកចិត្តនៅក្នុងការអនុវត្តបញ្ជាថ្នាក់លើនោះ?

**(៧)-បញ្ចូលមនោគមន៍វិជ្ជាពាលាអាវ៉ាសែដល់ស្រទាប់យុវជនខ្មែរ** អោយស្វែងរកសប្បាយឆ្កួតនឹងស្រីស្រា ល្បែងគ្រឿងញៀនរាំរែកផឹកស៊ីសប្បាយហ៊ឺហារ ស្វែងរកមធ្យោបាយរកលុយដោយមិនបានគិតខ្វល់រឿងអ្វីឡើយ និងបង្ហាត់បង្រៀននៅរបៀបប្រព្រឹត្តិបទឧក្រិដ្ឋដូចជាលួចឆក់ប្លន់ជីវិត វ៉ះកាបូបកាប៉ៅ បន្លំ ឆបោក ឃាតកម្ម បាញ់បោះកាង ដើម្បីរកលុយបានយ៉ាងងាយស្រួល ដើម្បីបំពុលដល់សង្គខ្មែរអោយវង្វេងស្រវឹងគ្មានដឹងអ្វីទាំងអស់។ ប្រជាជានខ្មែរកាន់ព្រះពុទ្ធសាសនាស្លូតបូតសុភាពរាបសារ ទន់ភ្លន់មានសីលធម៌ដូចប្រជាជនថៃបច្ចុប្បន្ននេះអញ្ចឹង មិនដែលស្គាល់អ្វីដែលហៅថាបន្លំឆបោក លួចឆក់ ប្លន់ជីវិត បាញ់បោះកាងបងធំបងតូចអ្វីនោះទេ។ ដូច្នេះពួកក្រុមឧក្រិដ្ឋជនសំងាត់បាក់គីមានតួនាទីពិសេសបំផុតគឺនាំវប្បធម៌ពាលាអាវ៉ាសែមកបញ្ចូលក្នុងវប្បធម៌ខ្មែរដោយយកស្រីខូចយួនជាអ្នកបង្រៀនផ្ទាល់នៅរបៀបប្រើប្រាស់គ្រឿងញៀន បន្ទាប់ពីពួកគេចាប់ផ្តើមញៀនហើយ ពួកបាក់គីជាគ្រូទី២ ចាប់ផ្តើមបង្រៀននៅវិធីរកលុយងាយៗ បណ្តុះបណ្តាលនៅរបៀបយុទ្ធសាស្ត្រសាហាវព្រៃផ្សៃ ហើយពួកគេតែងតែដើរតួដូចបងធំ សំលាប់ប្រហារប្រជាជនធ្វើជាគំរូ ដើម្បីអោយយុវជនខ្មែរធ្វើតាម បើមានរឿងរ៉ាវ ពួកគេចេញមុខកាង ចេញមុខជួយធ្វើជាខ្នងដល់យុវជនខ្មែររហូតចេះចាំមេរៀនឆក់ប្លន់សំលាប់រកស៊ីខុសច្បាប់ដោយមិនចាំបាច់សួរគ្រូអ្វីឡើយ តែពេលទទួលលុយគឺត្រូវតែដឹងគុណគ្រូ ដឹងគុណខ្នងបង្អែក ដោយមានពិធីស៊ីផឹកស្រីស្រាល្បែងថ្នាំញៀន និងមានស្រោមសំបុត្រហៅថា "**ទឹកចិត្តស្លួចស្ទើង** "គឺជាលុយសគុណតបស្នងខ្នងបង្អែកមានបណ្តាសក្តិខ្ពស់ៗក្នុងរដ្ឋាភិបាលអាយ៉ង បន្ទាប់មកពួកគេសុំការណែនាំពីរបៀបធ្វើបទឧក្រិដ្ឋដែលមានប្រសិទ្ធិភាពជាងមុន និងទទួលបានប្រាក់កាសច្រើនសន្ធឹកជាងមុន និងសុំពឹងពាក់ការពារអោយបានច្រើនជាងមុនដើម្បីបង្កើនភាពកក់ក្តៅដល់ពួកគេ។

ក្រៅពីនេះ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីមានភារៈពិសេសមួយទៀតគឺបណ្តុះនៅខួរក្បាលអប្រក្រតីដល់សង្គមខ្មែរ អោយប្រកាន់ខ្ជាប់នៅជំហរស្អប់ខ្ពើមគ្នា មិនទុកចិត្តគ្នា ខ្លាចរអាគ្នា និងចងគំនុំ សងសឹក ចងអាឃាតគ្នាទៅវិញទៅមក ជាពិសេសធ្វើអោយនិយាយតែពីរឿងអាក្រក់ពីគ្នា បង្អាប់បន្ថោក មួលបង្កាច់តែអំពីខ្មែរគ្នាឯង និងបញ្ចេញសាច់ដុំបាញ់កាប់ចាក់សំលាប់ប្រហារតែខ្មែររួមឈាមគ្នាឯង ហើយ លើកតំកើនជាតិសាសន៍ដទៃ គោរពកោតខ្លាចជាតិសាសន៍ដទៃៗ សូម្បីតែនិយាយដើមពីក្រោយក៏តែមិនហ៊ានផង ជាពិសេសគឺ សាសន៍យួន សាសន៍ចិនហ្នឹងឯង តែផ្ទុយទៅវិញបែរជាឃើញជនជាតិខ្មែរ

ខំប្រឹងអួងក្អេងក្អាងសំដែងនូវភាពសាហាវឃោរឃៅព្រៃផ្សៃដាក់ខ្មែរគ្នាឯងទៅវិញ។ ប្រជាជាតិខ្មែរស្ទើរតែលែងស្គាល់អ្វីទៅដែលហៅថាការពិត តថភាព ឧត្តមគតិជាតិ ព្រលឹងវិញ្ញាណស្នេហាជាតិ ឬក៏មនសិការជាតិ ស្មារតីសម្បជញ្ញៈជាតិស្អីគេនោះទេ។ សូមបញ្ជាក់ថាពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ត្រូវបានគណៈបក្សប្រជាជនកម្ពុជាបំបិទចោល កំទេចចោលនៅឆ្នាំ ១៩៩៧ បន្ទាប់ពីរដ្ឋប្រហារថ្ងៃ៥-៦ កក្កដា ឆ្នាំ ១៩៩៧ ទំលាក់សម្តេចក្រុមព្រះនរោត្តមរណឬទ្ធិចេញពីតំណែង។ ការបំបិទចោល សំលាប់កំទេចចោលនៅពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី គឺដោយសារតែគណៈបក្សប្រជាជនកម្ពុជាបារម្ភខ្លាចបែករឿងសំងាត់ភេរវកម្មនយោបាយដែលពួកគេធ្វើចាប់ពីឆ្នាំ១៩៩៣ រហូតដល់១៩៩៧ ដូចជាការដាក់បន្ទុះគ្រាប់បែកចងកៅស៊ូជាបន្តបន្ទាប់ ឃាតកម្មនយោបាយ ការបាញ់ប្រហារប្រជាជនស្លូតត្រង់ ការប្លន់ជីវិតដែលធ្វើឡើងដោយរដ្ឋាភិបាលអាយ៉ងយួន,,,,,,,។ល។ និង ។ល។ លើសពីនេះទៅទៀតដោយសារពួកបាក់គីដឹងសាច់រឿងច្រើនខ្លាំងពេក ចេះក្បួនយុទ្ធសាស្រ្តល្បិចប្រព្រឹត្តិបទឧក្រិដ្ឋយ៉ាងស្ទាត់ជំនាញពេកដែលធ្វើអោយគណៈបក្សប្រជាជនកម្ពុជាពិបាកគ្រប់គ្រងពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ហើយម្យ៉ាងវិញទៀតដោយសារតែលោក ជាស៊ីម ហ៊ុនសែន លោក ហុក ឡង់ឌី និង លោក ជា សុផារ៉ា (ចៅហ្វាយក្រុងភ្នំពេញនៅជំនាន់នោះ) បាន រៀបចំបង្កើតស្ថាបនានៅអង្គការឧក្រិដ្ឋជនបែបថ្មីដែលហៅថា អង្គការ អេស អូ វ៉ាយ (S.O.Y) មាន ន័យថាអង្គការយុវជនពិសេស (Special Organization of Youths) ជំនួសអោយអង្គការ ឧក្រិដ្ឋជនសំងាត់បាក់គី ហើយគណៈបក្សប្រជាជនកម្ពុជាយកកងកំលាំងរដ្ឋាភិបាលរួមដៃគ្នាជាមួយពួកសមាជិកសកម្មរបស់អង្គការ អេស-អូ -វ៉ាយ (S.O.Y) សំលាប់ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ដើម្បីបំបិទតាង បំបិទកស្មិណសាក្សីទៅថ្ងៃក្រោយ ដើម្បីជៀសវាងយប់យល់សុបិន្តច្រើននាំវិបត្តិទៅអនាគត។

## ***២-អង្គការយុវជនពិសេស អេស-អូ-វ៉ាយ*** S.O.Y (Special Organization of Youths)




**ហ៊ុន-ណាល់** ជាចោរលួច រៀនថ្នាក់ទី៤ នៅវិទ្យាល័យព្រះសីហនុខេត្តកំពង់ចាម ពេលខ្ញាក់ភ្នែកក៏រត់ចូលព្រៃ ប្តូរឈ្មោះ មកជា **ហ៊ុន-សែន** ឪពុកឈ្មោះ **ហ៊ុន-នៀង** ជាចោរលួចគោនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ម្តាយឈ្មោះ **ឌី-ប៉ុក** ជាអ្នកលក់នំអាកោរតាមភូមិ។

រូប **ហ៊ុន-សែន** នាឆ្នាំ១៩៨៣ ឈ្មោះដើមគឺ **ហ៊ុន-ណាល់** ជាចោរលួចនៅក្រូចឆ្មារ ខេត្តកំពង់ចាម រហូតដល់អ្នកស្រុកតាមចាប់ រត់ដួលជុងមែកត្របែកខ្ញាក់ភ្នែកម្ខាង រត់ចូលព្រៃម៉ាគី ដូរឈ្មោះជា **ហ៊ុន-សែន** ពូកែខាងប្រើ **ល្បិចភ្លែក្រុស** ទើបយួនលើកបន្ទុបជា **រដ្ឋមន្ត្រីក្រសួងការបរទេស** នាពេលយួនឈ្លានពានត្រួតត្រាខ្មែរ។ **កុំថាឡើយតែប្រវត្តិចោរខ្ញាក់ភ្នែករបស់ខ្លួន** សូម្បីតែព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ **យួនឈ្លានពានខ្មែរនាឆ្នាំ១៩៧៩ ក៏វាព្រុសហើយព្រុសទៀត កុហក់ ១០០០ ដង ឱ្យតែគេជឿ១ដង គឺជោគជ័យ** ព្រុសដល់តែជនមនុស្សអគតិមួយចំនួន និងប្រទេសមួយចំនួនជឿថា **យួនរំដោះខ្មែរឆ្នាំ១៩៧៩**។ ដើម្បីសំលាប់ជាតិខ្មែរបំផុតពូជសងសឹកនឹងភ្នែកខ្ញាក់ម្ខាងរបស់ខ្លួន អានេះបានអនុវត្តិន៍ផែនការ **ក៥** របស់យួនដើម្បី **បំផ្លាញព្រៃប្រល័យខ្មែរ ក្នុងនាមភ្លែស្គាល់ចិត្តម្ចាស់** ។ ជាមេភេរវិករបញ្ជាឱ្យបោកគ្រាប់បែកលើហ្វូងបាតុករថ្ងៃ៣០មិនា១៩៩៧នៅមុខរដ្ឋសភា មេរដ្ឋប្រហារ ថ្ងៃ៥-៦ កក្កដា១៩៩៧ដើម្បីលុបសន្ធិសញ្ញាក្រុងប៉ារីស អនុវត្តសន្ធិសញ្ញាព្រំដែនយួន-ខ្មែរ ឆ្នាំ១៩៨២-១៩៨៣-១៩៨៥។ជាមេស្ថាបនិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ, វ៉ាយ ឆ្នាំ១៩៩៧ និងជាប្រធានផ្តាច់មុខនៃអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ បន្ទាប់ពី លោក ហុក-ឡង់ឌី ត្រូវបានសំលាប់បំបិទមាត់នៅខែវិច្ឆិការ ឆ្នាំ ២០០៨។



**ជា-សុផារ៉ា** ជាចៅហ្វាយក្រុងភ្នំពេញនាសម័យបោកគ្រាប់បែកលើហ្វូងបាតុកម្មស៊ីវិលមុខរដ្ឋសភាឆ្នាំ១៩៩៧ បានអនុវត្តផែនការរដ្ឋប្រហារ ៥-៦ ខែកក្កដា១៩៩៧ ជាអ្នកផ្តួចផ្តើមគំនិតបង្កើតក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ឆ្នាំ១៩៩៧ និងបានអនុវត្តបញ្ជា ហ៊ុន-សែន រៀបចំកំលាំងពួកក្រុមក្មេងស្ទាវក្រុមបងតូចបងធំ ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ វាយ បង្ក្រាបសំលាប់ពួកបាតុកម្មប្រឆាំងឆ្នាំ១៩៩៨ និងប្រើកំលាំងពួកនេះធ្វើបាតុកម្មវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញ នៅខែមករា ឆ្នាំ ២០០៣

អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ មានន័យថាអង្គការយុវជនពិសេស គឺជាប្រភេទនៃអង្គការឧក្រិដ្ឋជនសំងាត់មួយរបស់គណៈបក្សប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងដោយស្តេចចោរ ហ៊ុន-សែន នៅ

ក្នុងឆ្នាំ ១៩៩៧ បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃ ៥-៦ កក្កដា ១៩៩៧ បណ្តេញសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិចេញពីអំណាច។ សម្តេចស្តេចចោរ ហ៊ុន សែន បានបញ្ជាអោយលោក ជា-សុផារ៉ា (ជាអភិបាលក្រុងនៃរាជធានីភ្នំពេញ រហ័ស្សនាមសំងាត់របស់គាត់គឺ ការ-ប្រាំ **K-5** ត្រូវបានគេហៅថាបងការប្រាំ) រៀបចំបង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ដែលមានលំនាំបែបបទ មានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងស្ថាប័នពួកឆ្មាំក្រហមរបស់លោក **ម៉ៅ-សេទុង** នៅក្នុងកំឡុងសម័យបដិវត្តន៏វប្បធម៏នៃរបបសាធារណៈប្រជាមានិតចិននា (People's Republic of China) ប៉ុន្តែខុសគ្នាពីពួកឆ្មាំក្រហមរបស់លោក ម៉ៅ សេទុង ដែលចេញមុខជាចំហរតាមលក្ខណៈផ្លូវច្បាប់ ចំណែកឯពួកក្រុម អេស អូ វ៉ាយ មានលក្ខណៈជាលួចលាក់មិនចេញមុខ ធ្វើសកម្មភាពដោយអាថ៏កំបាំង ហើយចំពោះការសំលាប់ប្រជាជនដ៏សាហាវឃោរឃៅការប្រព្រឹត្តិបទឧក្រិដ្ឋលើប្រជាជនខ្លួនឯងយ៉ាងសាហាវព្រៃផ្សៃនោះគឺមានដូចគ្នាបេះបិទ គឺមានន័យថាៈ "**រាល់គ្រប់ទង្វើរដែលពួកកុំមុយនីស្ត៏ធ្វើ គឺសុទ្ធតែមានបញ្ជាពីថ្នាក់លើទាំងអស់ បើគ្មានបញ្ជា គឺមិនហ៊ានធ្វើទេ ទោះបីកុំមុយនីស្ត៏ប្រើរូបភាពជាចោរ ឬជាឃាតករក៏ដោយ សុទ្ធជាបញ្ជារបស់ថ្នាក់លើទាំងអស់**"។ ក្នុងការបង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ នេះ លោក ជា សុផារ៉ា បានពិភាក្សាជាមួយលោក ជា ស៊ីម ជាមេដឹកនាំគណៈបក្សប្រជាជនកម្ពុជា អំពីពួកមនុស្សដែលសក្តិសមនឹងតែងតាំងជាមេដឹកនាំអង្គការយុវជនពិសេសនោះ។ បន្ទាប់ពីកិច្ចពិភាក្សាគ្នារវាង ហ៊ុន-សែន ជា-ស៊ីម និង ជា-សុផារ៉ា រួចរាល់មក ពួកគេក៏បានសំរេចចិត្តជ្រើសរើសយកលោក កែន-ចំរើន (ជាអនុប្រធានកងពលអ៊ី-៧០ [E-70] ឈ្មោះដើមគឺ ហ៊ុន-ដារ៉ា រហ័ស្សនាមហៅ កែន-ដាវីត ដែលត្រូវបានហ្វឹកហាត់ និងបង្វឹកសិល្បៈក្បាច់គុណនិនច្ចា និងក្បួនយុទ្ធសាស្រ្តដាកកុងនៅក្រុងហាណូយ ចាប់តាំងពីគាត់អាយុ ១៤ ឆ្នាំ) អោយធ្វើជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ((Source[A3]))។ បន្ទាប់ពីលោក កែន-ចំរើន ក្លាយជាប្រធានអង្គយុវជនពិសេស អេស,អូ,វ៉ាយ មក លោក កែន-ចំរើន និងលោក ជា-សុផារ៉ា ដោយមានការយល់ព្រម និងឯកភាពពីថ្នាក់លើគឺ ហ៊ុន-សែន ផងនោះ ពួកគេក៏បង្កើតក្រុមបងធំបងតូច និងក្រុមជនអន្ធពាលជាច្រើនក្រុមតាំងពីក្រុងភ្នំពេញរហូតដល់ខេត្ត ស្រុក ខ័ណ្ឌ ភូមិឃុំ,,,,,,,,,ពាសពេញទូទាំងប្រទេសកម្ពុជា គឺគ្រាន់តែរាជធានីភ្នំពេញមានក្រុមបងធំបងតូចរហូតដល់ជាង ៦០ ក្រុម។ នៅក្នុងការបង្កើតក្រុមបងធំបងតូចដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ គណៈបក្សប្រជាជនកម្ពុជាបានចាត់តាំងពួកអ្នកមានបណ្តាសក្តិសមល្មមចាប់ពីសក្តិពីរបីឡើងទៅដល់ផ្កាយនៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលមានខាងផ្នែកប៉ូលីសទាហ៊ាន ពួកចារបុរស

ខាងទាហ៊ានប៉ូលីស កងអង្គរក្សរបស់ពួកថ្នាក់ដឹកនាំជាន់ខ្ពស់ កងរាជអាវុធហត្ថដែលមានចិត្តឆៅដៃដល់សាហាវឃោរឃៅពូកែខាងបាញ់បោះកាប់ចាក់ ស្តាប់បង្គាប់បញ្ជាថ្នាក់លើដោយមិនចាំបាច់គិតពីហេតុផល ពួកមេបនរកស៊ីជួញដូរមនុស្ស ពួកជួញដូរគ្រឿងញៀន ពួកជួញដូរទំនិញ និងអាវុធខុសច្បាប់ ហើយនិងពួកក្មេងពាលក្មេងអាណាថាដែលមានចិត្តកាចសាហាវព្រៃផ្សៃគ្មានមនោសញ្ចេតនា គ្មានទីពំនឹកអាស្រ័យ ប៉ុន្តែពួកអ្នកអស់ទាំងនោះត្រូវតែស្ថិតក្នុងក្របខណ្ឌ័គណ:បក្សប្រជាជនកម្ពុជា ហើយស្មោះត្រង់ដាច់ខាតចំពោះគណ:បក្សប្រជាជនកម្ពុជា ត្រូវបានបក្សជ្រើសតាំង និងចាត់តាំងអោយធ្វើជាមេក្រុមបងធំបងតូចដែលពួកគេទាំងនោះត្រូវបាននិយមហៅថា "លោកបងធំ! លោកបងធំ! "ស្អីគេនោះ។ ពួកមេបងធំនិមួយៗមានតួជានាទីទទួលខុសត្រូវលើក្រុមបងតូចបងធំរបស់ខ្លួន ដឹកនាំកូនចៅរបស់ខ្លួនរកលុយចំណូលតាមគ្រប់មធ្យោបាយ និងតំរង់ទិសកូនចៅរបស់ខ្លួនអោយដើរតាមត្រីវិស័យទិសដៅរបស់គណ:បក្សប្រជាជន និងអនុវត្តន៏តាមបញ្ជារបស់គណ:បក្សប្រជាជនកម្ពុជាដែលដាក់អោយពួកគេធ្វើ បន្ថែមលើការរកចំណូលអោយបក្ស ។ ពួកមេបងក្រុមបងធំនិមួយៗមានតួនាទីកៃណ្ឌប្រមូលមនុស្សអោយចូលក្រុមរបស់ខ្លួន និងចាត់ចែងមនុស្សក្នុងក្រុមរបស់ពួកគេស្របតាមសភាពការណ៏ និងរបត់នយោបាយដែលគណ:បក្សប្រជាជនដាក់ទិស។ សូមញ្ជាក់ថា **ពួកសមាជិក កូនចៅ អាម៉ីអាចោង មនុស្សនៅក្នុងក្រុមបងតូចបងធំទាំងនោះគឺមិនដឹងខ្យល់អ្វីទាំងអស់ មិនដឹងរឿងរ៉ាវហេតុការណ៏ ឬអង្គហេតុអ្វីទាំងអស់ ហើយក៏មិនដឹងថាពួកគេកំពុងតែបំរើអោយគណ:បក្សប្រជាជនកម្ពុជា និងរាល់កិច្ចការទាំងឡាយដែលពួកគេកំពុងធ្វើគឺសុទ្ធតែជារឿងនយោបាយដែលពាក់ព័ន្ធយ៉ាង ស៊ីជំរៅទៅនឹងគណ:បក្សប្រជាជនកម្ពុជា** ផ្ទុយទៅវិញ **ពួកកូនចៅអាម៉ីអាចោង ពួកសមាជិកនៅក្នុងក្រុមបងតូចបងធំអស់ទាំងនោះគ្រាន់តែដឹងថាពួកគេខ្លាច គោរព និងស្តាប់បង្គាប់បញ្ជារបស់មេបងធំរបស់ពួកគេ** ហើយពួកគេយកលុយដែលពួករកបានអោយមេបងធំរបស់ពួកគេ ដើម្បីស៊ីផឹកសូកប៉ាន់ថ្នាក់លើ និងរកខ្នងបង្អែកត្រួសត្រាយផ្លូវអោយពួកគេដើរ ហើយពួកគេដឹងតែព្យាយាមបំពេញកាតព្វកិច្ចដែលមេបងធំរបស់ពួកគេដាក់អោយធ្វើ និងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីធ្វើអោយលោកបងធំរបស់ពួកគេសប្បាយចិត្តពេញចិត្តនឹងពួកគេ ដោយសង្ឃឹមថាមេបងធំរបស់ពួកគេនឹងទុកការងារថ្មីៗទៀតអោយពួកគេធ្វើនៅថ្ងៃមុខ ហើយពួកគេនឹងទទួលបានផលកំរៃ ប្រយោជន៏ខ្លះៗពីការងារអស់ទាំងនោះ។ **មានតែមេក្រុមបងធំតែប៉ុណ្ណោះទើបមានសិទ្ធិពេញលេញក្នុងនាមជាសមាជិក ឬក៏ជាសមាជិកពេញសិទ្ធិរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ** ហើយពួកមេបងធំអស់ទាំងនោះ ត្រូវបានគណ:បក្សប្រជាជន

ចាត់អោយចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំ និង ពួកមេដឹកនាំពិសេសនៃកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនកម្ពុជានៅតាមមូលដ្ឋានរបស់ពួកគេ ដើម្បីទទួលបញ្ជា និងផែនការពិសេសដែលបក្សដាក់អោយពួកគេអនុវត្តន៍ ហើយពួកអធិបតីតំណាងអង្គ ប្រជុំបានអនុញ្ញាតិអោយពួកមេបងធំទាំងនោះរាយការណ៏នៅរាល់ពត៏មានខុសប្រក្រតី ពួកជនទាំងឡាយដែលត្រូវបានសង្ស័យថាជាពួកប្រឆាំង ជាបក្សពួកប្រឆាំង ជាពួកក្បត់ ឬពួកដែលមានបំណងចង់ក្បត់ និង ពួកដែលធ្វើអោយរាំងស្ទះដល់ការអនុវត្តន៏ផែនការរបស់គណៈបក្សប្រជាជនកម្ពុជា លើសពីនេះទៅទៀត ពួកមេបងធំទាំងនោះត្រូវបានអនុញ្ញាតិអោយផ្តល់មតិយោបល់នៅអ្វីដែលគួរធ្វើ ឬអ្វីដែលមិនគួរធ្វើ ដើម្បីបោសសំអាតពួកប្រឆាំង ពួកដែលធ្វើអោយរាំងស្ទះដល់ការអនុវត្តន៏ផែនការរបស់បក្ស ថាតើគួរត្រូវគាប្បីចាត់វិធានការយ៉ាងដូចម្តេចនោះ? ហេតុដូច្នេះហើយ ទើបពួកមេបងធំទាំងនោះដឹងរាល់កិច្ចសំងាត់ផ្ទៃក្នុងរបស់គណៈបក្សប្រជាជនយ៉ាងច្បាស់ជាក់ប្រាកដថែមទាំងទទួលបានប្រយោជន៏យ៉ាងធំសម្បើម និងគុណ សម្បត្តិពីបក្សផងដែរ មានដូចជាអំណាចបុណ្យសក្កិទ្រព្យសម្បត្តិប្រាក់កាស លាភសក្ការៈផ្សេងៗជារង្វាន់ លើកទឹកចិត្ត រួមផ្សំនិងពាក្យលើកសរសើរបញ្ជោរលើកជើងផងដែរ ប៉ុន្តែពួកមេក្រុមបងធំបងតូចអស់ទាំងនោះ ក៏ទទួលរងគ្រោះថ្នាក់យ៉ាងខ្លាំងណាស់ដែរព្រោះពួកគេត្រូវបានគណៈបក្សប្រជាជនកម្ពុជាសំលាប់បំបិទមាត់ ត្រូវបានដាក់គុក ឬត្រូវគំរាមកំហែងដល់អាយុជីវិតដោយវិធីផ្សេងៗ ដោយសារតែពួកមេក្រុមបងធំទាំងនោះ ដឹងរឿងសំងាត់ច្រើនពេក បន្សល់ដានច្រើនពេក ធ្វើការមិនស្អាត ចាត់ការមិនរលូន ឬក៏ពួកគេមិនស្តាប់បង្គាប់បញ្ជារថ្នាក់លើ រឺងរូសធ្វើអោយខូចផែនការ មិនអនុវត្តន៏តាមផែនការថ្នាក់លើដាក់អោយ និងករណី ក្បត់បក្សជាដើម,,,,,។ល។ និង។ល។ (សូមបញ្ជាក់ថាគណៈបក្សប្រជាជនកម្ពុជាគឺជាពួកកុំមុយនីស្តផ្តាច់ការ ដូច្នេះពួកគេតែងតែប្រជុំពួកបក្ខជន សកម្មជន ឥស្សរៈជនសំខាន់ៗនៅក្នុងបក្សជារឿយៗរៀងរាល់សប្តាហ៏ រាល់ខែ រាល់ឆ្នាំដើម្បីពង្រឹង និងពង្រីកកំលាំងអំណាច វិសាលភាពបក្ស រកចំណូលអោយបក្សអោយបានច្រើនជាងពេលមុនៗ និងលាងខួរក្បាល ខាត់ដុសជំនឿមនោគមន៏វិជ្ជា ស្របតាមផែនការទិសដៅរបស់បក្ស ដើម្បីរកមធ្យោបាយបោសសំអាតខ្មាំងផ្ទៃក្នុងផ្ទៃក្រៅរបស់ពួកគេ និងបំបាត់ចោលពួកស្រពិចស្រពិលមិនច្បាស់លាស់សមដូចដែលពួកគេពោលថា **"បើមិនមែនជាមនុស្សក្នុងបក្ស មិនចូលបក្ស គឺមានតែជាខ្មាំង " ដូច្នេះបើជាខ្មាំង សុទ្ធតែក្នុងបញ្ជីស្បែកខ្មៅទាំងអស់** )។ ហ៊ុន សែន និងគណៈបក្សប្រជាជនកម្ពុជាបានប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ នៅក្នុងគោលបំណងពិសេសដូចខាងក្រោមនេះ

**(១)-សមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើប្រាស់ជាឧបករណ៍សំលាប់រង្គាលពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីនៅក្នុងគោលបំណងបំបិទភស្តុតាងពួកក្រុមឧក្រិដ្ឋជនសំងាត់បាក់គី**

ដើម្បីបញ្ចប់នៅរាល់បញ្ហាផលវិបាករបស់ពួកបាក់គី និងកំទេចសាក្សីឧក្រិដ្ឋជនទាំងអស់មិនអោយបែកធ្លាយបែករឿងអាថ៌កំបាំងនៃបទឧក្រិដ្ឋឃាតកម្ម និងភេរវកម្មប្លន់ជីវិត,,,,,លិចឮទៅខាងក្រៅ។ ពួកក្រុមសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីរាប់រយនាក់ត្រូវបានពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលរួមដៃសហការជាមួយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ សំលាប់យ៉ាងសាហាវព្រៃផ្សៃបំផុត ហើយគណៈបក្សប្រជាជនបានបិទផ្លាកពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីថាជាចោរប្លន់ ជាឃាតករ ជាពួកចោរចាប់ជីវិតមនុស្ស និងជាពួកឃួនសេរីផងដែរ ឬជាក៏ជាចលនាវំដោះ ចលនាក្បត់,,,,,,,,។ល។ និង។ល។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ដោយមានការគាំពារជួយជ្រោងជ្រែងពីពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល និងមានការរៀបចំផែនការយុទ្ធសាស្រយ៉ាងម៉ត់ចត់ពីថ្នាក់ដឹកនាំគណៈបក្សប្រជាជនកម្ពុជាផងនោះ ពួកគេត្រូវបានបញ្ជូអោយសំលាប់ពួកបាក់គីយ៉ាងសាហាវឃោរឃៅព្រៃផ្សៃបំផុត ដោយប្រើរូបភាពជាប្រជាជនវាយចោរស្លាប់នៅតាមទីប្រជុំជន ឬទីកន្លែងដែលពួកបាក់គីធ្វើសកម្មភាពព្រោះថ្នាក់លើរបស់ CPP ជាអ្នកបញ្ជូពួកសមាជិកអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់បាក់គី អោយធ្វើសកម្មភាពលួចឆក់ប្លន់ជីវិត សំលាប់ឃាតកម្ម,,,,,,,,ហើយបានបញ្ជូឱ្យពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំ ពួកក្រុមសមាជិក នៃអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ក្លែងជាប្រជាជនរងចាំទីកើតហេតុ ហើយធ្វើពុតជាផ្អើលឆោឡោជ្រួលច្របល់ មកចូលជួយជនរងគ្រោះ ព្រួតគ្នាចូលរួមវាយចោររហូតដល់ស្លាប់ ធ្វើហាក់បីដូចជាមានគំនុំនឹងពួកចោរខ្លាំងណាស់ ហើយប្រជាជនក៏ផ្អើលចោមរោមមើល បង្កើតជាភាពច្របូក

| | |
|---|---|
|  | នេះជាសកម្មភាពពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំ ពួកក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ក្លែងភេទធ្វើជាប្រជាជនរងចាំទីកើតហេតុ ធ្វើជាផ្អើលឆោឡោមកវាយសំលាប់ពួកឧក្រិដ្ឋជន ដែលជាគោលដៅបំបិទមាត់បំបាត់ដានអតីតកាលរបស់គណៈបក្សប្រជាជនកម្ពុជា។ |

ច្របល់លាយឡំគ្នារវាងប្រជាជនសមញ្ញ និងពួកក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ។ ពេលខ្លះស្នៀកពាក់កងកំលាំងទៅបាញ់ប្រហារសំលាប់ពួកបាក់គីស្រស់ៗតែម្តង ដោយបិទផ្លាក ប្រកាសប្រាប់ប្រជាជនថាបាញ់ចោរសំលាប់ព្រោះចោរ តដៃ! ។ ពួកសមាជិកនៃអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានគេសំលាប់ និងត្រូវបានស្លាប់ជាបន្តបន្ទាប់ ប៉ុន្តែដើម្បីសំរេចបេសសកម្មជាតិរបស់ពួកគេ ពួកគេសុខចិត្តក្រាញនទៀលមិនរត់គេចខ្លួនជាដាច់ខាត ហើយព្យាយាមអនុវត្តតាមបញ្ជាថ្នាក់លើគឺ លោក ហុក-ឡង់ឌី ដោយគ្មានការសង្ស័យអ្វីឡើយ។ ចំណែកលោក ហុក-ឡង់ឌី បានពង្រឹងជំនឿទុកចិត្តអោយពួកបាក់គីថែមទៀត ដោយលោក ហុក-ឡង់ឌី ខ្លួនឯងនេះបានក្លែងធ្វើជាមានទំនាស់ជាមួយ ហ៊ុន-សែន ក្នុងរឿងប្រជែងអំណាចគ្នានៅក្នុងបក្ស ហើយមានការប៉ះទង្គិចគ្នាយ៉ាងបែបនេះ ដែលជាសិល្បៈសង្គ្រាមមួយរបស់យួនដែលបានរៀបចំនុតឆាកលោ្ខនអោយក្រុមអាយ៉ងរបស់ខ្លួននៅក្នុងគណៈបក្សប្រជាជនកម្ពុជា ដើម្បីពង្រឹងអំណាច និងក្តោបអំណាចក្នុងប្រទេសកម្ពុជាអោយកាន់តែរឹងមាំ ចាក់គ្រឹះយ៉ាងណែនក្នុងដៃនោះ យួនកុំមុយនីស្ត៍បានបញ្ជាអោយអាយ៉ងរបស់ខ្លួនបែងចែកជា ៣ពួក ឬជា៣ខ្សែ នៅក្នុងគណៈបក្សប្រជាជនគឺ ខ្សែ ជា-ស៊ីម, ស-ខេង ខ្សែ ហ៊ុន-សែន និងខ្សែ ហុក-ឡង់ឌី ដែលខ្សែទាំងបីនេះធ្វើកិច្ចការតាមមុខសញ្ញារៀងៗខ្លួនទៅតាមខ្សែរញាក់ និងការបង្គាប់បញ្ជារបស់យួន ដែលរូបភាពខាងក្រៅមើលទៅហាក់បីដូចកំពុងបែកបាក់គ្នា ប្រជែងអំណាចគ្នានៅក្នុងជួរបក្ស ប៉ុន្តែតាមការពិតពួកគេទាំង៣ខ្សែនេះគឺគ្រាន់តែជាឧបករណ៍ប្រើប្រាស់ដើម្បីបំរើគោលបំណងលេបត្របាក់ទឹកដីខ្មែរប៉ុណ្ណោះ មិនបានបែកបាក់គ្នា មានទំនាស់នឹងគ្នាអ្វីឡើយ ដូចជាករណីបោកគ្រាប់បែកមុខរដ្ឋសភាវាយប្រហារលើជនបាតុករស៊ីវិលគឺ លោក ហុក-ឡង់ឌី (អគ្គស្នងការប៉ូលីសជាតិផ្កាយមាស៤) ជាអ្នកផ្តល់យោបល់អោយប្រើគ្រាប់បែកវាយប្រហារ រីឯ ហ៊ុន-សែន (នាយករដ្ឋមន្ត្រីទី២)គឺជា អ្នកបញ្ជាអោយក្រុមអង្គរក្សរបស់ខ្លួនឱ្យវាយប្រហារដោយគ្រាប់បែកទៅលើរូបលោក សម-រង្ស៊ី និងហ្វូង បាតុករស៊ីវិលកាលពីថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ ចំណែកឯលោក ស-ខេង (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ)និង លោក ជា-សុផារ៉ា (អភិបាលក្រុងរាជធានីភ្នំពេញ) ជាពួកអ្នកសំរួលដំណើរការវាយប្រហារនេះអោយមានភាពរលូន ហើយបន្ទាប់ពីវាយប្រហារដោយគ្រាប់បែករួចភ្លាមៗនោះ លោក ជា-សុផារ៉ា ជាអ្នកយកឡានទឹកទៅលាងសំអាតទីកន្លែងកើតហេតុ និងបានយកម៉ាស៊ីនឆក់យកកំទេចគ្រាប់បែកចេញពីទីកន្លែងកើតហេតុ ដើម្បីបំបាត់នៅរាល់ភស្តុតាងដែលសេសសល់ និងជួយសំរួលពត៌មានកើតហេតុអោយផ្ទុយពីការពិត បូកនឹងប្រតិមិតិក្នុងរឿងបទឧក្រិដ្ឋភេរវកម្មនេះ ដែលធ្វើពួកគណៈបក្សផ្សេង

ដទៃៗទៀតយល់ច្រលំ ហើយគិតខុស សន្និដ្ឋានខុស និងផ្សព្វផ្សាយព័ត៌មានខុស អោយគណៈបក្សប្រជាជនកម្ពុជាថែមទៀតផង។ មូលហេតុនេះហើយ ទើបពួកអង្គការបាក់គីតស៊ូបំពេញបេសសកម្មដោយឥតសង្ស័យ និងឥតញញើតរុញរាឡើយ ដោយសារភាពក្លាហានហួសប្រមាណគ្មានគិតពិចារណានេះហើយ បានជាពួកគេបាត់បង់ជីវិតយ៉ាងសន្ធឹកសន្ធាប់ ព្រោះលោក ហុក-ឡង់ឌី បានបញ្ជាអោយពួកបាក់គីធ្វើសកម្មភាពប្លន់ជីវិតសំលាប់ជួញដូរ,,,,,,,,, ហើយ លោក ហុក-ឡង់ឌី ខ្លួនឯង និងគណៈបក្សប្រជាជន ជាពួកអ្នកបញ្ជាកងកំលាំងប្រដាប់អាវុធ និងក្រុម អេស, អូ,វ៉ាយ រងចាំប្រហារពួកបាក់គី ដូច្នេះហើយ ទោះបីជាពួកបាក់គីនៅកន្លែងទីណាក៏ដោយ ក៏ត្រូវបានកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល និងពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ប្រម៉ាញ់ពួកបាក់គីបានយ៉ាងងាយជាទីបំផុត។ គ្មានរបាយការណ៍បញ្ជាក់ច្បាស់លាស់ថាពួកបាក់គីចំនួនប៉ុន្មាននាក់ត្រូវបានសំលាប់ទេ តែបើតាមសំដីរបស់លោក កែន-ចំរើន ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ បានអោយដឹងថា "អា មិន និង អាថាច់ ចាន់ ជាមនុស្សសេសសល់ចុងក្រោយបំផុតដែលមានសំណាងមកជាប់គុកនៅព្រៃស តែពួកវាគ្រាន់តែរស់បណ្តោះអាសន្នប៉ុណ្ណោះ ព្រោះពួកវាគ្រាន់តែតួអង្គឧបករណ៍នៃឆាកល្ខោន តាមប្រភព (Source$^{C2}$)។ តែបើតាមលោក ទូច-មៅ ដែលជាចោរប្លន់នៅអាគារសេ នៃគុកព្រៃស បាននិយាយថានៅខែតុលា ឆ្នាំ២០០៧ ថា រូបគាត់បានជាប់បន្ទប់វិន័យ(ជាបន្ទប់ទារុណកម្មគ្មានពន្លឺថ្ងៃ)ជាមួយបងមិន និងបងចាន់ ដែលជាអង្គរក្សលោក ហុក-ឡង់ឌី នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៦ នោះ បានដឹងរឿងជាច្រើនអំពីពួកគាត់ បងមិន និងបងចាន់ បាននិយាយថាកាលពីគាត់នៅក្រៅសំបូរលុយផឹកស៊ីណាស់ គិតតែសប្បាយ ជាពិសេសពេលប្លន់ជីវិតម្តងៗ លុយមិនដឹងជាយកទៅណាអស់ទេ ប៉ុន្តែលុយទាំងនោះប្រៀបដូចជាមានស្លាប ពួកគាត់បានតែមកត្រឹមកាន់រយៈពេលខ្លីតែប៉ុណ្ណោះ រួចហើយលុយទាំងនោះនឹងហោះចេញទៅវិញ ព្រោះប៉ាប៉ាអោយមនុស្សមកយកអស់ ទុកតែបន្តិចបន្តួចសំរាប់ពួកគាត់សប្បាយផឹកស៊ីស្រីស្រាតែប៉ុណ្ណោះ ប៉ាប៉ា (ហុក-ឡង់ឌី) អោយពួកគាត់ធ្វើតែករណីធំៗប៉ុណ្ណោះ បើអោយពួកគាត់ទៅប្លន់វិញ គឺចាប់ពីរាប់ម៉ឺនដុល្លាឡើងទៅ ពួកគាត់មិនធ្វើទេចំពោះរឿងតូចតាចនោះ។ ខ្ញុំបានព្យាយាមរកលោកមិន និងលោកចាន់ដែរ ប៉ុន្តែមិនមានឱកាសបានជួបពួកគាត់សោះ ព្រោះពួកគាត់ទាំង២នេះ ត្រូវបានចាងហ្វាងគុកព្រៃ-ស ព្យាយាមអោយចោរវាយសំលាប់បំបិទមាត់ តែដោយសារវិជ្ជាគុនពួកគាត់ខ្លាំង ក៏មិនស្លាប់ ដូច្នេះបានជាចាងហ្វាងគុកព្រៃ-ស ចាប់ពួកគាត់ដាក់ក្នុងបន្ទប់វិន័យ ហើយបន្ទាប់មកក៏បញ្ជូនពួកគាត់ទៅកាន់គុកត្រពាំងឃ្លុង ក្រោយមកក៏បានដំណឹងពីលោកធូ-ដ៉ារ៉ា ថា

អាមិន អាចាន់ ត្រូវបានគេសំលាប់បំបិទភស្តុតាងទៅហើយ ។

**(២) -រកលុយអោយគណៈបក្សប្រជាជនកម្ពុជាតាមរយៈ**ការលួចឆក់ប្លន់ ជិវិតសំលាប់ ជួញដូរមនុស្ស អាវុធទំនិញខុសច្បាប់ ជួញដូរ និងចែកចាយគ្រឿង ញៀនអោយបក្ស លាងលុយក្រខ្វក់ ឃាតកម្មស៊ីឈ្នួល កុហក់បោកប្រាស់,...,. ។ល ។ និង ។ល ។ គណៈបក្សប្រជាជនប្រកបមុខរបរងងឹតសព្វយ៉ាងដើម្បីបង្កើនប្រាក់ចំណូលចូលបក្សក្នុងការពង្រឹងអំណាចរបស់ខ្លួន ហើយមុខរបរជួញដូរគ្រឿងញៀនគឺជាអាទិភាពចំបងបំផុតក្នុងការបង្កើនប្រាក់ចំណូលចូលបក្សអោយកាន់តែច្រើនអណេក ហើយបញ្ជូននាំចេញនាំចូលគ្រឿងញៀនទៅកាន់ប្រទេសក្រៅ មិនទាន់គ្រប់គ្រាន់ទេ ដូច្នេះ ការបង្កើតក្រុមបងធំបងតូចទូទាំងប្រទេសទើបបន្ថែមចំណូលកើនឡើងរាប់សិបដងសំរាប់គណៈបក្សប្រជាជនក្នុងការពង្រឹងបណ្តាញចារកម្ម បំពាក់គ្រឿងឧបករណ៏ចារកម្មអាស្សាណូទំនើប (modern spy bugs) (Source$^{Special}$) ដើម្បីពង្រឹងអំណាចផ្ទៃក្នុង និងកំទេចពួកបក្សប្រឆាំងអោយបានកាន់តែឆាប់រហ័សថែមទៀត ។ ករណីរកស៊ីគ្រឿងញៀនក្នុងទ្រង់ទ្រាយធំនេះ គឺមានចរាចរនៅក្នុងស្រុក និងនាំចេញទៅបរទេសដែល ចាប់ពីរាប់គីឡូក្រាមឡើង ទៅរហូតដល់ថ្នាក់ រាប់រយ និងរាប់សិបតោន ដែលពួកគេបែងចែកជា ៣ ប្រភេទនៃមុខទំនួញគឺៈ

**-ប្រភេទទី១ គឺជាប្រភេទគ្រឿងញៀនដែលមិនទាន់បានកែច្នៃសោះ** គឺជាគ្រឿងញៀនផលិតផលជាវត្ថុធាតុដើមមានដូចជាកញ្ឆា គ្រាប់ពូជគ្រឿងញៀន ឬដើមរុក្ខជាតិដទៃៗទៀតដែលពួកគេអាចដាំក្នុងប្រទេសខ្មែរបាន ហើយផលិតចេញជាទ្រង់ទ្រាយធំសំរាប់ការនាំចេញទៅក្រៅប្រទេស ហើយបើតាមប្រភពឯកសារដែលមានចំណងជើងថា **U.S. accuses Hun Sen on drugs; terrorism** ប្រទេសកម្ពុជាបានក្លាយជាប្រទេសពាណិជ្ជកម្មធំចម្បងបំផុតមួយនៃការផ្ទេរថ្នាំញៀនប្រភេទហេរ៉ូអ៊ីន និងកញ្ឆា នៅអាស៊ីអាគ្នេយ៏នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយថ្នាំញៀនកញ្ឆារបស់ប្រទេសកម្ពុជាត្រូវបានចាប់រឹបអូសបានទំងន់ចំនួន ១២០ តោន នៅក្នុងទ្វីបអ៊ឺរ៉ុបនៅក្នុងកំឡុងឆ្នាំ ១៩៩៦ (Cambodia has become a major transshipment point for Southeast Asian heroin and marijuana in recent years, with 120 tons of Cambodian marijuana seized in Europe during 1996 សូមមើលវិបសាយ **http://www.garella.com/rich/grenpost.htm**

http://ki-media.blogspot.com/2007/06/cpp-tycoon-senator-mong-reththys-shady.html

http://hengpov.wordpress.com/

ក្នុងរឿងករណីដូចគ្នាដែរ នៅក្នុង ប្រទេសខ្មែរ ថ្នាំញៀនកញ្ឆារបស់លោក ឧកញ៉ា ម៉ុង ឫទ្ធី ចំនួន ៧ តោន តាមប្រភព (**Source**$^{D1}$) ដែល លោក ហូ សុខ (មកពីបក្សហ្វុនស៊ិនប៉ិច ជាអនុរដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃនៅក្នុងរដ្ឋាភិបាលចំរុះ អាណត្តិទី១) បានចាប់បានកញ្ឆារបស់លោក ម៉ុង ឫទ្ធី ចំនួន ៧ តោននៅ ឆ្នាំ ១៩៩៧ នៅកំពង់ផែក្រុងព្រះ សីហនុ ពីកុងទីន័រដែលបិទផ្លាកថាកៅស៊ូនោះ។ ប៉ុន្តែលោក ហេង-ពៅបានអះអាងថារូបលោកជាអ្នករឹបអូស យកកញ្ឆា ៧ តោន ដែលលាក់ក្នុងកុងទីនឺ ដាក់ក្នុងកប៉ាល់រួចជាស្រេច បំរុងនឹងនាំចេញទៅកាន់ប្រទេសន័រវេ (Norway) នៅកំពង់ផែក្រុងព្រះសីហនុ ជារបស់ក្រុមហ៊ុន របស់លោក ម៉ុង ឫទ្ធី ដែលជាមិត្តជិតស្និតរបស់ ហ៊ុន-សែន ហើយបន្ទាប់មកលោក ហូរ-សុខ ជាអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃមកពីគណៈបក្ស ហ្វុនស៊ីនប៉ិច បានសុំអោយលោក ហេង-ពៅ ចាប់ខ្លួនលោក ម៉ុង-ឫទ្ធី តែលោក ហេង-ពៅ មិនអាចធ្វើបាន ព្រោះលោក ម៉ុង-ឫទ្ធី ជាប់ពាក់ពន្ធ័នឹងលោក ហ៊ុន-សែន គឺមិនអាចប៉ះពាល់បានឡើយ (**Source**$^{D1}$)។ តែត្រូវបាន ហ៊ុន-សែន ព្រមានគំរៀមបកវិញថា បើចង់ចាប់ លោកឧកញ៉ា ម៉ុង ឫទ្ធី អោយពាក់ក្បាលពាសដែកមកផង



***Mong Reththy** receiving a narcotic medal*

http://www.youtube.com/watch?v=_IH9Zh24EXw

ទីបំផុតបន្ទាប់រដ្ឋប្រហារ លោក ហូរ-សុខ ត្រូវបានសំលាប់ស្លាប់យ៉ាងអណោចអធមក្នុងរដ្ឋប្រហារថ្ងៃ ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ ព្រោះលោក ហូរ-សុខ គឺជាវរៈជនឆ្លាតវៃស្មោះត្រង់នឹងជាតិ ដែលជាឧបសគ្គរាំង ស្ទះដល់ពាណិជ្ជកម្មម៉ាហ្វីយ៉ារបស់គណៈបក្សប្រជាជនកម្ពុជា និងធ្វើអោយរាំងស្ទះដល់ការអនុវត្តបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ។

គោលដៅដ៏ធំបំផុតរបស់យួនកំមុយនីស្តនៅក្នុងបេសកកម្មរំលាយជាតិខ្មែរ គឺផែនការបោសសំអាតខ្មាំងក្រុងហាណូយ ដើម្បីដកបន្លាចេញពីទ្រូង និងដកស្នឹមចេញពីកែវភ្នែកគឺ កំទេចរាល់**ពួកអ្នកជាតិនិយមខ្មែរ និងពួកវរៈជនស្នេហាជាតិខ្មែរ** ចំណែកឥស្សរៈជន គ្រាន់តែជារឿងបន្ទាប់ បន្សំតែប៉ុណ្ណោះ គឺយួនចំលងយក

ទាំងស្រុងនៅយុទ្ធសាស្ត្រសិល្បៈសង្គ្រាមរបស់ស្តេចចិនឈ្មោះ **ស៊ី៖ ហ៊ាំង ទី** Shih Huang Ti (256 B.C-206 B.C) ដែលវាយទន្ទ្រានលេបយកនគរជិតខាងទាំង៨ ហើយសំលាប់ ពួកអ្នកចេះដឹងពួកអ្នកប្រាជ្ញចោលអស់ រួចបង្រួបបង្រួមធ្វើជានគរតែមួយ យកឈ្មោះព្រះអង្គធ្វើជាឈ្មោះនគរ ហៅថា នគរឆិន (China) គឺប្រទេសចិន ហ្នឹងឯង សូមមើលសៀវភៅ WORLD HISTORY by Irving L.Gordon, second Edition (Revised 1982) ។

**-ប្រភេទទី២៖ជាប្រភេទគ្រឿងញៀនជាលក្ខណៈផលិតផលសំរេច** ដែលបាននាំចូលពីខាងក្រៅប្រទេសចូលមក មានដូចជា ហេរ៉ូអ៊ីន ទឹកកក ,,,,,,,,,ជាដើម ដែលគណៈបក្សប្រជាជននាំមកពីប្រទេស ភូមា ឬក៏ពីប្រទេសឡាវ ចូលមកប្រទេសកម្ពុជា ហើយនាំចេញទៅកាន់ប្រទេសទាំង៥៦ នៅក្នុងបណ្តាញម៉ាហ្វីយ៉ា ដែលពួកគេរកស៊ីជាមួយ ។ តាមសំដីរបស់លោក **កែន-ចំរើន** (ឈ្មោះនៅក្នុងក្រុមអន្ធពាល Mafia បានហៅរូបគាត់ថា **កែន-ដាវីត**) បានពោលថា ក្នុងរយៈពេលដែលគាត់កាន់តំណែងជាប្រធាន អង្គការឧក្រិដ្ឋជនសំងាត់អេស អូ វ៉ាយ គណៈបក្សប្រជាជនកម្ពុជា បានចាត់រូបគាត់អោយដើរតួជា**ថៅកែធំ** ដើម្បីនាំគ្រឿងញៀនចេញក្រៅប្រទេស ជាពិសេសគឺហេរ៉ូអ៊ីន ទៅកាន់ ៥៦ ប្រទេស មានដូច ជាប្រទេស ថៃ ម៉ាឡេស៊ី ប្រ៊ុយនេតៃវ៉ាន់ ហុងកុង កាណាដា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក រុស្សី,,,,,,,,,,,,,។ល។ និង ។ល។ នៅពេលដែលលោក កែន-ចំរើន ធ្វើជាថៅកែធំនោះ គឺគណៈបក្សប្រជាជនអនុញ្ញាតិអោយគាត់ប្រើប្រាស់តាមចិត្តចង់ ហើយគាត់អាចផ្ញើរថ្នាំហេរ៉ូអ៊ីនចំនួយ បួន-ប្រាំ គីឡូក្រាមភ្ជាប់ជាមួយថ្នាំហេរ៉ូអ៊ីនរាប់តោនរបស់គណៈបក្សប្រជាជនកម្ពុជាផងដែរ ។ The Cambodian drug trade includes cannabis, methamphetamine, and high graded heroin ប្រទេសកម្ពុជាជាប្រទេសពាណិជ្ជកម្ម គ្រឿងញៀនរួមមាន កញ្ឆា មិតាអំហ្វេតាមីន និងហេរ៉ូអ៊ីនក៏រិតខ្ពស់ នេះបើតាមប្រភព (Source$^{D3}$) ហើយក្រៅពីលោក កែន-ចំរើន ដែលដើរតួជាថៅកែធំនោះ នៅមានលោក ថេង-ប៊ុនម៉ា ម៉ុងរិទ្ធី,,,,,,,,, សុទ្ធតែត្រូវបានបញ្ជា និងរៀបចំឡើងដោយឥស្សរៈជនមេដឹកនាំជាន់ខ្ពស់របស់គណៈបក្សប្រជាជនកម្ពុជាដែលមាន ហ៊ុន-សែន លោក ជា-សុផារ៉ា លោក ហុក-ឡង់ឌី និងពួកក្រុមឧត្តមសេនីយដទៃៗទៀត នៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់រាជ

រដ្ឋាភិបាលកម្ពុជាដូចជាករណីនៅក្នុងឆ្នាំ ១៩៩៧ លោក ថេង-ប៊ុនម៉ា និង ហ៊ុន-សែន បានរកស៊ីគ្រឿងញៀន ចូលហ៊ុនគ្នា ហើយ ហ៊ុន-សែន បានប្រើល្បិចពាលស៊ីពាលលេងលោកថេង-ប៊ុនម៉ា ស្ទើរអស់ចុងអស់ដើម ។

| | |
|---|---|
|  មេម៉ាហ្វីយ៉ាខ្មែរឈ្មោះ លោក **ថេង-ប៊ុនម៉ា** | លោក **ថេង-ប៊ុនម៉ា** ជាមហាសេដ្ឋីថ្នាំញៀនរបស់កម្ពុជា ជាម្ចាស់សណ្ឋាគារប្រណិត ឈ្មោះ "Intercontinental" នៅភ្នំពេញ ជាម្ចាស់កាសែតរស្មីកម្ពុជា Rasmei Kampuchea ជាសារពត៌មានម៉ាហ្វីយ៉ា (Mafia) ខ្មែរធំជាងគេបោះពុម្ពផ្សាយ ១៨ 000ច្បាប់ក្នុង១ថ្ងៃនិងជាព្រឹទ្ធាចារ្យបង្រៀនពួកមេដឹកនាំគណៈបក្សប្រជាជនកម្ពុជា អោយចេះវិធីរស៊ីជួញដូរគ្រឿងញៀនជាមួយពួកម៉ាហ្វីយ៉ា ៥៦ប្រទេសលើពិភពលោក ដើម្បីរកលុយចិញ្ចឹមបក្ស។ http://www.ask.com/wiki/Drugs_in_Cambodia |

បានបញ្ជូអោយលោក ថេង-ប៊ុនម៉ា ទទួលខុសត្រូវក្នុងការនាំចេញហេរ៉ូអ៊ីន ទំងន់ ៦៧៥0 គីឡូក្រាមផ្ទុកនៅក្នុង ៥៣ កុងតឺនឺរ នាំចេញទៅកាន់ប្រទេសដាណឺម៉ាក ប៉ុន្តែត្រូវបានរដ្ឋាភិបាលដាណឺម៉ាកចាប់ និងរឹបអូសយកថ្នាំហេរ៉ូអ៊ីនអស់ទាំងនេះ (Source$^{B4\ and\ B5}$) ហើយនៅពេលនោះ ហ៊ុន-សែន បានខឹងសម្បានឹងលោក ថេង-ប៊ុនម៉ា យ៉ាងខ្លាំង ហើយតំរូវអោយលោក ថេង-ប៊ុនម៉ា សងមាសសុទ្ធចំនួន ៥ តោនមកអោយ ហ៊ុន-សែន វិញ ប៉ុន្តែលោក ថេង-ប៊ុនម៉ា បានទៅទីក្រុង ហុងកុង ទិញមាសសុទ្ធបានតែចំនួន ១ តោន យកអោយ ហ៊ុន-សែន។ ហ៊ុន-សែន បានរឹបអូសយកសណ្ឋាគារប្រណិតថ្នាក់ផ្កាយ៥ ឈ្មោះអ៊ិនធឺកុងទីណង់តាល់ របស់លោក ថេង-ប៊ុនម៉ា នៅទីក្រុងភ្នំពេញធ្វើជាផ្ទះរងចាំលោក ថេង-ប៊ុនម៉ា យកមាសសុទ្ធ ឬលុយមកដូរ (the luxury hotel "Intercontinental" in Phnom Penh) ហើយត្រូវបានដាក់បំរាមហាមមិនអោយលោក ថេង-ប៊ុនម៉ា ចូលជួបជាដាច់ខាត ។

ករណីនៅឆ្នាំ ២00៣ លោក ហេង-ពៅ បានចាប់រឹបអូសយកថ្នាំញៀនហេរ៉ូអ៊ីន ចំនួន ៣៦ គីឡូក្រាម ពីលោក ងួរ-សម្បត្តិ នៅខ័ណ្ឌទួលគោករាជធានីភ្នំពេញគឺជាមនុស្សរបស់លោកឧត្តមសេនីយផ្កាយ៣ ឈ្មោះ សៅ-សុខា និង ពាក់ព័ន្ធនឹងលោកឧត្តមសេនីយផ្កាយ២ ឈ្មោះលោក ដុំ-ហាក់ តែត្រូវបាន ហ៊ុន-សែន បានឃាត់លោក ហេង-ពៅ ហាមមិនឱ្យចាប់លោក ដុំ-ហាក់ និងសំលាប់លោក ងួរ-សម្បត្តិ បំបិទមាត់

http://hengpov.wordpress.com/

**http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html**

ដោយ សារតែ លោក ដុំ-ហាក់ និងលោកសៅ-សុខា គ្រាន់តែដើរតួនាទីជាថៅកែធំថ្នាំញៀន ជួសមុខឱ្យគណៈបក្សប្រជាជនកម្ពុជា ជួសមុខឱ្យ ហ៊ុន-សែន ជាប្រមុខ ដើម្បីចែកចាយបោះដុំអោយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ យកលក់បន្តអោយពួកក្រុមក្មេងស្ទាវក្រុមបងតូចបងធំតែប៉ុណ្ណោះ។

**-ប្រភេទទី៣ : ជាគ្រឿងញៀនកែច្នៃផលិតនៅក្នុងប្រទេស** ដោយគ្រាន់តែនាំវត្ថុធាតុដើមចូលមកពីខាងក្រៅហើយកែច្នៃចេញជាគ្រឿងញៀនដ៏មហាគ្រោះថ្នាក់ដូចជាប្រភេទថ្នាំយ៉ាម៉ា ថ្នាំគ្រាប់ ខេ ការហ៊ិត,,,,,,,, ជាដើម ថ្នាំអស់ទាំងនេះសុទ្ធតែផលិតដោយគណៈបក្សប្រជាជន ជាពិសេសជនជាតិយួនដែលរកស៊ីបើកបនស្រី ឬជនពាក់ពន្ធ័នឹងបនបារ សុទ្ធតែចេះទាំងអស់ ហើយពួកគេចេះផ្លាស់ប្តូរវត្ថុធាតុដើមយ៉ាងស្ទាត់ជំនាញទៅតាមអ្វីដែលពួកគេមាន។ បើតាមសំដីលោកគីមវ៉ាន់សាង ដែលជាមេបនម្នាក់ជាប់គុកដោយសារប្រពន្ធប្រើល្បិនោះ នៅបន្ទប់៣២ អាគារអា A នៃគុកព្រៃស នៅខែវិច្ឆិការ ឆ្នាំ ២០០៦ បានបង្ហើបអោយដឹងថាអ្នកដែលស្ទាត់ជំនាញក្នុងការផលិតថ្នាំញៀនដូចជា ថ្នាខេ ថ្នាំគ្រាប់ ថ្នាំយ៉ាម៉ា ,,,,,,គឺតាសេង នៅសណ្ឋាគារហូលីដេ ជាមនុស្សរបស់ ហ៊ុន-តូ ក្មួយប្រុសរបស់ ហ៊ុន-សែន។ ក្នុងការលួចរូបមន្តដើម្បីផលិតថ្នាំយ៉ាម៉ានោះ លោក គិម-វ៉ាន់សាង បានព្យាយាមយកចិត្តយកថ្លើមស្រីស្នេហ៍របស់តាសេងឈ្មោះអាមុីដែលជាសិស្សជំនិតផងដែរហើយចេះវិធីផលិតថ្នាំយ៉ាម៉ាយ៉ាងស្ទាត់ជំនាញដែលមានគុណភាពលើសថ្នាំមកពីខាងក្រៅទៅទៀត គាត់បានបញ្ជាក់ថែមទៀតថាគ្រប់ពួកអ្នករកស៊ីបើកហាងស្រីគឺចេះទាំងអស់ ខ្ញុំក៏សួរគាត់ផលិតបែបយ៉ាងម៉េច គាត់ថា យើងត្រូវតែឆ្លាតពីវត្ថុធាតុដើមត្រូវតែប្រែប្រួលតាមអ្វីដែលយើងមាន ដំបូងយើងត្រូវយកធាតុផ្សំ ទឹកស៊ីលិច (ដើម្បីយកពណ៌) ប្រេងម្រះព្រៅ (ដើម្បីយកក្លិនក្រអូប) កញ្ឆា (បើបានហេរ៉ូអ៊ីនកាន់តែប្រសើរ, កញ្ឆាធ្វើអោយងងុយដេក តែបើត្រូវមេអាស៊ីតវិញ វាក្លាយជាអត់ងងុយតែធ្វើអោយញៀន) ម៉េវ៉ាកាហ្វេអ៊ីន (ធ្វើអោយអត់ងងុយ ស្រវឹង ង៉ាង) ម៉េវ៉ាគ្រាប់ឈូក (ដាក់យកបរិមាណអោយបានច្រើន) កិនកំទេចលាយ បញ្ចូលគ្នា ជាទឹកប៊ិក១ រួចលាយជាមួយមេអាស៊ីត កូរតែមួយភ្លែតឆ្អួតរឹង ហើយយកទៅ

ចាក់ពុម្ពលក់ ប៉ុន្តែក្នុងការលក់ដូរត្រូវចំណាយច្រើនទៅលើពួកកងកំលាំង និងទៅលើខ្នងបង្អែកនៅក្នុងតំបន់របស់គាត់ គ្មានអ្នករកស៊ីណាមួយដែលមិនចំណាយ ហើយឈរជើងហ្នឹងនោះទេ។

ក្នុងលំដាប់គ្រឿងញៀនប្រភេទទី៣ នេះ គណៈបក្សប្រជាជនកម្ពុជាបានផលិតដ៏ច្រើនសន្ធឹកសន្ធាប់ ហើយត្រូវការដីដាំដុះយ៉ាងធំសម្បើមដើម្បីដាំកញ្ឆា និងដើមអាភៀនដោយលួចលាក់ ដីធ្លីនៅស្រុកខ្មែរមិនថាដីភ្នំ ដីទំនាប ឬដីព្រៃឡើយ អោយតែមានបំរ៉ាមហាមឃាត់មិនអោយប្រជាជនឆ្លងកាត់ ឬដើរជិតបៀត គឺសុទ្ធតែជាដីដាំដើមកញ្ឆា និងដាំរុក្ខជាតិផលិតថ្នាំញៀនទាំងអស់ ទោះបីរដ្ឋាភិបាលបិទផ្លាក ប្រើរូបភាពបែបណាក៏ដោយ គឺគ្រាន់តែជាល្បិចបំភាន់ភ្នែកប្រជាជនទាំងអស់ ជាពិសេសដីព្រៃភ្នំ (ពាក្យដីវិនិយោគ និង ដីបន្ទាយកងទ័ព ដីក្រុមហ៊ុន ដីថៅកែបរទេស គឺជាលេសបិទបាំងយ៉ាងសាមញ្ញរបស់គណៈបក្សប្រជាជន) ដែលជាតំបន់ហាមឃាត់របស់ពួកគេ។ ដូច្នេះកញ្ឆា ជាអាទិភាពសេដ្ឋកិច្ចយ៉ាងចម្បងសំរាប់បង្កើននៅប្រាក់ចំណូលទ្វេរាប់សិបដងអោយគណៈបក្សប្រជាជនសំរាប់កែច្នៃចេញជាប្រភេទគ្រឿងញៀនដទៃៗទៀតដូច ជាថ្នាំគ្រាប់ ថ្នាំខេ ថ្នាំយ៉ាម៉ា,,,,,,,និងថ្នាំរាប់សិបប្រភេទទៀតដែលមានលក្ខណៈបំភាន់ភ្នែកមើលទៅដូចថ្នាំពេទ្យធម្មតា ឬជារូបរាងស្ករគ្រាប់ នំនែកផ្សេងៗ ,,,,,,,,ក្រៅពីនេះ កញ្ឆាត្រូវបានលក់នៅក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស ចំណែកប្រេងម្រះព្រៅវិញ គ្រាន់តែជាផលិតផលផ្គួបផ្សំតែប៉ុណ្ណោះ។ ដូច្នេះហើយបញ្ហាទីផ្សារ និងបញ្ហាបញ្ចេញទំនិញគ្រឿងញៀនទាំងនេះបានចោទឡើងដែលគណៈបក្សប្រជាជនត្រូវតែរកមធ្យោបាយដោះស្រាយជាបន្ទាន់ មូលហេតុនេះហើយដែលគណៈបក្សប្រជាជនចាំបាច់ត្រូវតែបង្កើតចេញជាក្រុមបងតូចបងធំ ហើយបង្ខឹកពួកគេអោយប្រើថ្នាំញៀន ដែលក្នុងករណីបង្ហាត់បង្រៀននេះ ពួកគេអោយយុវជន ក្មេងស្ទាវសាកល្បងដោយអត់យកលុយ ឬយកក្នុងកំរៃស្តួចស្តើងបំផុត រហូតដល់ពួកយុវជនពួកក្មេងស្ទាវក្លាយទៅជាញៀនថ្នាំ ទើបពួកគេលក់ឡើងថ្លៃកប់ក្តោងតែម្តង។ ចំណែកឯពួកមេក្រុមបងធំនិមួយៗ (លោកបងធំ) មានឋានៈត្រឹមតែជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ តែប៉ុណ្ណោះ ពួកមេបងធំទាំងនោះមានតួនាទីអនុវត្តន៏តាមបញ្ជារបស់មេដឹកនាំគណៈបក្សប្រជាជនកម្ពុជា ទទួលថ្នាំញៀនពីគណៈបក្សប្រជាជនកម្ពុជាយកទៅលក់ចែកចាយអោយកូនចៅអាមុីអាថោង និងមនុស្សនៅក្នុងក្រុមបងតូច

បងធំរបស់ខ្លួន ហើយប្រមូលប្រាក់កំរៃចំណេញពីការលក់ថ្នាំញៀននេះអោយទៅថ្នាក់លើ ហើយប្រាប់កូនចៅរបស់ខ្លួនថាជាលុយសូកប៉ាន់ ជាលុយសគុណ ជាលុយសំរាប់ខ្ទងបង្អែកដើម្បីរកស៊ីទៅថ្ងៃក្រោយ ក្រៅពីនេះ តួនាទីរបស់មេបងធំត្រូវដឹកនាំកំលាំងមនុស្សរកលុយ និងផ្តល់មធ្យោបាយអោយរកលុយដល់បក្សពួកកូនចៅរបស់ខ្លួន។ បើតាមសំដីរបស់លោក ហេង-សុវណ្ណរិទ្ធិ ហៅបងហ៊្វលីព (Source$^{A5}$) បានប្រាប់ថា លោកបានធ្លាប់ចូលរួមប្លន់ហាងមាស ហាងដូរលុយ,,,,,ជាមួយលោក ហ៊ុន-ពៅ (ជាកូនរបស់ ហ៊ុន-ណារី និងក្មួយរបស់ ហ៊ុន-សែន) មានពេលខ្លះ ហ៊ុន-ពៅ បានប្លន់បីកន្លែងក្នុងមួយថ្ងៃក៏មាន សូម្បីតែហាងប្តូរប្រាក់លី-ហ៊្វរ នៅជិតផ្សារអូឬស្សីក៏ ហ៊ុន-ពៅ ជាអ្នកប្លន់ដែរ ហើយ ហ៊ុន-ពៅ នេះគឺជាអ្នកនៅពីក្រោយឆាកសកម្មភាពក្មេងស្ទាវប្លន់រំដោះអ្នកទោស នៅតុលាការក្រុងភ្នំពេញ ហើយបញ្ជាអោយកងកំលាំងសំលាប់បំបិទមាត់ស្ទើរតែទាំងអស់ ទុកតែអ្នកដែលមិនដឹងថា ហ៊ុន-ពៅ បញ្ជាអោយប្លន់តែប៉ុណ្ណោះ ក្រោយមកខ្លាចបែករឿងសំងាត់ ហ៊ុន-ណារី បានបញ្ជូន ហ៊ុន-ពៅ ទៅកាន់ប្រទេសភូមា មួយរយៈ។ តែបើតាមលោក ផន-ផល នៅបន្ទប់លេខ ១៧ អាគារអា នៃគុកព្រៃស បានប្រាប់ខ្ញុំថា ពួកគាត់គឺជាចោរ អាការ នៅខេត្តកណ្តាល នៅក្នុងក្រុមរបស់ពួកគាត់ភាគច្រើនសុទ្ធតែជាប៉ូលិស មួយក្តាប់តូចជាទាហ៊ាន ការធ្វើសកម្មភាពប្លន់ស្លៀកពាក់ស៊ីវិល ពេលខ្លះស្លៀកពាក់ឯកសណ្ឋានផងដែរ ប៉ុន្តែការប្លន់របស់ពួកគាត់ ភាគច្រើនប្រើកាំភ្លើងអាការច្រើនជាងប្រើកាំភ្លើងខ្លី ដូច្នេះរដ្ឋាភិបាលអោយរហ័ស្សនាមថា ចោរអាការ។ លុយដែលបានមកពីប្លន់ត្រូវចំណាយទៅលើប្រធានអង្គភាព ថ្នាក់លើមួយភាគធំ សល់បន្តិចបន្តួចយកទៅ ទិញថ្នាំជក់ ស៊ីផឹកស្រីស្រាសប្បាយអស់ តែបើមិនធ្វើអត់មានអីច្រកក្រពះ ព្រោះប្រាក់ខែតិច ជួនមិនទាំងបើកអោយទៀត គិត១ទៅរកលុយអោយតែថ្នាក់លើតែប៉ុណ្ណោះ ព្រោះថ្នាក់លើគោះលុយមិនឈប់ ស៊ីមិនចេះឆ្អែត ទីបំផុតគឺថ្នាក់លើហ្នឹងឯងជាអ្នកចាប់ពួកគាត់ វាយដុំធ្វើទារុណកម្មរហូតគ្រាំក្នុងក្អួតឈាមតាមមាត់ បង្ខំអោយពួកគាត់ឆ្លើយតាមចិត្តដែលពួកគេចង់បាន ម្នាក់១សុទ្ធតែទទួលទោសចាប់ពី ១៥ឆ្នាំ រហូតដល់ ៣០ ឆ្នាំឡើងលើក៏មាន។ ចំណែកលោកសុខ-ធី ហៅ បូ-កាប់ឆៅ បាននិយាយថាគាត់គឺជាមនុស្សជំនិតរបស់ កែន-ចំរើន ពួកគាត់មិនចេះប្លន់ ឬធ្វើសកម្មភាពផ្តេសផ្តាស់ទេ គឺមើលទៅតាមកាលៈទេសៈ បើថ្នាក់លើបើកអោយធ្វើ គឺ

ពួកគាត់ធ្វើ តែបើថ្នាក់មិនអនុញ្ញាតិទេ គឺពួកគាត់មិនធ្វើទេ ជាពិសេសនៅពេលបង្ក្រាបបាតុកម្មម្តងៗគឺពួកគាត់សប្បាយរកលុយណាស់ ព្រោះអ៊ីគណៈបក្សប្រជាជនបើកដៃអោយពួកគាត់ធ្វើសកម្មភាពដោយសេរី ប៉ុន្តែបានលុយមកគឺត្រូវតែអោយថ្នាក់លើ បើមិនអញ្ចឹងទេ គឺត្រូវគេចាប់ដាក់គុក។ លោកសុខធី បានបន្ថែមទៀតថាគាត់មិនមែនជាអ្នករៀនចេះដឹងអ្វីទេ ប៉ុន្តែតាមការជាក់ស្តែងដែលគាត់បានឃើញនោះគឺថាជីវិតជាចោរ គឺរកលុយសំរាប់តែចិញ្ចឹមគេ មិនអាចធ្វើមានបានទេ ព្រោះថា បើមិនអោយថ្នាក់លើ ក៏ត្រូវយកលុយសូកតុលាការដែរ ព្រោះថ្នាក់លើចាប់ដាក់គុក ហើយតុលាការជាអ្នកកាត់ទោស មិនខុសពីសែហ្វនិយាយទេ **បើជាប់គុកហើយគឺគេក្បៀបដូចអំពៅលុះត្រាតែអស់ទឹក** គុកមិនត្រឹមតែជាម៉ាស៊ីនក្បៀបទឹកអំពៅទេ តែពេលខ្លះក៏ជាទ្រុងសំរាប់រក្សាជ្រូក ទុកអោយតុលាការជាអ្នកកាប់សាច់យក។ ចំពោះលោក មុំ-ម៉េត វិញមិនមែនធ្វើការអោយអង្គការអេស.អូ.វ៉ាយ នោះទេ ប៉ុន្តែគាត់គឺជាអង្គរក្សអាវខ្មៅរបស់លោក ហ៊ុន-សែន ក្រោយមកគេចឈប់ធ្វើដូរឈ្មោះមកជាមនុស្សធម្មតាវិញព្រោះអ៊ីគាត់ធុញទ្រាន់នឹងសំលាប់មនុស្សជារៀង រាល់ថ្ងៃដែលហ៊ុន-សែន តែងតែបញ្ជាគាត់អោយធ្វើដូចជាសំលាប់ពួកប្រឆាំង សំលាប់អ្នកដែល ហ៊ុន-សែន ទាស់ចិត្ត សំលាប់អង្គរក្សដែលត្រូវបំបិទមាត់ គឺសំលាប់មិនចេះចប់មិនចេះហើយ ដោយសារតែការធុញទ្រាន់បែបហ្នឹងហើយ ទើបគាត់ដូរមុខរបរមករកស៊ីឆបោកវិញ ព្រោះគ្រាន់តែប្រើថ្វីមាត់ គឺអាចយកលុយបានដោយងាយ មិនចាំបាច់ប្រើកាំភ្លើងអ្វីឡើយ តែត្រូវតែបង់អោយទៅក្រសួងមហាផ្ទៃក្នុងមួយខែគឺចំនួន ១៥០ ដុល្លសហរដ្ឋអាមេរិក រួមទាំងប្រាក់ខែរបស់គាត់ទៀតផង ព្រោះពួកគាត់សុទ្ធតែកាន់កាតពីរបីកន្លែង ដូចជាកាតប៉ូលីស កាតទាហ៊ាន កាតអង្គរក្ស,,,,,,,,។ល។ រីឯឈ្មោះ សយ-ចាន់ណា និងឈ្មោះបុត្រជាអង្គរក្សហ៊ុន-សែន នៅអាគារសេ នៃគុកព្រៃ ស បានប្រាប់ខ្ញុំនៅខែកុម្ភៈ ឆ្នាំ ២០០៩ ថា ពួកគាត់ជាអង្គរក្សយាមផ្ទះ និងរត់តាមឡាន ហ៊ុន-សែន ពួកគាត់ពីមុនគ្រាន់តែជាក្មេងដើរលេងប៉ុណ្ណោះ ក្រោយមកក៏មានគ្នីគ្នាហៅចូលធ្វើជាអង្គរក្សព្រោះស្រួលរកលុយ តែពេលចូលស៊ុប គឺមេរបស់ពកួគាត់នៅបន្ទាយ ជាប្រធានអង្គរក្សគិតតែពីគោះលុយ គោះស៊ីផឹកមិនឈប់ ហើយបង្ហាញពីផ្លូវរកលុយ ព្រមទាំងបញ្ជាក់ថាធ្វើអ្វីក៏ដោយ ធានាមិនមានបញ្ហាឡើយ អោយតែគេចផុតពីកន្លែងកើតហេតុ ហើយរត់ចូលបន្ទាយបាន គឺ

អ្វី១ផុតហើយ មិនចាំបាច់បារម្ភទេ។ គ្រប់អងរក្ស សុទ្ធតែរកស៊ីប្លន់ រកស៊ីកាងបាញ់បោះ និងរកស៊ីមុខរបរមិនធម្មតា និងចេះប្រើប្រាស់ថ្នាំញៀនទាំងអស់។

**(៣)-អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ត្រូវបានប្រើប្រាស់សំរាប់ធ្វើបាតុកម្មស៊ីវិល**ដើម្បីវាយកំទេចគោលដៅ និងបង្រ្កាបបាតុកម្មដែលប្រឆាំងនឹងគណៈបក្សប្រជាជនកម្ពុជា ជាពិសេសគឺបង្រ្កាប និងសំលាប់បាតុកម្មមហាជនស៊ីវិលដែលមាននិន្នាការសមានចិត្តគាំទ្រគណៈបក្សប្រឆាំងដូចជាព្រឹត្តិការណ៏សំលាប់រង្គាលបង្រ្កាបពួកបាតុកម្មស៊ីវិលដែលគាំទ្របក្សប្រឆាំងនៅខែកញ្ញាឆ្នាំ ១៩៩៨ នៅមុខរដ្ឋសភា មុខសណ្ឋាគារកាំបូដយ៉ាណា និងទល់វត្តបូទុម នៅក្បែរវត្តលង្កា ត្រូវបានសំលាប់ប្រជាជនស្លូតត្រង់ខ្មែរអស់រាប់រយនាក់ និងសំលាប់ពួកសមាជិកគណៈបក្សប្រឆាំង។ នៅពេលនោះគឺគ្រាន់តែក្រុមលោក បូ-កាប់ឆៅ ដែលជាក្រុមបងតូចបងធំរបស់ពួកក្មេងអាណាថាតែមួយក្រុមគឺសំលាប់ប្រជាជនបានប្រមាណជាជាង ៦០ នាក់ ហើយចុះទំម្រមក្រុមបងតូចបងធំឯទៀត១ ដែលលោក កែន-ចំរើន កែណ្ឋមកពីបណ្តារខេត្តក្រុងផ្សេង១ទៀតទូទាំងប្រទេសនេះ តើសំលាប់ប្រជាជនខ្មែរបានចំនួនប៉ុន្មានទៅ? នៅមានពួកកងកំលាំងប្រដាប់អាវុធពួកអង្គរក្សស្តេចចោរ ហ៊ុន-សែន ,,,,,,,,ដែលក្លែងបន្លំធ្វើជាបាតុករស៊ីវិលគាំទ្រគណៈបក្សប្រជាជនកម្ពុជារួមដៃសហការជាមួយអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ បានសំលាប់រង្គាលពួកបាតុកម្មប្រជាជនស៊ីវិលដែលគាំទ្រពួកបក្សប្រឆាំងអស់ជាច្រើននាក់ទៀត ជាពិសេសនោះគឺពួកកងកំលាំងប្រដាប់អាវុធតែម្តងដែលបានចាប់ពួកបាតុករស៊ីវិលរបស់បក្សប្រឆាំងយកទៅសំលាប់ចោល និងយកទៅទំលាក់នៅជ្រោះពិចនិលទាំងរស់រាប់រយនាក់ទៀត នេះបើតាមសំដីរបស់លោក មុំ-ម៉េត ជាអង្គរក្សអាវឈុតខៀវរបស់អា ហ៊ុន-សែន បាននិយាយខ្ញុំនៅបន្ទប់លេខ ១៧ អាគារអា នៃគុកព្រៃ-ស នាខែមករា ឆ្នាំ ២០០៧ និង សូមមើលវិបសាយវិដេអូ ស្តីពីពួកកងកំលាំងប្រដាប់អាវុធរបស់ ហ៊ុន-សែន និង ពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយសំដែងសមត្ថភាពសំលាប់ប្រជាជនខ្មែរ និងព្រះសង្ឃខ្មែរយ៉ាងសាហាវនៅខែកញ្ញា ឆ្នាំ ១៩៩៨ ដើម្បីប្តូរយក **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជានឹងផ្តល់អោយពួកគេបន្ទាប់ពី បង្រ្កាបបាតុកម្មរួចហើយ

(1) http://www.youtube.com/watch?v=wzBWG3Uj4JM

--------->Hun Sen's armed forces and S.O.Y killing Khmer people and monk

(2).http://www.youtube.com/watch?v=9t7AYmx3saM&feature=related

--------->S.O.Y demonstraton with helping of CPP armed forces killed and rob Khmer people

3-) http://www.youtube.com/watch?v=QGNXN4X_eVw&NR=1)។

*Sam Rainsy continues US case against Hun-Sen killing Khmer people

-(http://www.voanews.com/khmer-english/news/Sam-Rainsy-Continues-US-Case-Against-Hun-Sen-130421913.html )

## មូលហេតុអ្វីបានជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ និងមនុស្សនៅក្នុងក្រុមបងតូចបងធំពេញចិត្តនឹងសំលាប់ប្រជាជនខ្មែរស្លូតត្រង់ដែលគ្មានគំនុំជាមួយខ្លួនយ៉ាងដូច្នេះ?

ក្នុងការប្រើប្រាស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងពួកក្រុមអ្នកលេងក្រុមបងធំបងតូចដែលបំរើអោយគណៈបក្សប្រជាជនកម្ពជាដោយមិនដឹងខ្លួននោះ គណៈបក្សប្រជាជនកម្ពុជាមិនបានចំណាយអ្វីធំដុំឡើយ ផ្ទុយទៅវិញគណៈបក្សប្រជាជនកើបភោគផលទ្រព្យសម្បត្តិកំណប់ដីមហាសាលលុយដុល្លាដីសទ្នឹកពីប្រជាជនខ្មែរ ដោយគ្រាន់តែប្រើប្រាស់ក្រុមបងតូចបងធំជាកត្តាលីករតែប៉ុណ្ណោះ គឺកើបលុយបានយ៉ាងងាយស្រួលបំផុតពីប្រជាជនខ្មែរ តាមរយៈលួចឆក់ប្លន់ជីវិតលក់គ្រឿងញៀនឆបោក,,,,,,,,,, មិនត្រឹមតែចំណេញផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺគណៈបក្សប្រជាជនកម្ពុជាថែមទាំងប្រើប្រាស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ និងក្រុមបងតូចបងធំក្នុងផ្នែកនយោបាយទៀត ដូចជាប្រើប្រាស់អោយដើរតួជាបាតុករសំរាប់ការពារផលប្រយោជន៏គណៈបក្សប្រជាជន និងផលប្រយោជន៏យួនដូចជាករណីធ្វើបាតុកម្មវាយដុតស្ថានទូតថៃ ធ្វើបាតុកម្មបំរើឱ្យគោលបំណងរបស់គណៈបក្សប្រជាជន និងដើរតួនាទីជាបាតុកម្មស៊ីវិលដើម្បីបង្រ្កាបបាតុកម្មស៊ីវិលរបស់បក្សប្រឆាំង ដូចជាករណីបង្រ្កាបបាតុកម្ម នៅខែកញ្ញា ឆ្នាំ ១៩៩៨ ដែលរៀបចំឡើងដោយគណៈបក្សប្រជាជនកម្ពុជា ដោយចាត់អោយកងកំលាំងប្រដាប់អាវុធ រួមសហការជាមួយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ទៅ សំលាប់បង្រ្កាបបាតុកម្មប្រជាជនស៊ីវិលដែលគាំទ្របក្សប្រឆាំង។ នៅក្នុងការសំលាប់បង្រ្កាបបាតុកម្មប្រជាជនស៊ីវិលដែលគាំទ្របក្សប្រឆាំងនេះ ហ៊ុន-សែន បាន បានបញ្ជូអោយកំលាំងរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ដែលមានក្រុមបងតូចបងធំ និងបណ្តុញក្រុមជនអន្ធពាលជាសកម្មជននោះ អោយដើរតួជាបាតុករស៊ីវិលគាំទ្រគណៈបក្សប្រជាជន

ដោយមានក្រុមកងកំលាំងប្រដាប់អាវុធស្លៀកពាក់ស៊ីវិល និងក្រុមអង្គរក្សពួកមេដឹកនាំកំពូល១ចូលរួមក្លែងជាបាតុករ ដើម្បីធ្វើបាតុកម្មបង្ក្រាបបាតុកម្មស៊ីវិលរបស់ប្រជាជនខ្មែរ និងបង្ក្រាបបាតុកម្មរបស់ពួកគណៈបក្សប្រឆាំង។ នៅពេលថ្នាក់លើ ពិសេស ហ៊ុន-សែន មានការខ្លាចរអារនឹងប្រើកងកំលាំងប្រដាប់អាវុធសំលាប់រង្គាលបាតុករនៅក្នុងបាតុកម្មរបស់គណៈបក្សប្រឆាំង ហ៊ុន-សែន បានប្តូររូបភាពមកប្រើពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អោយដើរតួក្លែងភេទជាបាតុករស៊ីវិល ទៅសំលាប់រង្គាលពួកគណៈបក្សប្រឆាំងជំនួសអោយកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនវិញ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៩៨។ នៅពេលដែលលោក កែន-ចំរើន បានទទួលបញ្ជាពី ហ៊ុន-សែន ហើយ គាត់បានបញ្ជាទៅពួកមេបងធំ និងពួកមនុស្សជំនិតរបស់គាត់អោយប្រមូលកំលាំងអោយបានច្រើនដើម្បីធ្វើបាតុកម្ម បង្ក្រាបបាតុកម្មពួកប្រឆាំង ហើយលោក កែន-ចំរើន បានបញ្ជាទៅឈ្មោះ បូកាប់ឆៅ (Source[A6 and A7])អោយទៅប្រាប់ពួកមេដឹកនាំក្រុមបងតូចបងធំទាំងអស់នៅក្នុងក្រុងភ្នំពេញ ដែលមានជាង ៦០ ក្រុម អោយប្រមូលមនុស្ស និងក្រុមបក្សពួករបស់ខ្លួនដើម្បីធ្វើបាតុកម្មបង្ក្រាបពួកប្រឆាំង ថែមទាំងបង្ហើបនៅ**ឱកាសរកលុយពិសេស**ផងមានន័យថារដ្ឋអំណាចរបស់គណៈបក្សប្រជាជនកម្ពុជាទុកពេលអោយពួកក្រុមបងតូចបងធំ និងសមាជិកបក្សពួកនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ មានឱកាសរកលុយដោយសេរីនៅក្នុងរយៈពេលចាប់ពី ៣ ថ្ងៃ ទៅ ១ សប្តាហ៍ ឬទៅមួយខែ ទៅតាមក្រុមបងតូចបងធំនិមួយ១ដែលសំរេចស្នាដៃនៅក្នុងការបង្ក្រាប ល្អ ឬមិនល្អ គុណភាពប្រសិទ្ធិភាពនៅក្នុងការបង្ក្រាបនោះ ធ្វើអោយគណៈបក្សប្រជាជនពេញចិត្ត ឬអត់? ហើយនៅក្នុងឱកាសរកលុយដែលមានថេរៈវេលាកំណត់ដែលគណៈបក្សប្រជាជនកម្ពុជាផ្តល់អោយពួកគេ គឺបានសេចក្តីថា ពួកបងតូចបងធំ ពួកក្រុមជនអន្ធពាល និងបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ នោះ មានសិទ្ធិនៅក្នុងការរកលុយដោយការលួចឆក់ប្លន់ជីវិត ឃាតកម្ម ស៊ីឈ្នួល ជួញដូរមនុស្ស ជួញដូរថ្នាំញៀន ឬការរកលុយដោយមធ្យោបាយណាក៏ដោយ គឺមិនមានទោសពៃមិនមានការចាប់ចងអ្វីឡើយ គឺគណៈបក្សប្រជាជនកម្ពុជាអនុញ្ញាតិអោយពួកគេធ្វើ នៅក្នុងឱកាសពិសេសដែលមានអាទិភាពដូចមានលិខិតបេសកកម្មរបស់ ហ៊ុន-សែន នៅក្នុងដៃ។ នៅពេលដែល ពួកបងតូចបងធំ

ពួកក្រុមជនអន្ធពាល និងបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ បានដំណឹងពី **ឱកាសរកលុយពិសេស** ពីថ្នាក់លើរបស់ពួកគេហើយ ពួកគេចាប់ផ្តើមមានកំលាំងចិត្តសប្បាយរីករាយឥតឧបមានឹងលាភសក្ការៈដែលគណៈបក្សប្រជាជននឹងផ្តល់អោយពួកគេ ហើយនៅពេលវេលាមកដល់ លោក កែន-ចំរើន បានរៀបចំក្បួនយុទ្ធសាស្រ្តប្រៀបបីដូចជា យុទ្ធសាស្រ្តទាហ៊ាន ដោយគាត់បានប្រមូលផ្តុំ ពួកបងតូចបងធំ ពួកក្រុមជនអន្ធពាល និងក្រុមបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ហើយបានរៀបចំជា ៣ ខ្សែត្រៀម មុននឹងចូលវាយប្រហារដើម្បីសំលាប់ពួកហ្វូងបាតុករប្រជាជនខ្មែរដែលធ្វើបាតុកម្មប្រឆាំងនឹងគណៈបក្សប្រជាជន។ ពួកបងតូចបងធំ ពួកហ្វូងជនអន្ធពាល និងបក្សពួកក្រុមកងកំលាំងប្រដាប់អាវុធ ក្រុមអង្គរក្សដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ត្រូវបានបែងចែកជា ៣ខ្សែត្រៀមដូចតទៅនេះ

-**ខ្សែត្រៀមទី១** គឺពួកគេប្រដាប់ដោយអាវុធបន្ទាប់បន្សំដូចជា កាំបិតតាំងតោ ពូថៅ កាំបិតខ្លី ដាវ ដំបង ព្រនង់ ដំថ្ម,,,,,,,,មានទាំងទុងគណៈបក្សប្រជាជនកម្ពុជាផងដែរ នេះគ្រាន់តែខ្សែត្រៀមបញ្ឆោតពួកអ្នកកាសែតអន្តរជាតិ ពួកអ្នកសារពត៌មានអន្តរជាតិ ព្រោះនៅគ្រាដំបូងមិនទាន់ជ្រួលច្របល់អាចត្រូវថតបាន។



https://www.msu.edu/course/iss/325/stein/revolt.htm

**ខ្សែត្រៀមទី១** នៃក្បួនបាតុកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ S.O.Y អេស.អូ.វ៉ាយ ដែលត្រូវបានបញ្ជា និងរៀបចំដោយ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាដើម្បីសំលាប់រង្គាលហ្វូងបាតុកម្មរបស់ពួកគណៈបក្សប្រឆាំងដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជាផ្តល់ដល់ពួកគេ បន្ទាប់ពីបញ្ចប់បេសកកម្ម។

| | |
|---|---|
| **ខ្សែត្រៀមទី១-ទី២- ទី៣** នៃក្បួនបាតុកម្មអង្គការឧក្រិដ្ឋជនសំងាត់អេស,អូ,វ៉ាយ  | **ខ្សែត្រៀមទី១-ខ្សែត្រៀមទី២-ខ្សែត្រៀមទី៣** នៃក្បួនបាតុកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ S.O.Y អេស,អូ,វ៉ាយ ដែលត្រូវបានបញ្ជានិងរៀបចំដោយ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាកំពុងដង្ហែរក្បួនមកសំលាប់រង្គាលពួកហ្វូងបាតុកម្មរបស់ពួកគណៈបក្សប្រឆាំងដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជាផ្តល់ដល់ពួកគេ បន្ទាប់ពីបញ្ចប់បេសកកម្មរួចរាល់ ។ |

-**ខ្សែត្រៀមទី២** គឺពួកគេត្រូវបានបំពាក់ទៅដោយអាវុធដូចខ្សែត្រៀមទី១ដែរ ប៉ុន្តែមានលាយឡំនឹងកាំភ្លើងខ្លី និងកាំភ្លើងមួយចំនួនដទៃទៀត (Source$^{D5}$) ។ ខ្សែត្រៀមនេះសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងមិនស្លាប់បានច្រើនទេ តែសំរែកឈឺចាប់ពួកគេមុនស្លាប់ ងាយនឹងធ្វើអោយពួកបាតុករប្រឆាំងបាក់ស្បាតរាងចាលមិនហ៊ានធ្វើទៀតនៅថ្ងៃក្រោយ ។

-**ខ្សែត្រៀមទី៣** គឺត្រូវបានបំពាក់អាវុធដូចខ្សែត្រៀមទី១ ខ្សែត្រៀមទី២ដែរ ប៉ុន្តែពួកគេត្រូវបានបំពាក់បន្ថែមដោយកាំភ្លើងខ្លី កាំភ្លើងវែង កាំភ្លើងពាក់កណ្តាលស្វ័យប្រវត្តិដូចជា A-K, M-16………. ហើយនៅក្នុងខ្សែត្រៀមទី៣នេះ ពួកសមាជិកដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ច្រើនតែជាពួកកងកំលាំងប្រដាប់អាវុធស្លៀកពាក់ស៊ីវិល ពួកចារបុរសស៊ើបការណ៍របស់គណៈបក្សប្រជាជន និងពួកកងអង្គរក្សរបស់ ហ៊ុន-សែន ដូច្នេះពួកគេមានសមត្ថភាពខ្ពស់អាចសំលាប់មនុស្សបានច្រើនបំផុត ហើយមានប្រសិទ្ធភាពជាងខ្សែត្រៀមទី១ និងខ្សែត្រៀមទី២ នៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ។

នៅក្នុងការបង្រ្កាបសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងនេះ លោក កែន-ចំរើន មិនត្រឹមតែរៀបក្បួនយុទ្ធសាស្រ្តជា ៣ ខ្សែត្រៀមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជាអោយក្រុមហ្វូងមនុស្សរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អោយផ្លាស់ប្តូរក្បួនពីខ្សែត្រៀមមួយទៅកាន់ខ្សែត្រៀមមួយទៀតដើម្បីវាយប្រយុទ្ធសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងអោយមានប្រសិទ្ធភាពខ្ពស់។ ក្នុងពេលផ្លាស់ប្តូរក្បួនខ្សែត្រៀមនេះ ពួកហ្វូងបាតុកម្មរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ នៃត្រៀមទី១ បែងចែកគ្នាសំរាក ដើម្បីរកលុយជាបណ្តើរៗ អ្នកខ្លះប្លន់សំលាប់នៅកន្លែងផ្សេងៗ អ្នកខ្លះវាយយកម៉ូតូនៅជិតក្បែរបរិវេណបាតុកម្ម អ្នកខ្លះលួចឆក់ ,,,,,,,,លួមតែបាតុកម្មចប់សព្វគ្រប់ ពួកគេអាចកើបលុយបានយ៉ាងច្រើនក្រាស់ក្រែលបានមួយចំនួនទៅហើយ។ លុះដល់ពេលរាត្រី គណៈបក្សប្រជាជនចាប់ផ្តើមផ្តល់រង្វាន់អោយដល់ពួកហ្វូងមនុស្សរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ទៅតាមតួនាទី និងឋានៈរបស់ពួកគេ គឺពួកមេក្រុមតូចៗក្នុងម្នាក់ៗទទួលបាន ១០០ ដុល្លា ក្នុងមួយថ្ងៃ (Source[A8 and A9]) ហើយសមាជិកធម្មតាអាម៉ីអាថោងតូចតាច ក្នុងម្នាក់ៗទទួល បានចំនួន ២០០០០ រៀល (ពីរម៉ឺនរៀល) ក្នុងមួយថ្ងៃ រួមទាំងការផ្តល់អាហារមានបាយកញ្ចប់ ស្រា បារី ចំណីអាហារផ្សេងៗ ថ្នាំយ៉ាម៉ាទាំងចានៗ ថ្នាំខេ ថ្នាំគ្រើ និងថ្នាំញៀនហេរ៉ូអ៊ីន ទៅតាមគុណសម្បត្តិ និងឋានៈនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ អ្នកខ្លះមានឋានៈតូចជាមនុស្សធម្មតានៅក្នុងក្រុម ប៉ុន្តែសំលាប់មនុស្សបានច្រើននៅក្នុងពេលបង្រ្កាបពួកបាតុកម្មប្រឆាំង នោះអាចមានសិទ្ធិជ្រើសរើសថ្នាំញៀនដោយសេរី និងត្រូវបានមនុស្សក្នុងក្រុមសរសើរលើកទឹកចិត្ត រួមទាំងពាក្យសរសើរបញ្ចោរពីលោកបងធំរបស់ពួកគេទៀតផងនៅក្នុងពិធីជប់លៀង ដែលរៀបចំឡើងដោយគណៈបក្សប្រជាជនកម្ពុជា ពួកគេផឹកស៊ីប្រូកប្រាជ្ញរហូតដល់ម្នាក់ៗស្រវឹង និង ង៉ាងថ្នាំវេងៗខ្លួន អ្នកខ្លះឆ្លៀតរកលុយក្នុងពេលកំពុងផឹកស៊ី ហើយថែមទាំងយកខ្សែករ ជញ្ជៀន លុយ មក បង្ហាញលោកបងធំ និងក្រុមមនុស្សនៅក្នុងក្រុមពួកគេដោយនិយាយថា " លោកបង! ពួកខ្ញុំគ្រាន់តែចេញក្រៅមួយភ្លែតបានប៉ុណ្ណេះ (ដោយលើកបង្ហាញខ្សែករក្រវិលពេជ្រ ចិញ្ចៀន លុយ) ចំណែកម៉ូតូវិញ ពួកខ្ញុំយកទៅទុកក្នុងឡហើយ ទុកអោយលោកបងធំជាអ្នកចាត់ចែង ! លោកបងធំរបស់ពួកគេ ក៏និយាយទៅកាន់ហ្វូង មនុស្សរបស់ខ្លួនថា ពួកឯងទាំងអស់ឃើញទេ!

ពួកវាពូកែណាស់! គ្រាន់តែជប់លៀងផឹកស៊ីប៉ុណ្ណឹងក៏ឆ្លៀតរកលុយបានដែរ! ពួកឯងទាំងអស់កុំភ្លេច! ឱកាសពិសេសរកលុយរបស់យើងមានតែប៉ុន្មានថ្ងៃទេ រួសរាន់ ប្រញាប់ឡើង ! កុំអោយខកពេល! ពេលនោះពួកហ្វូងមនុស្សនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ក៏ចាប់ផ្តើមចេញទៅរកលុយរៀង១ខ្លួនទៅតាមជំនាញរបស់ពួកគេ ដូចជា លួច ឆក់ ប្លន់ ជិះត សំលាប់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស វាយដំប្រហារគ្នាតាមផ្លូវ លួចគាស់ផ្ទះ បុកហាង បុកទូរមាស,,,,,,,,,,,។ល។ និង។ល។ សមដូចសំដីរបស់ លោកសុខ-ធី បាននិយាយថា "**សំលាប់មនុស្សតែមួយថ្ងៃ មានឱកាសរកលុយបានរាប់ខែណាំ!** "។

លោក កែន-ចំរើន ដែលប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ តែងតែសំដែងនៅក្តីគោរព និងសរសើរដល់លោក ជា-សុផារ៉ា ជានិច្ច ហើយតែងតែហៅលោក ជា-សុផារ៉ា ថា "ប៉ាប៉ា!! "មិនដាច់ពីមាត់ឡើយក្នុងការទំនាក់ទំនងក្នុងផ្លូវមិនធម្មតា ព្រោះអ៊ីលោក ជា-សុផារ៉ា ជាអ្នកផ្តល់គំនិតអោយដល់ ហ៊ុន-សែន នៅក្នុងការបង្កើតក្រុមបងតូចបងធំ បង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ក្នុងការប្រមូលលុយចំណូលចូលគណៈបក្សប្រជាជនកម្ពុជា និងប្រើប្រាស់ជាឧបករណ៍សំលាប់មនុស្សពួកបក្សប្រឆាំងយ៉ាងមានប្រសិទ្ធិភាពបំផុត ជាពិសេសគ្រាន់តែបិទផ្លាកពួកអ្នកស្លាប់ថាមានរឿងជាមួយពួកក្រុមអន្ធពាល និងក្រុមបងធំ មានរឿងដោយសារស្រី រឿងចោរប្លន់សំលាប់ រឿងឈ្លោះគ្នាសំលាប់ច្រលំ រឿងរាលកែកាំភ្លើង រឿងជំពាក់លុយ រឿងប្រជែងរបររកស៊ី រឿងជួលគេសំលាប់ដោយសារទំនាស់ រឿងទំនាស់គ្រួសារ រឿងឧប្បត្តិហេតុ រឿងធ្វើលរត់ជាន់គ្នាស្លាប់ រឿងលិចទូកស្លាប់អស់១ទូក,,,,,,,។ល។ និង។ល។ នោះ គឺសុទ្ធតែជារឿងឃាតកម្មសំលាប់បំបិទមាត់ទាំងអស់ មិនមែនរឿងឧប្បត្តិហេតុទេ ប៉ុន្តែគណៈបក្សប្រជាជនកម្ពុជាតែតែបង្វែងដានទៅជារឿងផ្សេង ដើម្បីគេចចេញពីការទទួលខុសត្រូវនៅរាល់អំពើដ៏ខ្មៅក្រខ្វក់និងសាហាវយង់ឃ្នងរបស់ខ្លួនតែប៉ុណ្ណោះ។

អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ត្រូវបានគណៈបក្សប្រជាជនប្រើប្រាស់ដើម្បីបំរើផលប្រយោជន៍ប្រជាជាតិយួនផងដែរ ក្នុងពេលអារ្យធម៌ថៃ ខ្សែភាពយន្តថៃ ទំនិញផលិតផលថៃ បានហូរចូលយ៉ាងគំហុកចូលមកកម្ពុជា ហើយជាទីពេញនិយម និងមានប្រជាប្រិយភាពបំផុតរបស់ប្រជាជនខ្មែរ ធ្វើឱ្យប្រទេសយួនលំបាកក្នុងការបង្ហូរទំនិញចូលមកលក់ស្រុកខ្មែរ ទោះបីជាយួនខំប្រឹងធ្វើទំនិញក្លែងក្លាយលក់ដោយសេរីក្នុងប្រទេសខ្មែរយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចទៅរួច ដូច្នេះមានតែបញ្ជា ហ៊ុន-សែន រក

មធ្យោបាយកាត់បន្ថយឥទ្ធិពលថៃ មូលហេតុនេះហើយ ទើប ហ៊ុន-សែន សំរេចអោយលោក ជា-សុផារ៉ា និង លោក កែន-ចំរើន ប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អោយក្លែងធ្វើជាបាតុកម្មស៊ីវិល ឬ បាតុកម្មប្រជាជនដើម្បីវាយកំទេចគោលដៅប្រម៉ាញ់ដែល ហ៊ុន-សែន និងយួន ចង់បាននោះ។ ដំបូងទីនៃរូបភាពបាតុកម្មគឺឃើញមានសុទ្ធតែពួកក្រុមក្មេងស្ទាវរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ជិះម៉ូតូទាំងហ្វូងៗតាមផ្លូវស្រែកហ៊ោរកញ្ជ្រៀវពាសពេញក្រុងភ្នំពេញ រួមទាំងមានពាក្យជេរប្រមាថដល់តារាខ្សែភាពយន្តថៃ ហៅនាងផ្កាយព្រឹក ដោយឆ្លោះតំរង់ទៅ រកអត្ថន័យ "ស្រីថៃចង់បានអង្គរវត្តខ្មែរ " បន្ទាប់មកពួកគេបង្កើតភាពជ្រួលច្របល់កាន់តែខ្លាំងទៅៗតាមរយៈ ប្រពន្ធ័ឃោសនារបស់រដ្ឋាភិបាល មានកាសែត វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ព្រឹត្តិប័ត្រ និងប្រព័ន្ធឃោសនារបស់ម៉ាហ្វីយ៉ា ដូចជាកាសែតរស្មីកម្ពុជារបស់លោក ថេង-ប៊ុន http://www.ask.com/wiki/Drugs_in_Cambodia http://www.garella.com/rich/grenpost.htm

និងការជួយផ្សព្វផ្សាយតគ្នាពីតំបន់មួយទៅតំបន់របស់ក្រុមបងតូចបងធំ ក្រុមជនអន្ធពាល ដែលដើរតួគ្រប់ប្រភេទមនុស្សតាំងពីតួអង្គរត់មូតូឌុបរហូតដល់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ បន្ថែមលើល្បិចឆ្កែព្រុសរបស់អា ហ៊ុន-សែន ផងនោះ ធ្វើអោយផុសពត៌មានគ្រប់ទីកន្លែងធ្វើវិទ្ធង្សនាប្រឆាំងនឹងថៃតាមរយៈពាក្យចចាមអារាមផ្សាយតៗគ្នាចេញពីពួកក្រុមមនុស្សនៅក្នុង ក្រុមបងតូចបងធំ និងពួកសមាជិក



http://www.2bangkok.com/burning.shtml

The offices of Cambodia Shinawatra Telecommunications, firebombed, windows smashed, with masonry damage.








Thai owned soft drinks cannery virtually razed to the ground

http://www.2bangkok.com/burning.shtml

របស់ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ហើយធ្វើឱ្យបញ្ហាវិបត្តិរីកធំទៅៗឈានដល់ក្បួនបាតុកម្មទ្រង់ទ្រាយធំ បុកសំដៅទៅគោលដៅសំខាន់ៗរបស់ថៃ ហើយចូលទៅវាយកំទេច លួចប្លន់ និងដុតបំផ្លាញទីតាំងផ្សេងៗរបស់ថៃដូចជា  វាយកំទេច និងវាយដុតបំផ្លាញមជ្ឈមណ្ឌល (Source$^{D7}$) និងរោងផលិត

ភេសជ្ជៈកំប៉ុងថៃ,,,,,,,,,  ហើយទីបំផុតរហូតដល់ឈានចូលទៅវាយដុតកំទេចស្ថានទូតថៃប្រចាំក្រុងភ្នំពេញ នាថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៣ គឺជាបាតុកម្ម ធ្វើឡើងដោយហ្វូងក្មេងពាលនៅក្នុងក្រុមពួកជនអន្ធពាល




ស្ថានទូតថៃប្រចាំក្រុងភ្នំពេញ  ត្រូវបានពួកក្រុមបងតូចបងធំនៅក្នុងអង្គការឧក្រិដ្ឋជន សំងាត់អេស.អូ.វ៉ាយ ( ត្រូវបានបញ្ជូនដោយ គណៈបក្សប្រជាជនកម្ពុជា) វាយកំទេច  ដុតបំផ្លាញដើម្បីប្តូរនឹងឱកាសរកលុយពិសេស។   បើសង្គ្រាមកើតឡើង រដ្ឋាភិបាលអាយ៉ង យួន ដឹកនាំដោយ ហ៊ុន-សែន នឹងសំលាប់រង្គាលប្រជារាស្ត្រខ្មែរដើម្បីសងសឹងនឹងភ្នែក ខ្វាក់ម្ខាងរបស់ខ្លួន ដោយគ្រាន់តែយកលេសសង្គ្រាមខ្មែរ-ថៃ ក្តោបអំណាចផ្តាច់មុខទាំង ៣ ក្នុងដៃ ហើយសំលាប់ជាតិខ្មែរដោយចោទ ថា ខ្មាំង ឬជាចារជនរបស់ថៃតែប៉ុណ្ណោះ។

http://www.2bangkok.com/burning.shtml



***ឱកាសរកលុយពិសេស** = ការអនុញ្ញាតិអោយពួកក្រុមបងតូចបងធំ នៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ មានឯកសិទ្ធិពិសេសក្នុង ការលួចឆក់ប្លន់ជីវិតសំលាប់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ឃាតកម្មស៊ីឈ្នួល,.....ដោយគ្មានការចាប់ចង យកទោសពៃអ្វីឡើយ ទៅតាមពេលវេលាកំណត់ជាក់លាក់របស់គណៈបក្សប្រជាជនកម្ពុជាដែលបានអនុញ្ញាតិឱ្យពួកគេធ្វើ បន្ទាប់ពីពួកគេបានសំរេចស្នាដៃសមិទ្ធិផលឱ្យគណៈបក្សប្រជាជនកម្ពុជារួចហើយនោះ។



Rioters set fire to the Thai embassy and attacked Thai-owned businesses in Phnom Penh

http://news.bbc.co.uk/2/hi/asia-pacific/2709261.stm



They were angry at alleged remarks by a Thai actress, saying Angkor Wat belonged to Thailand

http://news.bbc.co.uk/2/hi/asia-pacific/2709261.stm



Many people were injured, and one was killed, as protesters burned and looted buildings

http://news.bbc.co.uk/2/hi/asia-pacific/2709261.stm

រូបភាពទាំងនេះគឺជាក្រុមបងតូចបងធំនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ដែលខំប្រឹងសំដែងសមត្ថភាពវាយកំទិចដុត បំផ្លាញស្ថានទូតថៃប្រចាំនៅក្រុងភ្នំពេញ ដុតរូបព្រះមហាក្សត្រថៃ និងដុតទង់ជាតិថៃ ដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែល គណៈបក្សប្រជាជនកម្ពុជានឹងផ្តល់ឱ្យពួកគេរយៈពេល ៣ថ្ងៃ ឬ ១អាទិត្យ ទៅ ១ខែ ទៅតាមសមត្ថភាពរបស់ពួកគេ។

ហើយពួកក្រុមបងតូចបងធំ (Source[D8]) របស់អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ដែលដឹកនាំដោយលោក កែន-ចំរើន ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ហើយត្រូវបានបញ្ជាឱ្យធ្វើ បាតុកម្មដោយ ហ៊ុន-សែន និង លោក ជា-សុផារ៉ា នៅក្នុងគោលដៅបំរើផលប្រយោជន៍ចៅហ្វាយយួនរួមគ្នា និង ជួយ

អភិវឌ្ឍន៍សេដ្ឋកិច្ចយួន និងជួយពង្រីកទីផ្សារបញ្ចេញទំនិញរបស់យួនអោយបានកាន់តែឆាប់រហ័សទៀតផង គឺផលប្រយោជ៍ពាណិជ្ជកម្មយួនតែម្តង ព្រោះថាបាតុកម្មរបស់ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ វាយប្រហារដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញ និងមជ្ឈមណ្ឌលពាណិជ្ជកម្មថៃ និងកន្លែងផ្សេងៗទៀតរបស់ថៃនោះ គឺមិនមែនពួកគេធ្វើឡើងដោយគំនិតជាតិនិយមអ្វីឡើយ សូមមើលរូបៈ



http://reatreygirl.blogspot.com/2009_10_16_archive.html

( គ្រាន់តែប្រជាជនខ្មែរនៅខេត្តស្វាយរៀង និងលោក សម-រង្ស៊ី បានដកបង្គោលព្រំដែនដែលយួនឈ្លានពានចូលពី ៣០០ ម៉ែត្រ ទៅ ៥០០ ម៉ែត្រ ចូលក្នុងដីខ្មែរនោះ លោក សម-រង្ស៊ី ត្រូវបានពួកតុលាការអាយ៉ងយួនកាត់ទោសឱ្យជាប់គុក ២ ឆ្នាំ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងអំពីបទញុះញង់ឱ្យមានការបែងចែកពូជសាសន៍ ) ប៉ុន្តែធ្វើឡើងក្នុងគោលបំណងធ្វើរដ្ឋប្រហារសេដ្ឋកិច្ចថៃ ដោយយកលេសលើបញ្ហាទាំងនេះ ដើម្បីរាំងខ្ទប់ពាណិជ្ជកម្មថៃមិនអោយទំនិញរបស់ថៃនាំចូលមកប្រទេសកម្ពុជាដោយងាយស្រួលនោះទេ និងបង្កើតចេញជាផលវិបាកផ្សេងៗជាសេរីនៃទំនាស់ ទោះបីរដ្ឋាភិបាលអាយ៉ងយួនបានសងប្រទេសថៃ ចំនួន ៤៣លានដុល្លាសហរដ្ឋអាមេរិកក៏ដោយ ក៏ជនជាតិយួននៅតែចាត់ទុកថាចំណេញ។ By website http://www.thaivisa.com/forum/topic/6097-thai-embassy-reopens-in-phnom-penh/ http://www.nationalradio.com/PPBurning.shtml Tuesday February 4, Channel News Asia reported the figure to be US $43 million. Thai companies say the violence

caused more than US$46.8 million in damage but it's not clear if any of them have been compensated yet. សមដូចជនជាតិយួនម្នាក់ដែលស្លៀកពាក់ជាឯកសណ្ឋានប៉ូលីសខ្មែរនៅព្រែកអែម បាននិយាយថា "**សងថៃ ៤៣ លានដុល្លាគឺមិនខាតទេ បើយើងយកលុយ ៤៣ លានដុល្លា ទៅទិញទឹកចិត្តប្រជារាស្ត្រខ្មែរអោយឈប់ស្រឡាញ់ចូលចិត្តថៃ ឬកាត់បន្ថយឥទ្ធិពលថៃនោះ គឺមិនបានទេ ឥឡូវនេះពួកយើងមិនត្រឹមតែកាត់បន្ថយឥទ្ធិពលថៃ វប្បធម៌ថៃបាន ប៉ុណ្ណោះទេ គឺថែមទាំងមានលេសរាំងខ្ទប់ទំនិញថៃ មិនអោយហូរចូលស្រុកខ្មែរដោយសេរីទៀតផង គឺយើង ទេជាអ្នកចំណេញ ចំណែកថៃជាអ្នកខាត** " បន្ទាប់ពីវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញរួច មិនទាំងបានប៉ុន្មានសប្តាហ៍ផង គេឃើញបដាវែងៗចងកាត់ទទឹងថ្នល់ស្ទើរគ្រប់វិថីធំៗដោយសរសេរពាក្យថា "**ទំនិញវៀតណាម! ទំនិញវៀតណាម!** " ពេលនោះប្រជាជនខ្មែរគ្មានជំរើសទេ ព្រោះទំនិញថៃត្រូវបានបិទមិន អោយចូលស្រុកខ្មែរ មានតែប្រើទំនិញយួនសិន ទោះបីមិនចង់ក៏ដោយ ។ រដ្ឋាភិបាលអាយ៉ងយួនដឹកនាំដោយ ហ៊ុន-សែន



បានប្រើលេសបូកលេស ប្រើរឿងបូករឿង បន្តសេរីនៃបញ្ហាមិនចេះដាច់ មិនចេះចប់មិនចេះហើយ ជាមួយនឹងប្រទេសថៃ ហើយបាននាំចាក់បញ្ចូលរាល់គ្រប់ប្រភេទទំនិញរបស់យួនចូលមកប្រទេសខ្មែរយ៉ាងគំហុគ ព្រោះថា បើមិនធ្វើដូច្នេះទេ គ្មានលេសអ្វីដើម្បីផ្លាស់ប្តូរលក្ខខណ្ឌកិច្ចសន្យាអ្វីឡើយ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងអាចផ្លាស់ប្តូរខាងផ្នែកចិត្តសាស្ត្រប្រជារាស្ត្រខ្មែរបានមួយផ្នែកតូចទៀតផង។ លើសពីនេះទៅទៀតនោះ ហ៊ុន-សែន អាចយកចំណេញលើស្ថានការណ៍ដោយ **វិធីត្រីងៀតឆ្លៀតពង** បង្កើតព្យុះពន្យុះ ភ្លៀងគៀងសភាពការណ៍នយោបាយទៅរកលេសទំនាស់ព្រំដែនខ្មែរ-ថៃ លេសជាប៉ះទង្គិចដោយអាវុធបន្តិចបន្តួចដោយសារទំនាស់ជាយដែន នៅក្នុងគោលបំណងដេញវិនិយោគទុនរត់ចេញពីប្រទេសថៃទៅកាន់ប្រទេសវៀតណាម និងប្រទេសចិន ហើយប្រើប្រព័ន្ធឃោសនាបំផ្លែងការពិត ផ្សាយបំពុលសភាពការណ៍ដដែលៗ បង្វែរខួរក្បាលរាស្ត្រខ្មែរឱ្យផ្តោតលើបញ្ហាទំនាស់ព្រំដែនខ្មែរ-ថៃ ភ្លេចអស់រឿងក្បត់ជាតិ លក់ជាតិ ការប្លន់ដណ្តើមដីធ្លីពីប្រជារាស្ត្រខ្មែរ និងអំពើពុករលួយរបស់ពួកមេដឹកនាំរដ្ឋាភិបាលអាយ៉ងយួន ហើយក្នុងពេលដែលប្រជារាស្ត្រខ្មែរកំពុងតែប្រឈមមុខបញ្ហាក្រីក្រខ្វះមុខខ្វះក្រោយ និងវិបត្តិសព្វបែបសព្វយ៉ាងនោះ គណៈបក្សប្រជាជនកម្ពុជា ក៏ប្រើល្បិចជិះក្របីចំលងផុក ដល់ត្រើយសើយគូថ ដើម្បីសំលាប់បំបិទមាត់ពួកក្មេងស្ទាវ ពួកក្រុម បងតូចបងធំនៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អស់ជិត ៤00 នាក់តែក្នុងរយៈពេលមិនដល់ ២ ម៉ោងផង ប្រើល្បិចខ្សែភ្លើងឆក់បាក់ស្ពានរត់ផ្អើលជាន់គ្នានៅកោះពេជ្រ ព្រោះថាពួកក្មេងពួកក្មេងអាវ៉ាសែ និងពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់អេស,អូ,វ៉ាយ អស់ទាំងនេះ ត្រូវបានគណៈបក្សប្រជាជនប្រើប្រាស់ដោយមិនដឹងខ្លួនដើម្បីរកលុយ និងធ្វើការបំរើឱ្យគោលនយោបាយរបស់គណៈបក្សប្រជាជនកម្ពុជា ដូចជាលួចឆក់ប្លន់ជីវិត ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ជួញដូរអាវុធ សំលាប់ពួកក្រុមប្រឆាំង ធ្វើបាតុកម្មសំលាប់ពួកបាតុករស៊ីវិលនៅឆ្នាំ ១៩៩៨ និង ធ្វើបាតុកម្មវាយស្ថានទូតថៃប្រចាំនៅទីក្រុងភ្នំពេញ ដើរតួជាពួកចារកិច្ចតាមដានពួកប្រឆាំង បក្សប្រឆាំង និងពួកមនុស្សដែលគណៈបក្សប្រជាជនមិនទុកចិត្ត,,,,,,,ម្យ៉ាងទៀតបើទុកពួកអ្នកទាំងនេះតទៅទៀត បារម្ភខ្លាចបែកការណ៍ បែករឿងធ្លាយអាថ៌កំបាំងសំងាត់ទៅថ្ងៃក្រោយ ដូច្នេះមានតែសំលាប់ពួកគេចោលដើម្បីកុំឱ្យយប់យូរសុបិន្តច្រើន ព្រោះថាពួកមនុស្សនៅក្នុងក្រុមបងតូចបងធំអស់ទាំងនេះគឺ ស្តាប់បង្គាប់លោកបងធំរបស់ពួកគេណាស់ បើសិនជាលោកបងធំរបស់ពួកគេកោះអញ្ជើញពួកគេអោយចូលរួមអបអរសាទរ ចូលរួមជប់លៀង ចូលរួមធ្វើបាតុកម្ម ឬចូលរួមពិធីអ្វីមួយនោះ ពួកគេប្រាកដជាទៅចូលរួមជាមិនខាន គឺពួកគេស្តាប់បង្គាប់បញ្ជាលោកបងធំរបស់

ពួកគេជាជាងស្លាប់បង្គាប់ម៉ែឪបងប្អូនរបស់ពួកគេ ដូច្នេះនៅលើកោះពិជ្ជនៅថ្ងៃនោះគឺប្រាកដជាមានផែនការអ្វីមួយដែលលោកបងធំរបស់ពួកគេរៀបចំទុកសំរាប់អោយពួកគេធ្វើ ដូចគ្នានឹងការចូលរួមធ្វើបាតុកម្មសំលាប់ពួកបាតុករបក្សប្រឆាំង និងបាតុកម្មវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញផងដែរ ដោយពួកគេសង្ឃឹមទុកជាមុនថា **គណៈបក្សប្រជាជនកម្ពុជានឹងប្រើពួកគេអោយធ្វើអ្វីមួយដូចពេលមុនៗ ហើយនឹងផ្តល់ដល់ពួកគេនៅឱកាសរកលុយពិសេស** ដូចពេលមុនៗផងដែរ ប៉ុន្តែពួកគេស្មានមិនដល់ថា គណៈបក្សប្រជាជនកម្ពុជាបានត្រៀមពិធិខ្សែភ្លើងឆក់រត់ផ្អើលជាន់គ្នាស្លាប់ ជំនួសពិធីជប់លៀងអបអរសាវទទល់តែសោះ និងរៀបចំពួកមនុស្សរបស់គណៈបក្សប្រជាជននៅទីកើតហេតុដើម្បីសំដែងល្ខោនធ្វើជាបានឃើញ បានឮ បានរងគ្រោះដែរ ហើយ និយាយបង្វែងដានសភាពការណ៍ពីខ្សែភ្លើងឆក់ មកឧប្បត្តិហេតុផ្អើលរត់ជាន់គ្នាទៅវិញទីបំផុតមហាឃាតករញីឈ្មោល ហ៊ុន-សែន និង ប៊ុន-រ៉ានី ដែលជាមេឃាតកររៀបចំក្បួនប្រហាររង្គាលនេះបែរជាធ្វើពុតជាយំ សោកសៅ សោកស្តាយ យ៉ាងទំនងរបស់គេ ( **សូមបញ្ជាក់ថានៅក្នុងនោះក៏មានក្មេងធម្មតា និងមនុស្សធម្មតាចូលរួមស្លាប់ដោយពួកគេមិនបានដឹងសាច់រឿងហេតុការណ៍ត្រៀមទុកជាមុនបែបនេះឡើយ** )
http://www.cchrcambodia.org/admin/media/report/report/english/CCHR%20Report%20-%20The%20Koh%20Pich%20Tragedy.%20One%20Year%20on,%20Questions%20Remain%20(ENG).pdf



http://www.theaustralian.com.au/news/world/cambodian-bridge-victims-died-from-electric-shocks/story-e6frg6so-1225960410939

ពួកក្រុមក្មេងស្ទាវ និង ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបាន ហ៊ុន-សែន សំលាប់បំបិទមាត់ ដោយប្រើល្បិចឆក់ខ្សែភ្លើង បាក់ស្ពាន រត់ផ្អើលជាន់គ្នាស្លាប់អស់ជិត ៤00 នាក់ នៅលើកោះពេជ្រ នាខែ វិច្ឆិការ ឆ្នាំ ២០១០ ។



http://www.cchrcambodia.org/admin/media/report/report/english/CCHR%20Report%20-%20The%20Koh%20Pich%20Tragedy.%20One%20Year%20on,%20Questions%20Remain%20(ENG).pdf

ពួកក្រុមក្មេងស្ទាវ និងពួកក្រុមបង តូចបងធំនៃអង្គការ ឧក្រិដ្ឋជន សំងាត់ អេស-អូ-វ៉ាយ ត្រូវបាន ហ៊ុន-សែន សំលាប់បំបិទមាត់ ដោយ ប្រើល្បិចឆក់ខ្សែភ្លើង បាក់ ស្ពានរត់ផ្អើលជាន់គ្នាស្លាប់ អស់ជិត ៤00 នាក់ នៅលើ កោះពេជ្រ នៅខែវិច្ឆិការ២០១០។

By website: http://www.theaustralian.com.au/news/world/cambodian-bridge-victims-died-from-electric-shocks/story-e6frg6so-1225960410939

The Hong Kong-based Asian Human Rights Commission claimed yesterday that witnesses reported the military using water cannons as thousands stampeded over a bridge in the capital on Monday night, causing electric shocks from the bridge lights. The instances of electrocution must have stemmed from either the electric wiring on the bridge or military intervention.

**By website:** http://www.cchrcambodia.org/admin/media/report/report/english/CCHR%20Report%20-%20The%20Koh%20Pich%20Tragedy.%20One%20Year%20on,%20Questions%20Remain%20(ENG).pdf

Page 22: A number of witnesses were cited in the media as saying that people were electrocuted during the incident. For example, a fruit seller near to the bridge that night said that the electrical wires of the lightning cables were cut, making the bridge shake and electrocuting people when they touched the bridge railings and lightning cable.73 A survivor who was on the bridge, said that some policemen also received electric shocks.74 An

eyewitness, who escaped the bridge with minor injuries, said that some people jumped off the bridge and one of them accidentally hit a light and cut the wire.75 Another survivor said that her husband and sister-in-law were victims of electric shocks; her sisterin-law died after being shocked, while her husband also received a serious shock when he did not remove his hand from the railing quickly enough.76 Of the family members of the dead that CCHR spoke to, only one person said that the cause of death of their loved one related to electrocution. However, some of the victims who were injured (26%, 20 people) said they heard of people being electrocuted. The victims could not explain what had happened, and were quite vague about the details. In addition, a man from Phnom Penh hesitated before saying anything, stating that he was "afraid for [his] personal security" if he mentioned electrocution."

(Noted that other simple teen, adults and Khmer people went to Koh Pich too, without contact to S.O.Y and they don´t know the crime happen)

**(៤)-ពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំនៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ត្រូវបានប្រើប្រាស់ដើម្បីធ្វើឃាតកម្មនយោបាយ និងបង្ករភាពវឹកវរចលាចលសង្គម បង្កើតអសន្តិសុខសង្គម អស្ថេរភាពសង្គម**មុនការបោះឆ្នោតសំរាប់អាណត្តិថ្មី និងស្ថានភាពដែលគណៈបក្សប្រជាជនគិតថាចាំបាច់ដើម្បីឆ្លៀតកេងយកចំណេញខាងនយោបាយ និងសេដ្ឋកិច្ច ហើយដែល ហ៊ុន-សែន ខ្លួនឯង តែងតែធ្លាប់បានប្រកាសថាមានតែខ្លួនវាម្នាក់ប៉ុណ្ណោះទេ ទើបអាចទុបស្កាត់មិនអោយមានចោរ ឬបទឧក្រិដ្ឋកើតមានឡើង។ បើសិនវាប្រកាសតាមម៉េក្រូថា **មិនឱ្យមានចោរ គឺ មិនមានទេ** តែពេលប្រជាជនភ្លេចត្រចៀក គឺចោរមានលើសដើម។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជានិច្ចជាកាលត្រូវបានប្រើដើម្បីសំលាប់ប្រជាជនដែលមិនពេញចិត្ត មិនដើរតាម ឬរិះគន់ទិចទៀនគណៈបក្សប្រជាជនកម្ពុជា ហើយពួកគេត្រូវបានបញ្ជូអោយសំលាប់ពួកអ្នកដែលមាននិន្នាការទៅរកពួកបក្សប្រឆាំង មាននិន្នាដែលចេញពីគណៈបក្សប្រជាជន ឬក្បត់នឹងគណៈបក្សប្រជាជនកម្ពុជា។ លើសពីនេះទៅទៀត ពួកក្រុមក្មេងស្ទាវ ពួកក្រុមអន្ធពាល ពួកក្រុមបងតូចបងធំ និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើប្រាស់សំរាប់សំលាប់និងគំរាមកំហែងដល់ពួកអ្នកដែលមិនគាំទ្រគណៈបក្សប្រជាជនកម្ពុជា គឺមានគោលដៅបោសសំអាតខ្មាំង ដែលត្រូវបានពួកគេប្រកាន់ទ្រឹស្តីមួយដែលថា **អ្នកដែលមិនចូលបក្សមានន័យថាប្រឆាំង មានន័ថាខ្មាំង**។ កិច្ចការពិសេស

របស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ គឺបោសសំអាត និងកំទេចឱ្យអស់រាល់ពួកអ្នកជាតិនិយមខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកវីរៈជន ពួកវីរៈជនខ្មែរ ពួកឥស្សរៈជនខ្មែរ និងពួកអ្នកនយោបាយខ្មែរដែលមានទិន្នាការប្រឆាំង ឬមិនពេញចិត្ត មិនយល់ស្របតាមការអនុវត្តន៍ ការសំរេច និងគោលដៅពិសេសរបស់គណៈបក្សប្រជាជនកម្ពុជាដែលជាអាយ៉ងកញ្ជះដាច់ថ្លៃរបស់យួនកុំមុយនីស្តក្រុងហាណូយ ។ ពួកក្រុមក្មេងស្ទាវ ពួកក្រុមអន្ធពាល ពួកក្រុមបងតូចបងធំ និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានបញ្ជូអោយសំលាប់ពួកអ្នកនយោបាយ និងពួកអ្នកគាំទ្របក្សប្រឆាំង ពួកអ្នកដែលមានទិន្នាការប្រឆាំង ហើយពួកគេបានធ្វើឃាតយ៉ាងប៉ិនប្រសព្វជាទីបំផុត ដោយបំផ្លែងចេញជារូបភាពផ្សេងៗ ដូចជា ឧប្បត្តិហេតុចៃដន្យ គ្រោះថ្នាក់ចរាចរ ខ្សែភ្លើងឆក់ ឈឺស្លាប់ ខ្យល់គ ឈ្លោះគ្នាទំនាស់គ្រួសាររឿងគ្រួសារ រឿងច្រណែន រឿងប្រណាំងប្រជែង រឿងប្រចន្ទ័ រឿងជំពាក់លុយ រឿងបំណុល រឿងប្លន់សំលាប់ មានទំនាស់ជាមួយពួកក្មេងស្ទាវពួកបងតូចបងធំ រឿងស្នេហាត្រីកោណ រឿងដណ្តើមស្រីជាមួយពួកអាស្ទាវ រឿងរាលកៃកាំភ្លើង រឿងងាងថ្នាំ,,,,,,,,, ។ល។ និង ។ល។



http://www.theaustralian.com.au/news/world/cambodian-bridge-victims-died-from-electric-shocks/story-e6frg6so-1225960410939

មើលវាពុតធ្វើយំ ដូចមែនទែនអញ្ចឹង! មេឃាតករញីឈ្មោល កំពុងពុតធ្វើយំដើម្បីបំភាន់ភ្នែកមហាជនកុំឱ្យសង្ស័យថាខ្លួននៅពីក្រោយខ្នងនៃការសំលាប់បំបិទមាត់ពួកក្រុមក្មេងស្ទាវ ក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ

នេះជាអាស័យដ្ឋានអ៊ីនថឺនិតស្តីពីអា ហ៊ុន-សែន បញ្ជូឱ្យកងកំលាំងប្រដាប់អាវុធសំលាប់រង្គាលព្រះសង្ឃ និងហ្វូងបាតុករយ៉ាងសាហាវឃោរឃៅនៅខែកញ្ញាឆ្នាំ ១៩៩៨

http://il.youtube.com/watch?v=wzBWG3Uj4JM&feature=related

http://www.youtube.com/watch?v=sb7cawCPp2c

**មេឃាតករញីឈ្មោលចេះយំ ផែនដីក្រឡាប់ចាក់ទេដឹង?**

**ហ៊ុន-សែន** អនុវត្តផែនការ ក៩,ជាអ្នកសំរួលដល់អង្គការឧក្រិដ្ឋជនសំងាត់បាក់គី (១៩៩១-១៩៩៧) បង្កើតអង្គការឧក្រិដ្ឋជន សំងាត់ អេស-អូ-វ៉ាយ(១៩៩៧-២០០៣) ជាមេបង្រ្កាប សំលាប់ហ្វូងបាតុករស៊ីវិលខ្មែរនៅខែកញ្ញា១៩៩៨ ជាមេអង្គការឧក្រិដ្ឋជនសំងាត់អាវខៀវ (១៩៩៧-បច្ចុប្បន្ន) និងជាមេ ឃាតករសំលាប់

ស្លាប់អស់ជិត ៤00នាក់ នៅកោះពេជ្រនាខែវិច្ឆិការ ២០១០ ដោយ ប្រើល្បិចឆក់ខ្សែភ្លើងបាក់ស្ពាន រត់ផ្អើលជាន់គ្នាស្លាប់។ ប្រព័ន្ធ ឃោសនាក្នុងដៃផ្សាយកុហក់យ៉ាងម៉េចក៏បាន បើអ្នកក្នុងស្រុក តវ៉ា ប្រើកងកំលាំងប្រដាប់អាវុធ ឃាតករសំងាត់ សំលាប់ ឬប្រើតុលាការចាប់ដាក់គុក តើនរណាហ៊ាននិយាយថា ឆក់ខ្សែភ្លើងស្លាប់? គ្រប់ប្រព័ន្ធឃោសនាស្រុកខ្មែរ ទាំងភាសាខ្មែរ និងអង់គ្លេស សុទ្ធតែជាឧបករណ៏នយោបាយ របស់ ហ៊ុន-សែន ទាំងអស់ បើមិនបំរើ ហ៊ុន-សែន គឺមានតែជាប់គុក ដោយចោទថា ផ្សាយពត៌មានមិនពិត និងត្រូវបានសំលាប់ យ៉ាងសាហាវ។

បំបិទមាត់ពួកក្មេង ស្មាវ ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ អស់ ជិត៤00នាក់ នៅកោះពេជ្រនៅខែ វិច្ឆិកា ២០១០ ដើម្បីចៀងវាងនៅ "យប់យូរសុបិន្តច្រើន" នាំឱ្យបែករឿងសំងាត់។ បោក អង្គការសហប្រជាជាតិ បង្កើតតុលាការសាលាក្តីខ្មែរក្រហម កាត់ទោសពួកខ្មែរ ក្រហមដូចតុលាការយួនកាត់ទោសខ្មែរក្រហមឆ្នាំ១៩៧៩ ដើម្បី លាងទោសកំហុសបទឧក្រិដ្ឋឈ្លានពានរបស់យួនកំមុយនីស្ត៍ ថែមទាំងបានជំនួយលុយដុល្លាដ៏ ច្រើនចែកគ្នាចាយយ៉ាងសប្បាយហ៊ឺហា គ្រាន់តែសំដែង ល្ខោនកាត់ទោសតែប៉ុណ្ណោះ។



http://www.cchrcambodia.org/admin/media/report/report/english/CCHR%20Report%20-%20The%20Koh%20Pich%20Tragedy.%20One%20Year%20on,%20Questions%20Remain%20(ENG).pdf

**សំណើចពិឃាត**

**ប៊ុន-រ៉ានី:** បងខំប្រឹងយំអោយចេញទឹកភ្នែកទៅ!

**ហ៊ុន-សែន:** បងចេះតែសំលាប់មនុស្ស បងពិតជាមិនចេះយំទេ តើបានទឹកភ្នែកមកពីណាទៅ?

**ប៊ុន-រ៉ានី:** យកកូនកន្សែងជូតបន្ទំទៅ ទើបសំដែងល្ខោនពុតធ្វើយំសម! មើលពួកសារពត៌មានវាមើលយើងហ្ន៎!

**ហ៊ុន-សែន:** ដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែរបាន បងមានតែធ្វើតាមគំនិតអូនទៅចុះ! (មើលរូបខាងលើ)

Hun-Sen's Killing crimes and genocide crimes against humanity

http://www.youtube.com/watch?gl=IL&feature=related&hl=en&v=wzBWG3Uj4JM

http://www.youtube.com/watch?v=_IH9Zh24EXw

http://ki-media.blogspot.com/2011/09/hun-sens-crime-against-humanity.html

http://www.youtube.com/watch?v=j-voBgXdhlE (Secret Criminal Organization of Black Uniform)

**សមិទ្ធិផលរបស់ ហ៊ុន-សែន នៅក្នុងការសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយគឺមានដូចខាងក្រោមនេះ**



***ហ៊ុន-សែន ជាមេភេរវករ*** បោកគ្រាប់បែក មុខរដ្ឋសភាថ្ងៃ ៣០មិនា១៩៩៧ វាយប្រហារលើពួកបាតុករស៊ីវិល និងលើរូបលោកសមរង្ស៊ី ជាមេដឹកនាំគណៈបក្សប្រឆាំងនៅមុខរដ្ឋសភា **គណៈបក្សប្រជាជនកម្ពុជា យកឃាតកម្ម និងភេរវកម្មធ្វើជាឧបករណ៍គ្រប់គ្រងប្រទេសដើម្បីសំរេច បេសកកម្ម រំលាយជាតិសាសន៍របស់ក្រុងហាណូយ** ។ នេះជា **ល្បិចសំលាប់មួយគំរៀម១000**

http://www.youtube.com/watch?v=DmDPWrMCn48&feature=related

http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html

http://www.garella.com/rich/grenehrl.htm



***ហ៊ុន-សែន ជាមេឧក្រិដ្ឋជនសង្គ្រាម*** ធ្វើរដ្ឋប្រហារនៅថ្ងៃ ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ ដើម្បីកំទេចភាពរាំងស្ទះនៅក្នុងការអនុវត្តសន្ធិសញ្ញាព្រំដែន ខ្មែរ-យួន ឆ្នាំ ១៩៩៨២-១៩៨៣ និង ១៩៨៥ និងបន្តអនុវត្តយុទ្ធសាស្ត្រលេបទឹកដីខ្មែរ រំលាយជាតិសាសន៍ខ្មែរ

http://www.seasite.niu.edu/khmer/ledgerwood/july_56_1997_events.htm

http://www.youtube.com/watch?v=u-pAksDMmgU

http://www.youtube.com/watch?v=P6jVFJYElc0

http://www.seasite.niu.edu/khmer/ledgerwood/july_56_1997_events.htm

**ច្បាប់អន្តរជាតិនៅឯណា? សិទ្ធិមនុស្ស តំលៃមនុស្សជាតិ និងលិទ្ធិប្រជាធិបតេយ្យនៅឯណា? តើអា ហ៊ុន-សែន** បានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សហគមន៍អន្តរជាតិ បានជាសហគមន៍អន្តរជាតិមិនត្រឹមតែមិនចាប់អា ហ៊ុន-សែន ទេ ថែមទាំងឃិបឃិតជាមួយអា ហ៊ុន-សែន បង្កើតតុលាការសាលាក្តីខ្មែរក្រហមកាត់ទោសសំដែងល្ខោនលាងបទឧក្រិដ្ឋឈ្លានពាន អោយ យួនកំមុយនិស្ត៍ និងផ្តល់ជំនួយដល់ **ហ៊ុន-សែន** ទៀត? តើ **ហ៊ុន-សែនះ** ឱ្យប៉ុន្មានភាគរយ?

## ឧក្រិដ្ឋកម្មប្រឆាំងនឹងសាសនារបស់ អា ហ៊ុនសែន និង គណៈបក្សប្រជាជនកម្ពុជា

នេះជាអាស័យដ្ឋានអ៊ីនធឺនិតស្តីពីសកម្មភាពកងកំលាំង ប្រដាប់អាវុធរបស់អា ហ៊ុន-សែន វាយបង្រ្កាប និង សំលាប់ហ្វូងបាតុកម្មរបស់ព្រះសង្ឃ នៅខែ កញ្ញា ឆ្នាំ ១៩៩៨ នៅទីក្រុងភ្នំពេញ

http://www.hrw.org/news/2009/01/21/vietnam-halt-abuses-ethnic-khmer-mekong-delta

http://vi-media.blogspot.com/2010/01/hun-xens-cops-hunting-khmer-krom-monks.html

http://www.hrw.org/news/2007/12/20/cambodia-ensure-safety-buddhist-monks

http://il.youtube.com/watch?v=opfPLoKms_U

http://www.youtube.com/watch?v=opfPLoKms_U&NR=1

http://www.youtube.com/watch?v=_IH9Zh24EXw

http://www.youtube.com/watch?v=utAyYQBObLw&feature=related



សំលាប់ វាយសំពង ទាត់ធាក់ព្រះសង្ឃខ្មែរបែបយ៉ាងនេះ! នេះឬជា **ជាតិ សាសនា ព្រះមហាក្សត្រ** របស់អា ហ៊ុនសែន?





ព្រះសង្ឃមួយអង្គ ត្រូវបានពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ វាយបែកឈាម ថ្ងៃ២០ ខែមេសា ឆ្នាំ ២០០៧ បន្ទាប់ចូលរួមបាតុកម្មនៅមុខស្ថានទូតវៀតណាមនិង សហរដ្ឋអាមេរិក។



ក្រុមព្រះសង្ឃធ្វើបាតុកម្មមុខស្ថានទូតយួន ត្រូវបានកងកំលាំងប្រដាប់អាវុធចាប់ដាក់ក្នុងឡាន។

http://www.hrw.org/en/node/79437/section/7

http://www.hrw.org/news/2009/01/21/vietnam-halt-abuses-ethnic-khmer-mekong-delta





ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ អា ហ៊ុនសែន និង គណៈបក្សប្រជាជនកម្ពុជា

http://www.youtube.com/watch?v=wzBWG3Uj4JM&feature=player_embedded



http://www.youtube.com/watch?v=wzBWG3Uj4JM

http://www.youtube.com/watch?v=rovjo_T328E

http://hengpov.wordpress.com/

http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html

http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

ឧក្រិដ្ឋកម្មជន្លៀសប្រជាជន និងប្លន់ដីធ្លីរបស់ របស់ អា ហ៊ុនសែន និង គណៈបក្សប្រជាជនកម្ពុជា

http://www.youtube.com/watch?v=v9p_ILKEdjY&feature=related

http://www.youtube.com/watch?v=DfIjrBdcHMI&feature=related

http://www.youtube.com/watch?v=AQsha2tGm5I&feature=related

http://www.youtube.com/watch?v=qGBPtccFE6w&feature=related

http://khmerization.blogspot.com/2012/01/savagery-and-violence-by-phnom-penh.html

http://www.youtube.com/watch?v=1aIlFeLJCkk&feature=related





http://www.youtube.com/watch?v=Qs41SHumX9I&feature=related



http://www.youtube.com/watch?v=qGBPtccFE6w&feature=related

**៥-ធ្វើចារកម្ម តាមដាន ស៊ើបការណ៍ យកពត៌មាន ប្រមូលពត៌មានអោយគណៈប្រជាជនកម្ពុជាៈ**

ពួកក្រុមបងតូចបងធំ ពួកក្មេងអាណាថា ពួកក្រុមជនអន្ធពាល និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើសំរាប់តាមដានសភាពការណ៍ ហេតុការណ៍ សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរ ថាតើប្រជាជនខ្មែរ គ្រួសារជនជាតិខ្មែរនីមួយៗមានអ្វីខ្លះ? មានសមាជិកប៉ុន្មាននាក់? សមាជិកគ្រួសារនីមួយៗប្រកបមុខរបរអ្វីខ្លះ? នៅទីកន្លែងណាខ្លះ? ចូលផ្ទះ និងចេញពីផ្ទះនៅម៉ោងប៉ុន្មាន? រកប្រាក់ចំណូលបានមួយថ្ងៃប៉ុន្មាន? មានទំនាក់ទំនងជាមួយនរណាខ្លះ? មានសក្តិឋានៈ មុខតំណែង និងតួនាទីប៉ុនណា? មានពាក់ព័ន្ធពួកបក្សប្រឆាំងឬទេ? មានខ្នងបង្អែកប៉ុនណា? នៅក្នុងជួរស៊ីវិល ឬកងកំលាំងប្រដាប់អាវុធ? សក្តិប៉ុន្មាន ផ្កាយប៉ុន្មាន? មានកាំភ្លើងនៅក្នុងផ្ទះឬទេ? ពាក់ព័ន្ធនឹងអង្គការណាខ្លះ? ការតាមដានត្រូវបានធ្វើឡើងតាមក្រុមបងតូចបងធំនិមួយៗនៅប្រចាំតាមតំបន់នីមួយៗ ហើយសកម្មភាពតាមដានស៊ើបអង្កេតត្រូវបានធ្វើឡើងជាប្រចាំថ្ងៃ ជារៀងរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ ដោយមានការផ្លាស់ប្តូរវេនម៉ោងគ្នា ចែកពេលវេលាគ្នាតាមដាន ប្តូរក្រុមគ្នាចល័តតាមការចាត់តាំងរបស់ថ្នាក់លើ និងការចង្អុលទិសរបស់អាជ្ញាធរមូលដ្ឋានដែនដី។ ដោយសារតែពួកក្រុមបងតូចបងធំ ពួកសមាជិក នៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ មានតួនាទីរកលុយចំណូលអោយបក្ស និងថ្នាក់លើផងនោះ ការតាមដានស៊ើបការណ៍ ស៊ើបអង្កេត ឃ្លាំមើល គឺជា **ឱកាសរកលុយពិសេស** តាមជោគជតាហេងស័យរបស់ក្រុមនីមួយៗរបស់ពួកគេ ទៅតាមលទ្ធភាពជាក់ស្តែង និងសមត្ថភាពរបស់ពួកគេផងដែរ ហើយការរកលុយនេះគឺធ្វើបានទៅតាមឱកាសហុចអោយ មិនថាលួចឆក់ប្លន់នៅតាមផ្ទះទេ សូម្បីតាមថ្នល់ ក៏ពួកគេធ្វើ ដោយមិនប្រកាន់ពេលវេលា ឬទីកន្លែងណានេះទេ ក្រុមអង្គរក្ស ហ៊ុន-សែន និងក្រុមបងតូចបងធំ ពួកអេស-អូ-វ៉ាយ តាមដានខ្ញុំតាមផ្ទះលើដងផ្លូវទេពផននៅឆ្នាំ២០០៣ ២០០៤ ២០០៥ និង ២០០៦ មុនចាប់ខ្ញុំដាក់គុកព្រៃស គឺ ពេលពួកវាឃើញពួកអ្នកដំណើរ ឬស្រីៗជិះមូតូ ពាក់មាស ពេជ្រ ជាប់នឹងខ្លួន ពួកវាចាប់ផ្តើមធ្វើសកម្មឆក់ឬ ក៏ប្លន់តែម្តង ដូចជាឆក់កាបូប ឆក់លុយឆក់គ្រឿងអលង្ការរបស់របររបស់ពួកអ្នកដំណើរ ពេលខ្លះធ្វើអោយ មានគ្រោះថ្នាក់ដល់ពួកអ្នកដំណើរដួលម៉ូតូក្បែរស្លាប់ក៏មាន និងប្លន់ម៉ូតូក្បែរផ្ទះខ្ញុំស្ទើរតែរៀងរាល់ថ្ងៃ តែពួកប៉ូលីសមិនអើរពើអ្វីឡើយព្រោះគោរពតាមបញ្ជាបក្សដាក់ទិសអោយរកចំណូលបែបយ៉ាងនេះ។

**៦-បំផុសពត៌មាន ប្រឌិតឈុតល្ខោន បំផ្លើងហេតុការណ៍ និងអនុវត្តល្បិចឆ្កែព្រួសរបស់អា ហ៊ុន-សែនៈ**

គណៈបក្សប្រជាជនកម្ពុជាដែលស្ថិតនៅក្រោមការដាក់ទិស និងដឹកនាំតំរង់ទិសរបស់រដ្ឋាភិបាលក្រុងហាណូយ

ដែលជាប្រទេសកំមុយនីស្ដ៏ផ្ដាច់ការតាមដានគ្រប់គ្រងជីវភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជន ប៉ុន្តែដោយសារពួកមេដឹកនាំយួនកំមុយនីស្ដមានការស្ទាត់ជំនាញខាងសិល្បៈសង្រ្គាម ពួកវាបានប្រើប្រព័ន្ធបណ្ដាញចារកម្មគ្រប់គ្រងដឹកនាំពពួកឆ្កែយ៉ាងល្អ បើឆ្កែមួយណាមិនចេះព្រុស មិនស្ដាប់បង្គាប់ និងមិនចេះខាំសំលាប់ប្រជាជនខ្មែរ ត្រូវបានយួនដកតំណែង ចាប់ដាក់គុកដូចជាលោក ប៉ែន-សុវណ្ណ ជាគំរូស្រាប់ ឯលោក ចាន់-ស៊ី ត្រូវបានសំលាប់។ ដូច្នេះនៅក្នុងចំណោមឆ្កែយួនទាំងអស់ យួនបានសំរេចជ្រើសរើសឆ្កែអាណាថាគ្មានទីពឹងមកបង្វឹកបង្ហាត់ បង្រៀនអោយចេះព្រុស និងចេះខាំសំលាប់រាស្ត្រខ្មែរ។ បន្ទាប់ពីធ្វើការពិសោធន៏ពួកក្រុមឆ្កែជាច្រើនក្បាលអស់រយៈពេលជាច្រើនឆ្នាំមក **ពួកមេដឹកនាំយួនកំមុយនីស្ដក៏សំរេចជ្រើសរើសអា ហ៊ុន-សែន ដែលជាឆ្កែអាណាថា ជាចោរលួចខ្សាក់ភ្នែកមួយក្បាល រត់ចូលព្រៃ គ្មានទីជំរក គ្មានចំណីអាហារ មកបង្វឹករហូតដល់អា ហ៊ុន-សែន ពូកែខាងព្រុស និងប្រសព្វខាងខាំសំលាប់ប្រជារាស្ត្រខ្មែរ អោយធ្វើជាមេដឹកនាំរដ្ឋាភិបាលអាយ៉ង**។ នៅក្នុងការគ្រប់គ្រងប្រជាជនខ្មែរតាមបែបសង្គមសត្វព្រៃដូចរឿងភាគបុរាណចិន ដែលយកអំពើឃាតកម្ម ភេរវកម្ម ទារុណកម្ម ការលួចឆក់ប្លន់ជីវិត,,,,,,,មកធ្វើជាឱ្យឧបករណ៏គ្រប់គ្រងប្រជាជនខ្មែរយ៉ាងណែនក្នុងដៃនោះ។ រដ្ឋាភិបាលអាយ៉ងបានបន្ថែមប្រព័ន្ធបណ្ដាញចារកម្ម និងឧបករណ៏ចារកម្មអាសន្យាណ្ឌូទំនើប រួមជាមួយនិងយុទ្ធសាស្ត្រឆ្កែព្រុសដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយអោយបានឆាប់ជាទីបំផុត ហើយបានពាក់អាវលិទ្ធិប្រជាធិបតេយ្យ យកបក្សប្រាឆាំងជាឧបករណ៏បោកប្រាស់យកជំនួយសហគមន៏អន្តរជាតិ និងកំចីបរទេសទៅបំប៉នសេដ្ឋកិច្ចយួន និងចិញ្ចឹមប្រជាជនយួនអោយរស់នៅយ៉ាងសំបូរសប្បាយធ្វើជាម្ចាស់លើប្រជាជាតិខ្មែរ យកប្រជាជនខ្មែរធ្វើជាទាសករលើទឹកដីរបស់ខ្លួន ហើយយួនចង់ចាប់ ចង់កាប់សំលាប់ និងលក់ដូរបានស្រេចតែចិត្ត ដោយគ្រាន់តែពាក់អាវប្រជាធិបតេយ្យ និងប្រើប្រាស់ល្បិចឆ្កែព្រុស គឺអាចបោកប្រាស់សហគមន៏អន្តរជាតិយកប្រាក់ជំនួយអន្តរជាតិ យកប្រាក់កំចី និងបោកប្រាស់អង្គការសហប្រជាជាតិ ឱ្យបង្កើតតុលាការសាលាក្ដីខ្មែរក្រហមកាត់ទោសលាងកំហុសលាងបទឧក្រិដ្ឋឈ្លានពានរបស់យួនយ៉ាងងាយស្រួលបំផុត មិនដឹងថាពួកសហគមន៏អន្តរជាតិ អង្គការសហប្រជាជាតិ ល្ងង់គិតមិនយល់ ឬក៏ពួកអស់នេះបាន ទទួលផលប្រយោជន៏អ្វីមួយពីអា ហ៊ុន-សែន និងយួន ហើយពុតធ្វើជាល្ងង់ដើម្បីប្តូរយកផលប្រយោជន៏។ ការប្រើល្បិចឆ្កែព្រុសនេះ ក្រៅពីប្រព័ន្ធឃោនាវិទ្យុ ទូរទស្សន៏ កាសែតទស្សនាវដ្ដី ពួកកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ងនោះ នៅមានពួកក្រុមអង្គការឧក្រិដ្ឋជនបាក់គីអេស-អូ-វ៉ាយ និងអាវខ្មៅ អោយជួយស្រែកព្រុសបន្ថែមលើវត្ថុបំណងដែលពួកគេចង់បាន។ ដូចជាអា ហ៊ុន-

សែន បានចាត់អោយលោក ភុន-ភាព ចោទសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ដោយឥតសមហេតុផល http://www.youtube.com/watch?v=LHRIMXUdyLA&feature=related ហើយ ធ្វើរដ្ឋប្រហារក្តាប់អំណាចរួចហើយនោះ អា ហ៊ុន-សែន ព្រួយបារម្ភខ្លាចបែករឿងសំងាត់ ក៏ប្រើល្បិច សំលាប់លោក ភុន-ភាព ដោយប្រើចិត្តសាស្រ្តមិនអោយពួកខ្មែរក្រហមដែលចុះចូលភ្ញាក់ផ្អើលនោះ បានប្រើ ប្រាស់ពួកក្រុមបងតូចបងធំ ពួកក្រុមជនអន្តពាល ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលផ្សាយព្រុសក្រៅផ្លូវការថា លោក ភុន-ភាព ស្លាប់ហើយ ការព្រុស ផ្សាយនេះគឺធ្វើឡើង សព្វទីកន្លែង និងធ្វើគ្រប់រូបភាពទាំងអស់ដូចជាដើរតួជាម៉ូតូឌុប កម្មករ អ្នករត់ឡានតាក់ស៊ី ពួកកងកំលាំងប្រដាប់អាវុធ រហូតដល់ពួកមន្ត្រីរាជការ,,,,,,,ហើយទីបំផុតក៏បង្ហាញ រូបភាពបទសម្ភាសរបស់លោកភុន-ភាព តាមទូរទស្សន៏ទ-ទ-ក ដើម្បីធ្វើពួកខ្មែរក្រហមដែលចុះចូលលែង ផ្តោតអារម្មណ៏លើលោកភុន-ភាព,,,,,,,, បន្ទាប់មកលោក ភុន-ភាពត្រូវបានសំលាប់បំបិទមាត់ ហើយក៏លែង មានប្រជាជននឹកគិតដល់ពីរឿងនេះទៀត ,,,,,,,នៅករណីធ្វើឃាតលោកគីម-សុខា មិនបានសំរេច គឺនៅតាម ដងវថីផ្លូវស្តុបទេពផន នៅពេលលោកគីម-សុខា បានជិះឡានសំដៅមកផ្ទះ ពួកគណ:បក្សប្រជាជនកម្ពុជា បានរៀបចំឡានដឹកដែកដើម្បីបុកសំលាប់លោក គិម-សុខា និងរៀបចំពួកកំលាំងអង្គការឧក្រិដ្ឋជនសំងាត ់អេស-អូ-វ៉ាយ ដើម្បីសំដែងល្ខោនក្នុងរឿងនេះ ដោយដើរតួជាអ្នករត់ម៉ូតូឌុប ជាកម្មករ ជាជាងជុសជុល ម៉ូតូកង់ ជាមនុស្សឆ្លងកាត់ទីកើតហេតុ ជាប៉ូលីស ដែលនៅទីនោះដែរ ជាប្រជាជននៅជិតក្បែរៗនោះ,,,,, រងចាំងសំដែងឈុតឃាតកម្ម,,,,,,,ជាជាងកាត់សក់ ជាអ្នកមកកាត់សក់ មកជុសជុលម៉ូត,,,,,,,,ពេលឡាន របស់លោក គិម-សុខា មកជិតដល់ផ្ទះ ឡានដឹកដែកក៏បើកសំរុកមកបុកឡានលោកគីម-សុខា តែមកបញ្ចិត ធ្វើអោយលោក គិម-សុខា មានឱកាសចុះពីឡាន ហើយរត់ចូលផ្ទះ,,,,,,ពេលនោះប្រជាជនចោមរោមមើល ក៏មានអ្នកមកសួរនាំអំពីទីកើតហេតុនោះ,,,,,,,,, ក្រុមពួកសំដែងល្ខោនក៏ស្ទុះមកសំដែនល្ខោនក៏ចេញមកបក ស្រាយពីអំពើឃាតកម្មអោយទៅជារឿងគ្រោះថ្នាក់ចរាចរ,,,,,ពេលប្រជាជនចង់និយាយការពិត ត្រូវបានពួក កងកំលាំងប្រដាប់អាវុធ កំលាំងអង្គការឧក្រិដ្ឋ ជនសំងាត់អេស-អូ-វ៉ាយ ចេញមកគំរៀមកំហែង សំឡុតថា"ចេះដឹងស្អី! ពួកគេនៅទីនោះដែរ! ពួកគេឃើញ ហេតុការណ៏ដែរ! កុំមកនិយាយមួលបង្កាច់! កុំមកចេះដឹងរឿងគេ ចង់នាំរឿងដាក់ខ្លួនហ្អី!" ពេលនោះ មានទាំងអ្នកដកកាំភ្លើងខ្លីចេញពីចង្កេះ សំញើញចេញក្រៅអាវ ហើយពោលថា "សាច់មិនបានស៊ី ចង់យក ឆ្អឹងព្យួរករហ្អី! ខ្លះទៀតពោលថា

"អ៊ីងឯងចេះដឹងស្អី ចង់ងាប់ហ្អេះ! ចេះដឹងរឿងគេសម្បើមណាស់!" ពេល នោះប្រជាជនដែលឃើញហេតុការណ៍ ប្រែក្លាយស្ងាត់ស្ងៀម ចូលផ្ទះរៀងៗខ្លួន ហើយលោក គិម-សខា ខ្លួនឯងក៏មិនហ៊ាននិយាយថាជាគ្រោះឃាតកម្មទេ ហើយបែរជារក្សាភាពស្ងៀមស្ងាត់ទៅវិញ។ និយាយអោយខ្លីនៅក្នុងការប្រើល្បិចឆ្កែព្រុសនេះ គណៈបក្សប្រជាជនកម្ពុជាបានពឹងផ្អែកលើក្រុមពួកបងធំបងតូច ក្រុមពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ជាជាងពួកក្រុមកងកំលាំងប្រដាប់អាវុធ និងពួកក្រុមសំងាត់ដទៃៗទៀត បើអា ហ៊ុន-សែន ចង់បានព្យុះពន្យុះភ្លៀង ចង់អោយសប្រែជាខ្មៅ ចង់អោយខ្មៅប្រែជាស គឺតាមតែអំពើចិត្តរបស់វា គឺចាត់អោយក្រុមទាំងនេះទៅព្រុសសព្ទទីកន្លែង ព្រុសតាមការកំណត់របស់ថ្នាក់លើ និងព្រុសហើយព្រុសទៀត ព្រុសដដែលៗ ដោយពួកវាដើរតួសំដែងថា ពួកវានៅទីកើតហេតុនោះដែរ ពួកវាបានឃើញ បានរងគ្រោះ បានឮ បានដឹងហេតុការណ៍នៅទីនោះដែរ។ បើរឿងឃាតកម្មនយោបាយវិញ ពួកវាផ្សាយថារឿងប្លន់សំលាប់ ដូចជាករណីរឿង ឃាតកម្មលើរូបលោក ឱម-រដ្ឋសាឌី ត្រូវបានអា ហ៊ុន-សែន ចាត់ពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ រួមជាមួយក្រុមកងកំលាំងប្រដាប់អាវុធផងដែរ បានផ្សព្វផ្សាយជាថារឿងប្លន់ទូរស័ព្ទ ដែលខ្លះដើរតួជាអ្នកឧប ជាអ្នកប្រមឹក ជាអ្នកបំរើ ជាកម្មករ ជាស្រីឡង់សេ ជាមន្ត្រីរាជការ,,,,,,,ផ្សាយហើយផ្សាយទៀត ធ្វើសព្វទីកន្លែង បើប្រជាជនណាហ៊ានតវ៉ា គឺត្រូវបានពួកវាគំរាមសំលាប់ ឬចាប់ដាក់គុក ឬត្រូវបានសំលាប់យ៉ាងវេទនា,,,,,,,, ដូចករណីរឿងអា ហ៊ុន-សែន បានចុះអនុសញ្ញាបំពេញបន្ថែមជាមួយយួន (Additional Convention) នៅខែតុលា ឆ្នាំ ២០០៥ ទទួលស្គាល់និងការពារសន្ធិសញ្ញាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៧៩ ស្តីពីសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងលោក ហេង-សំរិន និងលោក ផាន់-វ៉ាន់ឌុង កិច្ចព្រមព្រៀងស្តីពីដែនទឹកប្រវត្តិសាស្ត្រថ្ងៃទី សន្ធិសញ្ញាថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ១៩៨២ សន្ធិសញ្ញាស្តីពីគោលការណ៍ដំណោះស្រាយជំលោះព្រំដែននៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៨៣ និងសន្ធិសញ្ញាស្តីអំពីការលុបបំបាត់ព្រំដែនរវាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាមថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៨៥ (The Treaty of People's Republic of Kampuchea on 27th December 1985; please read Website ------>
http://www.cfcambodge.org/Doc/Dec131005A.pdf

http://www.youtube.com/watch?v=coLolWfMFsQ

http://books.google.co.th/books?id=BZPgB2CZOl8C&pg=PA167&lpg=PA167&dq=Cambodia-Vietnam+treaty+in+1979&source=bl&ots=WtGnV5jIDI&sig=7uTcuJqxdL0JANk6dsTQCE2QwjU&

hl=en&sa=X&ei=eeP7TqrTI8bsrAftub10&ved=0CDMQ6AEwAw#v=onepage&q=Cambodia-Vietnam%20treaty%20in%201979&f=false

http://www.khmerinstitute.org/articles/boraletterII.htm

http://www.khmerinstitute.org/articles/art09.html

http://www.dur.ac.uk/resources/ibru/publications/full/bsb5-2_amer.pdf

http://www.cfcambodge.org/Doc/Dec131005A.pdf

http://sokheounpang.wordpress.com/2009/11/21/cambodia-does-lose-land-to-vietnam-the-twisted-traitorous-svar-kim-hong/

https://www.dur.ac.uk/resources/ibru/publications/full/bsb5-2_amer.pdf

http://www.scribd.com/doc/18661239/Border-Conflicts-Between-Cambodia-and-Vietnam

http://www.khmerinstitute.org/docs/Doc%20Notes%20on%20Cambodia%20Boundary%20Maps%20Nov%202005.pdf

http://sokheounpang.files.wordpress.com/2009/11/doc-notes-on-cambodia-boundary-maps-nov-2005.pdf

ដើម្បីទទួលស្គាល់ជាចំហរ អនុវត្ត និង ការពារនៅរាល់សន្ធិសញ្ញាខុសច្បាប់អស់ទាំងនេះ ហ៊ុន-សែន បានចាប់រាល់ពួកអ្នកដែលហ៊ានរិះគន់ ដាក់គុកព្រៃស រួមមានលោក គិម-សុខា លោក ប៉ា ងួនទាង លោក ម៉ម-សណង់ដូ និងលោក រុងឈុន ដោយចោទថា ផ្សាយពត៌មានមិនពិត ដើម្បីអនុវត្តន៏យុទ្ធសាស្រ្ត សំលាប់មួយគំរៀមមួយពាន់ និងល្បិចឆ្កែ ព្រុសរបស់ខ្លួន ដូចវាព្រុសថាយួនរំដោះលើរឿងពិតដែល យួនឈ្លានពានលុកលុយខ្មែរនាឆ្នាំ ១៩៧៩ សូមមើល

http://peacecorpsonline.org/messages/messages/467/2042320.html

http://editorials.cambodia.org/2006/02/seeing-through-hun-sen.html

http://www.sophanseng.info/cambodia/brief-history-of-vietnamese-expansionism-vis-a-vis-cambodia/

http://www.country-data.com/cgi-bin/query/r-2226.html

http://domnengkhmer.blogspot.com/2011/03/re-18-march-1970-destruction-of.html

http://www.topix.com/forum/city/honolulu-hi/T3D52JB406E7GO024

http://books.google.co.th/books?id=tW_eEVbVxpEC&pg=PA794&lpg=PA794&dq=General-Van+Tien+Dung+assault+Cambodia&source=bl&ots=pwikCj0pb8&sig=oUoFyxUyx8qI1A2oSkb22

wtkRCM&hl=en&sa=X&ei=cVn8ToSgFMzIrQfOoNnvDw&ved=0CEMQ6AEwBw#v=onepage&q=General-Van%20Tien%20Dung%20assault%20Cambodia&f=false

http://www.upi.com/Top_News/Special/2010/09/24/Cambodian-politician-gets-prison-sentence/UPI-55031285325040/

http://ki-media.blogspot.com/2010/09/key-dates-sam-rainsy-saga.html

http://news.bbc.co.uk/2/hi/asia-pacific/4552054.stm

http://www.youtube.com/watch?v=4bgQjL38TOs&feature=plcp&context=C38fafc0UDOEgsToPDskLPM_e3PJ1GRcggvXZjUaDK




ដូចគ្នាផងដែរ ប្រជាជនខ្មែរនៅខេត្តស្វាយរៀងទៅដកបង្គុលព្រំដែនយួនឈ្លានពាន ត្រូវបានគណៈបក្សប្រជាជនកម្ពុជាចាប់ដាក់គុក ហើយកាត់ទោសលោក សម-រង្ស៊ី អោយជាប់គុកជាច្រើនឆ្នាំដើម្បីធ្វើអោយលោក សម-រង្ស៊ី មិនមានឱកាសចូលរួមបោះឆ្នោត ហើយថ្មីៗនេះលោក សម-រង្ស៊ី ត្រូវបានតុលាការកាត់ទោសអោយជាប់គុក ចំនួន ១០ ឆ្នាំ សូមមើល
http://www.youtube.com/watch?v=lrjrajpKo_Y

http://ki-media.blogspot.com/2010/09/assassination-of-union-leader.html

លោក **ជា-វិជ្ជា** ត្រូវបានពួកក្រុមអង្គការឧក្រិដ្ឋជន សំងាត់ អាវឈុតខ្មៅបាញ់សំលាប់ ហើយបានយកកាសែតម៉ាហ្វីយ៉ាដាក់កល់ក្រោមក្បាលលោកមុនពេលពួកគេបានចាកចេញ ។ នេះបញ្ជាក់ថាឃាតករមានភាពស្ទាត់ ជំនាញខាងពិឃាតខ្លាំងណាស់ធ្វើឱ្យជនរងគ្រោះមិនអាចរត់ដល់ថ្នល់ផង ថែមទាំងមានពេលវេលាយកកាសែតទ្រាប់ក្បាលអោយទៀត ។ ប៉ុន្តែរដ្ឋាភិបាលអាយ៉ង បែរជាចាប់លោក បនសំណាង និង សុខ-សំអឿន មកពាក់ផ្លាកឃាតករបង្វែងដានបទឧក្រិដ្ឋអោយឃាតឆ្ងាយពីគណ:បក្សប្រជាជនកម្ពុជាទៅវិញ ។

http://ki-media.blogspot.com/2010/09/assassination-of-union-leader.html

http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html
http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

ដើម្បីលាងសំអាតបទឧក្រិដ្ឋឃាតកម្មនយោបាយរបស់ ហ៊ុន-សែន រួមទាំងឃាតម្មនយោបាយលើរូបលោក ហូ-សុខ ដែលធ្វើឡើងដោយលោក ហុក-ឡង់ឌី ផងដែរ។ លើពីនេះទៅទៀត កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលដើរតួជា ឃាតករ និង ភេរវករ ដែលជាឧបករណ៏តែមួយគត់របស់គណះបក្សប្រជាជនកម្ពុជា និង របស់យួនកំមុយនីស្ដ៏ក្រុងហាណូយសំរាប់គ្រប់គ្រងប្រជាជនខ្មែរ និងក្ដាប់អំណាចយ៉ាងណែននៅក្នុងដៃ ដូចជាករណីអា **ហ៊ុន-សែន** បានបញ្ជូអោយក្រុមអង្គរក្សរបស់ខ្លួនឈ្មោះលោក **ហុយ-ពិសិដ្ឋ** ជាអ្នកដឹកនាំក្រុមធ្វើការវាយប្រហារដោយគ្រាប់បែកលើហ្វូងបាតុកម្មស៊ីវិលរបស់ប្រជាជនដែលទាមទារសុំអោយកែរទំរង់ប្រពន្ឋ័តុលាការខ្មែរនៅមុខរដ្ឋសភាជាតិនាទីក្រុងភ្នំពេញនៅថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៧ ហើយបទឧក្រិដ្ឋកម្ម នេះត្រូវបានផ្ដល់គំនិតមិតិយោបល់ដោយលោក ហុក-ឡង់ឌី និង ផ្ដល់លុយដោយលោក ហេង-ពៅ

http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html

**FBI Points Finger in Cambodian Attack**

http://www.garella.com/rich/grenpost.htm
http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html
http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html

http://www.youtube.com/watch?v=DmDPWrMCn48

http://hengpov.wordpress.com/

http://doc-video.cambodia.org/2011/03/grenade-attack-event-on-march-30-1997.html

http://www.garella.com/rich/grenpost.htm

http://www.globalpost.com/dispatch/asia/091218/us-policy-cambodia

http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html

**FBI Points Finger in Cambodian Attack**

http://www.garella.com/rich/grenpost.htm
http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html

http://www.garella.com/rich/grenpost.htm

http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html
http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html





http://www.globalpost.com/dispatch/asia/091218/us-policy-cambodia

មេដឹកនាំគណៈបក្សប្រឆាំងលោក សម-រង្ស៊ី ប្រញាប់ប្រញាល់គេចេញពីទីកើតហេតុ បន្ទាប់ពីការវាយប្រហារដោយគ្រាប់បែកលើពួកបក្សប្រឆាំងនៅខាងក្រៅរដ្ឋសភា នៅថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ បណ្តាលអោយស្លាប់ចំនួន ១៦ នាក់ និងជាងរាប់រយនាក់ទៀតរងរបួសនៅក្នុងការផ្ទុះគ្រាប់បែកនេះ។



បន្ទាប់ពីគ្រាប់បែកផ្ទុះរួចហើយ សំលេងសំរែកប្រជាជនរងគ្រោះស្រែកធូរទ្រហោរយំយ៉ាងឈឺចាប់បំផុត តែបែរជារថក្រោះរបស់រដ្ឋាភិបាលបញ្ឆេះម៉ាស៊ីនទ្រហឹងអ៊ឹងកងអមសំរែកជនរងគ្រោះទេ ចំណែកជនដៃដល់បែរជារត់រួចយ៉ាងសុវត្ថិភាព ក្រោយមកលោក ជា-សុផារ៉ា បែរជាយកម៉ាស៊ីនមកស្រូបយកកំទេចគ្រាប់បែក និងយកឡានទឹកមកលាងសំអាតភស្តុតាងដានស្នាមឧក្រិដ្ឋទៅវិញ ហើយក្រសួងមហាផ្ទៃបានចាត់អ្នកជំនាញឈ្មោះលោក ប្រាជ្ញ-បញ្ញា អោយមកស្រាវជ្រាវរឿងនេះ តែត្រូវបានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន នេះបើតាមសំដីរបស់លោក លី-រ៉ាស៊ី អតីតជាប្រធានព្រហ្មទណ្ឌកិរិតស្រោល,,,,,,បានប្រាប់ខ្ញុំនៅអាគារអា នៃគុកព្រៃស នៅខែតុលា ឆ្នាំ ២០០៦ ហើយលោក លី-រ៉ាស៊ី បានផ្តាំខ្ញុំថា"**បើចង់ច្បាស់រឿងនេះ អោយរកលោក ប្រាជ្ញ-បញ្ញា អោយឃើញ ហើយ ពេលខ្ញុំរៀបចេញពីគុក គាត់នឹងផ្តល់ឯកសារភស្តុតាងឧក្រិដ្ឋរបស់គណៈបក្សប្រជាជនកម្ពុជាមកឱ្យខ្ញុំ**" តែគួរ ឱ្យស្តាយ ពេលខ្ញុំសល់រយៈ ៤ខែខាងមុខទៀតរៀបចេញពីគុក ខ្ញុំត្រូវបានចាងហ្វាងគុកព្រៃ-ស ឈ្មោះ ម៉ុង-គីមហេង ដាក់អោយនៅបន្ទប់លេខ ១ អាគារសេ ដែលមានសុទ្ធតែ

ពួកអង្គរក្ស ហ៊ុន-សែន នៅជាមួយខ្ញុំចំនួន៦នាក់ដែលខ្ញុំស្គាល់ ហើយខាងមុខបន្ទាប់ខ្ញុំក៏មានអង្គចំនួន ៤ នាក់ ដែលខ្ញុំស្គាល់ ហើយខ្ញុំត្រូវបានដាក់កំហិតមិនអោយចេញពីបន្ទាប់ ឬក៏ឆ្លងកាត់អាគារគុកឡើយ ហើយនៅពេលជួបអង្គការគឺសុទ្ធតែប៉ូលីសអមដំណើរខ្ញុំ ធ្វើឱ្យខ្ញុំគ្មានឱកាសធ្វើការទាក់ទងជាមួយពួកអ្នកទោសឡើយ។ មិនត្រឹមតែប៉ុណ្ណោះ កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលត្រូវបានបញ្ជាឱ្យសំលាប់ប្រជាជនខ្មែរ និងបំផ្លាញជាតិខ្មែរ ព្រមទាំងឆក់ប្លន់យ៉ាងបើកចំហរដោយមិនខ្លាចញញើតនឹងច្បាប់អន្តរជាតិ អង្គការសហគមន៍អន្តរជាតិឬប្រទេសមហាអំណាចណាឡើយ ទោះបីឪសហរដ្ឋអាមេរិកក៏មិនអាចធ្វើអ៊ី ហ៊ុន-សែន បានឡើយ សមដូចលោក ម៉ុង-គីមហេង ចាងហ្វាងគុកព្រៃសបានគំរាមសំលាប់ខ្ញុំក្នុងគុកដោយព្រមាននៅថ្ងៃទី ១០ ខែតុលាឆ្នាំ២០០៧ថា **"អង្គការវាគ្មានបានប្រយោជន៍អ្វីទេ អាអង្គការវាស្រែកដើម្បីឱ្យបានលុយតែប៉ុណ្ណោះ"** ។ ជាការជាក់ស្តែង គណៈបក្សប្រជាជនកម្ពុជាមិនគោរពច្បាប់អន្តរជាតិ ឬកិច្ចព្រមព្រៀងក្រុងប៉ារីសអ្វីឡើយ ដូចជាការធ្វើរដ្ឋប្រហារបង្ហូរឈាមនៅកណ្តាលក្រុងភ្នំពេញនៅថ្ងៃទី ៥-៦ កក្កដា ឆ្នាំ ១៩៩៧ ដណ្តើមយកអំណាចផ្តាច់មុខដើម្បីប្រើអំណាចផ្តាច់ការបំរើគោលនយោបាយលេបទឹកដីខ្មែរ និងរំលាយជាតិសាសន៍ខ្មែររបស់យួនកំមុយនីស្តក្រុងហាណូយ ដោយទាត់ចោលកិច្ចព្រមព្រៀងក្រុងបារីសថ្ងៃ ២៣ តុលា ឆ្នាំ ១៩៩១ ហើយចុះសន្ធិសញ្ញាបំពេញបន្ថែមជាមួយរដ្ឋាភិបាលក្រុងហាណូយដើម្បីអនុវត្តសន្ធិសញ្ញាព្រំដែនខ្មែរ-យួន នៅឆ្នាំ ១៩៨២-១៩៨៣ និង ១៩៨៥ ជំនួសកិច្ចព្រមព្រៀងក្រុងប៉ារីស

http://www.youtube.com/watch?v=coLolWfMFsQ ។ ការសំលាប់រង្គាលប្រជាជនខ្មែរនៅខែកញ្ញា ឆ្នាំ ១៩៩៨ កងកំលាំងប្រដាប់អាវុធត្រូវបានបញ្ជារអោយស៊ើបការណ៍ ស៊ើបអង្កេតតាមដានរាល់សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរ អ្នកនយោបាយខ្មែរទាំងក្នុងបក្ស និងក្រៅបក្ស ពួកឥស្សរៈជនខ្មែរ ពួកវរៈជនខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកអ្នកជាតិនិយមខ្មែរ ពួកបក្សប្រឆាំង និងពួកអ្នកមាននិន្នាការប្រឆាំង ពួកដែលមិនចុះចូលពួកយួនកំមុយនីស្ត ពួកដែលមិនចុះចូលនឹងអា ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជា និងពួកអ្នកក្បត់បក្ស ឬជនដែលគេសង្ស័យថាក្បត់,,,,,,,ប្រសិនបើឱកាសហុចឱ្យពួកចារកម្មរបស់កងកំលាំងប្រដាប់អាវុធនឹងធ្វើការលួចឆក់ប្លន់ ចាប់ជីវិត ចាប់ដាក់គុក ចាប់ធ្វើទារុណកម្ម ឬសំលាប់ទៅតាមការដាក់ទិសរបស់បក្ស ឬទៅតាមការបញ្ជារបស់ ហ៊ុន-សែន និងថ្នាក់លើរបស់គណៈបក្សប្រជាជនកម្ពុជា។ ហ៊ុន-សែន ហុក-ឡង់ឌី និងពួកមេដឹកនាំជាន់ខ្ពស់ដទៃៗទៀត បានប្រើប្រាស់ពួកក្រុមកងកំលាំងប្រដាប់អាវុធ និងកងកំលាំងអង្គរក្សអោយធ្វើជាកំលាំងជំនួយ ជាអ្នកជំនាញការ និងជាសមាជិករបស់

អង្គការឧក្រិដ្ឋជនសំងាត់បាក់គី អង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងអង្គការឧក្រិដ្ឋជនសំងាត់អាវខៀវ ឬឈុតខៀវ ព្រមទាំងធ្វើជាមេក្រុមបងតូចបងធំផងដែរ ។ លើសពីនេះទៅ កងកំលាំងប្រដាប់អាវុធរបស់រាជ

| | |
|---|---|
|  ប្រជាជនខ្មែរគេចវាសពីការសំលាប់របស់ CPP |  សកម្មភាពបំផ្លាញទីក្រុងភ្នំពេញរបស់ CPP |
|  សកម្មភាពប្លន់ប្រមូលទ្រព្យសម្បត្តិប្រជារាស្ត្រខ្មែរ របស់ពួកកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនកម្ពុជា ។ |  សកម្មភាពប្លន់ប្រមូលទ្រព្យសម្បត្តិប្រជារាស្ត្រខ្មែរ របស់ពួកកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនកម្ពុជា ។ |

http://www.seasite.niu.edu/khmer/ledgerwood/july_56_1997_events.htm

រដ្ឋាភិបាលបានបំពេញតួនាទីបំបិទភស្តុតាង លុបស្នាមដានឧក្រិដ្ឋ សំលាប់សាក្សី ប្រឌិតសាក្សី និងភស្តុតាង តាក់តែងឆាកល្ខោននយោបាយ បន្ថែមលើភស្តុតាង និងឧក្រិដ្ឋជនសិប្បនិម្មិត្ត ដើម្បីដូរនឹងលកខ័ណ្ឌដែលជាគោលដៅរបស់យួនកុំមុយនីស និងគណៈបក្សប្រជាជនកម្ពុជាចង់បាន,,,,,,,,,,,,,,ពួកឧក្រដ្ឋករ ឃាតករ និងភេរវករ ដែលក្រុងហាណូយយល់ថាអស់តំលៃនៅក្នុងការប្រើបាស់ ឬបារម្ភខ្លាច បែករឿងអាថ៌កំបាំង និងពេលវេលាប្រធានសក្តិមកដល់ហើយនោះ គឺត្រូវតែកំទេចចោលជាចាំបាច់ និងជា បន្ទាន់ ។

គណៈបក្សប្រជាជនកម្ពុជាត្រូវតែសំរេចភ្លាមដោយគ្មានការយោគយល់ ឬរារែកអ្វីឡើយ គឺជីវិតពួក ឧក្រិដ្ឋករ ឃាតករ និងភេរវករ ប្រៀបដូចជាអាចម៏អណ្តែតលើទឹក មិនថាបុណ្យឋានៈធំតូចអ្វីឡើយ គឺ វាសនាដូចគ្នា គ្រាន់តែមុន ហើយនិងក្រោយតែប៉ុណ្ណោះ គឺខ្លះត្រូវបានសំលាប់ ខ្លះត្រូវបានជាប់គុកជាច្រើន ឆ្នាំរហូតដល់មួយជីវិតក៏មាន ដោយគ្រាន់តែពាក់ផ្លាកថាជាឃាតករ ភេរវករ ចោរប្លន់ ចោរចាប់ជំរិត ជាជនក្បត់ ទាក់ទងរណសិរ្ស ឬចលនារំដោះផ្សេងៗ ខ្លះទៀតត្រូវបានភៀសលាក់ខ្លួនក្លែងភេទដូរត្រគោល។ ដូចជា ករណីលោក ហេង-ពៅ លី-រ៉ាស៊ី យមរាជ,,,,,,,ដែលបេសកកម្មគ្រប់យ៉ាងរបស់ពួកគាត់គឺសុទ្ធតែធ្វើតាមការបញ្ជារបស់លោក ហុក-ឡង់ឌី ហ៊ុន-សែន និងថ្នាក់ដឹកនាំកំពូល៧របស់គណៈបក្សប្រជាជនកម្ពុជា ហើយទីបំផុតត្រូវបានជាប់គុកអស់ជាច្រើនឆ្នាំ ចំណែកលោក ហុក-ឡងឌី ដែលជាមេឃាតករ ភេរវករ មេចោរប្លន់ជំរិត និងជាមេបនស្រីបនល្បែង រកលុយអោយឃ្លាំងរដ្ឋយួនរាប់មិនអស់ បញ្ចូលជនជាតិយួនឱ្យហូរចូលស្រុកខ្មែររាប់ភ្លេច និងបានសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយរាប់មិនអស់មិនហើយ ទីបំផុតត្រូវបានសំលាប់បំបិទមាត់យ៉ាងអាណោចអធម សូម្បីតែសាកសព្វទាំងមូល ក៏មិនអាចរក្សាបានផង។ នៅអា ហ៊ុន-សែន មួយទៀត មិនដឹងថាក្រុងហាណូយសំលាប់បំបិទដោយរបៀបណា? របៀបផ្ទុះយន្តហោះក្រឡាប់ឡាន ផ្ទុះគ្រាប់បែក ឬមួយក៏ត្រូវសំលាប់ដោយរបៀបឃាតកម្មនយោបាយ?,,,,,,,,,បើរឿងចាប់កាត់ទោស ហ៊ុន-សែន គឺមិនអាចធ្វើបានឡើយ ព្រោះថា ឧក្រិដ្ឋកម្មរបស់ ហ៊ុន-សែន ស្តែងចេញអោយឃើញនៅការបញ្ជារបស់រដ្ឋាភិបាលយួនកំមុយនីស្ត៍ ជាក់ច្បាស់ជាង អំពើឧក្រិដ្ឋកម្មខ្មែរក្រហមដែលពាក់ព័ន្ធនឹងយួនកំមុយនីស្ត៍ ចុះបើបែកការ មិនវិវរធំដល់យួនកំមុយនីស្ត៍ទៅហើយ តែមិនអ៊ីទេ យួនឆ្លាតណាស់ បើសហគមន៏អន្តរជាតិ នឹងរកឃើញថា អំពើឧក្រិដ្ឋកម្មលើប្រជាជនខ្មែរដែលធ្វើឡើយដោយខ្មែរក្រហម និង ហ៊ុន-សែន គឺសុទ្ធតែជាបញ្ជារបស់រដ្ឋាភិបាលយួនកំមុយនីស្ត៍ គឺយួននឹងដូររដ្ឋាភិបាលមកជារបបសេរីនិយមភ្លាម ហើយចាប់ខ្មោចលោក ហូ-ជីមិញ មកកាត់ទោសដូចប៉ុល-ពត នោះ នឹងបោកយកលុយជំនួយរបស់សហគមន៏អន្តរជាតិបានរាប់មិនអស់ ដូចអា ហ៊ុន-សែន សំដែងល្ខោនបង្កើតសាលាក្តីតុលាការខ្មែរក្រហមអញ្ចឹង។ តើសហគមន៏អន្តរជាតិល្ងង់ ឬក៏ពួកគេទទួលផលប្រយោជន៏នៅពីខាងក្រោយភាពល្ងង់ខ្លៅរបស់ពួកគេ បែរជាមើលមិនឃើញអា ហ៊ុន-សែន ជាមេឧក្រិដ្ឋករ ជាមេឃាតករ ជាមេភេរវករ និងមើលមិនឃើញយួនកំមុយនីស្តនៅពីខាងក្រោយរបបក្រហម?

## ***៥-រចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា:***

បើគណៈបក្សប្រជាជនកម្ពុជាដាក់**បញ្ចូលនរណាម្នាក់ចូលក្នុងបញ្ជីស្បែកខ្មៅរបស់ពួកគេហើយ អ្នកនោះកំរររត់គេចខ្លួនរួចណាស់ ព្រោះថា គណៈបក្សប្រជាជនកម្ពុជា ជាពិសេសអា ហ៊ុន-សែន តែម្តងតែងតែប្រើគ្រប់មធ្យោបាយដើម្បីប្រមាញ់គោលដៅរបស់ខ្លួនអោយបាន ហើយក្នុងការសំលាប់គោលដៅនោះ** ពួកវាតែងតែបែងចែកជាជំហ៊ានៗទៅ តាមរចនាសម្ព័ន្ធឃាតកម្មដូចតទៅ:

**ដ្យាក្រាមនៃរចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា**




**-ជំហ៊ានទី១ គឺដំណាក់កាលបញ្ជាពីថ្នាក់លើ ពីហ៊ុន-សែន ប៊ុន-រ៉ានី ហុក-ឡង់ឌី:** ពាក្យស្លោកកុំមុយនីស្តបានពោលថា ***រាល់គ្រប់បញ្ជា គ្រប់ទង្វើរ និងរាល់គ្រប់ការសំរេចរបស់ថ្នាក់លើ គឺសុទ្ធតែជាការត្រឹមត្រូវទាំងអស់ ថ្នាក់ក្រោមមិនចាំបាច់ចង់ដឹងពីមូលហេតុអ្វីឡើយ ហើយក៏មិនត្រូវវារែកស្ទាក់ស្ទើរក្នុងការអនុវត្តបញ្ជាឡើយ អ្នកដែលមិនធ្វើតាម មិនអនុវត្តតាមបញ្ជាថ្នាក់លើគឺមានន័យថាជាខ្មាំង បើជាខ្មាំងគឺត្រូវតែកំទេចចោល***។ នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៦ អា ហ៊ុន-សែន បាននិយាយក្នុងពិធីថ្លែងសន្ទរកថា នៅខេត្តកំពង់ធំថា "***ផោមក្នុងទឹក ក៏វាដឹងដែរ គ្មានអ្វីលាក់វាជិតទេ*** " ដូច្នេះគ្មានអ្វីគួរឱ្យឆ្ងល់ទេ នៅរាល់គ្រប់អំពើឃាតកម្មនយោបាយ ភេរវកម្មបោកគ្រាប់បែកលើហ្វូងបាតុករនៅមុខរដ្ឋសភាថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ អំពើមនុស្សឃាតផ្សេងៗ ការឆក់ប្លន់ជីវិត ការស្លាប់ដោយសារពេទ្យពិឃាត ការស្លាប់ដោយគ្រោះថ្នាក់ចរាចរ ការស្លាប់ដោយឧប្បត្តិហេតុផ្សេងៗរបស់ពួកអ្នកនយោបាយប្រឆាំង និងពួកអ្នកគាំទ្រនយោបាយប្រឆាំង គឺសុទ្ធតែជាការរៀបចំ បង្កើតឡើងដោយគណៈបក្សប្រជាជនទាំងអស់ រួមទាំងការរកស៊ីជួញដូរមនុស្ស ជួញដូរគ្រឿងញៀន ឃាតករស៊ីឈ្នួល អំពើពុករលួយជាដើម,,,,,,, គឺសុទ្ធជាទង្វើររបស់គណៈបក្សប្រជាជនកម្ពុជា ជាអ្នកធ្វើទាំងអស់ បើពួកវាជាអ្នកធ្វើ តើពួកវាអាចបញ្ជាអោយតុលាការរបស់ពួកវាចាប់ផ្តន្ទាទោសដែរឬ? សូម្បីតែកុំមុយនីស្តគ្នាវាក៏ដោយ អោយតែមិនស្តាប់បញ្ជារប់សថ្នាក់លើ ត្រូវបានថ្នាក់

លើចាត់ទុកជាខ្មាំង ហើយត្រូវតែកំទេចចោលជាដាច់ខាត ដូចជាករណីលោក ហេង-ពៅ គ្រាន់តែមិនបាន អនុវត្តន៍តាមបញ្ជារបស់លោក ហុក-ឡង់ឌី ត្រូវបានដកហូតចេញពីតំណែងខ្ពង់ ហើយទីបំផុតដកបុណ្យសក្តិ ចាប់ដាក់គុក កាត់ទោសអោយនៅក្នុងគុកជិត ១០០ ឆ្នាំ ចុះល្មមតែពួកប្រឆាំងដែលមិនមែនជាគ្នា របស់ពួកវា តើទៅយ៉ាងណា? សូមមើលអាស័យដ្ឋានអ៊ីនធឺនិតខាងក្រោមនេះ

http://www.youtube.com/watch?v=DmDPWrMCn48&feature=related

http://hengpov.wordpress.com/

http://www.garella.com/rich/grenpost.htm

http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html

http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

**-ជំហ៊ានទី២ គឺជំណាក់កាលតាមដានស៊ើបការយកពត៌មាន:** នៅពេលដែលថ្នាក់លើ (ហ៊ុន-សែន ប៊ុន-រ៉ានី ហុក-ឡង់ឌី,........,) របស់គណះបក្សប្រជាជនកម្ពុជា ដាក់បញ្ជាហើយ ក្រសួងស្ថាប័នពាក់ព័ន្ធនឹងកងកំលាំង ប្រដាប់អាវុធតែងតែប្រើពួកចារកម្មដែលមាន៥ គឺ ចារបុរស្សមនុស្សរស់ ប្រតិចារបុរស ចារបុរសមនុស្សក្នុង ចារបុរសរនុកក្នុង មរណះចារបុរស នៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់ពួកគេដែលបំពាក់ទៅដោយ ឧបករណ៏អាសន្យាណូទំនើប (Spy Bugs) ដែលជាឧបករណ៏តាមដានទំហំតូចៗអាចមានដល់តូចជាងឡេវ អាវ ឬប៊ិនចុងជើងធូប ឬជាសរសៃលោហះដូចខ្សែរសយ were equipped by the modern spy bugs tools and modern spies bugs cameras, electric spies bugs, ipads and cell phone spies bugs, spies bugs tools such shirt bottom, pen, glasses, bag, lighter, cigarette box, and small spies bugs tools bigger than point of needle.....etc.,..... សំរាប់បង្កប់តាមបន្ទប់ផ្ទះ ឡាន គ្រឿងឧបករណ៏ ប្រើប្រាស់ ក្នុងកញ្ចប់បារី មួក ប៊ិច ឬក៏បង្កប់ក្នុងទីអាថ៌កំបាំងដែលស្មានមិនដល់ ហើយពួកអ្នកតាមដានគឺ គ្រាន់តែមើលតាមអេក្រង់កំព្យូទ័រ ពីចំងាយ គឺអាចឃើញរូបភាព និងស្តាប់សំលេងបានយ៉ាងច្បាស់ សូមមើល ($Source^{Special}$) ដើម្បី តាមដានរាល់ទង្វើរសកម្មភាពទាំងក្នុងផ្ទះ ទាំងក្រៅផ្ទះ របស់មនុស្សដែលជា គោលដៅប្រមាញ់ពិសេសរបស់ គណះបក្សប្រជាជនកម្ពុជា ដោយមានឧបករណ៏ទំនើប ធម្មតាជាជំនួយ បន្ថែមដូចជាទូរស័ព្ទ វិទ្យុទាក់ទង (Walkie-Talkie) យានជំនិះ កាំភ្លើងខ្លី គ្រាប់បែកដៃ លុយកាក់ ស្បៀងអាហារ ឧបករណ៏ប្រើប្រាស់

ផ្សេងៗ បើចាំបាច់ត្រូវតែសំលាប់គោលដៅមុនការបញ្ជាឱ្យឃាតករមក សំលាប់ ។












## ដ្យាក្រាមនៃរចនាសម្ព័ន្ធចារកម្មរបស់គណៈបក្សប្រជាជនកម្ពុជា




ពួកចារកម្មអស់ទាំងនេះចែកចេញជា ៣ ក្រុមទៀតគឺ សំរាប់ផ្លាស់ប្តូរគ្នា សង្កេតឃ្លាំមើលតាមដាន ហើយ

បើសិនជាទាក់ទងនឹងអ្នកនយោបាយប្រឆាំងសំខាន់ៗ ពួកចារកម្មទាំង ៣ ក្រុមនេះ ដើរតួជាឃាតករសំលាប់គ្នាទៅវិញទៅមកគឺ ក្រុមទី២សំលាប់ក្រុមទី១ ក្រុមទី៣សំលាប់ក្រុមទី២ ហើយ អង្គរក្សអាវខ្មៅ ឬក្រុមដ៏ទៃទៀតសំលាប់ក្រុមទី៣។ លើសពីនេះទៅទៀតនោះ គឺ ហ៊ុន-សែន តែងតែចូលចិត្តប្រើប្រាស់ពួកក្រុមក្មេងស្ទាវ និង ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ អោយតាមដានមនុស្សដែលជាគោលដៅប្រមាញ់បន្ថែមលើពួកចារកម្មរបស់កងកំលាំងប្រដាប់អាវុធ ព្រោះ ហ៊ុន-សែន មិនចេះទុកចិត្តនរណាឡើយ ដោយសារតែវាជាមនុស្សជំនិតរបស់លោកប៉ែន-សុវណ្ណ ហើយក្បត់លោកដើម្បីប្តូរនឹងអំណាចដែលយួនផ្តល់អោយ ហើយវាតែងតែធ្លាប់បានថ្លែងសន្ទរកថាជាសាធារណៈថា "**ប្រយ័ត្ន! អាអោនណាស់ គឺគ្រោះថ្នាក់ណាស់! មានតែបន្លាដែលនៅជិតជើងទេ ដែលធ្វើអោយមុតជើង! អាជិតកៀកណាស់ គឺគ្រោះថ្នាក់ណាស់!** "។ មូលហេតុដែល ហ៊ុន-សែន ចូលចិត្តប្រើប្រាស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ព្រោះពួកនេះលាក់ការណ៍បានល្អ ដោយសារតែបណ្តាញប្រព័ន្ធពួកគេស្មុគស្មាញស្មានមិនដល់ គឺហ៊ុន-សែន គ្រាន់តែបញ្ជូទៅលោក ជា-សុផារ៉ា និងលោក កែន-ចំរើន ពេលនោះលោក កែន-ចំរើន បានបញ្ជូទៅ**ពួកមេក្រុមបតូចបងធំ "លោកបងធំៗ**" ដែល**មានឋានៈ**គ្រាន់តែជា**សមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ** តែប៉ុណ្ណេះ ហើយពួកមេក្រុមបងតូចបងធំ "លោកបងធំៗ" បានបញ្ជូទៅកាន់កូនចៅរបស់ខ្លួន ពួកមនុស្សដែលស្ថិតនៅក្នុងក្រុមបងតូចបងធំរបស់ខ្លួន (ដែលពួកគេមិនដែលដឹងសោះថា តើអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជាអ្វីឡើយ) អោយតាមដាន សង្កេតឃ្លាំមើល មនុស្សដែលបងធំស្អប់ ដែលមានបញ្ហាជាមួយលោកបងធំរបស់ពួកគេ បើអ្នកណាធ្វើបានជោគជ័យ អ្នកនោះនឹងទទួលការកោតសរសើរលើកទឹកចិត្តមានមុខមានមាត់ជាងគេនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ថែមទាំងមាន**ឱកាសរកលុយពិសេស**ច្រើនជាងគេនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ហើយបើមានបញ្ហាវិញនោះ លោកបងធំរបស់ពួកគេនឹងចេញមុខជួយ ឬចេញមុខកាងជំនួស ដូច្នេះហើយបានជាពួកក្រុមក្មេងស្ទាវ ពួកក្រុមក្មេងអាណាថា និងពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ប្រឹងប្រែងតាមដានរាល់សកម្មភាពមនុស្សដែលជាគោលដៅប្រមាញ់ ម្យ៉ាងវិញទៀតគឺ ហ៊ុន-សែន មិនចាំបាច់ធ្វើការចំណាយលុយកាក់អ្វីទេ គឺ ហ៊ុន-សែន គ្រាន់តែផ្តល់ **ឱកាសរកលុយពិសេស** ដល់ពួកក្រុមក្មេងស្ទាវ ក្រុមពួកក្មេងអាណាថា និងពួកក្រុមបងតូចបងធំនៃអង្គការ ឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជាការស្រេច។

**-ជំហ៊ានទី៣ គឺដំណាក់កាលសំលាប់ពិឃាត :** គណៈបក្សប្រជាជនកម្ពុជា មានប្រភពដើមកំណើតចេញមកពីយួនកុំមុយនីស្ត៍ដែលជាអ្នកបង្កើត និងបន្ទុបពួកគេឱ្យស្ថិតនៅលើបល្ល័ង្គអំណាចដែលសោយអំណាចរហូតដល់បច្ចុប្បន្ននេះ ហើយយកព្រះមហាក្សត្រធ្វើជាទ្រនាប់ជើងរបស់ពួកគេដើម្បីឈរលើអំណាចទាត់ធាក់វាយប្រហារសំលាប់ប្រជារាស្ត្រខ្មែរស្រេចតែក្បាលចិត្តដោយគ្រាន់តែយកលេសថាអនុវត្តតាមព្រះហត្ថលេខារបស់ព្រះមហាក្សត្រ ឬធ្វើតាមព្រះរាជត៏រិះព្រះមហាក្សត្រតែប៉ុណ្ណោះ។ ទោះបីជាពួកថ្នាក់ដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជាចេញប្រភពមកពីពួកចោរលួចចោរប្លន់ក្មេងពាលក្មេងអាណាថា មិនបានរៀនសូត្រជ្រៅជ្រះក៏ដោយ ប៉ុន្តែពួកគេបានទទួលការហ្វឹកហាត់សិល្បះសង្រ្គាមបែបកុំមុយនីស្ត៍ពីចៅហ្វាយយួនរបស់ពួកគេ ហើយពួកគេមានជំនាញប៉ិនប្រសព្វណាស់ចំពោះខាងរឿងសំលាប់ឃាតកម្ម ការធ្វើភេរវកម្ម ការគំរៀមកំហែងការបំបាក់ស្មារតីប្រជារាស្ត្រខ្មែរអោយភ័យរន្ធត់ខ្លាចបាក់ស្បាត ការប្រើឃាតករក្នុងបណ្តាញខ្សែសង្វាក់ចុចអន្ទាក់គឺជាជំនាញរបស់ពួកគេនៅក្នុងការក្តោបអំណាច ហើយ **ចំណុចខ្លាំងរបស់ពួកកុំមុយនីស្ត៍គឺ ប្រើប្រាស់ឃាតកម្ម ទារុណកម្ម និងភេរវកម្មដែលប្រើជាឧបករណ៍តែមួយគត់សំរាប់គ្រប់គ្រងប្រទេស និងត្រួតត្រាក្តោបក្តាប់ប្រជាជនខ្មែរយ៉ាងណែននៅក្នុងដៃ** ហើយ **ចំណុចខ្សោយរបស់ពួកកុំមុយនីស្តគឺសេដ្ឋកិច្ច តែបើពួកវាមានសេដ្ឋកិច្ចហើយគឺប្រៀបបីដូចជាសត្វខាដុះស្លាប ធ្វើអ្វីក៏បាន**។ ទោះបីជាពួកថ្នាក់ដឹកនាំកុំមុយនីស្ត៍កំពូលៗរបស់គណៈបក្សប្រជាជនកម្ពុជាសំលាប់ប្រជារាស្ត្រខ្មែររាប់មិនអស់ក៏ដោយ ក៏ពួកគេប៉ិនប្រសព្វធ្វើអោយពិភពខាងក្រៅដូចជាសហគមន៏អន្តរជាតិ មហាអំណាចពិភពសេរីមានសហរដ្ឋជាមេខ្លោងជាដើមនៅតែមិនដឹងខ្យល់អ្វី ហើយថែមទាំងចូលរួមប្រល័យប្រជារាស្ត្រខ្មែរតាមរយៈលុយជំនួយ និងលុយកម្ចីបរទេសរបស់ពួកគេ ផ្តល់អោយដល់រដ្ឋាភិបាលភេរវករខ្មែរ **ព្រោះថាលុយជំនួយ លុយកម្ចីបរទេសដែលរដ្ឋាភិបាលភេរវករខ្មែរ ទទួលបានពីសហគមន៏អន្តរជាតិ អង្គការអន្តរជាតិ ប្រទេសមហាអំណាចនានារដ្ឋាភិបាលភេរវករខ្មែរបានយកលុយទាំងនោះទៅបង្កើតអង្គការឧក្រិដ្ឋជនសំងាត់មួយហើយមួយទៀតហើយយកលុយទាំងនេះទៅលើកទឹកចិត្តឃាតករ ទិញទឹកចិត្តឃាតករសំលាប់ឃាតករបំបិទភស្តុតាង ទិញទឹកចិត្តប្រជាជនអោយជួយសំរួលដល់ដំណើរការឧក្រិដ្ឋកម្មតាមរយៈទិញពត៏មាន និងជួលទីតាំងឱ្យពួកក្រុមឃាតករប្រព្រឹត្តិបទឧក្រិដ្ឋបានឆាប់រហ័ស ទិញទឹកចិត្តមនុស្សធម្មតាឱ្យជួយតាមដានស៊ើបអង្កេតអោយពួកវាទិញអាវុធទំនើបៗ ទិញឧបករណ៍ប្រើប្រាស់ទំនើបៗក្នុងការសំរួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋផេង្សៗ និងអំពើឃាតកម្មរបស់ខ្លួនដូចជា ទូរស័ព្ទ វិទ្យុទាក់ទង កំព្យូទ័រ យានជំនិះគ្រប់ប្រភេទ ជួលផ្ទះសំណាក់ទីអាស្រ័យ**

**និងទិញឧបករណ៍ចារកម្មអាសន្នឡាណូទំនើប** (modern spy bugs' tools) ដើម្បីសំរួលដល់ការតាមដានស៊ើបការណ៍ ការប្លន់ជីវិត ការចាប់ចង ការសំលាប់ ការធ្វើឃាតកម្មនយោបាយ ការធ្វើភេរវកម្មជាដើម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស, ,,,,,,,, ។ល។ និង ។ល។

through foreign aid and foreign loan to increase their secret criminal organizations and terrorists, because **these money from foreign aid and foreign loan that western superpowers, United Nations or US… gave Cambodian Royal Government (same to give the terrorists government), CPP's top leaders and Hun Sen take these money to :**

-built many secret criminal organizations such Backy, S.O.Y, Black Shirt….etc.

-to buy the killers, criminals and terrorists help them kill Khmer people ,

-to destroy all the evidences of CPP's crimes and kill the true witnesses as well as invent the new evidences and false witnesses.

-to kill the killers, witnesses, criminals and terrorists for keeping the secret crimes of CPP's top leaders and Hun Sen forever,

-buy the informations from simple people and rent people to follow, spy scout the target people or hunted people and facilitate the process of CPP's crimes or report the important informations to them.

-to buy the modern spies bugs tools, modern electronic spies bugs, spies cameras, ipads, cell phones, walkie-talkie, vehicles, rent the house, buy the foods, as well as buy the informations, ……etc.,

ចំពោះជំហ៊ានទី៣នេះ គឺដំណាក់កាល នៃការសំលាប់ ពួកមេដឹកនាំគណៈបក្សប្រជាជនប៊ិនប្រសព្វនិងពូកែខ្លាំងណាស់ក្នុងរឿងនេះ ជាពិសេស គឺ មេឃាតករញីឈ្មោល ហ៊ុន-សែន ប៊ុន-រ៉ានី ហុក-ឡង់ឌី ហេង-ពៅ ម៉ក់ជីតូ,,,,,, បន្ទាប់ពីពួកគេបានទទួលបញ្ជាហើយ ការតាមដានស៊ើបអង្កេតកំពុងតែដំណើរការនោះ ពួកឃាតករ ពួកកងកំលាំងប្រដាប់ អាវុធ ពួកកងអង្គរក្ស ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ អង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ សុទ្ធតែស្ថិតនៅក្នុងការត្រៀមលក្ខណៈរងចាំថ្នាក់លើបញ្ជាអោយសំលាប់គោលដៅយ៉ាងរីករាយ និងភ័យខ្លាចផងដែរ។ ចំពោះឃាតករញីឈ្មោល ហ៊ុន-សែន ប៊ុន-រ៉ានី វិញ នៅពេលដែលពួកគេបញ្ជាអោយសំលាប់ប្រហារមនុស្ស ដែលជាគោលដៅប្រមាញ់នោះ ពួកគេមិនចេះប្រើឃាតករតែមួយក្រុមនោះទេ ពួកគេតែងតែប្រើយ៉ាង ហោចណាស់ក៏ មាន ២ក្រុម ទៅ ៣ក្រុមឡើងទៅ ដូចជាករណីសំលាប់លោកឧត្តមសេនីយជាថៅកែឈើម្នាក់ នៅក្រុងកំពង់សោមដែលក្បត់បញ្ជារបស់ ហ៊ុន-សែន លួចឈើ

ទៅលក់អោយថៃ។ ក្នុងការរៀបផែនការ សំលាប់នេះ គឺ ហ៊ុន-សែន បានបញ្ជូនក្រុមទី១ទៅគឺមេដឹកនាំអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ឈ្មោះ កែន-ចំរើន អោយឈ្លបចូលផ្ទះវិឡាលោកឧត្តមសេនីយសំលាប់អង្គរក្សលោកឧត្តមសេនីយអស់១២នាក់ និងរងចាំនៅបន្ទប់លោកឧត្តមសេនីយដែលកំពុងរួមស្នេហ៍លើគ្រែជាមួយស្រីកំណាន់វ័យក្មេងរបស់គាត់ តែ លោក កែន-ចំរើន មិនទាន់បាញ់សំលាប់ទេ រងចាំបញ្ជាផ្ទាក់លើ បន្ទាប់មកក្រុមឃាតករទី២មកដល់ដែលមានលោក មុំ-សុផាន់ ជាអង្គរក្សរបស់ ប៊ុន-រ៉ានី បានហក់ផ្លោះចូលរបងផ្ទះវិឡារបស់លោកឧត្តមសេនីយ ហើយចូលទៅកាន់បន្ទប់ផ្ទុំលោកឧត្តមសេនីយដែលកំពុងរួមស្នេហ៍ បន្ទាប់មកក៏មានបញ្ជាតាមកាសស្តាប់ត្រចៀក ពីផ្ទាក់លើ ហ៊ុន-សែន ថា អាហ្អែង ម៉េចក៏មិនបាញ់ទៅ ស្រាប់តែពេលនោះគ្រាប់កាំភ្លើងរបស់ លោក កែន-ចំរើន បាញ់បានមុន ធ្វើឱ្យលោកឧត្តមសេនីយស្លាប់ទៅហើយ លោក មុំ-សុផាន់ ក៏បាញ់បន្ថែម ហើយបន្ទាប់មកពួកឃាតករក្រុមទី៣ គឺជាអង្គរក្សរបស់ ហ៊ុន-សែន ចំនួន ៥ ឡានមកដល់ រងចាំប្រហារជាស្រេច តែដោយសារកិច្ចការចប់សព្វគ្រប់ ពួកគេក៏ទៅផឹកស៊ីដុតគោរនៅលើភ្នំស៊ីតតេយ៉ាងសប្បាយទៅតាម ក្រុមរបស់ពួកគេរៀងៗខ្លួន។ ករណីសំលាប់លោក ឱម-រដ្ឋសាឌី ដែលជាតំណាងរាស្ត្រម្នាក់ និងជាទីប្រឹក្សា ផ្ទាល់របស់សម្តេចក្រុមព្រះនរោតម រណឫទ្ធិ គឺ ហ៊ុន-សែន បានបញ្ជូនអោយក្រុម មុំ-សុផាន់ មុំ-ណារី អោយទៅធ្វើឃាតលោក ឱម-រដ្ឋសាឌី នៅពេលដែលក្រុមឃាតករទៅដល់នោះ លោក មុំ-សុផាន់ ក៏យកកាំភ្លើងខ្លីផ្ទុងលោក ឱម-រដ្ឋសាឌី បំរុងនឹងបាញ់ ស្រាប់តែមានគ្រាប់កាំភ្លើងបាញ់លោក ឱម-រដ្ឋសាឌី បានមុនទៅហើយ ពេលនោះលោក មុំ-សុផាន់ ក៏បាញ់លោកឱម-រដ្ឋសាឌី បន្ថែមតែម្តង ហើយក៏គេចខ្លួនទៅ តែត្រូវបានប៉ូលីសអន្តរជាតិចាប់បាននៅពេលក្រោយមក។

**-ជំហ៊ានទី៤ គឺជំណាក់កាលលាងសំអាតភស្តុតាងបទឧក្រិដ្ឋ :**



ឯកឧត្តម **ស-ខេង** ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានតួនាទីជួយសំរួល លាក់បាំង បង្វែងដាន លាងសំអាត រាល់បទឧក្រិដ្ឋភេរវកម្ម ឃាតកម្ម ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស លួចឆក់ប្លន់ ជីវិត របស់គណៈបក្សប្រជាជនកម្ពុជា និងជួយការពារ លាក់បាំងរាល់ការសំលាប់ឃាតកម្មរបស់គណៈបក្សប្រជាជន។



លោក ហេង-ពៅ ជាអគ្គស្នងការនគរបាលរាជធានីភ្នំពេញ មានតួនាទីជួយសំរួល លាក់បាំង បង្វែងដានប្រឌិតរឿង លាងសំអាតបទល្មើសឧក្រិដ្ឋលួច ឆក់ ប្លន់ជីវិត ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ឃាតកម្មភេរវកម្មរបស់គណៈបក្សប្រជាជនកម្ពុជា និង ជួយរកលុយផ្តល់ដល់ឃាតកររបស់ ហ៊ុន-សែន ហុក-ឡង់ឌី

បន្ទាប់មកក្រុមកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលស៊្អីគេនោះចុះមកធ្វើអន្តរាគមន៏ តែតាមការពិតគ្រាន់តែចុះមកមើលស្ថានភាពជាក់ស្តែង ដើម្បីឱ្យដឹងច្បាស់ថាតើមនុស្សដែលជាគោលដៅប្រមាញ់នោះ ស្លាប់ដាច់ខ្យល់ លែងដកដង្ហើមហើយឬនៅ? បើសិនជានៅមិនទាន់ស្លាប់ទេនោះ ពួកក្រុមកងកំលាំងប្រដាប់អាវុធនឹងបង្ហើយធ្វើឱ្យស្លាប់តាមគ្រប់មធ្យោបាយផ្សេងៗ ដូចជាពន្យាពេលដោយគ្រាន់តែ ប្រើលេសស៊ើបអង្កេត ប្រើលេសធ្វើរបាយការណ៏កំណត់ហេតុ ប្រើលេសអោយសញ្ញាពាក្យសំងាត់ទៅឡានពេទ្យឱ្យមកយឺតយូរ ឬពួកគេសំលាប់ចោលនៅកន្លែងកើតហេតុ នៅលើឡានពេទ្យ ឬទុកឱ្យដល់ពេទ្យ ហើយអោយពួកពេទ្យពិឃាតមកចាក់ថ្នាំសំលាប់តែម្តង។ ក្នុងការលាងសំអាតបទឧក្រិដ្ឋទាំងឡាយនោះគឺ មានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឈ្មោះលោក ស-ខេង អគ្គស្នងការនគរបាលជាតិផ្កាយមាស ៤ ឈ្មោះលោក ហុក-ឡង់ឌី (បច្ចុប្បន្នត្រូវបានជំនួសដោយលោក នេត្រ-សាវឿន ជាក្មួយប្រសារ ហ៊ុន-សែន) និង អគ្គស្នងការនគរបាលជាតិឈ្មោះលោក ហេង-ពៅ ( បច្ចុប្បន្នត្រូវបានជំនួសដោយលោក ទូច-ណារត្ន័)។ ពួកអស់ទាំងនេះមិនត្រឹមតែមានតួបំបាត់ភស្តុតាង ឃុបឃិតប្រព្រឹត្តិបទឧក្រិដ្ឋគ្រប់យ៉ាង លុបស្លាកស្នាមដានតំរុយបទឧក្រិដ្ឋគំរៀមសាក្សី សំលាប់សាក្សី សំលាប់ឧក្រិដ្ឋជនបំបិទភស្តុតាង ប្រឌិតបទល្មើសបន្ថែម វត្ថុតាងសាក្សីប្រឌិតជនឧក្រិដ្ឋភស្តុតាងសាក្សីភ្ជាប់ជាមួយបទល្មើសឧក្រិដ្ឋ លាក់បាំងបទឧក្រិដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជ្រោងជ្រែង ជួយសំរួលដំណើរការបទឧក្រិដ្ឋ និងបានផ្តល់រង្វាន់ដល់ពួកឃាតករ និងពួក ភេរវករទៀតផង។ ដូចជាករណីនៅឆ្នាំ ១៩៩៧ លោក ហេង-ពៅ នៅជាមួយពួកមេភេរវករ ហ៊ុន-សែន និង ហុក-ឡង់ឌី ដែលពួកគេបានកំពុងពិភាក្សាគ្នាអំពីវិធីកំចាត់ពួកបាតុករបក្សប្រឆាំង ពេលនោះ លោក ហុក-ឡង់ឌី បាននិយាយទៅ កាន់ ហ៊ុន-សែន ថា "ម៉េចក៏មិនប្រើគ្រាប់បែកដៃវាយប្រហារទៅ? "ពេលនោះ ហ៊ុន-សែន ឆ្លើយតបវិញថា "វាជាគំនិតល្អមួយដែរ,,,,,ខ្ញុំអាចបញ្ជូនលោក សិដ្ឋ ទៅធ្វើរឿងនេះ ព្រោះគាត់ ពូកែខាងហ្នឹង

ណាស់ ” ហើយ ហ៊ុន-សែន បានបញ្ជាអោយលោក ហុក-ឡង់ឌី អោយផ្តល់លុយដល់ លោក ហុយ-ពិសិដ្ឋ ធ្វើការងារនោះ ”។ លោក ហុក-ឡង់ឌី ក៏បានបញ្ជាទៅលោក ហេង-ពៅ អោយរកលុយ ១០០០០០ ដុល្លា សហរដ្ឋអាមេរិកផ្តល់អោយ លោក ហុយ-ពិសិដ្ឋ។ លុយនោះបានមកពីការិយាល័យប៉ូលីស គ្រឿងញៀន (Hoc Lundy said to Hun Sen, ' why don't you use hand grenades.' Hun Sen said that it was a good idea... "I can send Seth to do it and he is a good operator." He authorized Hoc Lundy to pay for Huy PiSeth to do the job. Hoc Lundy answered that he would put together the money to pay them. He suggested that I met with Seth. After that, Hoc Lundy ordered me to find the money (US$ 100000) to give to Huy Piseth. The money came from the police.) ។ នៅឆ្នាំ ១៩៩៧ នោះដដែល លោក ហូ-សុខ បានបញ្ជាអោយលោក ហេង-ពៅ ចាប់លោក ម៉ុង-ឬទ្ធី បន្ទាប់ចាប់រឹបអូសកញ្ឆា ៧ តោនជារបស់ក្រុមហ៊ុន-ម៉ុងឬទ្ធី នៅព្រំដែន កំពង់ផែសីហនុវិល ដែលត្រូវបាន ដាក់ក្នុងកប៉ាល់រួចស្រេចបំរុងនាំចេញទៅកាន់ប្រទេសន័រវេ ប៉ុន្តែ ហ៊ុន-សែន កាងមិនអោយចាប់ ហើយលោក ហេង-ពៅ ស្តាប់តាមបញ្ជារបស់ ហ៊ុន-សែន មិនចាប់លោក ម៉ុង-រិទ្ធី។ លោក ម៉ុង-រិទ្ធី បានឱ្យឡានមួយម៉ាក (1997 Landcruiser Toyota) ដល់លោក ហេង-ពៅ និង ផ្តល់ឡានជជុះម៉ាក Hilux ដល់ការិយាល័យលោក ហេង-ពៅ ហើយ ហ៊ុន-សែន បានបញ្ជាអោយចាប់ លោក ឆាយ-សុខុម ពាក់ផ្លាកទទួលទោសជំនួស លោក ម៉ុង-រិទ្ធី (I seized seven tons of marihuana belonging to Mon Rati's company. Mon Rati was a close friend of Hun Sen. The marihuana was hidden away in two containers and were ready to be shipped to Norway. The seizure occurred at a border port of Siha Nauk Vill, after the seizure, Mr. Ho Sok, I was afraid of Hun Sen and he was too powerful. I had no option but to obey. I accepted the car from Mon Rati. It was a 1997 Landcruiser Toyota. My office was given a second hand Hilux for use. it has a logo of Mon Rati's on it. Hun Sen subsequently ordered me to go and arrest another person Chai Sok Kom instead as a scapegoat. Chai worked in the military police belonging to Funcinpec Party) ។ បន្ទាប់ពីសំលាប់លោក ហូ-សុខ នៅខែកក្កដា ឆ្នាំ ១៩៩៧ រួចហើយ លោក ហុក-ឡង់ឌី បានបញ្ជាអោយលោក ហេង-ពៅ ផ្តល់ឡានឱ្យលោក ប៊ុន-ណា ជារង្វាន់ក្នុងការសំលាប់លោក ហូ-សុខ ។ លោក ហេង-ពៅ បានធ្វើតាមបញ្ជារបស់លោក ហុក-ឡង់ឌី ហើយបានផ្តល់ឡានម៉ាក a Camry 97 ដល់លោក ប៊ុន-ណា (I knew the two of them and they were Keov Vichet and Bon Na . They shot Ho Sok outside Ma Seun's office. I questioned them as to the killing. Bon Na replied that Hoc Lundy sent them to kill Ho Sok then and there. Hoc Lundy did not like Ho Sok. I was shocked and rang Hoc Lundy who said that if Ho Sok was alive he would create a lot of trouble for us. He asked me to give Bon Na a car from the police vehicle pool as his reward. I did what I was told and gave Bon Na a Camry 97) ។ សូមអានវិបសាយខាងក្រោមនេះ

http://hengpov.wordpress.com/

http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

នៅខែវិច្ឆិការ និងខែធ្នូ ឆ្នាំ ២០០៦ ខ្ញុំបានពិភាក្សាជាមួយលោក អ៊ុ-សំខេង ហៅ គង់-សុផល (អតីតជាព្រឹទ្ធបាលទោ នៅក្រសួងមហាផ្ទៃ) នៅអាគារអា នៃគុកព្រៃស ហើយលោក គង់-សុផល បានរៀបរាប់ប្រាប់ខ្ញុំបណ្តើរ ទំាងក្អកចេញឈាមតាមមាត់បណ្តើរថា "លោកត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៦ យកទៅធ្វើទារុណកម្មនៅប៉េអឹមផ្ទៃប្រទេសរហូតដល់ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០៦ ដោយវាយដុំ យកស្បោងប្លាស្ទិកគ្របក្បាលជ្រមុជទឹក យកដំបងឆក់មកឆក់ដល់សន្លប់ វាយទាត់ធាក់អុកជង្គង់ ពេលគាត់សន្លប់បាត់ស្មារតី ពួកគេយកទឹកមកចាក់ដាក់ក្បាលគាត់ ពេលគាត់ដឹងខ្លួន ពួកបន្តវាយឆក់រហូតដល់សន្លប់ម្តងហើយម្តងទៀត ដោយគ្មានសួរចំលើយអ្វីទាំងអស់ វាយទាត់ធាក់ឆក់ជ្រមុជទឹករហូតដល់ម៉ោងជាង ១២ យប់ជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃដែលពួកគេយកកាម៉ារ៉ាវីដេអូមកថតរូបភាពវីដូរគាត់ ហើយពួកគេតំរូវអោយគាត់និយាយថា ស្គាល់លោកយមរាជ (ហង្ស វុទ្ធី) ហើយបានបាញ់លោក សុខ-សេដ្ឋាមុន្នី និងថាលោក ហេង-ពៅ ជាអ្នកបញ្ជូអោយពួកគាត់ធ្វើ ហើយបន្ទាប់ថតខ្សែអាត់វីដេអូរួចរាល់ហើយ ពួកប៉េអ៊ឹមផ្ទៃប្រទេស បានបញ្ជូនលោក គង់-សុផល មកគុកព្រៃសនាថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០៦ ហើយនៅក្នុងខែកុម្ភៈ ២០០៦ ដដែល លោក គង់-សុផល ត្រូវបានញូនចេញពីគុកព្រៃស ទៅធ្វើទារុណកម្មម្តងទៀតរយៈពេល ២យប់ ៣ថ្ងៃ នៅប៉េអឹមផ្ទៃប្រទេស រហូតដល់គាត់ក៏អង្វរពួកគេថា ពួកបងចង់អោយខ្ញុំឆ្លើយយ៉ាងម៉េចក៏បាន សូមមេត្តាឈប់ធ្វើទារុណកម្មខ្ញុំទៅ! ពួកប៉េអឹមផ្ទៃប្រទេសតបវិញថា រូបភាពវីដេអូរដែលហ្អែងឆ្លើយនោះគឺថតមិនទំនង មានការខុសឆ្គង ហ្អែងត្រូវនិយាយអោយពួកអញថតម្តងទៀត!"។ ពេលនោះ ខ្ញុំក៏បានសួរលោក គង់-សុផល បន្ថែមទៀតថា "ហេតុអ្វី ក៏ពួកគេចាំបាច់ធ្វើបាបបងបែបហ្នឹង? ពីមុនធ្លាប់មានរឿងអ្វីឬ? លោក គង់-សុផល បានបញ្ជាក់ប្រាប់ខ្ញុំថា "លោកធ្លាប់បានធ្វើរបាយកាណ៏អោយលោក ស-ខេង ស្តីអំពីឃាតកម្មលើរូបកូនប្រុសលោក សៃ-កែវ (ជាព្រឹទ្ធសភា) នៅថ្ងៃទី ១ ខែតុលា ឆ្នាំ ១៩៩៥ នៅមុខសាលាគុយបា គឺលោក ម៉ក់-ជីតូ លោក សុខ-ខេមរិន និងលោក សុង-លី បានចាប់កូនប្រុសរបស់លោក សៃ-កែវ យកមកបាញ់ចោលនៅមុខសាលាគុយបា ដោយសារទំនាស់ដណ្តើមស្រីគ្នា ។ លោក គង់-សុផល បាននិយាយប្រាប់លោក ស-ខេង ហើយលោក ស-ខេង ក៏បានបញ្ជូអោយគាត់ធ្វើរបាយការណ៏អោយលោក"។

**-ជំហ៊ានទី៥ គឺដំណាក់កាលពេទ្យពិឃាតសំលាប់បង្ហើយ និងប្រឌិតមូលហេតុនៃការស្លាប់ៈ**

ចាប់ពីយួនឈ្លានពានខ្មែរឆ្នាំ ១៩៧៩ និងត្រួតត្រាលេបទឹកដីខ្មែរហូតដល់បច្ចុប្បន្ននេះ យួនបានរិះរកវាល់គ្រប់វិធីដើម្បីសំលាប់ជាតិសាសន៍ខ្មែរបំផុតពូជ ហើយអាចលាក់បាំងខ្សែភ្នែកសហគមន៍អន្តរជាតិបានយ៉ាងងាយស្រួលនោះ យួនកុំមុយនីស្តក្រុងហាណូយបានរិះរកកលឧបាយ និងយុទ្ធោបាយប្លែកៗប្រទាក់ក្រឡាគ្នាចាក់ច្រែះជាបណ្តាញប្រព័ន្ធខ្សែសង្វាក់ស្មុគស្មាញពិបាកនឹងយល់ដឹង ហើយគិតស្មានមិនដល់ ដោយបង្កើតនៅយុទ្ធវិធីឃាតកម្មចំឡែកៗ ហើយសាមញ្ញជាទីបំផុត ដោយបង្កើតចេញជាស្ថាប័នឃាតកម្មផ្សេងៗ គ្នាដើម្បីបង្វែងដានក្រសៃភ្នែកសហគមន៍អន្តរជាតិមិនអោយគិតដល់ថា ពួកមេដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជា គឺជាមហាចោរ ជាមេឃាតករ ជាមេភេរវករ ជាមេម៉ាហ្វីយ៉ាជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ជាមេបនស្រី ជាមេបារមេរង្គសាល ជាមេបនល្បែង និងជាមេអង្គការឧក្រិដ្ឋជនសំងាត់នៅកម្ពុជាឡើយ ហើយបើសិនជាទំនងជាបែកការណ៍ បែកធ្លាយរឿងសំងាត់របស់ពួកគេ ពួកគេចាប់ផ្តើមផ្លាស់ប្តូរយុទ្ធសាស្ត្រ ប្តូរយុទ្ធវិធីបង្វែរចេញជាអង្គហេតុផ្សេងៗតាមចិត្តដែលពួកគេចង់បាន។ យុទ្ធវិធីក្នុងការសំលាប់ជាតិសាសន៍ខ្មែរបំផុតពូជនេះ ចែកចេញជាដំណាក់ៗតាមសភាពការណ៍ជាក់ស្តែងដែលអាចធ្វើទៅរួច ដូចជាដំបូងសំលាប់តែពួកបដិវត្តន៍ប្រដាប់អាវុធ បន្ទាប់មកសំលាប់ពួកគណៈបក្សប្រឆាំង និងពួកអ្នកដែលគាំទ្រនិន្នាការប្រឆាំង បន្តទៀតគឺសំលាប់ពួកអ្នកដែលមិនចូលជាសមាជិកគណៈបក្សប្រជាជនកម្ពុជា ចុងក្រោយបំផុតគឺសំលាប់ទាំងមនុស្សនៅក្នុងបក្សដើម្បីធ្វើវិសុទ្ធភាពជាតិសាសន៍ ដែលពួកគេទុកតែជនជាតិខ្មែរកាត់យួន ខ្មែរកាត់ចិនដែលឆុងសាច់ឈាមរួចរាល់ហើយ អោយរស់នៅជាមួយជនជាតិយួន និងជនជាតិចិន នៅលើទឹកដីកំណើតខ្មែរ ហើយពួកគេនឹងទុកជនជាតិខ្មែរសុទ្ធមួយក្តាប់តូចសំរាប់រកចំណូលដោយតាំងពិពណ៌ឱ្យពួកទេសចរណ៍អន្តរជាតិមើលតែប៉ុណ្ណោះ។ ក្នុងការអនុវត្តន៍ផែនការលេបត្របាក់ទឹកដីខ្មែរ និងសំលាប់រង្គាលរំលាយជាតិសាសន៍ខ្មែរនេះ ពួកមេដឹកនាំរដ្ឋាភិបាលអាយ៉ងយួនដឹកនាំដោយ ហ៊ុន-សែន ដែលមានរដ្ឋាភិបាលក្រុងហាណូយនៅពីក្រោយនោះ តែងតែបង្កើតចេញជា អង្គការឧក្រិដ្ឋជនសំងាត់ផ្សេងៗយកមកសំលាប់រាស្ត្រខ្មែរដូចជាអង្គការឧក្រិដ្ឋជនសំងាត់បាក់គី អង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ អង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ រួមទាំងកងអង្គរក្ស និងកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលផង ដើម្បីផ្លាស់ប្តូរគ្នាសំលាប់ប្រជារាស្ត្រខ្មែរ ឥស្សរៈជនខ្មែរ វីរៈជនខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកបក្សប្រឆាំង និងពួកអ្នកដែលមាននិន្នាការគាំទ្របក្សប្រឆាំង ហើយចុងក្រោយបំផុតគឺពួកពេទ្យពិឃាត (ដែលបណ្តុះបណ្តាលបង្ហាត់

បង្រៀនដោយរដ្ឋាភិបាលក្រុងហាណូយដែលឈ្លានពានខ្មែរ និងត្រួតត្រាគ្រប់គ្រងខ្មែរចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់សព្វថ្ងៃនេះ)របស់គណៈបក្សប្រជាជនកម្ពុជា ជាអ្នកសំលាប់បង្ហើយជនរងគ្រោះ រួមទាំងឱសុទ្ធក្លែងក្លាយលក់ពាសពេញប្រទេសផងនោះ (ផោមក្នុងទឹកក៏ ហ៊ុន-សែន ដឹងដែរ រឿងអ៊ីដែលលក់ឱសថក្លែងក្លាយទូទាំងប្រទេសកម្ពុជា ហេតុអ្វីក៏ ហ៊ុន-សែន មិនដឹង?) "**Broken wind in the water, I knew all! Nothing can hide me**! " Hun Sen said. អាចសំលាប់បង្ហើយជនរងគ្រោះយ៉ាងងាយស្រួលដើម្បីចៀសវាង កុំអោយពួកសហគមន៏អន្តរជាតិចាប់ភស្តុតាងបាន ប៉ុន្តែបើដឹងពីពួកគេវិញ ក៏ចាត់ទុកថាជាការសំលាប់បន្តិច បន្តួច ហើយពួកឧក្រិដ្ឋករ ពួកមេឃាតករ និងពួកមេភេរវករ នៅតែរួចខ្លួនដដែល ដោយគ្មានអង្គការ អន្តរជាតិណាមួយ ឬក៏មហាអំណាចណាមួយ រួមទាំងសហរដ្ឋអាមេរិកផងដែរ ចេញមុខមកចាប់ហ៊ុន-សែន និងពួកមេដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជា យកទៅកាត់ទោសឡើយ។ ពួកមេដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជា CPP និងអា ហ៊ុន-សែន បានសំលាប់ប្រជាជនខ្មែរជាច្រើន ចាប់តាំងពីពួកគេកាន់អំណាចរហូតមកដល់ពេលបច្ចុប្បន្ន និងធ្វើទុកបុកម្និញប្រជាជនខ្មែរមិនចេះចប់មិនចេះ ហើយ រួមទាំងប្លន់ដីធ្លីផ្ទះសំបែងរបស់ប្រជាជនខ្មែរឥតឈប់ឈរ និងជន្លៀសប្រជាជនខ្មែរចេញពីលំនៅដ្ឋាន ដោយគ្មានសំណងសមរម្យ។

http://www.youtube.com/watch?v=DfIjrBdcHMI&lr=1&user=RFAKhmerVideo

<table>
<tr><td></td><td>http://www.youtube.com/watch?v=DmDPWrMCn48<br>http://hengpov.wordpress.com/<br>http://www.garella.com/rich/grenpost.htm<br>http://doc-video.cambodia.org/2011/03/grenade-attack-event-on-march-30-1997.html</td></tr>
<tr><td colspan="2">http://www.globalpost.com/dispatch/asia/091218/us-policy-cambodia</td></tr>
<tr><td colspan="2">http://www.garella.com/rich/grenpost.htm<br>http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html<br>http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html</td></tr>
<tr><td colspan="2">http://www.globalpost.com/dispatch/asia/091218/us-policy-cambodia<br>http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html</td></tr>
</table>

មហាអំណាចលោកខាងលិច សហរដ្ឋអាមេរិក សហគមន៍អន្តរជាតិ បានដឹងជាស្រេចអំពីបទឧក្រិដ្ឋឃាតកម្ម ភេរវកម្ម របស់អា ហ៊ុន-សែន និងពួកមេដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជារួចជាស្រេច ជាពិសេសភេរវកម្មបោកគ្រាប់បែករបស់អា ហ៊ុន-សែន វាយប្រហារលើហ្វូងបាតុកម្មរបស់គណៈបក្សប្រឆាំង ដែលដឹកនាំដោយលោក សមរង្ស៊ី នៅមុខរដ្ឋសភា ក្រុងភ្នំពេញ នៅថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ ដែលបណ្តាលស្លាប់ ១៦ នាក់ និងរបួសជាង ១០០ នាក់។ រហូតមកដល់បច្ចុប្បន្ន មិនទាន់ឃើញមហាអំណាច សហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ ចាប់អា ហ៊ុន-សែន យកទៅកាន់តុលាការអន្តរជាតិនៅ ឡើយទេ តែបែរជាឃើញ មាន **អង្គការសហប្រជាជាតិឃុបឃិតជាមួយ ហ៊ុន-សែន បង្កើតតុលាការសាលាក្តីខ្មែរក្រហម កាត់ទោស ពួកមេដឹកនាំខ្មែរក្រហម លាងកំហុសឱ្យយួន និងបង្កើតភាពស្របច្បាប់ឱ្យយួនក្នុង ឈ្លានពានស្រុកខ្មែរទៅវិញ ព្រោះសាលាក្តីខ្មែរក្រហមនេះមិនបានយកធាតុប្រវត្តិសាស្ត្រ និងធាតុនយោបាយ មកកាត់ទោសសំរេចក្តីទេ ជាហេតុធ្វើអោយមេឃាតករធំដូចជាយួន និងចិន រួចខ្លួនទៅវិញ** សមដូចសំដីរបស់អា **ហ៊ុន-សែន** ដែល ថា***ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ថាជាផ្នែកមួយផ្តល់សច្ចៈធម៌ដល់ប្រទេសវៀតណាម***

http://www.youtube.com/watch?v=Xlt34k1kBAs&feature=relmfu **ហើយគ្មានអ្វីគួរអោយឆ្ងល់នោះទេ ធាតុពិត គឺលោក ហ្វូរ-ជីមិញ ជាមេដឹកនាំយួនកុំមុយនីស្តិ៍គឺជាអ្នកបង្កើត បដិវត្តន៍កុំមុយនីស្តិ៍ឱ្យខ្មែរនោះ វាគ្មានរូបមន្ត ឯណាចេញជាកុំមុយនីស្តិ៍ខ្មែរសំលាប់ខ្មែរទេ?** គឺយួនជាអ្នកបញ្ជាពីក្រោយរៀបចំផែនការនៅពីក្រោយឆាកសំលាប់រង្គាលនេះ បើយោងតាមសំដីរបស់លោកនួន-ជា។ តុលាការសាលាក្តីខ្មែរក្រហម បានដើរតួនាទីជាអាយ៉ងតុក្កតារបស់អា **ហ៊ុន-សែន** ដែលវាបានព្រមានតុលាការសាលាក្តីខ្មែរក្រហមជាសាធារណៈជាច្រើនលើកថា ***សុខចិត្តអោយសាលាក្តីបរាជ័យ មិនអោយមានការនាំខ្លួនកម្មាភិបាលខ្មែរក្រហមបន្ថែមលើសពី ៥ នាក់ទៅកាត់ទោសទេ***

http://www.youtube.com/watch?v=Xlt34k1kBAs&feature=plcp&context=C3d5acc4UDOEgsToPDskLCf4u2E3uET3u_MqiYmRsK

http://www.youtube.com/watch?v=Xlt34k1kBAs&feature=plcp&context=C3447d19UDOEgsToPDskLXZuBALf93lmcq3Q2jecjz

http://www.youtube.com/watch?feature=endscreen&NR=1&v=yXDLhPXpFxM

ចំពោះពួកពេទ្យពិឃាតរបស់អា ហ៊ុន-សែន នេះ ក្រៅពីសំលាប់បង្ហើយជនរងគ្រោះ បង្វែរភស្តុតាងមរណៈភាព ថែមទាំងដើរតួនាទីជាអ្នកប្រឌិតបុព្វហេតុនៃការស្លាប់ និងបង្កើតចេញជាភស្តុតាងនិងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះដើម្បីអោយបទឧក្រិដ្ឋឃ្លាតឆ្ងាយពីគណៈបក្សប្រជាជនកម្ពុជា និង **ហ៊ុន-សែន**

## *ដ្យាក្រាមរបស់មនុស្សដែលជាគោលដៅពិឃាត*




មិនថាក្រៅគុក ឬក្នុងគុកទេ គឺថាពួកពេទ្យពិឃាតរបស់អា ហ៊ុន-សែន តែងតែប្រឌិតមូលហេតុនៃការស្លាប់ ដោយមូលហេតុផ្សេងៗនៅអ្វីដែលថ្នាក់លើចង់បាន ឬអ្វីដែលគណៈបក្សប្រជាជនកម្ពុជាចង់បាន ដូចជាក្នុងកំឡុងឆ្នាំ ២០០៦-២០០៩ ពេលដែលខ្ញុំនៅក្នុងគុកព្រៃស ខ្ញុំតែងតែឃើញអ្នកទោសដែលត្រូវបានពួកប៉ូលីស

គុក និងពួកឆ្មាំគុកវាយសំលាប់ស្ទើរតែជារៀងរាល់ថ្ងៃ តែខ្មោចពួកអ្នកទោសដែលត្រូវបានគេវាយស្លាប់នោះ ត្រូវបានបញ្ជូរអោយសែងចេញទៅខាងក្រៅគុក ហើយត្រូវបានដឹកទៅកាន់មន្ទីរពេទ្យមន្ទីរវង្សដើម្បីបិទផ្លាកលាបពណ៌ ថាឈឺស្លាប់ ឬស្លាប់ដោយសារតែជំងឺ បន្ទាប់មកប្រកាសថាឈឺស្លាប់ ជាពិសេសនៅក្នុងព្រៃស ចាប់តាំងពី លោក ម៉ុង-គីមហេង ត្រឡប់មកពីបំពាក់បំប៉ននៅវៀតណាមមក គាត់ក៏បែកឆ្វេងស្រេកឈាម ហើយបែកគំនិតប្រមូលពួកក្រុមអ្នកទោសជើងខ្លាំងមកបង្កើតក្រុមពួកឆ្មាំគុកយកស្នាយតាមអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ដើម្បីតាមដានអ្នកទោស និងវាយសំលាប់អ្នកទោសជំនួសប៉ូលីសគុក ចាប់តាំងពីខែកក្កដា ឆ្នាំ ២០០៨ ដល់ខែកុម្ភៈ ឆ្នាំ ២០០៩ ហើយការសំលាប់យ៉ាងចេញមុខ និង ឥតខ្លាចញញើតអ្វីទាំងអស់សម ដូច លោក ម៉ុង-គីមហេង ជាចាងហ្វាងគុកព្រៃស បានព្រមានសំលាប់ខ្ញុំនៅថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៧ ថា **គាត់ចង់សំលាប់ ឬបញ្ជូនខ្ញុំទៅត្រពាំងឃ្លុងក៏បាន! អង្គការសហប្រជាជាតិដកគាត់ចេញពីតំណែងមិនបានទេ! មានតែសម្តេច ហ៊ុន-សែន ទេទើបដកគាត់បាន! គាត់បញ្ជាក់ថា អាពួកអង្គការសហប្រជាជាតិអត់បានការណ៍អ្វីទេ ចេះតែស្រែកយកលុយតែប៉ុណ្ណោះ!** ដោយសារភាពមានះរបស់ខ្ញុំចង់ដឹងថាច្បាប់អន្តរជាតិមានប្រសិទ្ធិភាពឬអត់នោះ ខ្ញុំក៏ព្យាយាមប្តឹងអង្គការសហប្រជាជាតិ អង្គការកាកក្របាទក្រហមនិងអង្គការផ្សេងៗទៀតអំពីការវាយសំលាប់ពួកអ្នកទោស ហើយមិនដឹងជាពេលណាទើបពួកគេនឹងវាយសំលាប់ខ្ញុំដូចអ្នកទោសដទៃៗទៀតនោះ ខ្ញុំមានការខ្លាចញញើតខ្លាំងណាស់ពេលជួបអង្គការម្តងៗនៅក្នុងគុកព្រៃស ព្រោះ


ICRC identification card

បណ្ណសំគាល់របស់គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម

(សេអ៊ីសេអ៊ែរ_អាយស៊ីអ៊ើស៊ី)

This card has to remain with the prisoner during the whole duration of detention.

លិខិតនេះត្រូវទុកនៅសាមីខ្លួនឃុំក្នុងរយៈពេលជាប់ឃុំឃាំង

Full name / ឈ្មោះពេញ : TIENG-NARITH ទៀង ណារិទ្ធ

ICRC number / លេខសេអ៊ីសេអ៊ែរ : KHP-104160-01

ថាពេលត្រឡប់មកបន្ទប់គុកវិញ ប៉ូលីសប្រធានអាគារតែងតែស្រែកគំរាមសំលាប់ខ្ញុំថា វៃវាឱ្យងាប់ទៅ ការងារស្អីវា ប្តឹងតែអង្គការ ពុតធ្វើឈឺមិនចប់ ដើម្បីជួបអង្គការ រួចហើយប្តឹង,,,,ប៉ូលីសខ្លះទៀតព្រមានថា សំពងវាទៅ ចង់ដឹងថាវាឈឺឬក៏មិនឈឺនោះ? ទោះបីយ៉ាងណាក៏ដោយ ខ្ញុំមានសង្ឃឹមខ្លះថាជីវិតខ្ញុំអាចនៅរស់ ព្រោះថាខ្ញុំស្តាប់វិទ្យុអាស៊ីសេរី នៅខែតុលា ឆ្នាំ ២០០៨ ផ្សាយថា មានជនរងគ្រោះបានប្តឹងអង្គការចំនួន ២៧ ករណីហើយ អំពីការវាយធ្វើទារុណកម្មនៅក្នុងគុកព្រៃស,,,,,,,ទោះបីខ្ញុំមិនស្លាប់ក៏ដោយ ក៏នៅតែឃើញ ការវាយសំលាប់ពួកអ្នកទោសដូចមុនដដែល ហើយមន្ទីពេទ្យមន្ទីរឃុំតែងប្រកាសថាអ្នកទោសឈឺស្លាប់ ដូចមុនអញ្ចឹង ពេលខ្ញុំចេញពីគុកនៅខែ មិនា ឆ្នាំ ២០០៩ ខ្ញុំបានរំលឹករឿងការធ្វើទារុណកម្មវាយសំលាប់ពួក អ្នកទោស អោយលោក សម-សុផល (ធ្វើការនៅការិល័យឧត្តមស្នងការសហប្រជាជាតិទទួល បន្ទុកសិទ្ធិ មនុស្សប្រចាំប្រទេសកម្ពុជា) ស្តាប់ ពេលនោះ លោក សម-សុផល បានប្រាប់ខ្ញុំថា ចាំគាត់សំណូមពរឱ្យ ពួកគេឈប់វាយសំលាប់អ្នកទោស ហើយគាត់សុំឱ្យខ្ញុំកត់ត្រាទុកជាឯកសារ។ ដោយសារតែភាពទន់ខ្សោយ នៃច្បាប់អន្តរជាតិ មិនអាចធ្វើអ្វីលើពួកមេឃាតករស្រុកខ្មែរបែបនេះ ទើបខ្ញុំសំរេចចិត្តភៀសខ្លួនមកប្រទេស ថៃ ហើយដាក់ពាក្យសុំឱ្យ UNHCR នៅប្រទេសថៃជួយខ្ញុំ។ នៅខាងក្រៅគុកក៏ដូចគ្នាដែរ មិនដឹងថា អ្នករងគ្រោះប៉ុន្មាននាក់ត្រូវបានពួកពេទ្យពិឃាតសំលាប់ ដែលប្រកាសមូលហេតុនៃការស្លាប់ខុសពីមូលហេតុ ពិតប្រាកដ តែទោះបីជាយ៉ាងណាក៏ដោយ ក៏តុលាការស្ថិតក្នុងកណ្តាប់ដៃរបស់ពួកមេដឹកនាំនៃរដ្ឋាភិបាល ភេរវិករដែរ , the terrorism of CPP and Hun Sen used handgranades attack on Khmer innocent demonstrators on 30th , March, 1997 caused 16 people were killed and more than 100 were injured in the explosions.

http://www.youtube.com/watch?v=DmDPWrMCn48

http://hengpov.wordpress.com/

http://www.globalpost.com/dispatch/asia/091218/us-policy-cambodia

បើជនរងគ្រោះប្តឹង ក៏មិនមានលទ្ធផលអ្វីក្រៅពីតុលាការចោទដាក់បន្ទុកបន្ថែម ឬយកបទ ផ្សាយពត៌មាន មិនពិតមកគៀបសង្កត់ក្រុមគ្រួសារសាច់ញាតិជនរងគ្រោះ មិនអោយប្តឹងពួកគេបានឡើយ ចំណែកឯប្រពន្ធ័ ឃោសនារបស់ពួកវាតែងតែផ្សាយស្រេចតែក្បាលចិត្តទៅតាមអ្វីដែលពួកមេដឹកនាំចង់បាន។ ចំពោះសហគមន៍ អន្តជាតិចាប់ភស្តុតាងពួកគេមិនបានឡើយ ហើយបើទទួលបានភស្តុតាង ក៏ពួកចាត់ទុកជា រឿងតូចតាច

ប៉ុណ្ណោះ ព្រោះឃើញថាគណៈបក្សប្រជាជនកម្ពុជា និង **ហ៊ុន-សែន** សំលាប់ប្រជាជនខ្មែរបន្តិចបន្តួច តែប៉ុណ្ណោះ តែតាមពិត ត្បិតតែសំលាប់តិចៗ សំលាប់តក់ៗជាប្រចាំថ្ងៃ សំលាប់រយៈពេលយូរៗ ហើយបើបូក សំរុបនៃការ សំលាប់គ្រប់ករណី គ្រប់រឿងឃាតកម្មចូលគ្នាគឺច្រើនសម្បើមណាស់ ហើយ**បើចង់ដឹងពត៌មានពិត ទិន្នន័យពិត ថាតើគណៈបក្សប្រជាជនកម្ពុជា សំលាប់ប្រជារាស្ត្រខ្មែរអស់ចំនួនប៉ុន្មាននោះ សូមសិក្សា និងធ្វើស្ថិតិជំរឿន ពួកអ្នកស្លាប់ ដោយបង្កើតចេញជាអង្គការ ស្ថាប័នផ្សេងៗសិក្សាពីប្រជារាស្ត្រ ខ្មែរដែលមានសាច់ញាតិស្លាប់** ចាប់ពីឆ្នាំ ១៩៩១ រហូតដល់បច្ចុប្បន្ននេះដោយផ្តោតលើប្រធានបទ ស្លាប់ដោយសារៈ

-ស្លាប់ដោយសារអំពើឃាតកម្ម និងភេរវកម្ម ឬការធ្វើទារុណកម្មផ្សេងៗ,,,,,,,,

-ស្លាប់ដោយសារអំពើលួចឆក់ប្លន់ជីវិត ឬរូបភាពជាចោរដែលកងកំលាំងប្រដាប់អាវុធបាញ់សំលាប់,,,,,

-ស្លាប់ដោយសារជំងឺមិនសមហេតុផល និងពេទ្យពិឃាត និងឱសថក្លែងក្លាយ ស្រវឹងពុលខ្យល់គរ

-ស្លាប់ដោយសារឧប្បត្តិហេតុ គ្រោះថ្នាក់ចរាចរ ឆក់ខ្សែភ្លើង បាក់ស្ពាន ប្រើថ្នាំញៀន,,,,,,,,

-ស្លាប់ដោយសាររដ្ឋប្រហារ និងការបង្ក្រាបបាតុកម្ម

-ការបាត់ខ្លួន បាត់ដំណឹង ចាប់ពីឆ្នាំ ១៩៩១ ដល់ពេលបច្ចុប្បន្ននេះ

ការសិក្សាចំនួនអ្នកទាំងនេះ គួរតែជាភារកិច្ចរបស់ពួកគណៈបក្សប្រឆាំង ឬក៏អង្គការអន្តរជាតិ ដោយធ្វើជំរឿន ឬជំរុញទឹកចិត្តអោយប្រជាជនរាយការណ៍ ផ្តល់ពត៌មានអំពីសាច់ញាតិ និងក្រុមគ្រួសាររបស់ ពួកគេដែលត្រូវបានស្លាប់ ឬត្រូវបានសំលាប់ ឬការបាត់ខ្លួន បាត់ដំណឹង ចាប់តាំងពីឆ្នាំ ១៩៩១ រហូតដល់ ពេលបច្ចុប្បន្ននេះ ។

**-ជំហ៊ានទី៦ គឺដំណាក់កាល ដែលប្រពន្ធ័ឃោសនារបស់គណៈបក្សប្រជាជនកម្ពុជាផ្សព្វផ្សាយបំផ្លើសពត៌មាន បំផ្លែងការពិតតាមបញ្ជាថ្នាក់លើៈ**

ប្រព័ន្ធឃោសនាគឺជាដួងព្រលឹងនៃជោគជ័យ និងបរាជ័យរបស់សេដ្ឋកិច្ច និងនយោបាយ ជាចំណុចស្លាប់រស់របស់សង្គ្រាម និងសន្តិភាព ជាច័ន្ទគ្រាសសូរ្យគ្រាសនៃសិល្បៈសង្គ្រាមដឹកនាំនគរ ជាមាគ៌ាអរូបីយ៍នៃមនោគតិឆាកល្ខោនរបស់មេដឹកនាំផ្តាច់ការនាំនគរទៅរកភាពអន្តរាយ ប្រសិនបើមេដឹកនាំនោះមានគំនិតចង់សងសឹកចងអាឃាតជាមួយរាស្ត្រខ្លួនឯងនោះ គឺគ្រាន់តែបង្កើតព្យុះពន្យុះភ្លៀងប្រើល្បិចពន្លិចជាតិអោយនៅក្នុងបញ្ហាវិបត្តិបន្តគ្នាជាសេរីតតដាច់ឡើយ បន្លិចបោកបែកគ្រាប់បែកលើហ្វូងបាតុករ បន្លិចរដ្ឋប្រហារ បន្លិចទៅបង្រ្កាបបាតុកម្ម អត់រឿងបង្កើតចេញជារឿង អត់ហេតុបង្កើតចេញជាហេតុ យកលេសនេះលេសនោះមិនចេះចប់មិនចេះហើយ ដើម្បីកូរបញ្ហាអោយល្អក់វក់វី ហើយឆ្លៀតឱកាសសំលាប់រាស្ត្រខ្មែរ ដើម្បីសងសឹកនឹងភ្នែកម្ខាងដែលខ្វាក់ដោយតែលួចគេ។ ដោយសារតែកំលាំងទ័ពនៅក្នុងដៃ សេដ្ឋកិច្ចក្នុងដៃ តុលាការក្នុងដៃ ហើយប្រព័ន្ធឃោសនានៅក្នុងដៃទៀត ធ្វើអោយ ហ៊ុន-សែន សំលាប់រាស្ត្រខ្មែរតាមអំពើចិត្ត ផ្សាយកុហក់បង្វែងសាច់រឿងតាមអំពើចិត្ត បើសិនជាទំនងជាបែកការណ៍ បែកធ្លាយរឿងសំងាត់របស់ពួកគេពួកគេចាប់ផ្តើមផ្លាស់ប្តូរយុទ្ធសាស្ត្រ ប្តូរយុទ្ធវិធីបង្វែរចេញជាអង្គហេតុផ្សេងៗតាមចិត្តដែលពួកគេចង់បានដូចជានៅថ្ងៃទី ៣០ មិនា ១៩៩៧ ហ៊ុន-សែន បានបញ្ជូអោយក្រុម អង្គរក្សរបស់ខ្លួនបោកគ្រាប់បែកសំលាប់ហ្វូងបាតុករស៊ីវិល បន្ទាប់ពីយកកងកំលាំងប្រដាប់អាវុធមកសំលាប់បង្រ្កាបហ្វូងបាតុកម្មស៊ីវិលរបស់គណៈបក្សប្រឆាំងស្លាប់អស់យ៉ាងច្រើននៅខែកញ្ញា ឆ្នាំ ១៩៩៨ ដោយសារ តែខ្លាចសហគមន៍អន្តរជាតិថ្កោលទោស ពេលនោះ ហ៊ុន-សែន និងពួកថ្នាក់ដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជាក៏ប្តូរទ្រង់ទ្រាយរូបភាពសំលាប់របស់ខ្លួន ដោយពួកគេឈប់ប្រើកងកំលាំងប្រដាប់អាវុធយកទៅសំលាប់ http://www.youtube.com/watch?v=wzBWG3Uj4JM សំលាប់ហ្វូងបាតុករស៊ីវិលរបស់ពួកប្រឆាំង ហើយគណៈបក្សប្រជាជនកម្ពុជាបែរជាយកពួកក្រុមក្មេងស្ទាវ ក្រុមក្មេងអាណោថា ក្រុមបងតូចបងធំ និង ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ រួមជាមួយពួកកងអង្គរក្ស និងពួកកងកំលាំងប្រដាប់អាវុធស្លៀកពាក់ស៊ីវិល ក្លែងធ្វើជាបាតុកម្មស៊ីវិលគាំទ្រ ហ៊ុន-សែន ទៅវាយសំពងកាប់ចាក់បាញ់ http://www.youtube.com/watch?v=9t7AYmx3saM&NR=1 សំលាប់បង្រ្កាប

ហ្វូងបាតុកម្មពួកបក្សប្រឆាំងយ៉ាងសាហាវឃោរឃៅជាទីបំផុត ហើយសហគមន៏អន្តរជាតិពិបាកសន្និដ្ឋានស្ថិតក្នុងប្រតិមិតិ មិនដឹងថានរណាជាអ្នកសំលាប់។ ទោះបីជាគណៈបក្សប្រជាជនកម្ពុជាជាមេបិសាចស្រេកឈាម ហើយអា ហ៊ុន-សែន ជាមេគ្រោះ ដែលសំលាប់រង្គាលជនជាតិខ្មែររាប់មិនអស់ ហើយប្រជារាស្ត្រខ្មែរឈឺចាប់ចងគំនុំយ៉ាងណាក៏ដោយ ប៉ុន្តែសហគមន៏អន្តរជាតិធ្វើហាក់បីដូចជាមិនដឹងរឿងអ្វីអំពីកម្ពុជា នេះក៏ដោយសារតែផលប្រយោជ៏ដែលពួកគេទទួលបានជាអាថ៏កំបាំងពីអា ហ៊ុន-សែន និងយួនកំមុយនីស្ត៏ ហើយម្យ៉ាងវិញទៀត គណៈបក្សប្រជាជនកម្ពុជា និងអា ហ៊ុន-សែន បានក្តោបក្តាប់ប្រព័ន្ធឃោសនានៅក្នុងដៃយ៉ាងណែន គឺទាំងទូរទស្សន៏ វិទ្យុ កាសែត ទស្សនាវដ្តី និងសារពត៌មានជាតិទាំងអស់ រួមទាំងភាសាជាតិ និងភាសាបរទេសជាកម្មសិទ្ធិរបស់អា ហ៊ុន-សែន ទាំងអស់ ដូចជាកាសែត Phnom Penh Post, Cambodia Daily,………ជាពិសេសកាសែតរស្មីកម្ពុជាដែលជាកាសែតរបស់លោក ថេង-ប៊ុនម៉ា ដែលជាមេម៉ាហ្វីយ៉ាជួញដូរគ្រឿងញៀនដ៏ល្បីល្បាញលើពិភពលោក សូមមើល Drugs in Cambodia http://en.wikipedia.org/wiki/Drugs_in_Cambodia

ហើយរាល់គ្រប់ប្រព័ន្ធឃោសនាទាំងអស់នោះ គឺសុទ្ធតែផ្សាយរឿងដែលអា ហ៊ុន-សែនចង់បាន មិនប្រកាន់យកការពិត សីលធម៌វិជ្ជាជីវៈសារពត៌មានអ្វីឡើយ តែគ្រាន់តែដើតួនាទីជាឧបករណ៏បំផ្លែងហេតុការណ៏ប្រឌិតហេតុការណ៏ បំភាន់ពត៌មាន បង្វែងបទឧក្រិដ្ឋអោយឃាតឆ្ងាយពីគណៈបក្សប្រជាជនកម្ពុជា និងអួតសរសើរលើកកំពស់ពួកមេដឹកនាំឃាតករ ភេរវករ និងមេម៉ាហ្វីយ៉ាអោយខ្ពស់លើព្រះអាទិទេពតែប៉ុណ្ណោះ និងវាយប្រហារជនរងគ្រោះអោយទៅជាជនឧក្រិដ្ឋ ប្រាស់ចាកពីការពិត ហើយបើមាននរណាហ៊ានតវ៉ាប្រឆាំង និងមិនយល់ស្រប ត្រូវបានពួកមេដឹកនាំសំលាប់បំបិទមាត់ ឬចាប់ដាក់គុកដោយចោទបិទផ្លាកថាផ្សាយពត៌មានមិនពិត ហេតុការណ៏ឧក្រិដ្ឋកើតសព្វទីកន្លែង និងគ្រប់ពេលវេលា ចំណែកវិទ្យុអាស៊ីសេរី វិទ្យុវីអូអេ,....., គ្រាន់ទទួលបានមួយភាគដ៏តូចតែប៉ុណ្ណោះនៅពេលថ្ងៃ ចំណែកពេលយប់ពួកគេដេកពួនលាក់ខ្លួនអស់ ហើយពត៌មានដ៏តិចតួចនោះទៀត គឺគណៈបក្សប្រជាជនកម្ពុជាលាងសំអាតស្ទើរអស់ទៅហើយ ចំណែកសារពត៌មានខាងក្រៅប្រទេស មិនយល់ហេតុការណ៏អ្វី ក៏យកពត៌មានប្រព័ន្ធឃោសនាក្នុងស្រុកទៅផ្សាយបន្តដោយប្រើពាក្យថាយោងតាមកាសែតនេះកាសែតនោះ ប្រៀបបីដូចជួយផ្សាយលាងបទឧក្រិដ្ឋ

អោយអា ហ៊ុន-សែន ដូច្នេះរឿងសប្រែជាខ្មៅ រឿងងងឹតប្រែជាភ្លឺ ការឈឺចាប់រងគ្រោះរបស់ប្រជារាស្ត្រ គ្រាន់តែជាការធម្មតាចំពោះកែវភ្នែកសហគមន៍អន្តរជាតិ និងមហាអំណាចសហរដ្ឋអាមេរិក ហើយប្រជាជនកម្ពុជារស់នៅប្រៀបដូចសត្វព្រៃរងគ្រោះ ត្រូវបានយួនកុម្មុយនីស្ត និងអា ហ៊ុន-សែន កាប់សំលាប់បាញ់ប្រហារ ចាប់ចងធ្វើទារុណកម្មតាមតែអំពើចិត្តរបស់ពួកវា ចំណែកសហគមន៍អន្តរជាតិ និងមហាអំណាចនានាបែរជាធ្វើមិនដឹងហេតុការណ៍អ្វីទាំងអស់ ព្រោះអ៊ីពួកគេមិនដឹងជាទទួលផលប្រយោជន៍អ្វីខ្លះពី ហ៊ុន-សែន និងវៀតណាម ដែលមើលពុំឃើញ។ ពេលខ្លះ មនុស្សដែលជាគោលដៅប្រមាញ់ ត្រូវបានគណៈបក្សប្រជាជនទុកឱកាសអោយពួកក្រុមក្មេងស្ទាវ ក្រុមអន្ធពាល ក្រុមបងតូចបងធំ នៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជាអ្នកធ្វើ ឬឱ្យក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅជាអ្នកធ្វើ ហើយគណៈបក្សប្រជាជនកម្ពុជាគ្រាន់តែផ្តល់ពួកគេនៅ **ឱកាសរកលុយពិសេស** ចាប់ពី ៣ ថ្ងៃ ទៅ ១ អាទិត្យ ឬរហូតដល់ ១ខែ ទៅ ៣ខែ ទៅតាមការពេញចិត្ត របស់ថ្នាក់លើ។ ប្រព័ន្ធឃោសនាក្រៅពីផ្សាយដដែលៗអួតបំប៉ោងពួកមេដឹកនាំបិសាចកុម្មុយនីស្ត ផ្សាយបំភាន់ហេតុការណ៍ ប្រឌិតឆាកល្ខោន ប្រែក្លាយបទឧក្រិដ្ឋរបស់យួនអោយទៅភាពស្របច្បាប់ គឺវាមានប្រសិទ្ធិភាពណាស់នៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រឆ្កែព្រុស ដែលយួនកុម្មុយនីស្តបានធ្លាប់ធ្វើយ៉ាងជោគជ័យនៅឆ្នាំ ១៩៧៩ ដែលព្រុសហើយព្រុសទៀត ព្រុសរហូតដល់ប្រែក្លែងរឿងយួនឈ្លានពាន អោយទៅជាយួនរំដោះ រហូតចេញជាលទ្ធផលតុលាការសាលាក្តីខ្មែរក្រហម ធ្វើអោយអា ហ៊ុន-សែន ញ៉ាមដូចក្តាមស៊ីអាចម៍ បន្តសំលាប់រាស្រខ្មែរឥតឈប់ឈរតាមរយៈអង្គការឧក្រិដ្ឋជនសំងាត់បាក់គី អេស-អូ-វ៉ាយ អាវខ្មៅ ដែលមិនត្រឹមតែដើរតួនាទីជាឃាតករ ភេរវករ លួចឆក់ប្លន់ជីវិតទេ ថែមទាំងជួយប្រព័ន្ធឃោសនារបស់រដ្ឋាភិបាលបិសាចអនុវត្តល្បិចឆ្កែព្រុស ដោយស្រែកព្រុស ក្លែងភេទព្រុស ព្រុសបន្តកន្ទុយគ្នា រាយគ្រប់តំបន់ស្រុកភូមិឃុំ បន្លំជាពួកអ្នកស្រុក ឬសាច់ញាតិរបស់អ្នកស្រុក ផ្សាយព្រុសនៅអ្វីដែលអា ហ៊ុន-សែន ចង់បាន ព្រុសដល់តែប្រជាជនជឿពួកគេទាំងបង្ខំចិត្ត គួបផ្សំនឹងកាសែតម៉ាហ្វីយ៉ា និងប្រពន្ធ័ឃោសនារបស់រដ្ឋាភិបាលបិសាចអាយ៉ងយួនផងនោះ ធ្វើអោយរឿងសោកនាដកម្មរបស់ប្រជាជាតិខ្មែរ ទៅជារឿងកែកំសាន្តរបស់សហគមន៍អន្តរជាតិទៅវិញ។

## ៦-មូលហេតុអ្វីបានជា ហ៊ុន-សែន គ្រប់គ្រងក្រុមឃាតករយ៉ាងណែនក្នុងដៃយ៉ាងនេះ?

**(១)-ឧបករណ៍ចារកម្មអាសន្សាណូទំនើប(modern spy bugs' tools) :**

ជាឧបករណ៍តាមដានស៊ើបការណ៍ដ៏ ទំនើបបំផុត ហើយមានទំហំតូចបំផុត អាចទំហំតូចជាងឡេវអាវ ប៊ិនសរសៃអំបោះលោបាះ ប៊ិនចុងចង្កើះ និង អាចមានរូបរាង និងពណ៌ប្លែកៗ ដាក់បង្កប់ទៅលើឧបករណ៍ផ្សេងៗដូចជាវ៉ែនតា មួក ដែកកេះ មួលខ្នាស់ ជាសត្វល្អិត គ្រឿងអលង្ការ,,,,,,ហើយអាចលាក់គ្រប់កៀនគ្រលៀតតាមបន្ទប់ ទ្វារ បង្អួច បង្គន់ ចង្ក្រាន បាយ ទូរទឹកកក បន្ទប់គេង ក្នុងឡាន និងគ្រឿងឧបករណ៍ប្រើប្រាស់សព្វបែបយ៉ាងបាន ហើយពួកអ្នកតាមដានគឺគ្រាន់តែមើលតាមអេក្រង់កំព្យូទ័រ អាចឃើញរូបភាពគ្រប់យ៉ាង សកម្មភាពរស់រវើក និងអាចស្តាប់សំលេងច្បាស់បានល្អជាទីបំផុត ។ ឧបករណ៍តាមដានអាស្សាណូទំនើបមានផលប្រយោជន៍ណាស់សំរាប់ការពារសន្តិសុខ សុវត្ថិភាពជូនប្រជាជន និងសង្គម តែ ហ៊ុន-សែន បែរជាយកវាទៅប្រើប្រាស់សំរាប់ធ្វើឃាតមនុស្ស សំរាប់តាមដានស៊ើបអង្កេតពួកមនុស្សដែលជាគោលដៅប្រមាញ់ប្រហារ និងប្រើសំរាប់ប្លន់ជីវិតរកលុយចំណូលឱ្យគណៈបក្សប្រជាជនកម្ពុជា និងប្រើសំរាប់គ្រប់គ្រងឃាតករធ្វើឃាតកម្មនយោបាយដើម្បីបោសសំអាតពួកបក្សប្រឆាំង និងពង្រឹងអំណាចផ្ទៃក្នុងទៅវិញ។ បើតាមប្រសាសន៍លោក មុំ-សុផាន់ និយាយប្រាប់ខ្ញុំនៅអាគារអានៃគុកព្រៃសនៅឆ្នាំ ២០០៧ ថា ពេលខ្លះលោកមានការងឿងឆ្ងល់ខ្លាំងណាស់ នៅពេលដែលលោកបានយកកាំភ្លើងខ្លីផ្ទុំលោកឧត្តមសេនីយដល់ក្នុងបន្ទប់នៃផ្ទះវិឡានៅទីក្រុងកំពង់សោម នោះ ស្រាប់តែគាត់ឮសំលេងបញ្ជារបស់ ហ៊ុន-សែន តាមកាសស្តាប់សំលេងនៅក្នុងត្រចៀករបស់គាត់ថា "អាហ្វែងម៉េចក៏មិនបាញ់ ទៅ! ហ្វែងផ្ទុំធ្វើអ្វី! "។ នៅក្នុងករណីឃាតកម្មមួយទៀតនោះនៅឆ្នាំ ១៩៩៧ ក្រោយពេលរដ្ឋប្រហាររួច ប៊ុន-រ៉ានី បានបញ្ជា អោយពួកក្រុមលោក មុំ-សុផាន់ ដឹកស្រីម្នាក់ដែល ហ៊ុន-សែន បានរំលោភនិងស្រឡាញ់ចាក់ចិត្ត ធ្វើអោយ ប៊ុន-រ៉ានី ប្រចន្ឌ ហើយបានបញ្ជាអោយក្រុមរបស់លោក មុំ-សុផាន់ លោក មុំ-ណារី ចាប់ស្រីម្នាក់នោះពីខេត្តសៀមរាបទាំងយប់ដឹកឡានយក មកបាញ់សំលាប់នៅសំបុកចាប នៅទីក្រុងភ្នំពេញ ពេលដល់សំបុកចាប ស្រាប់តែ ប៊ុន-រ៉ានី បញ្ជាតាមទូរស័ព្ទថា "ហ្វែងម៉េចក៏មិនចាត់ការទៅ! ទុកដល់អង្កាលទៀត! " លោក មុំ-ណារី ក៏ចុះពីឡានដើម្បីបើកទ្វាអោយនាងចុះពីឡាន ប៉ុន្តែនាងនោះគ្រាន់តែបែរខ្លួនទៅទ្វារឡាន ងាកក្បាលទៅទ្វាឡាន លោក មុំ-សុផាន់ ក៏ប្រើកាំភ្លើងតកាណូង បាញ់នាងពីក្រោយក្បាលធ្លាយមកថ្ងាសខាងមុខ ចំណែកលោក មុំ-ណារី ក៏បិទទ្វាឡានភ្លាម ពេលនោះ

ស្រាប់តែឮសំលេង ប៊ុន-រ៉ានី បញ្ជាមកថា "ហ្អែងយកកាំបិតឈូតមុខអោយសុះកុំឱ្យចំណាំមុខនាងបាន! កាត់នាងជាពីរកំណាត់ ហើយយកបោះចោលនៅកន្លែងផ្សេងគ្នា! " លោក មុំ-សុផាន់ ឈូតមុខនាងហើយ ក៏កាត់ខ្លួននាងជាពីរកំណាត់ មួយកំណាត់ពីចង្កេះឡើងទៅក្បាលចោលទៅក្នុងទឹកទន្លេមុខសំបុកចាប រីឯមួយកំណាត់ទៀតពីចង្កេះទៅជើង យកចោលលើគោក ហើយនៅថ្ងៃស្អែកនោះ គាត់ក៏ទូរស័ព្ទទៅកាសែតម៉ាហ្វីយ៉ាឈ្មោះ កាសែតរស្មីកម្ពុជា អោយមកថតនាងទាំងខ្លួនអាក្រាតមួយកំណាត់ចុះមកក្រោមដីសែនស៊ិចស៊ី កាសែតដទៃទៀតដូចជាកាសែតកោះសន្តិភាពក៏មកថតរូបនោះផ្សាយដែរ មើលទៅគួរអោយរន្ធត់ព្រឺក្បាលណាស់ ។ លោក មុំ-សុផាន់ ក៏មានការងឿងឆ្ងល់ណាស់ថាហេតុអ្វីក៏ ហ៊ុន-សែន ប៊ុន-រ៉ានី ហាក់បីដូចជានៅទីកើតហេតុគ្រប់ពេលវេលា ដឹងសព្វដឹងគ្រប់នៅពេលបញ្ជាអោយគាត់សំលាប់មនុស្សម្តងៗ គឺសូម្បីតែចូលដល់បន្ទប់ ឬក៏បើកទ្វាឡានក៏ពួកគាត់ដឹងប្រៀបបីដូចជាព្រះអញ្ជើង ប្រហែលមកពី ហ៊ុន-សែន ប៊ុន-រ៉ានី មានវត្ថុសក្តិសិទ្ធិដូចជាគុជឃ្មុំ ក្រឡាប់កាប់ផ្ងា អាថាន់,,,,,ជួយប្រាប់ទេដឹង? ចំណែកលោក មុំ-ម៉េត វិញ ជាអង្គរក្សអាវខ្មៅរបស់លោក ហ៊ុន-សែន ដែលត្រូវបាន ហ៊ុន-សែន ខ្លួនឯងតែងតែហៅឈ្មោះក្រុមនេះថា "ក្រុមកងអត្តឃាតពិសេស " នៅពេល ហ៊ុន-សែន បញ្ជាពួកគាត់អោសំលាប់មនុស្សម្តងៗ ហាក់បីដូចជាដឹងច្បាស់នៅទីតាំងនោះខ្លាំងណាស់ ប្រៀបបីដូច ហ៊ុន-សែន នៅជាមួយគាត់អញ្ជើង តែងតែបញ្ជាគាត់ឱ្យបត់ឆ្វេងបត់ស្តាំបាញ់ប្រហារ ទោះបីទីនោះងងឹតក៏ដោយ។ ពេលចេញប្រតិបត្តិការសំលាប់មនុស្សប្លន់ ជីវិត ហ៊ុន-សែន តែងតែអោយក្រុមពួកគាត់ពាក់ឯកសណ្ឋានឈុតខ្មៅ ថែមទាំងមានកាតសំគាល់ខ្លួនពណ៌ផ្ទៃ មេឃទំហំប៊ិន២ផ្ទាប់ដៃ ម្ខាងរូបហ៊ុន-សែន ម្ខាងទៀតគឺរូបថតគាត់ សំរាប់ទុកស៊ៀតនៅចង្កេះខោបង្ហាញកាតពេលមានអាសន្ន សូមមើល (Source$^{A4}$) គាត់ងឿងឆ្ងល់ខ្លាំងណាស់ថា ហេតុអ្វីបានជា ហ៊ុន-សែន ដឹងរាល់សកម្មភាពរបស់គាត់ ហេតុអ្វីពេលគាត់យកខោអាវខ្មៅទៅបោកគក់ គាត់តែងតែឃើញសរសៃលោហៈរាងដូចខ្សែរសយនៅក្នុងហោប៉ៅអាវរបស់គាត់ជានិច្ច។ ទាំងលោក មុំ-សុផាន់ ជាអង្គរក្សផ្ទាល់របស់ ប៊ុន-រ៉ានី ទាំងលោក មុំ-ម៉េត ជាអង្គរក្សអាវខ្មៅរបស់ ហ៊ុន-សែន សុទ្ធតែមិនដឹងថា ហ៊ុន-សែន ប៊ុន-រ៉ានី គឺពួកគេប្រើប្រាស់ឧបករណ៍ចារកម្មអាសន្សាណូទំនើប(modern spy bugs' tools) ដើម្បីស៊ើបអង្កេត និង តាមដានរាល់សកម្មភាពរបស់ក្រុមឃាតកររបស់ពួកគេ ពេលពួកគេបញ្ជាអោយបំពេញបេសកកម្មប្លន់ជីវិត សំលាប់ធ្វើឃាតកម្មនយោបាយ,, ។ល។ និង ។ល។ លើសពីនេះទៅទៀតនោះ **ហ៊ុន-សែន តែងតែប្រើ ប្រាស់ឧបករណ៍ចារកម្មអាសន្សាណូទំនើប(modern spy bugs' tools) ទៅបង្កប់លើដៃគូ**

នយោបាយរបស់ខ្លួនដើម្បីតាមដានសកម្មភាពជីវិតផ្ទាល់ខ្លួន ផលិតជារឿងស៊ិចអាសអាភាស និងយករូបភាពស៊ិចខ្សែភាពយន្តអាសអាភាសនេះទៅតំរៀមដៃគូនយោបាយអោយដកខ្លួនចេញយ៉ាងងាយស្រួល ក្នុងនោះសូម្បីតែ ពួកត្រកូលក្សត្រក៏ត្រូវតែដកខ្លួនចេញពីជីវិតនយោបាយដែរ មិនមែនត្រឹមតែប្រើសំរាប់កំចាត់បក្សប្រឆាំងប៉ុណ្ណោះទេ។ អា ហ៊ុន-សែន តែងតែតំរៀមដៃគូនយោបាយដែលប្រឆាំងនឹងវា ដោយតំរៀមចុះតាមផ្សាយជាសាធារណៈតាមយូធូប វីដេអូ (Youtube and Video), នៅរូបអាសអាភាសរូបអាក្រាតនៅរបស់អ្នកនយោបាយប្រឆាំង រូបស៊ិច,,,,,,។ល។ បើតាមសំដីអា **ហ៊ុន-សែន** ដែលប៉ុសរិឡ្យ website http://kppmradio.org/ of **KPPM News** on January 13th, 2012, បានចាក់ផ្សាយនៅថ្ងៃទី **១៣ ខែ មករា ឆ្នាំ ២០១២ នោះ** គឺអា ***ហ៊ុន-សែន*** ***តំរៀមលោក គិម-សុខា*** ដូចតទៅនេះ

" ***ឥឡូវសូមផ្តាំទៅផង!*** កូនបានចាប់កំណើតពីកំពង់ចាម! កាលពីខែ៣ ឥឡូវកើតហើយ! ទៅមើលផង! ,,,,,,,,,,,ប៉ុន្តែកូនហ្នឹងមកចាប់កំណើតនៅសណ្ឋាគារស្ទី? ***ឃើញដេកពីយប់មិញ! មនោរម្យ,,,,,,*** មកចាប់កំណើតនៅហ្នឹង!,,,,ដល់កើត កើតថ្ងៃ ២០ ខែធ្នូ! កើតមិនរួចទៀត ទៅវះនៅពិភពបញ្ញា! ប្រពន្ធលួចលាក់ក្រោយនេះកូនពីរហើយ! ***កុំលាក់នរណាទៀត! ,,,,,,រូបថតកូនស្រីយ៉ាងម៉េច? ឈ្មោះមីតាទៅទៀត! អាកូនក្រោយនោះវាយ៉ាងម៉េច? ផ្តាំទៅផងកុំណាស់ពេក! ផ្តាំទៅផង!*** និយាយដាក់ក្បាលមីក្រូម៉ង ទៅមើលផង ឥឡូវនេះចេញពីពេទ្យហើយ!,,,,,, ហើយគាត់ចងទិញឥវ៉ាន់អ៊ីធ្វើរស្រីស្នេហ៍ទីពីររបស់គាត់ដែលមានកូនពីរទៅហើយ លែងស្រីស្នេហ៍ហើយ ប្រពន្ធតែម៉ងទៅ! កុំខ្វល់ពេក! ***គេដឹងណាស់! អាទិញណែម ទិញស្អីណា ទិញក្រូចថ្លុង ទិញអ៊ីត្រង់ណា មកណាត់ជួបគ្នាឯណា? ដើម្បីហុចអោយត្រង់ណា? ថាខ្ញុំមានរូបថតទាំងអស់! កាលពីលោកឯងទៅជួបគ្នានៅវើលស្តា បន្ទប់៣១១! (World Star"-***

Room-311) ក៏មានរូបភាពដែរ! កុំថាគេគ្មាននោះ! ពេលលោកឯងនៅហ្នឹង មនុស្សនៅជិតលោកឯងប្រាប់ភ្នាក់ងារទៅហើយ! រើលស្តូ បន្ទប់៣១១!អូអានេះដឹងមកពីណា? ដឹងមកពីមនុស្សលោកឯងហ្នឹងណា!,,,,,,,,,,,,,ព្រោះថាដឹងអ៊ីម្លេះ? ចុះបើមនុស្សនៅហ្នឹងស្រាប់ហើយនោះ! យ៉ាងណាក៏ខ្ញុំអត់បញ្ចេញអាហ្នឹងតាមយូធូបដែរ! កុំព្រួយនោះ! "

នេះជាភស្តុតាងដែលអា ហ៊ុន-សែន សំដែងចេញដោយខ្លួនវា តាមរយៈសំដីរបស់វា ដែលគំរាមលោក គឹម-សុខា ពីរចំណុចគឺៈ

-សំលាប់កូនប្រពន្ធរបស់លោក គឹម-សុខា ប្រសិនបើលោក គឹម-សុខា ហ៊ានប្រឆាំងអា ហ៊ុន-សែន សមដូចសំដីវាដែលថា ,,,,,,,,, កុំលាក់នរណាទៀត! ,,,,,,រូបថតកូនស្រីយ៉ាងម៉េច? ឈ្មោះមីតាទៅទៀត! អាកូនក្រោយនោះវាយ៉ាងម៉េច? ផ្តាំទៅផងកុំណាស់ពេក! ផ្តាំទៅផង!

-ចុះផ្សាយជាសាធារណៈនៅរូបអាក្រាតអាក្រៀសរបស់លោកគឹមសុខា ជាមួយស្រីស្នេហ៍ តាមយូធូប (Youtube /Video) ប្រសិនបើលោក គឹម-សុខា នៅតែប្រឆាំងអា ហ៊ុន-សែន ទៀតនោះ សមដូចសំដីអា ហ៊ុន-សែន ដែលវាពោលថា ថាខ្ញុំមានរូបថតទាំងអស់! កាលពីលោកឯងទៅជួបគ្នានៅរើលស្តូ បន្ទប់៣១១! ក៏មានរូបភាពដែរ! កុំថាគេគ្មាននោះ! យ៉ាងណាក៏ខ្ញុំអត់បញ្ចេញអាហ្នឹងតាមយូធូបដែរ! កុំព្រួយនោះ! ។ please listen to Hun Sen's speeches in website [http://kppmradio.org/](http://kppmradio.org/) of KPPM News on January 13, 2012 . ។

**ឧទាហរណ៍: រាជវង្សឈីន Qin Dynasty China** មហាថ្លឹកចារគ័របានជួយផ្តួលរំលំរាជវង្សឈីនពេលដំបូង។ បន្ទាប់មកអធិរាជទី១សោយទីវង្គត់ លោកមហាថ្លឹកបានឃុបឃិតជាមួយមន្ត្រីលីសី ដករាជទាយាទចេញពីតំណែង ហើយបានលើកបន្តុបអធិរាជអាយ៉ងពុករលួយទន់ខ្សោយឈ្មោះហ្វហៃ។ លោកមហាថ្លឹកធ្វើការសាកល្បងដើម្បីចង់ដឹងថាតើនរណាក្បត់គាត់ ថ្ងៃមួយលោកមហាថ្លឹកបានយកក្តាន់ឈ្មោលមួយចូលរាជដំណាក់ ហើយបង្គាប់អធិរាជអោយថាវាជាសេះមួយ។ ព្រះចៅអធិរាជបានមានបន្ទូលថា »លោកហៅក្តាន់ឈ្មោលថាជាសេះមួយ លោកយល់ខុសហើយ«! លោកមហាថ្លឹកបានត្រឡប់មើលរដ្ឋមន្ត្រី រួចអោយពួកគេថាជាសេះមួយ!។ រដ្ឋមន្ត្រីខ្លះនៅស្ងៀម ខ្លះទៀតព្យាយាមផ្គាប់ផ្គុន់លោកមហាថ្លឹកដោយឆ្លើយថាជាសេះមួយ។ ចំណែកព្រះចៅអធិរាជក្រោមបញ្ជាលោកមហាថ្លឹកចារគ័រយល់ព្រមហៅក្តាន់ឈ្មោលថាសេះមួយ។ ខណៈនោះចារបុរសម្នាក់របស់លោកមហាថ្លឹកចារគ័របានកត់ត្រារាល់គ្រប់សំដីរបស់រដ្ឋមន្ត្រី បន្ទាប់មកលោកមហាថ្លឹកចារគ័របានចោទប្រកាន់រាល់ពួកមន្ត្រីដែលថាក្តាន់ឈ្មោលថាក្បត់ ហើយយកទៅប្រហារជីវិត។

## យុទ្ធសាស្ត្រទី ១៤ ៖ ខ្ចីខ្មោចដាស់ព្រលឹង Borrow a Corpse to Raise the Spirit

ការប្រកាន់យកស្ថាប័នចាស់ ការឆ្លុះត្រឡប់រឿងចាស់ បច្ចេកវិទ្យាមួយឬវិធីសាស្ត្រមួយដែលត្រូវបានបំភ្លេចចោលជាយូរយារណាស់មកហើយ ឬត្រូវលះបង់ចោលជាយូរមកហើយ ហើយយកវាមកប្រើឡើងវិញ ដើម្បីធ្វើអោយវាសមរម្យឡើងវិញសំរាប់បំរើអោយគោលបំណងផ្ទាល់របស់អ្នក។ គឺធ្វើអ្វីមួយដែលមានពីអតីតកាលអោយរស់ឡើងវិញដោយអោយវាបំរើនៅគោលបំណងថ្មីមួយ ឬដើម្បីបកស្រាយឡើងវិញ និងនាំមកនៅគំនិតចាស់ៗ និងទំនៀម ទំលាប់ចាស់ៗ ធ្វើអោយវារស់ឡើងវិញដើម្បីបំរើផលប្រយោជន៍គោលដៅរបស់យើង។

**ឧទាហរណ៍: រាជវង្សហាន Han Dynasty China** នៅពេលអធិរាជហ្វយទីបានសោយទីវង្គត់នៅឆ្នាំ១៨៨មុនគ្រឹសសករាជ ទ្រង់គ្មានព្រះរាជទាយាទទេ។ ម្តាយរបស់ទ្រង់ព្រះ

ចៅអធិរាជានីឡូបានទិញក្មេងម្នាក់អាយុពីរបីឆ្នាំ មុនមរណៈភាពរបស់ទ្រង់ ហើយត្រាស់បង្គាប់អោយព្រះរាជសនិសារទ្រង់ថាជាបុត្របង្កើត។ ដើម្បីលាក់បាំងរឿងនេះបំបាត់ស្នាមដាន ព្រះចៅអធិរាជបានប្រហារជីវិតម្តាយក្មេងនោះ។ បន្ទាប់ពីព្រះចៅអធិរាជសោយទីវង្គត់ ព្រះរាជានីបានបន្តុបក្មេងប្រុសនោះអោយសោយរាជ្យ ហើយព្រះនាងធ្វើជារាជានុសិទ្ធិ។ ទោះបីជាយ៉ាងណាក៏ដោយ ម្តាយពិតប្រាកដរបស់ក្មេងត្រូវប្រហារជីវិត តាមពាក្យចចាមអារាមក៏និយាយថា »នៅពេលខ្ញុំក្លាយជាអធិរាជ ខ្ញុំនឹងយល់ថាអ្វីដែលគួរធ្វើ«។ ពេលចារបុរសអធិរាជានីរាយការណ៍ពីក្មេងប្រុសនោះ ព្រះនាងក៏ធ្វើឃាតក្មេងប្រុសនោះ ហើយបានបន្តុបអាយ៉ងផ្សេងទៀតជំនួស។ ព្រះចៅអធិរាជានីបានគ្រងរាជនគរគ្រប់គ្រងចក្រភពដ៏រុងរឿងមួយអស់រយៈពេល៨ឆ្នាំតាមរយៈអធិរាជកូនក្មេងបន្តបន្ទាប់គ្នា៦នាក់ដែលនាងបានលើកបន្តុបឡើងគ្រងរាជបល្ល័ង្គ មុននាងសោយទីវង្គត់យ៉ាងអាថ៌កំបាំងដែលតាមពាក្យចចាមអារាមថាមកពីការដាក់បណ្តាសារមួយចេញពីស្រីស្នំស្វាមីព្រះនាងដែលព្រះនាងធ្វើទារុណកម្មដោយកាយវិកលកម្ម។ព្រះរាជានីឡូត្រូវបានចងចាំក្នុងប្រវត្តិសាស្រ្តចិនថាជាស្ត្រីនាគកំណាចមួយក្នុងចំណោមស្រីនាគកំណាចទាំង៣ដែលបានដណ្តើមរាជបល្ល័ង្គរបស់ព្រះចៅអធិរាជ។

## យុទ្ធសាស្រ្តទី ១៥ ៈ បញ្ឆោតខ្លាអោយចុះពីលើភ្នំ Lure the Tiger Down the Mountain

គេមិនដែលវាយប្រហារគូរសត្រូវដែលបោះជំរំមូលដ្ឋានសឹករឹងមាំល្អដោយផ្ទាល់ទេផ្ទុយទៅវិញត្រូវបញ្ចុះបញ្ចូលខ្មាំងអោយចាកចេញពីជំរំមូលដ្ឋានរឹងមាំរបស់ខ្លួន ហើយបំបែកសត្រូវចេញពីប្រភពកំលាំងរបស់ខ្លួន។

## ឧទាហរណ៏ៈ ប្រទេសចិនសម័យរាជាណាចក្របី Three Kingdoms Period China

នៅឆ្នាំ១៩៩លោកស៊ុនសេ បានពង្រឹងដែនដីដែលទើបតែបានឈ្លានពានថ្មីៗរបស់ខ្លួននៅភាគខាងត្បូង ហើយគោលបំណងបន្ទាប់មករបស់គាត់គឺតំបន់ដែនដីឡូយ៉ាងដ៏សំបូរស្តុកស្តម្ភទៅកាន់ភាគខាងជើង។ ទោះបីជាយ៉ាងណាក៏ដោយតំបន់ស្រុកឡូយ៉ាងមានកងទ័ពអាជីពស្ទាត់ជំនាញ ការពាររឹងមាំយ៉ាងល្អ។ ជាបន្ថែមលើនេះ វាជាដែនដីតំបន់ជ័យភូមិសំបូរស្តុកស្តម្ភនិងមានសារៈប្រយោជន៏ក្រៃលែង មានច្រកចូលចង្អៀតពីរសំរាប់ការពារតំបន់ដែនដីរបស់ខ្លួន។ ទីប៉ឹក្សារបស់លោកស៊ុនសេ បានព្រមានប្រឆាំងនឹងការរំកិលទ័ពវាយប្រហារតទល់ដោយផ្ទាល់លើជំរុំមូលដ្ឋានសឹកដែលការពាររឹងមាំ ហើយជារដ្ឋដ៏មានអំណាច មានអ្នករៀបចំគំរោងផែនការជាច្រើនអ្នក។ លោកស៊ុនសេបានបញ្ជូនបេសកជន

ម្នាក់ផ្ទុកដោយអំណោយដ៏ច្រើនលើសលុបជាមួយលិខិតចុតម៉ាយមួយច្បាប់ទៅអោយស្តេចនៃស្រុកឡូយ៉ាងឈ្មោះព្រះអង្គម្ចាស់លីវស៊ុន។ក្នុងសំបុត្របានលើកសរសើរពីជំនាញទាហ៊ានរបស់ព្រះអង្គលីវស៊ុននិងបានស្នើរសុំព្រះអង្គជួយ។លោកស៊ុនសេបានសរសេរថា»អស់រយៈពេលជាច្រើនឆ្នាំមកហើយ រដ្ឋសាងលាវបានឈ្លានពានដែនដីរបស់ខ្ញុំ និងប្លន់យកទ្រព្យជ័យភ័ណ្ឌអច្ឆិនទ្រព្យជាច្រើនចេញទៅ ប៉ុន្តែទ័ពយើងនៅទន់ខ្សោយណាស់ ដើម្បីធ្វើការវាយប្រហារសងសឹក។ ប្រសិនបើព្រះអង្គម្ចាស់អាចវាយប្រហាររដ្ឋសាងលាវ យើងផ្តល់ជំនួយអោយ ហើយព្រះអង្គម្ចាស់ភ្ជាប់យករដ្ឋនោះបញ្ចូលទៅក្នុងនគររបស់ព្រះអង្គទៅចុះ!។ ស្តេចលីវស៊ុនជាមនុស្សសីដោរប្រកបដោយមហិច្ឆិតាលោភលន់ហួសប្រមាណ បានបង្កើតចិត្តចង់ពង្រីងដែនដីត្រួតត្រាបន្ថែម។ ស្តេចឡូជាងបានជំទាស់នឹងដំបូន្មានរបស់ក្រុមប្រឹក្សារាជបល្ល័ង្ករបស់ទ្រង់ និងវាយប្រហាររដ្ឋសាងលីវ។ រយៈពេលពីរឬពសប្តាហ៍ក្រោយមក ខណៈដែលស្តេចឡូជាងកំពុងបានរវល់ឡោមព័ទ្ធរាជធានីសាងលាវ លោកស៊ុនសេបានវាយប្រហារតំបន់ឡូជាងបានដោយងាយស្រួល។ ដោយគ្មានការគាំទ្រជំនួយពីលោកស៊ុនសេ ស្តេចឡូជាងបានបរាជ័យក្នុងការវាយយកតំបន់សាងលាវ ហើយព្រះទ្រង់បានត្រឡប់ទ័ពទៅរករាជធានីរបស់ទ្រង់វិញដែលបានធ្លាក់ក្នុងកណ្តាប់ដៃរបស់សត្រូវរួចហើយ។ លោកស៊ុនសេបានទទួលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ពីដែនដីតំបន់ឡូជាងហើយអតីតស្តេចឡូជាងមិនអាចធ្វើអ្វីបានទាំងអស់ មានតែភៀសព្រះកាយចេញទៅ។

## យុទ្ធសាស្ត្រទី ១៦ៈ ចាប់អ្វីមួយបាន ដំបូងលែងវាទៅសិន To Catch Something, First Let it Go

សត្វប្រមាញ់ដែលរើលែងរួច ជារឿយៗបង្កើតភាពវាយប្រហារចុងក្រោយដ៏អស់សង្ឃឹម។ ដើម្បីការពារការវាយប្រហារចុងក្រោយបែបនេះ អ្នកត្រូវតែអនុញ្ញាតិអោយខ្មាំងជឿថាពួកវានៅតែមានឱកាសមួយសំរាប់គេចខ្លួន ឬមានសេរីភាពបាន។គោលបំណងរបស់គាត់ដើម្បីវាយប្រហារបើកផ្លូវឈាម ត្រូវបានថមថយចុះ ដោយគោលបំណងរបស់សត្រូវដើម្បីគេចខ្លួន។ នៅទីបញ្ចប់សេរីភាព ឬសេចក្តីប្រាថ្នាចង់គេចខ្លួនត្រូវបានធ្វើអោយមានកំហុសកាន់តែខ្លាំងឈានទៅបំផ្លាញទឹកចិត្តសត្រូវដោយខ្លួនវា និងត្រូវបានចុះចាញ់ដោយគ្មានការវាយប្រហារ។

## ឧទាហរណ៍ៈ ប្រទេសចិនសម័យរាជវង្សសុង Song Dynasty Period China

នៅក្នុងរជ្ជកាលសុងភាគខាងត្បូង ឧត្តមសេនីយថាន់តាវលីបានចាប់ផ្តើមវាយប្រហារប្រឆាំងនឹងភាគខាងជើងក្នុងនាមជាអធិរាជម្នាក់។ ពាសពេញយុទ្ធនាការ ព្រះអង្គបានដណ្តើម

កាន់កាប់ទីក្រុងជាច្រើន ហើយបានបំផ្លាញសំណង់ការពារសត្រូវជាច្រើន ចាប់បានឈ្លើយសឹកចំនួន៥០០០នាក់។ ទីប្រឹក្សានានារបស់គាត់ បានស្នើរសុំអោយគាត់ប្រហារជីវិតឈ្លើយសឹក និងបំផ្លាញសត្រូវដើម្បីបង្កើនជ័យជំនះជាមួយការសំលាប់រង្គាល។ ប៉ុន្តែឧត្តមសេនីយថាន់តាវជីបានឆ្លើយថា»នៅពេលនេះ យើងបានវាយប្រហារដោយខុសឆ្គង ហើយត្រូវការធ្វើអោយប្រជាជនស្ងប់ចិត្ត។ កងទ័ពនៃស្តេចពិតប្រកាន់យកជំហរទៀងត្រង់ ដូច្នេះបុព្វហេតុគឺបញ្ហាគ្រប់យ៉ាងគឺធ្វើដើម្បីប្រជាជន។ គាត់ដោះលែងរាល់គ្រប់អ្នកទោសទាំងអស់អោយត្រឡប់ទៅផ្ទះសំបែងភូមិកររបស់ខ្លួនវិញ។ អតីតទាសឹកទាំងនេះបានប្រាប់ញាតិសន្តានរបស់ពួកគេអំពីការចាប់ខ្លួន និងការដោះលែងនិងប្រព្រឹត្តិកម្មដ៏ត្រឹមត្រូវរបស់ពួកគេដែលពួកគេទទួលពីស្នាដៃឧត្តមសេនីយថាន់តាវលី។ នៅពេលនោះ ពួកអានារ្យជនទាំងឡាយដែលស្នាក់អាស្រ័យនៅតាមតំបន់នានាមានចិត្តរីករាយសប្បាយចិត្ត ហើយនៅទីកន្លែងណាក៏ដោយដែលលោកឧត្តមសេនីយថាន់តាវលីទៅដល់ ពួកកុលសម្ព័ន្ធទាំងឡាយតែងតែបានចុះចូលនិងសុំចងសម្ព័ន្ធមិត្រជាមួយព្រះចៅអធិរាជ។

## យុទ្ធសាស្រ្តទី ១៧ៈ បោះចោលដំឥដ្ឋដើម្បីចាប់យកដំគុជ Toss out a Brick to attract Jade

ត្រៀមរៀបចំអន្ទាក់មួយ បន្ទាប់មកបញ្ចុះបញ្ចូលល្បួងលោមខ្មាំង បញ្ឆោតខ្មាំងអោយចូលអន្ទាក់ដោយប្រើប្រាស់នុយបញ្ឆោតនៅក្នុងសង្គ្រាម។ នុយបញ្ឆោតគឺជាការស្ទិនភ្នែក ការបំភាន់ភ្នែក បំភានឱកាស ដើម្បីទទួលបានប្រយោជន៍ដ៏ធំ។ នៅក្នុងជីវភាពប្រចាំថ្ងៃ អន្ទាក់គឺជាការស្ទិនភ្នែក ការបោកបញ្ឆោត ការបំភាន់សត្រូវតាមរយៈទ្រព្យសម្បត្តិ អំណាចយសសក្តិបុណ្យសក្តិ កិត្តិយស ស្រីស្រស់ផ្លូវភេទកាមគុណ។

## ឧទាហរណ៍: ប្រទេសចិននៅក្នុងសម័យសង្គ្រាមរវាងរដ្ឋនិងរដ្ឋ Warring States Era China

ពួកអភិជននគរជូ បានកំពុងរៀបចំវាយប្រហារនគរវៃដ៏ទន់ខ្សោយមួយ។ ដើម្បីរៀបចំត្រៀមវាយលុក ពួកគាត់បានណែនាំបង្ហាញនៅកលឧបាយផ្សេងៗដោយទ្រង់បានធ្វើអំណោយដល់ស្តេចនគរវៃនៅសេះព្រៃចំនួន៤០០ក្បាលនិងធ្វើពុតជាផ្តល់នៅអំណោយគុជប្បីដ៏មានសោភ័ណ្ឌភាពមួយ។ ស្តេចនគរវៃសប្បាយរីករាយឥតឧបមារ ហើយរដ្ឋមន្រ្តីរបស់ទ្រង់ទាំងអស់បានធ្វើសេចក្តីសាទរចំពោះទ្រង់ ប៉ុន្តែមានរដ្ឋមន្ត្រីម្នាក់របស់ទ្រង់ឈ្មោះណាននិនសីបានសំឡឹងមើលដោយក្តីអស់សង្ឃឹមនិងប្រកបដោយទុក្ខកង្វល់ក្រៃលែង។ ព្រះអង្គនគរវៃបានសម្លឹងមើលនៅអាកប្បកិរិយាអាក្ការៈរបស់លោកណាននិនសី រួចត្រាស់បង្គាប់សួរថា»រដ្ឋមហាអំណាចសប្បាយរីករាយពេញចិត្តនឹងយើង!ដូច្នេះហេតុអ្វីក៏លោករដ្ឋមន្ត្រីហាក់

បើដូជជាមានទុក្ខកង្វល់យ៉ាងនេះ«?។លោកណានរិនសីបានឆ្លើយតបថា »នគរមួយត្រូវតែពិនិត្យពិច័យយ៉ាងម៉ត់ចត់នៅរង្វាន់មួយដែលផ្តល់អោយដោយគ្មានស្នាដៃ ហើយគេមិនដែលគោរពដើរតាមនៅទីកន្លែងដែលគ្មានកងកំលាំងសក្តានុពលដើម្បីអនុវត្តន៍ច្បាប់ឡើយ ប៉ុន្តែនៅក្នុងករណីនេះ រដ្ឋមហាអំណាចដ៏ធំមួយបែរជាធ្វើអំណោយអោយរដ្ឋតូចតាចទៅវិញ ព្រះអង្គម្ចាស់គួរតែមានព្រះរាជតំរិះសញ្ជឹងគិតពិចារណាពីបញ្ហានេះក្រាបទូល«!។ព្រះអង្គម្ចាស់នគរវៃបានចេញព្រះរាជបញ្ជាទៅកាន់មេទ័ពព្រំដែនបង្កើនការប្រុងប្រយ័ត្ន និងការពារយ៉ាងម៉ត់ចត់នៅអ្វីដែលរដ្ឋមន្ត្រីរបស់ទ្រង់បានព្រមាន ហើយទ្រង់បានចេញព្រះរាជបញ្ជាអោយកងទ័ពរបស់ទ្រង់បង្កើនការប្រុងប្រយ័ត្ន។ ក្នុងពេលដ៏ខ្លីបន្ទាប់ពីនោះ ហេតុការណ៍ក៏កើតឡើងដូចដែលរដ្ឋមន្ត្រីរបស់ទ្រង់បានព្រមានអោយដឹងមុនមែនគឺអភិជននគរជី បានមកដល់ព្រំដែននៅពីមុខកងទ័ពដ៏ធំសម្បើមរបស់ទ្រង់។ ប៉ុន្តែពេលស្តេចនគរជីនសំលឹងមើលកងទ័ពនគរវៃបោះជំរំទីតាំងការពាររឹងមាំយ៉ាងប្រុងប្រយ័ត្នបែបនោះប្រកបដោយកំលាំងទ័ពដ៏ច្រើនលើសលុបរឹងមាំខ្លាំងក្លាបែបនេះ ស្តេចនគរជីនទ្រង់ក៏ដកដង្ហើមធំរួចមានបន្ទូលថា

‹‹អាឡា!មានសន្តទេពនៅក្នុងនគរវៃផង ពួកគេដឹងជាមុននៅផែនការរបស់យើង››។

## យុទ្ធសាស្រ្តទី ១៨: ចាប់ក្រុមចោរប្លន់ ត្រូវតែចាប់មេជាមុន

## To Catch The Bandits, First Capture Their leader

ប្រសិនខ្មាំងខ្លាំង យើងត្រូវចងសម្ព័ន្ធមិត្តជាមួយមេបញ្ជាររបស់ខ្មាំងតាមរយៈលុយ ឬ ការតំរៀមកំហែងតែប៉ុណ្ណោះ ដូច្នេះត្រូវតំរង់គោលដៅទៅចាប់មេដឹកនាំឬគោលបំណងបាញ់ឆ្ពោះទៅរកមេដឹកនាំ។ ប្រសិនបើមេទ័ពធ្លាក់ក្នុងផ្នែកសេសសល់នៃកងទ័ព បាក់ទ័ពបែកខ្ញែកគ្នាគឺគោលបំណងនឹងបាញ់ឆ្ពោះមករកអ្នកឬមេដឹកនាំរបស់អ្នក។ ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើពួកគេបានចងសម្ព័នជាមួយមេដឹកនាំតាមរយៈសេចក្តីស្មោះត្រង់ បន្ទាប់មកតាមយៈ សេចក្តីប្រុងប្រយ័ត្ន កងទ័ពអាចបន្តវាយប្រហារបន្ទាប់ពីមរណៈភាពរបស់មេបញ្ជាការដើម្បី ជាការសងសឹក។

## ឧទាហរណ៍ៈ ប្រទេសចិននាកំឡុងពេលនិទាឃរដូវ និងសិសិរដូវ

## Spring and Autumn Period China

នៅឆ្នាំ៧៥៦មុនគ្រឹស្តសករាជ ការបះបោរមួយត្រូវបានបង្កើតឡើងដោយមេបញ្ជាការឬមេទ័ពយីនជឺឈី បានដឹកនាំកងទ័ពវាយឡោមព័ទ្ធប្រឆាំងនឹងទីក្រុងយុទ្ធសាស្ត្រសួយយ៉ាង។ឧត្តមសេនីយការពារក្រុងឈ្មោះចាងស៊ុនបានកត់សំគាល់ឃើញថាមេទ័ពឈ្មោះយីនជឺឈីទទួលខុសត្រូវត្រួតត្រាលើការឡោមព័ទ្ធនោះ បានរៀបចំលំដាប់ក្បួនឡោមព័ទ្ធក្រុងយ៉ាងល្អអមដោយកងទ័ពបាញ់ព្រួញព័ទ្ធជុំវិញ។ លោកចាងស៊ុនបានជឿថាប្រសិនបើគាត់វាយប្រហារមេដឹកនាំបះបោរ គឺត្រូវតែវាយប្រហារទឹកចិត្តទ័ពបះបោរជាមុន បំផ្លាញទឹកចិត្តទ័ពបះបោរជាមុនហើយបន្ទាប់មកគាត់អាចចាប់ផ្តើមវាយប្រហារតទល់គ្នាបាន គាត់បានប្រឌិតផែនការមួយជាមួយអ្នកបាញ់ព្រួញដ៏ជំនាញបំផុតរបស់គាត់។នៅពេលតមកទៀតការបះបោរឬក្រុមបះបោរបានវាយប្រហារវាយលុកកំផែងរាជធានីដោយពួកគេយកដើមឈើបុកកំផែងក្រុង។ នៅពេលលោកយីនជឺឈីបានដឹងថាពួកអ្នកការពារត្រូវបានកាត់បន្ថយឬថយចុះដោយការបាញ់ព្រួញលើកងទ័ព គាត់មានអារម្មណ៍ថាទីក្រុងពិតប្រាកដត្រូវបានដណ្តើមកាន់កាប់រួចរាល់ជាស្រេច។ មុនការវាយប្រហារជាបន្តទៀតនោះ លោកយីនជឺឈី បានជិះសេះកិលខិតចូលកៀកកាន់តែខ្លាំងទៅៗដើម្បីត្រួតត្រាត្រួតពិនិត្យអោយកាន់តែប្រសើរឡើងនៅជ័យជំនះចុងក្រោយ។ នៅពេលឡើងជិះលើខ្នងសេះ គាត់មិនបានដឹងជាមុនថាក្បួនទ័ពបាញ់ព្រួញរបស់ខ្មាំងបាញ់ប្រសាចលើពួកគាត់ដើម្បីស្រោចស្រង់ស្ថានការណ៍សឹកក្នុងពេលបន្ទាន់មួយ។ គ្រាប់ព្រួញមួយផ្លែបានបាញ់ទំលុះភ្នែកឆ្វេងរបស់លោកយីនជឺឈី បណ្តាអោយគាត់ស្លាប់នៅពេលនោះតែម្តង។ ឧបសគ្គនៃមរណៈភាពរបស់លោកមេបញ្ជាការរបស់ពួកគេនៅចំពោះមុខទ័ពបះបោរទាំងមូល បានបង្ខូចទឹកចិត្តកងទ័ពទាំងមូលដ៏ច្រើនសន្ធឹកសន្ធាប់បានរត់បែកខ្ញែកខ្ចាត់ខ្ចាយពាសវាលពាសកាលនៅក្នុងទីលានសមរភូមិ។

## យុទ្ធសាស្ត្រទី ១៩: លួចដកអុសចេញពីខាងក្រោមឆ្នាំង

## Steal the firewood from under the pot

នៅពេលប្រឈមមុខជាមួយខ្មាំង ឬសត្រូវដែលមានអំណាចខ្លាំងក្លាដោយផ្ទាល់នោះ អ្នកត្រូវតែបន្សោយសត្រូវជាមុនសិន ដោយកំណត់មូលដ្ឋានគ្រឹះនៃប្រភពកំលាំងឬប្រភពអំណាចរបស់សត្រូវអោយបានច្បាស់ រួចហើយវាយប្រហារកំទេចនៅរាល់ប្រភពកំលាំងឬប្រភពអំណាចអស់ទាំងនោះរបស់ខ្មាំងអោយអស់តែម្តង។

**ឧទាហរណ៍: នៅក្នុងរឿងនិទានជប៉ុន Legendary Era Japan**

វិរៈបុរសសម័យបុរាណរបស់ជប៉ុនម្នាក់ឈ្មោះយ៉ាម្វតូតាកិរុគឺជាកូនទី៨០របស់ព្រះចៅអធិរាជកៃកូ។ ថ្ងៃមួយទ្រង់ត្រូវបានបញ្ជូនទៅបង្ក្រាបជនក្រៅច្បាប់ និងពួកអ្នកមិនគោរពច្បាប់ដែលមានជំនាញខាងកាប់ដាវយ៉ាងស្ទាត់ជំនាញរហ័សរហួនដែលទ្រង់ត្រូវបានបញ្ជូនទៅសំលាប់មនុស្សម្នាក់នោះ។ យ៉ាម្វតូតាកិរុមិនមានបំណងប្រយុទ្ធតតួជាមួយនឹងក្រុមចោរនោះទេ ហើយទ្រង់ធ្វើពុតជាមិនដឹងមិនឮនៅកេរ្តិ៍ឈ្មោះរបស់មនុស្សម្នាក់នោះទេ ដើម្បីចងមិត្តជំនួសការប្រយុទ្ធតតួវិញ។ ពួកគេបានក្លាយជាមិត្តល្អនឹងគ្នាធ្វើអ្វីៗជាមួយគ្នា ដែលសូម្បីតែហែលទឹក ក៏ទៅហែលជាមួយគ្នាយ៉ងទៀងពេលលើទីតាំងមូលដ្ឋានមួយ។ នៅពេលដែលលោកយ៉ាម៉ាតុតាកិរុត្រូវបានធានាថាពួកចោរប្លន់បានជួលកន្លែងជ្រកកោណដែលគ្មាននរណាសង្ស័យ ទ្រង់បានត្រៀមរួចជាស្រេចដើម្បីរកឱកាសសំលាប់ពួកចោរទាំងនោះ។ ថ្ងៃមួយនៅពេលពួកគេទៅហែលទឹកជាមួយគ្នា ទ្រង់បាននាំយកដាវឈើទៅជាមួយធ្វើជាគ្រឿងប្រើប្រាស់យកទៅតាមខ្លួននៅពេលធ្វើដំណើរ។ ពួកគេមានទំលាប់ហែលទឹកប្រណាំងគ្នាទៅមកកោះតូចមួយ ប៉ុន្តែពេលនេះខណៈដែលពួកគេកំពុងតែហែលទឹកប្រណាំងគ្នា មេចោរប្លន់បានហែលនាំមុខឆ្ងាយរំពេចនោះ ទ្រង់បានហែលត្រឡប់មកត្រើយវិញរងចាំនៅឆ្នេរសមុទ្រហើយទ្រង់បានដូរដាវរបស់ចោរយ៉ាងរហ័សដាក់ដាវឈើជំនួសវិញ។ បន្ទាប់មកពួកគេបានស្លៀកពាក់រួចស្រេច លោកតាកិរុបានងារត្រឡប់ទៅរកចោរសមុទ្រ ហើយបានសំដែងនៅបំណងពិតប្រាកដរបស់ខ្លួន។ មេចោរសមុទ្របានស្ទុះទៅចាប់ដាវជាបន្ទាន់ ប៉ុន្តែដាវនៅដៃរបស់ខ្លួនជាដាវឈើដែលមានស្នៀតនៅខាងក្នុងស្រោម។ ខណៈរំពេចនោះទ្រង់បានកំពុងតស៊ូប្រយុទ្ធទាញដាវយ៉ាងមុតចេញមកកាត់ក្បាលមេចោរប្លន់ដាច់តែម្តង។

## យុទ្ធសាស្រ្តទី ២០: ធ្វើអោយល្អក់ទឹកដើម្បីចាប់ត្រី Trouble the water to catch the fish

មុនការវាយប្រហារទៅលើកងទ័ពធំរបស់ខ្មាំងសត្រូវ អ្នកត្រូវតែបង្កើតភាពចលាចលភាពវឹកវរច្របូកច្របល់ដើម្បីធ្វើអោយសត្រូវរបស់អ្នកចុះខ្សោយផ្នែកប្រក្សត្យារម្មណ៍និងការវិនិច្ឆ័យរបស់ខ្លួន។ អ្នកត្រូវតែធ្វើអ្វីមួយដែលមិនធម្មតា ប្លែកៗចំឡែកអារម្មណ៍និងធ្វើអ្វីម្យ៉ាងដែលសត្រូវមិនអាចរំពឹងទុកជាមុនបាន ដែលទង្វើបែបបនោះនឹងបង្កើនការសង្ស័យដល់សត្រូវរបស់អ្នក ហើយបង្ករភាពច្របូកច្របល់ដែលធ្វើអោយសត្រូវរបស់អ្នកនឹកគិតស្មានមិនដល់។ សត្រូវដែលបាត់បង់ស្មារតីបែកអារម្មណ៍ ច្របូកច្របល់ចិត្ត នឹងធ្វើអោយងាយរងការខូចខាត។

**ឧទាហរណ៍: ប្រទេសចិននាកំឡុងនិទាឃរដូវនិងសិសិររដូវ**

នៅឆ្នាំ៦៣២មុនគ្រឹសសករាជ កងទ័ពនគរជីននិងនគរឈូ បានប្រឈមមុខគ្នាប្រយុទ្ធគ្នានៅតំបន់ឆឹងពូ )មុនពេលចំបាំងទីតាំងនេះមានឈ្មោះដូចគ្នា)។ នគរឈូបានបញ្ជូនបេសកកជនម្នាក់ទៅកាន់នគរជីនស្នើរសុំការប្រយុទ្ធដោយប្រើសេះចំបាំង រទេះចំបាំងប្រយុទ្ធតតួនៅថ្ងៃបន្ទាប់ដែលមេដឹកនាំនគរជីនឈ្មោះតុកវិនបានឡើងលើកំពូលប៉មដើម្បីសង្កេតមើលទៅលើស្ថានការណ៍សឹកជាក់ស្តែង ហើយបានសំលឹងមើលមកក្រោមមើលការរៀបចំជំរុំរបស់គាត់ដោយនិយាយថា‹‹ក្បួនច្បាប់ប្រតិបត្តិពីជំនាន់ចាស់ និងជំនាន់ថ្មីអាស្រ័យលើទំលាប់និយមចូលចិត្ត ផ្អែកលើស្ថានការណ៍ជាក់ស្តែង។ ពួកគេសក្តិសមនឹងប្រើប្រាស់ខ្លាំងណាស់››។ បន្ទាប់មកលោកតុកវិនបានបញ្ជារអោយកងទ័ពរបស់លោក អោយកាប់រំលំដើមឈើដែលធ្លាប់បានប្រើជាផ្នែកៗទៅតាមយុទ្ធសាស្រ្តជាក់ស្តែង និងទៅតាមវិធីចាស់បុរាណដែលមានរយៈពេលជាយូរលង់ណាស់មកហើយ ត្រូវធ្វើវាអោយទៅជាយុទ្ធវិធីថ្មីៗចំឡែកមួយ Unorthodoxy tactics។ ខណៈពេលដែលរទេះសេះប្រយុទ្ធតតួគ្នាដោយការចាប់ផ្តើមជាសំងាត់របស់តុកវិនបានចាប់ផ្តើមប្រើកងទ័ពសេះវាយប្រហារមួយរំពេចប្រឆាំងនឹងគនរឈូនៅស្លាបខាងស្តាំ ធ្វើអោយកងទ័ពនគរឈូដួលរំលំ។ នៅពេលជាមួយគ្នានេះនៅស្លាបខាងស្តាំត្រូវបានរុញច្រានចូលកំទេចតួទ័ពរបស់សត្រូវ។ កងទ័ពនគរជីននៅផ្នែកកណ្តាលបានលើកទុងបដាដកថយជាសញ្ញា ហើយបានចាប់ផ្តើមដកថយទៅក្រោយវិញ។ នៅពេលដែលកងទ័ពនគរជីនបានដកថយ ពួកគេបានអូសទាញដើមឈើដែលកាប់រំលំរួចជាស្រេចកាលពីព្រឹកមិញនោះនៅពីខាងក្រោយរទេះសេះ។ ទង្វើរបែបនេះធ្វើអោយពពួកភ្នក់ធូលីដីហុយឡើងទ្រលោមដែលធ្វើអោយមេបញ្ជាការទ័ពនគរឈូបានគិតថាកងទ័ពនគរជីនបានកំពុងភៀសខ្លួនចេញយ៉ាងភ័យតក់ស្លត់ហើយអន្ទះសារស្ទុះដេញតាមជាប្រញាប់។ ពេលដែលកងទ័ពធំឬតួទ័ពរបស់នគរឈូបានឡោមព័ទ្ធពពកធូលីដីដ៏ក្រាស់ ពួកគេមិនអាចមើលឃើញថាកងទ័ពគនគរជិនបានបំបែកគ្នាជា២កងពលហើយត្រឡប់ឡោមព័ទ្ធកងទ័ពនគរឈូវិញ។ ទ័ពនគរជីនបានវាយប្រហារដោយប្រើក្បួនមុខដង្កាប់បែបបុរាណមួយ ឬចលនាមុខដង្កោបបែបបុរាណនៅសងខាងស្លាបទ័ពទាំងពីររបស់កងទ័ពនគរឈូ។ ជាលទ្ធផលកងទ័ពនគរជីនបានឈ្នះកងទ័ពនគរឈូយ៉ាងល្បីល្បាញខ្ទរខ្ទារមួយ បន្ទាប់ពីឧត្តមសេនីយកងទ័ពនគរឈូត្រូវបានបញ្ជាអោយធ្វើអត្តឃាត។ លោកតុកវិនបានទទួលផលប្រយោជន៍យ៉ាងធំសម្បើមក្រៃលែងពីការបែកស្មារតីបាត់បង់ការផ្ចង់អារម្មណ៍ និងភាពច្របូកច្របល់ដោយបានផ្តល់ដោយការប្រយុទ្ធតតួដែលប្រើរទេះសេះចំបាំងដើម្បីផ្តើមវាយប្រហារពញាក់ស្មារតី ធ្វើអោយភ្ញាក់ផ្អើលដល់កងទ័ពសត្រូវទាំងពីរស្លាបសងខាង ហើយការដកថយមួយគឺជាការប្រើប្រាស់ឧបាយកលយ៉ាងប៉ិនប្រសប់ បញ្ឆោតកងទ័ពនគរឈូអោយចូលអន្ទាក់។

## យុទ្ធសាស្រ្តទី ២១: ជំរុះស្បែកអ្នកចេញប្រៀបដូចសត្វរៃមាស

## Shed Your Skin Like The Golden Cicada

នៅពេលដែលអ្នកស្ថិតនៅក្នុងគ្រោះថ្នាក់ដោយការបរាជ័យ ភ័ព្វសំណាងរបស់អ្នកមានតែមួយគត់គឺការភៀសខ្លួនចេញតែប៉ុណ្ណោះ ហើយរៀបចំក្រុមសារជាថ្មី បន្ទាប់មកអ្នកបង្កើតការបំភាន់ថ្មិនភ្នែកមួយ។ ខណៈដែលចំណាប់អារម្មណ៍ចេតនារបស់សត្រូវ ត្រូវបានផ្តោតទៅលើល្បិចដ៏ប៉ិនប្រសប់នេះ រំកិលទ័ពផ្លាស់ប្តូរមនុស្សរបស់អ្នកអោយចាកចេញទៅតាមទីកន្លែងផ្សេងៗនៅពីខាងក្រោយអាក្ការៈខាងក្រៅនៃវត្តមានរបស់អ្នក។

## ឧទាហរណ៍: ប្រទេសនាសម័យរាជាណាចក្រ៣ Three Kingdoms Period China

ស្តេចត្រាញ់ឆាវឆាវនៃនគរវៃ បានកំពុងដេញតាមកងទ័ពនគរស៊ុ និងប្រជារាស្រ្តដែលកំពុងភៀសខ្លួនរបស់របស់ស៊ុនគរ ដែលដឹកនាំដោយវីរៈបុរសចំការប៉ែសឈ្មោះព្រះអង្គម្ចាស់លីវពី និងលោកឆាងហ្វៃ។ ជួរខ្សែត្រៀមទ័ពដែលដកថយបានមកដល់ស្ពានឈើឆាងផាងដើម្បីឆ្លងទន្លេវៃនគរដោយមានកងទ័ពសត្រូវដេញតាមរាប់ម៉ោង ទើបមកដល់ពីខាងក្រោយស្ពាន។ នៅត្រើយម្ខាងទល់មុខទន្លេ មានព្រៃស្រោងយ៉ាងក្រាស់ លោកឆាងហ្វៃបានអោយព្រះអង្គម្ចាស់លីវពី និងឧត្តមសេនីយរបស់គាត់ឆ្លងទៅមុន ហើយនិយាយថា«ស្ពាននេះគឺជាចំណុចឆ្លងកាត់តែមួយគត់សំរាប់ផ្លូវដ៏សែនឆ្ងាយរាប់សិបយោជន៍ឬរាប់សិបមៃល៍(១មៃហ៍=១,៦គីឡូម៉ែត្រ) និងបានផ្តល់ដល់យើងនៅផលប្រយោជន៍តែមួយគត់។ សូមព្រះអង្គម្ចាស់មេត្តាដឹកនាំកងទ័ពនិងប្រជាជនឆ្លងទន្លេទៅមុនចុះនៅខណៈពេលដែលទូលបង្គំនៅបង្អាក់កងទ័ពនគរវៃដើម្បីពន្យាពេលអោយទ្រង់នាំទ័ពនិងប្រជាជនចាកចេញអោយបានកាន់តែឆ្ងាយតាមដែលអាចទៅរួច។ បន្ទាប់ពីកងទ័ពនគរស៊ុបានឆ្លងកាត់ទន្លេផុតទៅ លោកឆាងហ្វៃបានបញ្ជូនកងទ័ពសេះមួយក្រុមតូចឆ្លងកាត់ស្ពានចូលទៅក្នុងព្រៃដោយចងមែកឈើទៅនឹងកន្ទុយសេះរបស់កងទ័ព ហើយជិះសេះជុំវិញជារង្វង់។ លោកឆាងហ្វៃនៅតែអង្គុយកាងនៅកណ្តាលស្ពានដើម្បីបង្អាក់កងទ័ពនគរវៃ។ នៅពេលដែលការដេញតាមរបស់កងទ័ពនគរវៃមកដល់ ឃើញលោកឆាងហ្វៃអង្គុយតែម្នាក់ឯងនៅលើស្ពាន ទ័ពរបស់លោកឆាវឆាវក៏ឈប់នៅមុខស្ពាន ហើយលោកឆាវឆាវបានសំគាល់ឃើញថាពពកធូលីដីដ៏ធំក្រាស់នៅឆ្ងាយពីខាងក្រោយព្រៃឈើ ហើយត្រូវបានសង្ស័យថាជាអន្ទាក់មួយ។ លោកឆាងហ្វៃបានស្រែកគំហ៊កគំរៀមសំឡុតទ័ពរបស់វៃនគរ ប៉ុន្តែលោកឆាវឆាវត្រូវបានចាញ់កលឧបាយហើយរំកិលទ័ពជុំវិញមុនដកថយត្រឡប់ទៅវិញ។ លោកឆាងហ្វៃមើលឃើញថាកងទ័ពនគរវៃធ្លាក់ទឹកចិត្តក្នុងការដកថយទៅកាន់នគរវៃវិញ។ នេះធ្វើអោយកងទ័ពខូចទឹកចិត្តនៅក្នុងកង

ទ័ពនគរវៃប្រវេសប្រវាសប្រញាយគ្នារត់ចេញដូចមនុស្សឆ្កួតដើម្បីភៀសខ្លួនចេញពីតំបន់អន្ទាក់មួយដែលឡោមព័ទ្ធជុំវិញពួកគេ។ ល្បិចនេះធ្វើអោយព្រះអង្គម្ចាស់លីវពីនិងលោកឆាងហៃ្វមានពេលល្មមគ្រប់គ្រាន់ដើម្បីភៀសខ្លួនចេញជាមួយមនុស្សរបស់ពួកគេ ហើយប្រមូលផ្តុំទ័ពសារជាថ្មីនៅតំបន់ឈៀងលីង។

## យុទ្ធសាស្រ្តទី ២២៖ បិទទ្វារដើម្បីចាប់ចោរ Shut the door to catch the thief

ប្រសិនបើអ្នកមានឱកាសធ្វើការចាប់ខ្លួនសត្រូវទាំងស្រុង នៅពេលអ្នកធ្វើដូច្នេះ កំពុងនាំមកនៅការប្រយុទ្ធឬសង្គ្រាមតែមួយរយៈពេលខ្លី ហើយសន្និដ្ឋានចុងក្រោយត្រូវធ្វើជាបន្ទាន់។ ដើម្បីកុំអោយសត្រូវរបស់អ្នកគេចខ្លួន នាំបង្កបង្កើតគ្រាប់ពូជបដិវត្តន៍និងបង្កបញ្ហានៅថ្ងៃក្រោយនាពេលអនាគត។ ប៉ុន្តែប្រសិនបើនៅតែបន្តការភៀសខ្លួន សូមប្រុងប្រយ័ត្ននៅក្នុងការដេញតាម ប្រយ័ត្នចូលអន្ទាក់របស់ខ្មាំងសត្រូវ។

## ឧទាហរណ៍៖ ប្រទេសចិននាសម័យសង្គ្រាមរវាងរដ្ឋនិងរដ្ឋ Warring States Era China

នៅឆ្នាំ៤៩៩មុនគ្រឹសសករាជ រដ្ឋនគរវ្វៃបានឈ្លានពានរដ្ឋនគរយ្វេ ហើយបានសំរេចជោគជ័យចាប់បានអភិជនឈ្មោះគ័រជាងធ្វើជាទាសីកអស់រយៈពេល៣ឆ្នាំ មុនពេលដោះលែងគាត់អោយត្រឡប់មកកាន់រាជាណាចក្រវិញ។ នៅពេលដែលគាត់ត្រឡប់មកដល់រាជនគរវិញ លោកគ័រជាងបានមានផែនការធ្វើការសងសឹក។ អស់រយៈពេល៧ឆ្នាំគាត់គ្រប់គ្រងប្រកបដោយក្តីមេត្តាករុណានិងចិត្តសប្បុរសធម៌ បង្កើតនៅកេរ្តិ៍ឈ្មោះល្បីល្បាញថាជាមេដឹកនាំប្រកបដោយគុណធម៌និងភាពឆ្លាតវាងវៃរហូតដល់គាត់មានអារម្មណ៍ថាប្រធានវត្ថុវិស័យដ៏ស្មោះត្រង់របស់គាត់ ត្រូវបានត្រៀមរៀបចំប្រឈមមុខនឹងភាពលំបាកលំបិនសព្វយ៉ាង។ គាត់បានកោះប្រជុំនៅកងកំលាំងរបស់គាត់ ហើយប្រមូលផ្តុំកំលាំងវាយប្រហារនគរវ្វៃបានទទួលជ័យជំនះតាមផែនការដែលបានសំរេចទុកមុន។ ព្រះអង្គនគរវ្វៃត្រូវបានភៀសខ្លួនចេញ ប៉ុន្តែបញ្ហាពេលវេលាពីមុនទ្រង់ធ្លាប់ចាប់បានមេទ័ពគ័រជាង ដូច្នេះទ្រង់ក៏បញ្ជូនព្រះរាជទូតទៅរកមេទ័ពគ័រជាង ដើម្បីសុំក្តីមេត្តាអនុគ្រោះដោយទ្រង់បានរំលឹកពីអនុស្សាវរីយ៍ដែលនគរវ្វៃធ្លាប់ចាប់បានលោកមេទ័ពក្នុងកណ្តាប់ដៃ ហើយដោះលែងគាត់អោយត្រឡប់ទៅកាន់ព្រះរាជនគរវិញ។ ព្រះអង្គម្ចាស់នគរវ្វៃឥឡូវនេះសុំអោយលោកផ្តល់ក្តីមេត្តាអនុគ្រោះដល់ទ្រង់វិញ។ លោកមេទ័ពគ័រជាងបានកំពុងគិតពិចារណាយ៉ាងល្អិតល្អន់បំរុងផ្តល់ការអនុគ្រោះតាមសំណើរសុំរបស់ទ្រង់ ប៉ុន្តែនៅពេលនោះនាយករដ្ឋមន្ត្រីរបស់លោកមេទ័ពឈ្មោះលោកហ្វាន់លីបានធ្វើអន្តរាគមន៍ ហើយមានប្រសាសន៍ថា«នៅពេល

ឋានសួគ៌បានផ្តល់ភ័ព្វសំណាងដល់អភិជននគរយូវ និងដល់លោកមេទ័ពដោយបានផ្តល់ឱកាសអោយលោកក្តោបក្តាប់អំណាចលើផែនប្រថពី បើលោកមេទ័ពមិនចេះទាញយកផលប្រយោជន៍ពីឋានសួគ៌ ពីទេពលិខិតនោះទេ នៅថ្ងៃក្រោយលោកនឹងមានលទ្ធផលដូចសត្រូវម្នាក់(ព្រះអង្គម្ចាស់នគរវ៉ូ)របស់លោកនាពេលបច្ចុប្បន្ននេះ បើលោកធ្វើអោយខកខានមិនទទួលយកភ័ព្វសំណាងពីទេពលិខិតដែលផ្តល់អោយលោកនាពេលបច្ចុប្បន្នលោកត្រូវតែត្រូវបានបណ្តេញចេញពីព្រះរាជនគរ ហើយបន្ទាប់មករៀងរាល់ឆ្នាំនៃការលំបាកវេទនាដែលលោកធ្លាប់ធ្លាក់ក្នុងគ្រោះមរណៈ គ្រោះកាចកន្លងមក ហើយកិច្ចប្រឹងប្រែងកន្លងមករបស់លោកនឹងប្រែក្លាយទៅជាឥតន័យ»។ លោកអភិជនគ័រជាងក៏បានទទួលយកយោបល់និងធ្វើតាមសំដីរបស់លោកហ្វាន់លី ហើយបានបញ្ជូនព្រះរាជទូតព្រះអង្គនគរវ៉ូ អោយត្រឡប់ទៅវិញដោយមានផ្ញើរព្រះរាជសារមួយដែលមានន័យថាលោកមិនផ្តល់ការអនុគ្រោះក្តីមេត្តាករុណាដល់ទ្រង់ឡើយ។ នៅពេលព្រះអង្គម្ចាស់នគរវ៉ូបានទទួលព្រះរាជសារហើយ ព្រះអង្គក៏បោះបង់សេចក្តីសង្ឃឹម និងការតស៊ូចោលទាំងអស់ហើយទ្រង់ក៏ធ្វើអត្តឃាតទៅ!។

## យុទ្ធសាស្ត្រទី ២៣: ចងមិត្តជាមួយសត្រូវឆ្ងាយដើម្បីវាយសត្រូវជិត

## Befriend a distant enemy to attack one nearby

វាត្រូវបានគេស្គាល់ថាប្រជាជាតិនានាដែលមានព្រំដែនជាប់គ្នាបានក្លាយជាសត្រូវនឹងគ្នាខណៈពេលដែលប្រជាជាតិនានាត្រូវបានបំបែកកាត់ផ្តាច់ដោយចំងាយ និងឧបសគ្គរបាំងនានាបង្កើតជាសម្ព័ន្ធមិត្តនឹងគ្នាយ៉ាងល្អប្រពៃ។ នៅពេលអ្នកមានកំលាំងខ្លាំងក្លាបំផុតនៅក្នុងសមរភូមិមួយ ការគំរៀមកំហែងក៏ធំគឺចេញមកពីកំលាំងខ្លាំងបំផុតទី២នៅក្នុងសមរភូមិរបស់អ្នក គឺមិនមែនកំលាំងខ្លាំងបំផុតមកពីសមរភូមិដទៃៗឡើយ។ បន្លាដែលអាចមុតជើងយើងគឺជាបន្លាដែលនៅជិតជើងយើង គឺមិនមែនជាបន្លាដែលនៅឆ្ងាយពីជើងយើងទេ។

### ឧទាហរណ៍: ប្រទេសចិននាសម័យរាជវង្សហាន Han Dynasty China

នៅឆ្នាំ១១០នៃគ្រឹសសករាជ ខេត្តហ្វណានបានទទួលរងគ្រោះពីគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ការច្រូតកាត់ប្រមូលផលគឺទទួលបានផលតិចតួចស្តួចស្តើងណាស់ហើយប្រជាជនបានជួបគ្រោះទុរភិក្ស។ ពួកក្រុមចោរសមុទ្រ និងក្រុមចោរប្លន់ជាច្រើនដែលធ្វើដំណើរដោយគ្មានគោលដៅទៅលួចប្លន់និងធ្វើភេរវកម្មតាមទីជនបទលើអាណាប្រជារាស្ត្របំផ្លាញសេចក្តីសង្ឃឹមលើរដ្ឋអំណាច។ មន្ត្រីខេត្តម្នាក់ឈ្មោះថាយូហ្វ ត្រូវបានតែងតាំង

អោយក្តាប់អំណាចយ៉ាងពេញលេញ ដើម្បីសាកល្បងព្យាយាមស្តារបទវិន័យមួយចំនួន និងស្តារសណ្តាប់ធ្នាប់ក្នុងខេត្តឡើងវិញ។ នៅពេលគាត់បានមកដល់ទីរួមខេត្ត លោកបាន ចេញសេចក្តីប្រកាសមួយថាលោកត្រូវបានចាត់តាំងអោយរៀបចំកងកំលាំងយោធាមួយឡើង វិញហើយគាត់ត្រូវការរើសទាហ៊ានឡើងវិញះ

ដំបូងគាត់បានសន្យាលើកលែងទោសដល់អ្នកដែលប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មពីអតីតកាល ហើយផ្តល់អភ័យឯកសិទ្ធិដល់អ្នកដែលបំរើកងទ័ព។បន្ទាប់មកគាត់បានប្រកាសថាគាត់បាន កំពុងស្វែងរកមនុស្ស៣ប្រភេទអោយបំរើកងទ័ព:

ប្រភេទទី១នៃកងទ័ពគឺជាមនុស្សដែលធ្លាប់ធ្វើជាឃាតករនិងចោរប្លន់ ពួកទាំងនេះ ត្រូវបានតែងតាំងជាមេបញ្ជាការ ហើយទទួលប្រាក់ខែខ្ពស់ជាងគេបំផុត។

ប្រភេទទី២នៃកងទ័ពគឺជាប្រភេទមនុស្សដែលធ្លាប់ធ្វើជាចោរលួចពួកគេទទួលប្រាក់ខែ ខ្ពស់បន្ទាប់ពីទ័ពប្រភេទទី១។

ប្រភេទទី៣នៃកងទ័ពគឺជាប្រភេទមនុស្សដែលចូលរួមប្លន់ ចូលរួមជាមួយក្រុមចោរប្លន់ ព្រោះតែពួកគេគេចវេសពីពលកម្មការងារពិតប្រាកដនិងជាមនុស្សខ្ជិលច្រអូស ពួកគេទទួល បានប្រាក់ខែទាបជាងគេ។

ក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយមក លោកយូហ្វមានកងទ័ពរើសបញ្ចូលថ្មីជាង ៣០០នាក់នៅពេលកងទ័ពស្លៀកពាក់ឯកសណ្ឋាននិងបំពាក់អាវុធ។ លោកអោយកងទ័ពថ្មី ដើរព្យួហាយាត្រា និងណែនាំពួកគេដូចខាងក្រោមនេះ«កិច្ចការពីអតីតកាលរបស់អ្នកត្រូវ បានបំភ្លេចចោលនាពេលបច្ចុប្បន្ននេះ ហើយត្រូវបានរួចផុតពីការផ្តន្ទាទោស ប៉ុន្តែ អស់លោកត្រូវតែធ្វើអ្វីម្យ៉ាងដើម្បីលុបលាងទោសឧក្រិដ្ឋរបស់អស់លោកពីអតីតកាលដែល ប្រឆាំងនឹងសង្គមជាតិ។ ឥឡូវនេះដើម្បីធ្វើកិច្ចការនេះអ្នកត្រូវតែចេញទៅក្រៅចាប់ជន ឧក្រិដ្ឋជាសហការីរបស់អស់លោក ដែលមិនឆ្លើយតបទៅនឹងការអំពាវនាវរបស់ខ្ញុំ»។ កិច្ចការ នេះពួកគេបានធ្វើហើយតែក្នុងរយៈពេលមួយឆ្នាំ ភាពជាបងប្អូននឹងក្រុមចោរប្លន់ចោរសមុទ្រ ត្រូវបានបំផ្លាញជនឧក្រិដ្ឋខិចខី ធ្វើអោយប្រទេសមានសន្តិសុខសុវត្ថិភាពឡើងវិញ។

## យុទ្ធសាស្ត្រទី ២៤៖ ខ្ចីផ្លូវឈ្លានពាននគរគ័រ Borrow the road to conquer Guo

ខ្ចីធនធានរបស់សម្ព័ន្ធមិត្តទៅវាយប្រហារសត្រូវរួមមួយ។ នៅពេលមួយ សត្រូវបាន បរាជ័យ អ្នកត្រូវតែប្រើប្រាស់ធនធានជ័យភ័ណ្ឌរបស់សត្រូវដែលបរាជ័យទៅសងសម្ព័ន្ធ មិត្តដែលអោយអ្នកខ្ចីនៅពេលដំបូង។

## ឧទាហរណ៍: ប្រទេសចិននាកំឡុងនិទាឃរដូវ និងសិសិររដូវ Spring and Autumn Period China

រដ្ឋតូចៗមាននគរយូនិងនគរគ័រ មានព្រំដែនជាប់គ្នាទៅនឹងរដ្ឋធំមួយនៃនគរជីន។ នគរជីនដឹកនាំដោយលោកតុកសៀនបានសំរេចចិត្តវាយលុកឈ្លានពាននគរតូចៗទាំងពីរ។ក្តី ប្រាថ្នានេះគ្មាននគរណាមួយមិនដឹងទេ រដ្ឋទាំង២សុទ្ធតែបានចាត់វិធានការរៀងៗខ្លួនដើម្បី ការពារខ្លួនការពារព្រំដែនរបស់ពួកគេទុបទល់នឹងនគរជីន។ លោកឧត្តមសេនីយស៊ុនសី បានស្នើរអោយ ស្តេចនគរជីនវាយឡោមព័ទ្ធជារង្វង់លើនគរគ័រ តាមរយៈរដ្ឋនគរយូ ដើម្បី វាយពញាក់នគរគ័រអោយភ្ញាក់ផ្អើល។ ឧត្តមសេនីយស៊ុនបានស្នើរឡើងថាអភិជននគរយូ ជាមនុស្សប្រកបដោយមហិច្ឆិតាលោភលន់ប្រាកដជាសីសំណូកទទួលយកអំណោយត្បូងគុជ និងសេះនានាដើម្បីជាថ្នូរនឹងផ្លូវច្រកចូលចង្អៀតប្រកបដោយសន្តិសុខតាមរយៈដែនដីយូ។

លោកសៀនបានបារម្ភខ្លាចក្រែងតែ »នគរយូទទួលយកអំណោយ តែនឹងបដិសេធ មិនអោយច្រកផ្លូវចង្អៀតអោយយើងឆ្លងកាត់«។ ប៉ុន្តែឧត្តមសេនីយស៊ុនបានឆ្លើយតបវិញថា» ប្រសិនបើនគរយូគ្មានបំណងអោយយើងឆ្លងកាត់ ប្រាកដជាមិនទទួលយកអំណោយរបស់ពួក យើងទេ ប៉ុន្តែប្រសិនបើនគរយូទទួលអំណោយ គាត់នឹងអនុញ្ញាតិអោយយើងខ្ចីផ្លូវច្រក ចង្អៀតអោយយើងឆ្លងកាត់ មានន័យថារតនសម្បត្តិរបស់យើងត្រូវបានស្តុកទុកតែប៉ុណ្ណោះនៅ ក្នុងឃ្លាំងរបស់នគរយូ ជាជាងទុកនៅក្នុងឃ្លាំងរបស់យើង។

នៅពេលដែលសំណូកត្រូវបានបញ្ជូនទៅដល់ស្តេចនគរយូ មានរដ្ឋមន្ត្រីម្នាក់របស់ នគរយូឈ្មោះកុងជីឈីបានព្រមានប្រឆាំងនឹងការទទួលសំណូកដោយនិយាយថា«នគរយូគឺ ចំពោះគ័រ ប្រៀបបីដូចជាមាត់ជាប់ធ្មេញ។ បុព្វបុរសរបស់យើងបានផ្តាំថាបើសិនជា មាត់ឈឺឬខូច ធ្មេញនឹងត្រូវបាននៅត្រដាងហាលខ្យល់ត្រជាក់ មានន័យថានគរគ័អាចគង់វង់ នៅបានគឺអាស្រ័យលើនគរយូ ខណៈដែលសមត្ថភាពរបស់នគរយូអាចរស់នៅឡើងវិញ បានក៏អាស្រ័យលើនគរគ័រ ប្រសិនបើយើងធ្វើជាផ្លូវសំរាប់អោយនគរជីនឆ្លងកាត់ ដូច្នេះ នៅថ្ងៃណាមួយដែលយើងឃើញថានគរគ័រវិនាសអន្តរាយនៅពេលព្រឹក បន្ទាប់មកនគរយូនឹង បាត់បង់ជួបគ្រោះថ្នាក់នៅពេលល្ងាច«! ។ ហេតុអ្វីក៏ត្រូវអោយនគរជីនឆ្លងកាត់ផ្លូវច្រក ចង្អៀតនោះ? ទោះបីជាយ៉ាងក៏ដោយស្តេចនគរយូបានបដិសេធមិនព្រមស្តាប់ការទូន្មាននោះ

ទេ ហើយនគរជីនបានទទួលច្រកផ្លូវចង្អៀតឆ្លងកាត់យ៉ាងសុវត្ថិភាព ហើយបន្តឈ្លានពាននគរគ័រ ដល់ពេលវេលានាំទ័ព ត្រឡប់មកវិញ កងទ័ពនគរជីនបានឈប់នៅនគរយូនិងវាយឈ្លានពាននគរយូ។ បន្ទាប់ពីបានកាន់កាប់រាជធានីនគរយូរួចហើយ នគរជីនបានយករតនៈសម្បត្តិមកវិញ។ លោកឧត្តមសេនីយ ស៊ុនបាននាំយកត្បូងគុជ និងសេះមកថ្វាយស្តេចនគរជីនវិញ ហើយបាននិយាយដោយរីករាយថា«គ្រាប់ត្បូងគុជរក្សាទុកស្អាតដដែល គ្មាននរណាប៉ះពាល់សោះ ប៉ុន្តែហ្វូងសេះរបស់យើងហាក់បីដូចជាដុះធ្មេញច្រើនជាងមុន«!។

## យុទ្ធសាស្រ្តទី ២៥: ជំនួសស្នាមញញឹមដោយឈើពុក

## Replace the beams with rotten timbers

បង្វិចក្បួនច្បាប់ក្បួនទ័ពសត្រូវ ធ្វើអន្តរាគមន៍រាល់គ្រប់វិធីសាស្រ្តប្រតិបត្តិការទាំងឡាយរបស់ពួកគេ ផ្លាស់ប្តូរបទបញ្ជាច្បាប់វិធានដែលពួកគេធ្លាប់បានប្រើប្រាស់ជាបន្តបន្ទាប់ធ្វើអោយសត្រូវប្រព្រឹត្តិផ្ទុយនឹងការហ្វឹកហាត់តាមស្តង់ដាររបស់ពួកគេ។ នៅក្នុងមធ្យោបាយនេះអ្នកត្រូវផ្លាស់ប្តូរសសរគ្រឹះរបស់សត្រូវ។ ចំណាងសម្ព័ន្ធការរួមដែលបង្កើតក្រុមមនុស្សរបស់សត្រូវនិងរុះរើកំលាំងប្រយុទ្ធដ៏មានប្រសិទ្ធិភាពមួយរបស់សត្រូវ។

### ឧទាហរណ៍: ប្រទេសចិននៅសម័យរាជវង្សទាំង៦ Six Dynasties Period China

នៅឆ្នាំ៣៨៣ ព្រះចៅអធិរាជហ្វូជាងនៃរាជវង្សឈីនបានដឹកនាំកងទ័ពស្រួចមួយកងមានចំនួន៥០០០ទ័ពសេះ ដោយផ្ទាល់ដៃរបស់ព្រះអង្គទៅវាយប្រហារនគរជីនដឹកនាំដោយឧត្តមសេនីយសៀសី។ ដោយមើលឃើញថាកងកំលាំងរបស់កងទ័ពនគរជីនមានចំនួចច្រើនជាងការរំពឹងទុកមុនរបស់ទ្រង់ ព្រះចៅអធិរាជបានបញ្ជាអោយកងទ័ពរបស់ទ្រង់បង្កើតទីតាំងមូលដ្ឋានការពារកងទ័ពរបស់ខ្លួននៅតាមបណ្តោយឆ្នេរច្រាំងទន្លេ។ ដោយសារហេតុនេះកងទ័ពនគរជីនបានបោះជំរុំនៅផ្នែកត្រើយម្ខាងទល់មុខគ្នា។ គ្មានភាគីណាមួយហ៊ានឆ្លងទន្លេជាមុននោះទេ ចាប់តាំងពីវាត្រូវបានល្បីថាកងទ័ពណាមួយហ៊ានឆ្លងទន្លេ កងទ័ពនោះនឹងខូចខាតបង់ច្រើន។ ឧត្តមសេនីយសីរបស់នគរជីនបានបញ្ជូនបេសកកជនម្នាក់ឆ្លងទន្លេដោយនាំទៅជាមួយសារលិខិតចុតម៉ាយដែលមានន័យថា«ព្រះអង្គម្ចាស់!កងទ័ពរបស់ទ្រង់បានចូលជ្រៅទៅក្នុងដែនដីរបស់ពួកទូលបង្គំ ហើយកំពុងដាក់ពង្រាយក្បួនទ័ពត្រៀមត្រាអឹងកងពេញឆ្នេរទន្លេ។ នេះគឺជាផែនការសំរាប់ភាពទាល់ច្រករយៈពេលវែងដែលជាប់គាំងជា

យូរមកហើយ៖តើទ្រង់ត្រូវការធ្វើសង្គ្រាមវាយប្រយុទ្ធគ្នាឬ? ប្រសិនបើទ្រង់បញ្ជាមនុស្សរបស់ទ្រង់អោយដកថយទៅកាន់ចំងាយសុវត្ថិភាព មួយ ហើយអនុញ្ញាតិអោយកំលាំងកងទ័ពយើងឆ្លងកាត់ទន្លេ ដូច្នេះយើងអាចធ្វើសង្គ្រាម វាយប្រយុទ្ធគ្នាស្លាប់រស់ ហើយដោះស្រាយបញ្ហាវិបត្តិបានឆាប់រហ័សឆាប់ដឹងសដឹងខ្មៅ ដឹងឈ្នះដឹងចាញ់យ៉ាងឆាប់រហ័ស»។ព្រះថៅអធិរាជយល់ព្រមទៅតាមសំណើរនេះ។ នៅពេលនោះក្រុមទីប្រឹក្សារបស់ទ្រង់បានជំទាស់ ព្រះអង្គហ្វូជានបានប្រាប់ពួកគេថាទ្រង់មានផែនការត្រឡប់ទ័ពបកក្បាលវាយទ័ពនគរជីន បន្ទាប់ពីកងទ័ពរបស់ពួកគេបានឆ្លងទន្លេបានពាក់កណ្តាល។ ប៉ុន្តែឧត្តមសេនីយសៀបានគិតទុកជាមុនថាព្រះថៅអធិរាជប្រាកដជាក្បត់ពាក្យសន្យា ហើយលោកបានបញ្ជូនកងឈ្លបយកការណ៍សង្កេត ធ្វើអោយទ័ពខ្លួនឃើញថាសភាពខុសធម្មតាពេលកងទ័ពអធិរាជជ្រៀតចូល។ នៅពេលព្រះថៅអធិរាជបានបញ្ជាអោយកងទ័ពរបស់ទ្រង់ដកថយ កងទ័ពខុសប្លែកពីធម្មតារបស់កងទ័ពនគរជីន បានញាំងអោយកើតភាពវន្ទត់តក់ស្លុតដោយការផ្សព្វផ្សាយពាក្យចចាមអារាមថាកងទ័ពនគរឈីនបានកំពុងដកថយក្នុងភាពបរាជ័យហើយផ្សាយទៀតថាកងទ័ពនគរជីនបានធ្វើការដេញតាមយ៉ាងក្តៅគគុក។ការដកថយយ៉ាងឆាប់រហ័សបានត្រឡប់ចូលទៅក្នុងផ្លូវមួយដែលថាកងទ័ពនគរឈីនត្រូវបានបែកហ្វូងក្បួនទ័ពបែកខ្ញែកដើម្បីរត់គេចខ្លួនយកប្រាស់អាយុ។ព្រះថៅអធិរាជនិងឧត្តមសេនីយរបស់ទ្រង់កំពុងតែត្រឡប់ទ័ពយ៉ាងប្រញាប់ប្រញាល់យ៉ាងតក់ក្រហល់បន្ទាប់ពីការដកថយរបស់ខ្លួនដើម្បីបញ្ឈប់ទ័ពនគរជីនដែលកំពុងឆ្លងទន្លេ ប៉ុន្តែគ្មានប្រយោជន៍អ្វីទាំងអស់។ កងទ័ពនគរជីនបានឆ្លងទន្លេយ៉ាងឆាប់រហ័ស ហើយវាយប្រដេញកងទ័ពនគរឈីន ធ្វើអោយកងទ័ពនគរឈីនខូចខាតបាត់បង់យ៉ាងច្រើនឥតគណនា។ ព្រះថៅអធិរាជត្រូវបានត្រូវរបួសហើយគេចភៀសខ្លួនទាំងលំបាកលំបិន។ទ្រង់ត្រូវបានចាប់ខ្លួនហើយត្រូវបានច្របាច់ករសំលាប់ក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយមក។

## យុទ្ធសាស្រ្តទី ២៦៖ ចង្អុលដើមមន ប៉ុន្តែជេរប្រទេចដើមល្ហុប

### Point at the mulberry but curse the locust tree

ដើម្បីដាក់វិន័យ ត្រួតពិនិត្យ ឬព្រមានរាល់អ្នកដទៃៗទៀតដែលឋានៈរបស់ពួកគេ ឬតំណែងរបស់ពួកគេ ដោយមិនរាប់បញ្ចូលពួកគេនៅក្នុងការប្រឈមមុខដោយផ្ទាល់នៅទេ តែដោយប្រើសទិសភាព ឬពាក្យបញ្ឆិតបញ្ឆៀងពាក្យសដៀង ព្រមទាំងសំដីបិទមុខ។ ដោយគ្មានការដាក់ឈ្មោះអោយចំៗនោះទេ ជនជាប់ចោទទាំងនោះមិន

អាចវាយតប ឬសងសឹកដោយគ្មានបង្ហាញលាតត្រដាងនៅការរួមគំនិត ឬការចូលដៃក្នុងបទល្មើសរបស់ពួកគេនោះទេ។

## ឧទាហរណ៍: ប្រទេសចិននៅសម័យរាជវង្សហាន Han Dynasty China

បន្ទាប់ពីលោកកៅជូបានក្លាយជាព្រះចៅអធិរាជ ទ្រង់បានតែងតាំងកូនចៅជាច្រើនរបស់ទ្រង់អោយកាន់តំណែង។មានថ្ងៃមួយ ខណៈដែលទ្រង់បានកំពុងដើរលំហែរតាមបណ្តោយយ៉ររបៀងរាជវាំងរបស់ទ្រង់ ព្រះអង្គបានសំគាល់ឃើញថាមានរដ្ឋមន្ត្រីមួយចំនួនបានកំពុងនិយាយពាក្យបញ្ឆិតបញ្ឆៀងដៀមដាមខ្សឹបខ្សៀវអេចអូចគ្នាមិនចេះចប់។ព្រះអង្គក៏សួរទៅកាន់ទីប្រឹក្សារបស់ទ្រង់ឈ្មោះឆាងលៀងថា«តើពួកគេកំពុងនិយាយអំពីអ្វី«? ទីប្រឹក្សាបានឆ្លើយថា«សូមក្រាបថ្វាយបង្គំព្រះអង្គម្ចាស់ជីវិតតំកល់លើត្បូង តើទ្រង់ជ្រាបទេក្រាបទូល?ពួកគេកំពុងមានផែនការក្បត់ធ្វើបដិវត្តន៍ហើយក្រាបទូល«!។ ព្រះអង្គបានឆ្លើយតបថា«ប៉ុន្តែសន្តិភាពត្រូវបានស្តារឡើងវិញហើយសំរាប់ចក្រភពរបស់យើង!ហេតុអ្វីក៏ពួកគេកំពុងមានផែនការធ្វើបដិវត្តន៍«?។ ទីប្រឹក្សាតបវិញថា«នៅពេលព្រះអង្គម្ចាស់កើតចេញពីត្រកូលរាស្រ្តសមញ្ញធម្មតាវាគឺតាមរយៈមនុស្សទាំងនេះដែលទ្រង់បានដណ្តើមអំណាចកាន់កាប់ត្រួតត្រាចក្រភពទាំងមូល។ទ្រង់បានក្លាយជាទេវបុត្រនៃស្ថានសួគ៌ ប៉ុន្តែមនុស្សទាំងនោះដែលទ្រង់បានតែងតាំងតំណែងបុណ្យសក្តិរាល់មនុស្សទាំងអស់ដែលជាមិត្តភក្តិជិតស្និតរបស់ទ្រង់កាលពីអតីតកាល។ ឥឡូវនេះរាល់ពួកមន្ត្រីវ័យក្មេងទាំងនេះនៅក្នុងជួរទ័ពរបស់ទ្រង់កំពុងដឹងច្បាស់អំពីស្នាដៃគុណសម្បត្តិរបស់ពួកគេដែលធ្វើនៅពេលកន្លងមក ពួកគេជឿថាគ្មានដីធ្លីគ្រប់គ្រាន់សមល្មមទេនៅក្នុងចក្រភពទាំងមូលសំរាប់បែងចែកអោយពួកគេទាំងអស់ទៅតាមគុណសម្បត្តិស្នាដៃរបស់ពួកគេ។ដូច្នេះមនុស្សមួយចំនួនក្នុងចំណោមពួកគេនឹងមិនត្រូវបានទទួលដីធ្លីដែលព្រះអង្គទ្រង់បែងចែកអោយនោះទេ។ ហេតុដូច្នេះពួកគេមានផែនការក្បត់ធ្វើការបះបោរនៅថ្ងៃខាងមុខ«!។ ព្រះចៅអធិរាជសួរទៀតថា«តើយើងគួរធ្វើយ៉ាងដូចម្តេច?គួរធ្វើអ្វី«?។ទីប្រឹក្សាក៏បានឆ្លើយថា»នៅក្នុងចំណោមកូនចៅបក្សពួករបស់ទ្រង់ទាំងអស់ តើមួណាដែលទ្រង់ស្អប់ជាងគេឬមិនសព្វព្រះទ័យជាងគេ«?។ព្រះចៅអធិរាជបានឆ្លើយតបថា«គឺលោកយុងឈីនិងយើងគឺជាសត្រូវនឹងគ្នាកាលពីមុន»។ទីប្រឹក្សាក៏បានផ្តល់យោបល់ថា«ទ្រង់ត្រូវតែប្រញាប់ប្រញាល់ផ្តល់អំណាចអោយលោកយុងឈីមុនអ្នកដទៃៗទៀត ហើយធ្វើអោយពួកគេដឹងនៅអ្វីដែលទ្រង់បានធ្វើចំពោះកូនចៅបក្សពួកអ្នកដែលដើរតាមទ្រង់។នៅពេលដែលពួកគេមើលឃើញថាលោកយុងឈីត្រូវបានផ្តល់អំណាចអោយនោះ ពួកគេទាំងអស់នឹងមានអារម្មណ៍ស្ងប់សុខនៅរាល់រង្វាន់ផ្ទាល់ខ្លួនរបស់ពួកគេ»។

ព្រះចៅអធិរាជយល់ព្រម ហើយប្រារព្ធពិធីជប់លៀងផ្តល់កិត្តិយសដល់លោកយុងឈីដូចជាឋានៈបុណ្យសក្តិ និងដីធ្លីជាដើម។ នៅពេលនោះរដ្ឋមន្ត្រីដទៃៗទៀតបានចាកចេញពីពិធីជប់លៀងដោយនិយាយជាមួយគ្នាប្រកបដោយក្តីសប្បាយរីករាយឥតឧបមាថា‹‹សូម្បីតែលោកយុងឈីក៏អាចក្លាយជាអភិជនធំមួយដែរ ចំណែកពួកយើងឯទៀតៗមិនចាំបាច់ព្រួយបារម្ភអ្វីនោះទេ››។

## យុទ្ធសាស្ត្រទី ២៧ៈ ធ្វើពុតជាឆ្កួតនៅខាងក្រោយភាពហ្នឹងហ្ន

## Feign Madness But Keep Your Balance

លាក់ខ្លួននៅខាងក្រោយរបាំងស្រោមមុខឆ្កួតមួយដោយពុតធ្វើជាឆ្កួត ស្រវឹងអួរទីន្ទរឡប់សតិអត់ដឹងអ្វី ដើម្បីបង្កើតភាពច្របូកច្របល់ដល់អារម្មណ៍ចេតនារបស់សត្រូវ និងធ្វើអោយសត្រូវគិតច្របូកច្របល់ គិតខុសពីបំណងចេតនារបស់អ្នក និងការដឹងហេតុផលចលនាសកម្មភាពរបស់អ្នក។ បញ្ចុះបញ្ចូលបញ្ឆោតគូរសត្រូវរបស់អ្នកអោយយល់ដឹងតែពីអសមត្ថភាពរបស់អ្នក និងប៉ាន់ប្រមាណទាបលើអ្នក លើសមត្ថភាពពិសេសរបស់អ្នករហូតដល់គូរសត្រូវរបស់អ្នកមានជំនឿជឿជាក់ជ្រុលហួសហេតុលើខ្លួនឯង ធ្វើអោយបាត់ការប្រុងប្រយ័ត្នធ្វេសប្រហែសក្នុងកិច្ចការពារខ្លួន បន្ទាប់មកអ្នកវាយប្រហារសង្គ្រប់តែម្តង។

### ឧទាហរណ៍: ប្រទេសចិននៅសម័យរាជវង្សស្វយ Sui Dynasty China

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយរបស់ព្រះចៅអធិរាជយ៉ាងនៃរាជវង្សស្វយ មានលិចឡើងនៅកំណាព្យមួយ ដែលមានន័យថាជាការប្រាប់អោយដឹងមុននៅការធ្លាក់ចុះនិងការដួលរលំរបស់ដំណាក់រាជវាំងនៃរាជវង្សស្វយ ហើយតាមទំនាយមេឃដីទេពលិខិតគឺត្រូវអោយសន្តទេពក្នុងមនុស្សត្រកូលលីធ្វើជាអធិរាជគ្រប់គ្រងចក្រភពជំនួសរាជវង្សស្វយ។ពាក្យកំណាព្យកាព្យឃ្លោងនោះបានក្លាយជាមានប្រជាប្រិយភាពយ៉ាងខ្លាំងក្លាក្នុងចំណោមប្រជ្ជុលអាក្រក់ប្រជ្ជុលក្បត់ដែលជាប្រធានបទមិនស្មោះត្រង់ចំពោះការគ្រប់គ្រងដែលមិនល្បីឈ្មោះរបស់ព្រះចៅអធិរាជយ៉ាង។ព្រះចៅអធិរាជមានជំនឿឆ្វេងជ្រុល ហើយជឿលើទំនាយដោយខ្លួនឯង បានចាប់ផ្តើមបើកយុទ្ធនាការស្រាវជ្រាវរកមនុស្សដែលមានត្រកូលលីយកទៅប្រហារជីវិត។ ព្រះអង្គបានចាប់រដ្ឋមន្ត្រីនិងមន្ត្រីជាន់ខ្ពស់ត្រកូលលីជាច្រើនព្រមទាំងគ្រួសារពួកគេទាំងមូលយកទៅប្រហារជីវិតដោយផ្តែដាវ។ មានមន្ត្រីដែលមានតំណែលតូចតាចម្នាក់ឈ្មោះលីយានបំរើការជាអ្នកមើលការខុសត្រូវក្នុងខេត្តបញ្ជូនទៅតុលាការដើម្បីកាត់ទោស។

លោកលីយានបានពន្យាពេលក្នុងការបង្ហាញខ្លួនចូលក្នុងតុលាការដោយបានអះអាងថាខ្លួនមានសុខភាពខ្សោយ។ លោកលីយានបានមានក្មួយស្រីម្នាក់ដែលធ្វើជាស្រីបំរើក្នុងព្រះបរមរាជវាំង ហើយមានថ្ងៃមួយព្រះចៅអធិរាជបានសួរនាងពីកន្លែងដែលឪពុកមាររបស់នាងស្នាក់នៅ។ ស្ត្រីរូបនោះបានឆ្លើយតបវិញថាឪពុកមាររបស់នាងមានជំងឺ។ ព្រះចៅអធិរាជបានមានព្រះបន្ទូលថា«យើងឆ្ងល់ខ្លាំងណាស់ថាតើឪពុកមាររបស់នាងព្យាយាមរកសេចក្ដីស្លាប់ខ្លួនឯងឬ«?។ នៅពេលលោកលីយានបានឮសំដីបែបនេះលោកដឹងយ៉ាងប្រាកដថាប្រសិនបើលោកគោរពតាមដិការកោះហៅហើយចូលខ្លួនទៅកាន់តុលាការ លោកនឹងគ្មានឱកាសបានវិលត្រឡប់មកផ្ទះវិញឡើយ។ ហេតុដូច្នេះលោកក៏បានធ្វើពុតជាមានជំងឺឆ្កួត ហើយបានធ្វើពុតជាក្លាយខ្លួនជាមនុស្សប្រមឹកលែងដឹងអ្វីម្នាក់។ នៅពេលដែលចារបុរសរបស់ព្រះចៅអធិរាជបានរាយការណ៍អំពីឥរិយាបថអាកប្បកិរិយារបស់លោកលីយាន។ ព្រះចៅអធិរាជមានព្រះរាជតំរិះគិតថាមនុស្សឆ្កួតលីលាម្នាក់ មិនអាចបំពេញនៅទំនាយព្យាករនោះទេ ហើយក៏មិនចាំបាច់សង្ស័យលើលោកលីយានទៅទៀតដែរ។ គួរអោយភ្ញាក់ផ្អើលក្រៃលែង រយៈពេល២ឆ្នាំក្រោយមក ព្រះចៅអធិរាជសួយបានចាត់តាំងអោយលោកលីយានទទួលបន្ទុកយោធាក្នុងសមរភូមិមួយដើម្បីការពារចក្រភពប្រឆាំងនឹងការវាយលុករបស់ពួកកុលសម្ព័ន្ធអានាព្រៃជន។ លោកលីយានបានវាយប្រហារយ៉ាងក្លាហានក្លៀវក្លាទទួលបានការគោរពស្រឡាញ់ពីកូនទាហ៊ានរបស់លោក បានយាត្រាទ័ពចូលរាជធានី ហើយបានផ្តួលរលំរាជវង្សសួយ បំពេញតាមទំនាយព្យាករបង្កើតនៅរាជវង្សថាំងដ៏រុងរឿងមួយ។

## យុទ្ធសាស្ត្រទី ២៨៖ បញ្ចុះបញ្ចូលបញ្ឆោតសត្រូវឲ្យឡើងដំបូលផ្ទះ បន្ទាប់មកយកជណ្តើរចេញ

**Lure your enemy onto the roof, then take away the ladder**

ដោយការដាក់នុយនិងការបោកបញ្ឆោតបញ្ចុះបញ្ចូលសត្រូវ បញ្ឆោតសត្រូវអោយចូលក្នុងដែនដីអន្ទាក់របស់អ្នក។ បន្ទាប់មកកាត់ផ្តាច់នៅរាល់ខ្សែបណ្តាញទំនាក់ទំនងរបស់ខ្មាំង និងផ្លូវគេចភៀសខ្លួនរបស់ខ្មាំង ដើម្បីស្រោយស្រង់ស្ថានការណ៍របស់ពួកគេ ហើយអ្នកត្រូវតែវាយប្រហារតបតទាំងកងកំលាំងផ្ទាល់របស់អ្នក និងទាំងកត្តាធម្មជាតិ។

## ឧទាហរណ៍: ប្រទេសចិននៅសម័យរាជវង្សហាន Han Dynasty China

បន្ទាប់ពីបានបង្ក្រាបរាជាណាចក្រវៃដែលបានបះបោរកន្លងមក រាជវង្សហានដ៏ល្បីល្បាញបានដឹកនាំដោយឧត្តមសេនីយហាន់សីន ត្រូវបានបញ្ជូនអោយទៅបង្ក្រាបរាជា

ណាចក្រ២ដទៃទៀតដែបានបះបោរធ្វើបដិវត្តន៍គឺ នគរឈី និងនគរឈូ។ លោកឧត្តមសេនីយហាន់សីន ត្រូវបានបញ្ជូនទៅកាន់នគរឈី ប៉ុន្តែនគរឈូបានបញ្ជូនឧត្តមសេនីយរបស់ខ្លួនឈ្មោះឡុងឈូដោយមានកងកំលាំងទ័ពចំនួន២០០០០០នាក់ទៅវាយស្ទាក់ការឈ្លានពានរបស់រាជវង្សហានទៅលើនគរឈី។ឧត្តមសេនីយហាន់បានបញ្ជាអោយមនុស្សរបស់គាត់ទៅច្រកបំពេញបាវខ្សាច់ចំនួន១០០០០បាវ ហើយយកបាវខ្សាច់ទាំងអស់ទៅធ្វើទំនប់ទឹកទន្លេមិនអោយហូរចុះ។ នៅពេលព្រឹកបន្ទាប់មក ឧត្តមសេនីយហាន់បានដឹកនាំកងទ័ពរបស់ខ្លួនឆ្លងកាត់ទីទាបនៃទន្លេ ហើយបានវាយប្រហារនគរឈូ ប៉ុន្តែបន្ទាប់ពីការចូលប្រយុទ្ធរយៈពេលខ្លីមួយ កងទ័ពរបស់ឧត្តមសេនីយហាន់បានធ្វើពុតជាចុះចាញ់ ហើយបានភៀសខ្លួនដកមកក្រោយវិញឆ្លងកាត់ទន្លេ។ ឧត្តមសេនីយឡុងឈូបានប្រកាសថា ‹‹ឃើញទេ ខ្ញុំដឹងថាលោកឧត្តមសេនីយហាន់សីងជាមនុស្សកំសាកញី›› ហើយលោកបានបានដឹកនាំកងទ័ពរបស់ខ្លួនឆ្លងកាត់ទន្លេដេញតាមទ័ពរបស់ឧត្តមសេនីយហាន់។តាមរយៈសញ្ញាដែលបានត្រៀមបំរុងទុកជាមុនមួយ លោកឧត្តមសេនីយហាន់ បាន បញ្ជូនមនុស្សរបស់លោកទំលាយទំនប់ទឹកដែលទុបទឹកនោះ។ កងទ័ពរបស់ឧត្តមសេនីយ ឡុងឈូ ជាងពាក់កណ្តាលដែលបានឆ្លងកាត់ទន្លេត្រូវបានទឹកជំនន់ជន់ជោរបោកបក់កាត់ផ្តាច់កងទ័ពឧត្តមសេនីយឈូអោយលង់លិចទឹកស្លាប់នៅពាក់កណ្តាលស្ទឹង។ ឧត្តមសេនីយហាន់បានត្រឡប់ទ័ពពីការដកថយឡោមព័ទ្ធខ្លាំងជារាងរង្វង់ បន្ទាប់ពីត្រឡប់ក្បាលទ័ពវិញបានវាយប្រហារកងទ័ពស្រួចរបស់នគរឈូសំលាប់លោកឧត្តមសេនីយឡុងឈូរបស់នគរឈូ។ កងទ័ពដែលសេសសល់របស់នគរឈូបានភ័យតត់ស្លុត ហើយបានភៀសខ្លួនចេញគ្រប់ច្រកទិសទីទាំងអស់ ប៉ុន្តែត្រូវបានចាប់បានជាបន្តបន្ទាប់ដោយទាហ៊ានរបស់លោកឧត្តមសេនីយហាន់សីង។

## យុទ្ធសាស្រ្តទី ២៩: ចងផ្កាសូត្រលើដើមឈើងាប់ Tie silk blossom to the dead tree

ការចងផ្កាសូត្រលើដើមឈើងាប់មួយបានផ្តល់នៅការបោកស្និនភ្នែកបញ្ឆោតអោយគេមើលឃើញថាដើមឈើមានសោភ័ណ្ឌភាពស្រស់បំព្រងរស់រវើក។ តាមរយៈការប្រើប្រាស់ល្បិចកលធ្វើអ្វីមួយអោយខុសប្លែកពីធម្មតាគឺមានន័យថា ‹‹គ្មានតំលៃគឺធ្វើអោយមានតំលៃ គ្មានប្រយោជន៍គឺធ្វើអោយមានប្រយោជន៍ មិនមានគឺធ្វើអោយមាន មិនពិតគឺធ្វើអោយពិតគ្មានការគំរៀមកំហែងគឺធ្វើអោយមានគ្រោះថ្នាក់››។

## ឧទាហរណ៍: ប្រទេសចិននៅសម័យរាជាណាចក្រ៣ Three Kingdom Period China

នៅកំឡុងឆ្នាំចុងក្រោយនៃរាជាណាចក្រ៣ លោកសីម៉ាអី បានវាយដណ្តើមយករាជបល្ល័ង្កនគរវៃ ហើយបានតែងតាំងខ្លួនឯងជាព្រះមហាក្សត្រ និងផ្លាស់ឈ្មោះរាជាណាចក្រពីនគរវៃទៅជានគរជីន។ ពត៌មាននេះបានលិចឮទៅដល់ស្តេចប្រទេសជិតខាងរបស់នគរវៃគឺវូនគរដែលដឹងថា នគររបស់ទ្រង់ជាគោលដៅបន្ទាប់របស់ត្រកូលសីម៉ា ដែលប្រកបដោយមហិច្ឆិតាខ្ពស់ធំក្រៃលែង។ ព្រះអង្គបានបារម្ភយ៉ាងខ្លាំងថាព្រះអង្គទ្រង់នឹងសោយទីវង្គត់ក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខទៀត ទ្រង់ក៏បានផ្ទេររាជបល្ល័ង្កអោយព្រះរាជបុត្ររបស់ទ្រង់ឈ្មោះស៊ុនហាវអោយគ្រងរាជ្យបល្ល័ង្កនគរវូ ហើយមួយរំពេចនោះព្រះអង្គស៊ុនហាវមានក្តីសប្បាយរីករាយ ហើយធ្វេសប្រហែសរាល់កិច្ចការរាជនគរ។ អស់រយៈពេលពីរបីឆ្នាំក្រោយមក ស្តេចនគរវូបានកើតជំងឺឆ្កួតយ៉ាងឆាប់រហ័សនិងធ្ងន់ធ្ងរទៅៗ ហើយទីប្រឹក្សាព្រះអង្គទាំង១២ និងពួកមេទ័ពរបស់ទ្រង់ និងបណ្តាក្រុមគ្រួសារទាំងមូលរបស់ពួកគេត្រូវបានប្រហារជីវិតទៅលើរាល់គ្រប់បញ្ហាសង្ស័យបន្តិចបន្តួច ហើយជាលទ្ធផលទ្រង់ត្រូវបានប្រជារាស្ត្រជេរប្រមាថពាស់ពេញរាជនគរ។ ដោយដឹងឮថាប្រជាជននគរវូបានជេរប្រមាថទ្រង់ ព្រះអង្គសីម៉ាទ្រង់ជ្រាបហើយក៏បញ្ជាកងទ័ពជើងទឹកវាយប្រហារនគរវូ ដឹកនាំដោយមេទ័ពវាងឈុន។ ព្រះអង្គម្ចាស់នគរវូគ្មានយោបល់អ្វីបញ្ចេញប្រឆាំងនឹងការវាយប្រហាររបស់ទ័ពនាវារបស់លោកសីម៉ាទេ។ ព្រះអង្គបានកោះប្រជុំទីប្រឹក្សាព្រះរាជបល្ល័ង្កសេសសល់ ហើយមានទីប្រឹក្សាម្នាក់បានអត្ថាធិប្បាយពីយុទ្ធសាស្រ្ត ប្រើរបាំងឬស្សីចាក់ច្រែះប្រច្រាស់គ្នាមួយឆ្លងកាត់ទន្លេដើម្បីការពារទ័ពនាវារបស់លោកសីម៉ាកុំអោយចូលនគរវូរាជធានីជាងយិ។ ព្រះអង្គបានយល់ព្រមប្រើខ្សែចងរបាំងឬស្សីធំៗបញ្ច្រាស់គ្នាចងទាញខាងក្រោមបាតទន្លេ។ នៅពេលដែលលោកមេទ័ពវាងឈុនដឹងអំពីយុទ្ធសាស្រ្តរបាំងឬស្សីគាត់សើចហួសចិត្ត បញ្ជាអោយមនុស្សរបស់គាត់សាងក្បូនធំៗធ្វើពីក្តារបន្ទះដោយដាក់រូបសំណាកទីងម៉ោងធ្វើពីចំបើងស្លៀកពាក់ខោឈរកាន់អាវុធដោយជ្រលក់ប្រេងនិងដាក់ចងភ្ជាប់ជាមួយគន្លឹះភ្លើងសំរាប់ដុតទីងម៉ោង ហើយនៅពេលក្បូននានាទៅប៉ះរបាំងឬស្សី ក្បូននោះត្រូវបានដុតរបាំងឬស្សីឆេះអស់ ហើយបានបន្តអណ្តែតចុះតាមខ្សែទឹកទៅដល់រាជនគរវូ។ រាល់ឧបសគ្គនានាធ្វើពីរបាំងឬស្សីត្រូវបានបំផ្លាញដោយក្បូនទីងម៉ោងដែលឆេះយ៉ាងសន្ធោសន្ធៅ ពេលទ័ពនគរវូឃើញក្រុមនាវានិងក្រុមមនុស្សដែលមានភ្លើងឆេះសន្ធោសន្ធៅមកដល់ មានការភ័យឆក់ស្លុតភៀសខ្លួនទាំងញ័ររន្ធត់អស់ព្រលឹងពីខ្លួន។ ទីបំផុតលោកសីម៉ាបានកាន់កាប់នគរវូ ហើយបានបន្តបង្កើតរាជវង្សជីនដែលមានអាយុខ្លីមួយ។

## យុទ្ធសាស្រ្តទី ៣០: ដោះដូរតួនាទីភ្ញៀវធ្វើជាម្ចាស់ផ្ទះវិញ

### Exchange the role of guest for that of host

ការផ្ចាញ់សត្រូវពីខាងក្នុងដោយជ្រៀតចូលជំរុំសត្រូវនៅក្រោមរូបភាពខាងក្រៅជាកិច្ចសហប្រតិបត្តិការ ការចុះចូល ឬសន្ធិសញ្ញាសន្តិភាព។ នៅក្នុងមធ្យោបាយនេះ អ្នកអាចរកឃើញចំណុចខ្សោយរបស់សត្រូវ ហើយបន្ទាប់មកនៅពេលការប្រុងប្រយ័ត្នរបស់សត្រូវចុះខ្សោយ កិច្ចការពារធ្វេសប្រហែស ពួកឆ្មាំការពារសត្រូវឈប់សំរាក យើងត្រូវតែវាយប្រហារសត្រូវដោយផ្ទាល់នៅរាល់គ្រប់ប្រភពកំលាំងរបស់សត្រូវ។

**ឧទាហរណ៍: រឿងនិទានរបស់ជប៉ុន**

នៅសម័យសក្កិភូមិរបស់ជប៉ុនទីនោះលោកគ្រូកិនដូជាទីគោរពម្នាក់ដែលបានសម្រេចចិត្តធ្វើតេស្តប្រលងដល់កូនសិស្សដែលមានឋានៈដ៏ខ្ពង់ខ្ពស់បំផុត៣នាក់របស់គាត់។ គាត់បាននាំសិស្សរបស់គាត់ម្តងមួយៗអោយចូលទៅក្នុងវិហារបុរាណមួយនៅក្បែរភ្នំជាកន្លែងដែលគាត់បានប្រាប់សិស្សនិមួយដូចខាងក្រោម:

‹‹អ្នកបានសិក្សារៀនសូត្រជាមួយខ្ញុំអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ឥឡូវនេះខ្ញុំចង់ឃើញថាការបង្រៀនរបស់ខ្ញុំមានប្រយោជន៍ឬអត់? ខ្ញុំនៅទីនោះនៅក្នុងវិហាររងចាំការប្រលងតេស្តរបស់អ្នក បើអ្នកណាប្រលងជាប់ អ្នកនោះបានឡើងថ្នាក់››។

នៅក្នុងព្រះវិហារដ៏ងងឹតដុតភ្លើងទៀនភ្លឺផ្លូងៗ លោកគ្រូបានលាក់ខ្លួនដោយមានក្រុមពួកសាមូរៃមានគ្នាចំនួន៩នាក់មានអាវុធជាដំបងព្រនង់ ហើយត្រូវបានណែនាំអោយហក់លោតស្ទុះវាយប្រហាររាល់អ្នកណាម្នាក់ដែលបានចូលទៅក្នុងព្រះវិហារ។ សិស្សទី១បានចូលទៅក្នុងព្រះវិហារ ហើយមុនពេលរបស់គាត់សំរបសំរួលឬស៊ាំទៅនឹងពន្លឺ ត្រូវបានធ្វើអោយភ្ញាក់ផ្អើល និងត្រូវបានវាយដោយពួកសាមូរៃ។ លោកគ្រូបានមានប្រសាសន៍ថា »ខ្ញុំសូមទោស អ្នកបានប្រលងធ្លាក់ហើយ!«។

សិស្សទី២បានចូលទៅក្នុងព្រះវិហារហើយបានដឹងជាមុនថាពួកអ្នកលបលួចវាយប្រហារគាត់ក៏ស្ទុះគេចខ្លួនយ៉ាងស្វាត់ជំនាញចេញពីការវាយប្រហាររបស់ពួកគេ ហើយបានផ្ចាញ់ពួកគេ សិស្សដែលបានរត់គេចចេញក្រៅព្រះវិហារប្រកបដោយជ័យជំនះប៉ុន្តែជាថ្មីម្តងទៀតលោកគ្រូបានមានប្រសាសន៍ថា»ខ្ញុំសុំទោស! អ្នកប្រលងធ្លាក់ហើយ«!។

ចុងបញ្ចប់ សិស្សទី៣ត្រូវបាននាំទៅកាន់ព្រះវិហារ ហើយត្រូវបានប្រាប់អំពីការធ្វើ តេស្តប្រលង។ សិស្សនោះបានឆ្លើយតបថា «ប៉ុន្តែលោកគ្រូគឺជាមនុស្សជាទីគោរពរបស់ខ្ញុំ បញ្ញាក្បួនច្បាប់ពិធីការចែងថាការចូលទៅក្នុងព្រះវិហារមួយនោះ ជានិច្ចជាកាលលោកគ្រូត្រូវតែនាំមុខសិស្ស ប្រសិនបើលោកគ្រូមិនយល់ទាស់ទេ សូមលោកគោរពអញ្ជើញ ខ្ញុំនឹងដើរតាមលោកគ្រូចូលទៅកាន់ព្រះវិហារ»។ លោកគ្រូក៏បានឆ្លើយតបវិញថា «អ្នកជាមនុស្សឆ្លាតមែន! អ្នកបានរៀននៅរាល់អ្វីៗគ្រប់យ៉ាងទាំងអស់ដែលខ្ញុំអាចបង្រៀនអ្នក»។

## យុទ្ធសាស្ត្រទី ៣១: យុទ្ធសាស្ត្រស្រីស្រស់ The Strategy of Beautiful Women

បញ្ជូនស្រីស្រស់ស្រីស្អាតៗទៅអោយសត្រូវរបស់អ្នកជាសំងាត់កុំអោយសត្រូវរបស់អ្នកដឹងដើម្បីបង្ករបង្កើតជំលោះឈ្លោះទាស់ទែងគ្នានៅក្នុងជំរុំរបស់សត្រូវ និងបង្ករចេញជាការមិនព្រមព្រៀង មិនទុកចិត្តគ្នានៅក្នុងជំរុំ ឬទីតាំងរបស់សត្រូវ។ យុទ្ធសាស្ត្រនេះអាចដំណើរការក្នុងកំរិត៣យ៉ាងគឺ:

ទី១/ធ្វើអោយអ្នកគ្រប់គ្រងបានក្លាយជាងុបងល់ឈ្លក់វង្វេងនឹងសំរស់ លង់លក់ក្នុងតណ្ហារដែលធ្វើអោយសត្រូវធ្វេសប្រហែសនឹងការងារ ព្រមទាំងព្រងើយកន្តើយនឹងភារកិច្ចកាតព្វកិច្ចរបស់ខ្លួន ហើយធ្វើអោយការប្រុងប្រយ័ត្នរបស់សត្រូវថយចុះរួមតូចទៅៗនាំអោយសកម្មភាពការពាររបស់សត្រូវសោយចេញ និងកាន់តែខ្សោះទៅៗ។

ទី២/ធ្វើអោយមនុស្សប្រុសដទៃៗទៀតនៅក្នុងរាជវាំងឬជំរុំទីតាំងរបស់ខ្មាំងនឹងចាប់ផ្តើមសំដែងចេញឥរិយាបថឈ្លានពាន អាកប្បកិរិយាឈ្លើយច្រលើសបើស ជ្រួលជ្រើម បង្ហាញផ្លូវចិត្តចង់បានស្រីស្រស់នោះដែរ កើតចេញចិត្តប្រមាថថ្នាក់ដឹកនាំ ច្រណែននឹងមេដឹកនាំមានចេតនាប៉ងរកមធ្យាបាយក្បត់ចង់ប្លន់ដណ្តើមយកស្រីស្រស់នោះពីមេដឹកនាំដែលធ្វើអោយភ្លើងចិត្តឆេះសន្ធោសន្ធៅបង្កើតការរាំងស្ទះផ្សេងៗ បង្កើតឧបសគ្គផ្សេងៗរារាំងដល់កិច្ចសហប្រតិបត្តិការ និងកំពុងបំផ្លាញទឹកចិត្តមេទ័ព ឧត្តមសេនីយ កូនទាហ៊ាន។ល។

ទី៣/ស្ត្រីដទៃៗទៀតនៅក្នុងព្រះបរមរាជវាំងត្រូវបានជំរុញទឹកចិត្តអោយកើតចេញជាការច្រណែននិងការប្រច័ន្ទ ផ្គន្ធាឈ្នានីស ក្តៅក្រហាយនៅក្នុងចិត្ត ចាប់ផ្តើមបង្កើតផែនការក្បត់ ធ្វើគំរោងការសំងាត់ បង្កើតចេញនៅស្ថានការណ៍ក្តៅក្រហាយជាបន្តបន្ទាប់ បង្កើតភាពច្របូកច្របល់ក្នុងរាជវាំង កើតចេញជាបក្សពួកក្បត់បំផ្លាញគ្នាទៅវិញទៅមក បំផ្លាញផែនការសំងាត់ប្រទេសជាតិ ធ្វើអោយខូចកិច្ចការធំៗរបស់ប្រទេសជាតិ។

## ឧទាហរណ៍ៈ ប្រទេសចិននាសម័យរាជវង្សហាន Han Dynasty China

នៅឆ្នាំ១៩៩មុនគ្រឹស្តសករាជ ព្រះចៅអធិរាជរាជវង្សហានឈ្មោះថាព្រះអង្គការជូត្រូវបានដឹកនាំកងទ័ពដោយផ្ទាល់ព្រះអង្គប្រឆាំងនឹងការឈ្លានពានរបស់កុលសម្ព័ន្ធឈ្មោះសៀនន្ទូ។ ទោះបីជាយ៉ាងណាក៏ដោយព្រះចៅអធិរាជមិនបានយាត្រាទ័ពប្រឆាំងនឹងពួកកុលសម្ព័ន្ធដ៏ប៉ិនប្រសព្វនោះទេ ហើយព្រះអង្គត្រូវបានដឹកនាំទ័ពចូលក្នុងអន្ទាក់មួយរបស់ពួកកុលសម្ព័ន្ធនិងបានទទួលរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ខាតបង់ជីវិតទ័ពជាច្រើន។ ព្រះអង្គនិងទ័ពសេសសល់របស់ទ្រង់បានដកថយទៅកាន់ក្រុងភីងឆឹងដើម្បីភៀសខ្លួន ប៉ុន្តែត្រូវបានឡោមព័ទ្ធដោយកងទ័ពសេះចំនួន៣០០០០០នាក់។ នៅទីនោះ ព្រះចៅអធិរាជនៅតែស្ថិតនៅក្នុងការឡោមព័ទ្ធអស់រយៈពេល៧ថ្ងៃ ដោយគ្មានលទ្ធភាពនាំចូលនៅស្បៀងបរិក្ខាសឹកសំរាប់ពង្រឹងកងទ័ពអោយរឹងមាំនោះទេ។ ព្រះចៅអធិរាជបានគិតថានៅទីនេះគ្មានអ្វីដែលនៅសេសសល់ដើម្បីធ្វើកិច្ចការសឹកទៀតបានទេ ប៉ុន្តែមានតែការចុះចាញ់តែប៉ុណ្ណោះ នៅពេលនោះទីប្រឹក្សារបស់ទ្រង់ឈ្មោះឆឹនភីងបានចូលមកដល់ជាមួយនឹងយុទ្ធសាស្ត្រដទៃៗទៀត។ លោកឆិនភីងបានមានរូបគំនូរមួយគូររូបអ្នកម្នាងដ៏ស្រស់ស្អាតម្នាក់ ហើយគាត់បានប្រគល់ជាសំងាត់អោយទៅប្រពន្ធរបស់មេបញ្ជាការស្យុងនូ។ អមជាមួយរូបគំនូរគាត់បានផ្ញើរសារលិខិតមួយដែលសរសេរថាៈ«ព្រះចៅអធិរាជរបស់ទូលបង្គំមានបំណងចុះចាញ់ស្វាមីរបស់ព្រះនាងដើម្បីបំពេញព្រះហឫទ័យស្វាមីរបស់ព្រះនាងដែលទទួលជោគជ័យព្រះចៅអធិរាជនឹងបញ្ជូនអំណោយស្រីស្រស់ស្អាតដ៏ល្បីម្នាក់របស់ចិនអោយស្វាមីរបស់ព្រះនាងដើម្បីធ្វើជាស្រីស្នំរបស់ទ្រង់»។ នៅពេលប្រពន្ធរបស់លោកមេបញ្ជាការស្យុងនូបានឃើញរូបគំនូរនិងបានអានសំបុត្រហើយ កត់សំគាល់ឃើញថាព្រះនាងកើតចិត្តឆ្កួតលីលាប្រច័ណ្ឌនឹងស្វាមីរបស់ព្រះនាង។ ដោយសារការភ័យខ្លាចការប្រកួតប្រជែងសំរស់គ្នាជាមួយនឹងរូបគំនូរស្រីស្អាតនោះ និងព្រួយបារម្ភខ្លាចរូបគំនូរស្រីស្អាតលួចក្តីស្រឡាញ់ស្វាមីរបស់នាង ឆក់ប្តីនាងបាត់នោះ ព្រះនាងបានបញ្ចុះបញ្ចូលប្តីនាងបញ្ឈប់ការឡោមព័ទ្ធ និងត្រឡប់ទៅកាន់ភូមិកំណើតវិញ។ នៅពេលព្រឹកបន្ទាប់មក នៅពេលព្រះចៅអធិរាជបានក្រោកពីក្រឡាបន្ទំព្រះអង្គបានឃើញពួកកុលសម្ព័ន្ធស្យុងនូបានចាកចេញ ហើយទ្រង់អាចត្រឡប់ទៅកាន់រាជធានីប្រកបដោយសុវត្ថិភាព។

## យុទ្ធសាស្រ្តទី៣២៖ យុទ្ធសាស្រ្តបើកក្លោងទ្វាក្រុង The Strategy of Open City Gates

នៅពេលសត្រូវមានកំលាំងទ័ពច្រើនលើសលុបខ្លាំងជាងយើងហួសហេតុពេកនោះ ហើយស្ថានការណ៍របស់អ្នកដុនដាបខ្លាំងពេកដែលអ្នកសង្ឃឹមថា នឹងត្រូវឈ្លានពានក្នុងពេល ឆាប់ៗនោះ ហេតុនោះអ្នកត្រូវតែទំលាក់ចោលរាល់ពុតត្បុតទាំងអស់នៃការត្រៀមរៀបចំកងកំលាំងយោធា ហើយធ្វើសកម្មភាពអ្វីមួយដោយចៃដន្យ។ លុះត្រាណាតែសត្រូវរបស់អ្នកគិតលំអិតថាពិពណ៌នាយ៉ាងត្រឹមត្រូវមួយនៅស្ថានការណ៍របស់អ្នកថាមានអាកប្បកិរិយាឥរិយាបថមិនធម្មតា និងបង្កើតការសង្ស័យច្រើនមិនចេះចប់។ បើសំណាងល្អ សត្រូវនឹងបោះបង់ចោលការវាយសង្គ្រប់ឬត្រូវបានឃាត់ឃាំងដោយទូន្មានហាមមិនអោយវាយប្រហារ។

## ឧទាហរណ៍ប្រទេសចិននាសម័យរាជាណាចក្រ៣៖ Three Kingdoms Period China

នៅឆ្នាំ២៣៩មុនគ្រឹសសករាជលោកខុងមិញគឺជាអ្នករៀបយុទ្ធសាស្រ្តដ៏ល្បីល្បាញរបស់នគរស៊ុ បានចាប់ផ្តើមធ្វើការវាយប្រហារមួយប្រឆាំងនឹងនគរវៃ ដោយកំពុងតែបញ្ជូនកងទ័ពស្រួចមួយកងទៅឈ្លបយកការណ៍ពីសត្រូវ។ លោកសឺម៉ាអី កំពុងតែដឹកនាំកងទ័ពនគរវៃ មានកងទ័ពស្រួចចំនួន៥០០០០នាក់ ហើយកងទ័ពនគរទាំងពីរបានពើបប្រយុទ្ធគ្នា និងចាប់ដៃក្នុងសមរភូមិ ប៉ុន្តែកងទ័ពនគរវៃមានចំនួនច្រើនសន្ធឹកសន្ធាប់បានទទួលជ័យជំនះនៅថ្ងៃនោះ។ កងទ័ពស្រួចរបស់នគរស៊ុដែលបានចាញ់សឹកបានប្រញាប់ប្រញាល់ដកថយទៅកាន់ តួទ័ពធំរបស់កងទ័ពខុងម៉េងដែលទាហ៊ានរបស់ពួកគេមើលទៅហាក់បីដូចជាភ័យតក់ស្លុតក្នុងការជួបមុខសមមិត្តរបស់ពួកគេ ធ្វើអោយលោកខុងម៉េងគិតថាទ័ពសត្រូវកំពុងដេញតាមពួកគេហើយពួកគេបានភៀសសឹកយ៉ាងភ័យស្លុតឥតឧបមារ។ លោកខុងម៉េងនិងអង្គរក្សពីរបីនាក់បានភៀសខ្លួនចូលទៅកាន់ក្រុងយ៉ាងភីង ដោយមានកងទ័ពរបស់នគរវៃដេញតាមយ៉ាងក្តៅគគុកប្រកិតៗគ្នា។ ដោយសារកងទ័ពនគរវៃដ៏ច្រើនលើសលុបបានធ្វើការឡោមព័ទ្ធមិនអោយដកថយរួច ស្ថិតក្នុងការឡោមព័ទ្ធបែបនេះ លោកខុងម៉េងបានសំដែងនិងប្រើប្រាស់នៅ យុទ្ធសាស្រ្តដែលជាមធ្យាបាយដោះស្រាយចុងក្រោយបំផុតមួយដែលធ្វើអោយគាត់មានកេរ្តិ៍ឈ្មោះល្បីល្បាញពាសពេញនគរចិន។ លោកខុងម៉េងបានរុះរើផ្លាស់ប្តូរផ្ទាំការពារកំពែង ក្រុងចេញទាំងអស់ ហើយយកទុងជ័យចំបាំងចេញពីកំពែងទាំងអស់ យកទ័ពការពារកំពែង ចេញអស់ ហើយបញ្ជាអោយបើកទ្វារកំពែងក្រុងទាំង៤បើកចំហរ។ នៅពេលលោកសឺម៉ាអី មើល

ឃើញមានតែមនុស្សចាស់ៗពីរបីនាក់កំពុងតែបោសសំរាមយ៉ាងស្ងប់ស្ងាត់ និងបោសដីនៅក្រៅក្លោងទ្វាក្រុង។ រីឯលោកខុងម៉េងបានកំពុងតែអង្គុយលើប៉មមួយរបស់កំពែងញញឹមនិងដេញពិណរបស់គាត់យ៉ាងពិរោះ។លោកសឺម៉ាបានកត់សំគាត់ឃើញសភាពបែបនេះក៏និយាយទៅកាន់ក្រុមទីប្រឹក្សារបស់គាត់ថា:«បុរសនោះហាក់បីដូចជាសប្បាយចិត្តខ្លាំងណាស់ ខ្ញុំស្តាប់សំលេងពិណរបស់គាត់ពិរោះរណ្តំចិត្តខ្លាំងណាស់ គ្មានអ្វីគួរអោយសង្ស័យនោះទេ លោកខុងម៉េង ប្រាកដជារៀបគំរោងប្រើល្បិចដាក់អន្ទាក់យើងព្រោះបទភ្លេងដ៏ពិរោះរណ្តំបង្កប់ដោយអាថ៌កំបាំងក្នុងចិត្ត ចាំបំផ្លាញយើងអោយវិនាសអន្តរាយពេលយើងចូលអន្ទាក់របស់ពួកគេ«។ នៅពេលឈរស្តាប់សំលេងពិណបទភ្លេងដេញពិណមានចង្វាក់លោតចុះឡើងបទភ្លេងរបស់លោក ខុងម៉េង ឡើងគ្រលួចឡើងចុះហាក់បីដូជជាបង្ហាញនៅប្រថ្នុលដ៏អាក្រក់ ហើយសំលឹងមើលឥរិយាបថពិសេសបែបហ្នឹងរបស់ខុងម៉េងគួរអោយសង្ស័យខ្លាំងណាស់ ធ្វើអោយលោកសឺម៉ាអី បានត្រឡប់កងទ័ពរបស់លោកចាកចេញទៅលោកខុងម៉េង និងកងទ័ពសេស សល់របស់លោក បានចេញដំណើរនៅក្នុងទិសដៅផ្ទុយគ្នាហើយកងទ័ពត្រឡប់ទៅកាន់រាជធានីរបស់ពួកគេប្រកបទៅដោយសុវត្ថិភាពតាមផ្លូវធ្វើដំណើរ។

## យុទ្ធសាស្ត្រទី៣៣៖ យុទ្ធសាស្ត្រសាបព្រុសបង្ករបញ្ហាអោយសត្រូវចលាចល

## The Strategy of Sowing Discord

កំណត់អោយច្បាស់នៅសមត្ថភាពលទ្ធភាពសត្រូវរបស់អ្នកដើម្បីធ្វើការវាយប្រហារជាសំងាត់ដោយបង្ករបញ្ហាធ្វើអោយប្រជាជន កងទ័ព មេទ័ព និងឧត្តមសេនីយរបស់ខ្មាំងបះបោរត្រឡប់ទៅប្រឆាំងខ្មាំងវិញ ធ្វើអោយមនុស្សរបស់ខ្មាំងបង្កើតចលាចលប្រឆាំងនឹងខ្មាំងវិញធ្វើអោយមានជំល្លោះទំនាស់រវាងខ្មាំង និងខ្មាំងគ្នាឯងដូចជារវាងមិត្តភ័ក្ក សម្ព័ន្ធមិត្ត ទីប្រឹក្សាគ្រួសារ ឧត្តមសេនីយ មេទ័ព កូនទាហ៊ាន និងប្រជាពលរដ្ឋរបស់ពួកខ្មាំង។ ខណ:ដែលសត្រូវបានខ្វល់ខ្វាយអំពល់ទុក្ខរវល់ដោះស្រាយបញ្ហាជំលោះផ្ទៃក្នុងរបស់ខ្លួនសមត្ថភាពរបស់ខ្មាំងចុះខ្សោយនៅក្នុងការវាយប្រហារ និងការពារ ព្រោះសត្រូវរវល់តែជាប់ដៃដោះស្រាយបញ្ហាសំរបសំរួលដោះស្រាយវិបត្តិផ្ទៃក្នុង ជាឱកាសយ៉ាងល្អសំរាប់អ្នកក្នុងការវាយលុក បំផ្លាញខ្មាំង។

### ឧទាហរណ៍ប្រទេសចិនសម័យរាជវង្សទាំង៦៖ Six Dynasties Period China

នៅពេលចុងក្រោយនៃរាជវង្សវៃ ព្រះចៅអធិរាជឈ្មោះតៃវូ បានដឹកនាំកងទ័ព ចំនួន១០០០០០នាក់ប្រឆាំងនឹងឧត្តមសេនីយសុងឈ្មោះចាងជី។ ព្រះចៅអធិរាជមានកងទ័ព ខ្លាំងពូកែច្រើនលើសលុប បានវាយប្រដេញកងទ័ពឧត្តមសេនីយចាងជី រហូតទៅដល់ ទីក្រុង យុ កន្លែងដែលគាត់ទាល់ច្រក។ ទីក្រុងមានបន្ទាយរឹងមាំខ្លាំងពូកែ ការពារខ្លួនយ៉ាង សុវត្ថិ ភាព ហើយដូច្នេះព្រះចៅអធិរាជចមានផែនការធ្វើការឡោមព័ទ្ធក្រុង ហើយធ្វើអោយពួក អ្នក ការពារក្រុងអត់បាយស្លាប់ដាច់ស្បៀង ជួបគ្រោះទុរភិក្សព្រមទាំងចុះចាញ់ទ្រង់តែម្តង។ ប្រកបដោយអារម្មណ៍ជឿជាក់លើជំហាររបស់ខ្លួន ព្រះចៅអធិរាជបានបញ្ជូនរទេះសេះមួយ ដឹក ផ្ទុកទៅដោយពាងស្រាធំមួយទៅកាន់ក្លោងទ្វាក្រុងជាប់ជាមួយសារលិខិតមួយស្នើរសុំអោយ មានការដោះដូរស្រាគ្នាតាមប្រពៃណីមុននឹងការចាប់ផ្តើមឡោមព័ទ្ធទីក្រុងរបស់ទ្រង់។ លោក ឧត្តមសេនីយចាងជី បានដឹងថាគាត់បានត្រូវការវាយប្រយុទ្ធធ្វើសង្គ្រាមក្នុងសមរភូមិ អោយ បានឆាប់រហ័ស ទើបគេចផុតពីការបរាជ័យ ព្រោះបើបណ្តោយអោយឱកាសកន្លង ផុតទៅ កាលណាពន្យាពេលយូរ នាំអោយកងទ័ពរបស់គាត់ដាច់ស្បៀង អស់ស្បៀង អស់អាវុធ និងគ្រាប់រំសេវ ហើយនឹងបរាជ័យដោយចៀសមិនផុត។ លោកក៏បានបញ្ជូន ទាហ៊ាន របស់គាត់ទៅទទួលយកពាងស្រាដោយសំដែងនៅសេចក្តីថ្លែងអំណរគុណ ហើយ លោក បានផ្ញើរត្រឡប់ទៅវិញនៅពាងដ៏ធំបិតតែមស្រា បោះត្រាពីលើតែម បញ្ជូនទៅថ្វាយ ព្រះ ចៅអធិរាជវិញ។ នៅពេលដែលទាហ៊ានចាក់ស្រាមួយពែងថ្វាយព្រះចៅអធិរាជឃើញសុទ្ធ តែជាទឹកនោម។ ទង្វើរបែបនេះ បានបង្ករធ្វើអោយព្រះចៅអធិរាជអាម៉ាស់មុខ បាក់មុខនៅ ចំពោះមុខកូនទាហ៊ានរបស់ទ្រង់ ហើយប្រកបដោយកំហឹងក្រោធខ្លាំងនោះ ទ្រង់បានបញ្ជា អោយវាយលុកទីក្រុងជាបន្ទាន់ភ្លាមៗ។ ពួកអ្នកការពារត្រូវបានត្រៀមរៀបចំយ៉ាងល្អប្រពៃ ហើយតួទ័ពធំរបស់ព្រះចៅអធិរាជបានស្លាប់គរជើងគ្នាស្ទើរតែដល់កំពូលកំផែង។ ដោយសារ តែកំហឹងក្រោធរបស់ព្រះចៅអធិរាជអោយវាយលុកយ៉ាងប្រញាប់ប្រញាល់ ធ្វើអោយកង ទ័ព របស់ទ្រង់ស្លាប់បាត់បង់ជីវិតអស់ពាក់កណ្តាល។

## យុទ្ធសាស្ត្រទី៣4៖ យុទ្ធសាស្ត្រធ្វើអោយរបួសខ្លួនឯង

## The Strategy of Injuring Yourself

ធ្វើពុតជធាត្រូវរបួស មានហេតុផលពីរដែលអាចទៅរួចគឺៈ

៙ទី១៖សត្រូវបានប្រែជាស្ងប់ស្ងាត់ បន្ថយសកម្មភាពរបស់ខ្លួន បន្ថយកិច្ចប្រុងប្រយ័ត្នរបស់ខ្លួន បន្ធូរការការពាររបស់ខ្លួន ចាប់តាំងពីពេលនោះមក សត្រូវលែងគិតថាអ្នកជាការគំរាមកំហែងរបស់គេទៀតហើយ។

៙ទី២៖គឺជាមធ្យោបាយមួយដើម្បីផ្តាប់ផ្តន់សត្រូវរបស់អ្នកដោយខ្លួនឯង ដោយធ្វើពុតជារងរបួសធ្ងន់ត្រូវបានបង្ករដោយសត្រូវដែលវាយប្រហារគ្នាទៅមក។

### ឧទាហរណ៍ប្រទេសជប៉ុនសម័យអិដូៈ

ក្នុងកំឡុងរជ្ជកាលតូកុហ្គាវ៉ា លោកកាអិជូហ្ស អតីតជាចារបុរសម្នាក់បានស្ថិតនៅក្រោមការសង្ស័យហើយគាត់ស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយគេតាមសំលាប់។ជាយថាហេតុមនុស្សជាច្រើនត្រូវបានបញ្ជូនទៅសំលាប់លោក ហើយមនុស្សដែលបានបញ្ជូនទៅនោះគឺជាអ្នកស្គាល់គ្នាជាមួយលោកកាលពីអតីតកាលឈ្មោះថាលោកតុងបិ។ ដោយសារតែការមិនចង់សំលាប់មិត្តចាស់របស់ខ្លួន លោកតុងបិ និងលោកជូហ្សបានជ្រើសរើសយកល្បិចចាស់បុរាណយកមកប្រើ។ លោកតុងបិបាននាំលោកជូហ្សក្នុងឋានៈជាទាសឹក ឬជាអ្នកទោសត្រឡប់ទៅជួបនឹងសូគុន។ លោកជូហ្សបានសុំសូគុនអនុញ្ញាតិអោយលោកស្លាប់ប្រកបដោយកិត្តិយសថ្លៃថ្នូរនាថ្ងៃចុងក្រោយ ដោយលោកសុំធ្វើអត្តឃាតសំលាប់ខ្លួនឯងដោយប្រព្រឹត្តិទៅតាមពិធីហារ៉ាគិរិ។ សូគុនមានភាពចំឡែកក្នុងចិត្តដោយភាពក្លាហ៊ានជាក់ស្តែងរបស់ចារបុរសមិនខ្លាចសេចក្តីស្លាប់ ក៏អនុញ្ញាតិអោយគាត់ធ្វើអត្តឃាតតាមសំណូមពរ។ លោកជូហ្សបាន ដកកំបិទស្នៀតចេញមក ហើយគាត់បានចាក់ទំលុះពោះរបស់គាត់ គាត់ឆូតពីម្ខាងទៅម្ខាងពោះវៀនរបស់គាត់ ក៏បានហៀរលៀនចេញពីពោះធ្លាក់ទៅលើដីមុនពេលដួលស្លាប់។ ពួកឆ្មាំបានយកសាកសពទៅចោលក្នុងបារាយជុំវិញប្រាសាទ។ រយៈពេលមួយសន្ទុះក្រោយមកលោកជូហ្សបានហែលយ៉ាងរហ័សទៅឯច្រាំងទន្លេ ហើយភៀសខ្លួនទៅក្នុងស្រុក។ ដោយដឹងពីកេរ្តិ៍ឈ្មោះរបស់អ្នកចំបាំងរបស់គាត់បន្សល់ស្នាដៃអោយគាត់ធ្វើអត្តឃាតតាមពិធីបែបហារ៉ាគិរិ

លោកបានចងសាកសព្វកញ្ជ្រោងនៅលើពោះរបស់គាត់នៅពេលពោះវៀនកញ្ជ្រោងលានហៀរចេញធ្លាក់មកលើដី វាមិនខុសពីពោះវៀនរបស់មនុស្សឡើយ។

## យុទ្ធសាស្ត្រទី៣៥៖ យុទ្ធវិធីមួយដែលបានចងផ្គុំយុទ្ធវិធីជាច្រើន

### The Tactic of Combining Tactics

បញ្ហាសំខាន់ៗបំផុត គឺយើងប្រើយុទ្ធសាស្ត្រមួយយកឈ្នះលើសត្រូវ ដោយចងផ្គុំនៅយុទ្ធសាស្ត្រជាច្រើន អនុវត្តន៍ប្រតិបត្តិក្នុងពេលដំណាលគ្នា។ រក្សាទុកផែនការច្រើនផ្សេងគ្នាប្រតិបត្តិការនៅក្នុងគំរោងរួមមួយ ហើយការអនុវត្តន៍យុទ្ធសាស្ត្របែបនេះ ប្រសិនបើ យុទ្ធសាស្ត្រណាមួយនោះបរាជ័យ អ្នកនៅតែមានយុទ្ធសាស្ត្រជាច្រើនដទៃទៀតសំរាប់ប្រើ ជំនួសយុទ្ធសាស្ត្រមួយដែលបរាជ័យ។

### ឧទាហរណ៍ប្រទេសចិនសម័យសង្គ្រាមរវាងរដ្ឋ និងរដ្ឋ Warring States Era China

នៅឆ្នាំ២៨៤មុនគ្រឹសសករាជ នគរយានវាយប្រហារនគឈីរហូតដល់នគរឈីបរាជ័យហើយកងទ័ពនគរឈីដែលសេសសល់ដែលនៅក្រោមបញ្ជារបស់លោកធៀនថាន់បានភៀសខ្លួនទៅកាន់ក្រុងជីម៉ូ ជាតំបន់ឈរជើងចុងក្រោយមួយ។ ជាដំបូងនោះលោកធៀនថាន់បានយកស្រីៗឈរជាខ្សែនៅលើកំពែងក្រុងសុំចុះចាញ់ដោយសន្តិភាពហើយខណៈពេលនោះលោកបានបញ្ជូនមាសនិងរតនសម្បត្តិដែលបានប្រមូលបានពីប្រជាពលរដ្ឋដែជាអ្នកមានៗទៅអោយឧត្តមសេនីយឈីសឺ ដោយភ្ជាប់ជាមួយសារលិខិតដែលថាលោកស្នើរសុំអោយស្រីៗនិងកុមារក្មេងៗជំនួសមុខអោយកងទ័ពសុំធ្វើការចុះចាញ់ដោយសន្តិភាពនៅទីក្រុង។ រាល់ព្រឹត្តិការណ៍ទាំងនេះ បានបញ្ចុះបញ្ចូលលោកឧត្តមសេនីយឈីសឺអោយទទួលស្គាល់ថាទីក្រុងទាំងមូលពិតជាចុះចាញ់លោកហើយលោកក៏អនុញ្ញាតិអោយកងទ័ពរបស់លោកបន្ធូបន្ថយការយាមកាម ឈប់សំរាក បន្ថយកិច្ចការពារ។ បន្ទាប់ពីការត្រៀមរៀបចំយ៉ាងប្រុងប្រយ័ត្នបែបនេះ លោកធៀនថាន់ដឹងថាដល់ពេលវេលាចាប់ផ្តើមបើកការវាយបកវិញរបស់គាត់ហើយ ជាឱកាសល្អមួយសំរាប់វាយតបតវិញ។

៙ដំបូងលោកបានអោយប្រជាពលរដ្ឋនៅក្នុងទីក្រុងប្រមូលផ្តុំគ្នាវាយស្គ វាយឆ្នាំងនិង បានណែនាំផ្តល់សញ្ញាដល់ពួកគេ ដោយវាយស្គរខ្លាំងៗតាមដែលអាចធ្វើកើត។

៙បន្ទាប់មកលោកបានអោយកូនទាហ៊ានធ្វើជាឈ្លោះគ្នាកើតវិវាទនឹងគ្នានៅតាមកំផែងក្រុង ចេញពីខាងក្នុង។

៙បន្ទាប់មកទៀត លោកបានយកសត្វពាហនៈលាបពណ៌មានគំនូប្លែកៗពីគ្នាពណ៌ប្លែកៗគ្នា ដោយយកកាំបិត កណ្តៀវ និងក្វាងទៅចងជាប់នឹងស្នែង ហើយដុតចន្លុះភ្លើងចងជាប់នឹង កន្ទុយសត្វពាហនៈ។

មុនពេលភ្លឺ ព្រឹត្តិការណ៍ទាំង៣បានកើតឡើងជាបន្តបន្ទាប់គ្នាយ៉ាងលឿនបំផុត។ប្រជាពលរដ្ឋនៅទីក្រុងបានចាប់ផ្តើមបន្លឺសូរសំលេងខ្លាំងៗមិនសីគ្នាមួយដែលបានបង្អើលទាហ៊ានយានដែលកំពុងដេកលក់ស្កប់ស្កល់។ ក្រោយមកទៀតមានភ្លើងចន្លុះឆេះនៅកន្ទុយសត្វពាហនៈដែលព្រលែងចេញពីកំផែងក្រុង សត្វដែលក្តៅក្រហាយដោយសារភ្លើងចន្លុះឆេះនៅនឹងកន្ទុយបានរត់ផាសក្រញាំគ្មានទិសដៅវិលវល់ក្នុងជំរំទាហ៊ានយានកំពុងសំលាប់ទាហ៊ានយានដែលស្រឡាំងកាំងជាមួយស្នែងកាំបិត កណ្តៀវ ក្វាង និងបានរត់ចូលក្នុងតង់ ដុតបំផ្លាញឆេះជំរកតង់របស់ទាហ៊ានរបស់នគរយានដោយសារតែកន្ទុយភ្លើង។បន្ទាប់មកទៀតទាហ៊ានឈីដ៏ក្លាហានបានស្ទុះរត់ចេញពីក្លោងទ្វាក្រុងទៅវាយប្រហារទាហ៊ានយានដែលបាន ច្របូកច្របល់ចលាចល ភ័យរន្ធត់ភ្ញាក់ផ្អើលនោះ ស្លាប់គរជើងគ្នា ហើយលោកធៀនថាន់បាន វាយប្រហារទាហ៊ានយានរហូតដល់ទាហ៊ានយានបរាជ័យរត់ខ្ចាត់ខ្ចាយអស់ និងបានបន្តវាយកាន់កាប់ដណ្តើមបានទីក្រុងជាង៧០ក្រុង។

## យុទ្ធសាស្ត្រទី៣៦៖ ប្រសិនបើយុទ្ធសាស្ត្រទាំងអស់បរាជ័យ យើងដកថយ

## If All Else Fails We Retreat

ប្រសិនបើតាមជាក់ស្តែង រាល់វគ្គដំណើរយុទ្ធសាស្ត្របច្ចុប្បន្នទាំងអស់របស់អ្នក បរាជ័យ ហើយរាល់យុទ្ធសាស្ត្រទាំងអស់របស់អ្នកអនុវត្តទៅលែងរួច បរាជ័យគ្រប់ច្រកល្ហកនោះ យុទ្ធសាស្ត្រចុងក្រោយបំផុតគឺជាយុទ្ធសាស្ត្រដកថយ ជាយុទ្ធសាស្ត្រដ៏កំពូល

មានន័យថាបន្ទាប់ពីយុទ្ធសាស្រ្តដទៃទាំងអស់បរាជ័យ យើងដកថយសិន បន្ទាប់មកយើងបង្កើតក្រុមសារជាថ្មី ប្រមូលផ្តុំទ័ពសារជាថ្មី បង្កបង្កើតកងទ័ពឡើងវិញ។

**ឧទាហរណ៍ប្រទេសចិនសម័យរាជវង្សមិញ: Ming Dynasty China**

ព្រះចៅអធិរាជរបស់រាជវង្សមិញព្រះនាមហុងទីបានដកឪពុកមាព្រះបិតុលារបស់ទ្រង់ទាំងអស់ចេញពីតំណែង លើកលែងតែព្រះបិតុលារបស់ទ្រង់ម្នាក់ក្លែងពុតធ្វើជាមនុស្សឆ្កួត។គឺព្រះបិតុលាមួយអង្គនេះព្រះនាមសម្តេចយាន នៅឆ្នាំ១៤០៣បានដឹកនាំកងទ័ពដ៏ធំសម្បើមមួយវាយលុកចូលរាជធានីណានជីង ដណ្តើមយករាជបល្ល័ង្ក។ ទីក្រុងទាំងអស់ត្រូវបានឡោមព័ទ្ធ ហើយព្រះចៅអធិរាជគិតបំរុងនឹងធ្វើអត្តឃាត ប៉ុន្តែនៅពេលនោះមហាថ្លឹករបស់ទ្រង់បាន ចូលមកឃាត់បញ្ឈប់ទ្រង់ ដោយទូលប្រាប់ទ្រង់ថាព្រះឯយ្យការរបស់ទ្រង់ព្រះចៅអធិរាជ ព្រះនាមហុងទីបានបន្សល់ទុកនៅក្រឡាអុកមួយដែលទ្រង់ផ្តាំអោយថែរក្សាទុក ហើយទ្រង់បាន ត្រាស់បញ្ជាថាហាមមិនអោយបើកមើលទេ លើកលែងតែមានវិបត្តិធំមួយកើតឡើង គំរៀមកំហែងដល់រាជវង្ស ហេតុផលនោះទើបព្រះចៅអធិរាជដែលកំពុងគ្រងរាជ្យគួរតែបើកក្រឡាអុកនេះ។ ព្រះចៅអធិរាជបានមានព្រះបន្ទូលថា‹‹ជូនយើងទៅបើក្រឡាអុកជាបន្ទាន់ភ្លាម! យើងចង់ជ្រាបណាស់នៅអ្វីដែលព្រះបិតារបស់យើងធ្វើ ហើយមានអ្វីខ្លះដែលទ្រង់បានបន្សល់ទុកនៅទីនោះឥឡូវនេះ!››។នៅពេលដែលគំរបក្តាអុកបានបើកឡងពីប្រអប់ ទ្រង់បានទតឃើញមានផ្ទុកនៅស្បង់ជីវរព្រះសង្ឃព្រះពុទ្ធសាសនាមួយ មានប័ណ្ណបញ្ជាក់សំគាល់លើមួយ កំបិតកោរមួយ និងដំប្រាក់ចំនួន១០ដុំ។ រំពេចនោះ ព្រះចៅអធិរាជរបស់ទ្រង់ជ្រាបរាល់ហេតុកាណ៍ យល់ពីអត្ថន័យ ហើយដោយមានអ្នកចូលរួមអមព្រះរាជដំណើរផងនោះព្រះទ្រង់បានភៀស ព្រះកាយចេញពីព្រះបរមរាជវាំងតាមផ្លូវរូងដីសំងាត់មួយ ទៅកាន់ព្រះវិហារព្រះពុទ្ធសាសនា មួយ។ នៅទីនោះព្រះអង្គបានកោរព្រះកេសាហើយបានគ្រងស្បង់ជីវរ។ ព្រះអង្គបានធ្វើដំណើរ តាមផ្លូវចេញពីទីក្រុង ហើយប្រើគ្រប់មធ្យោបាយភៀសខ្លួនទៅខេត្តសីឈួន កន្លែងដែលទ្រង់ បានរស់នៅយ៉ាងអាថិកំបាំងនៅក្នុងវត្តអារាមឆ្ងាយដាច់ស្រយាលមួយ។

ទន្ទឹមគ្នានេះដែរ រាជវាំងត្រូវបានដុតបំផ្លាញក្នុងកំឡុងពេលវាយប្រហារ ហើយវាត្រូវបានសន្និដ្ឋានថាព្រះចៅអធិរាជអឹងសុង)ជាព្រះចៅអធិរាជទី៤ចាប់តាំងពីរជ្ជកាលរបស់ព្រះអង្គហុងទី(មានបុព្វជិតព្រះពុទ្ធសាសនាម្នាក់បានមកដល់ព្រះបរមរាជវាំងហើយបានអះអាងថាជា

ព្រះចៅអធិរាជចាស់ម្នាក់ឈ្មោះហុងទី។ ព្រឹត្តិកាណ៌ហេតុការណ៏បានត្រឡប់ទៅរកមនុស្ស ម្នាក់ដែលពាក់ផ្លាកជាព្រះចៅអធិរាជបោកប្រាស់បន្លំគេឯង ប៉ុន្តែពាក្យចចាមអារាមមួយ បាន ចាប់ផ្តើមផ្សាយថា ព្រះចៅអធិរាជនៅមានព្រះជនគង់នៅឡើយ។ ដើម្បីបង្រាបពាក្យ ចចាមអារ៉ាម បញ្ចប់ពាក្យចចាមអារ៉ាម និងដោះស្រាយបញ្ហានេះ ការសើបអង្កេតជាផ្លូវ ការមួយ ត្រូវបានធ្វើឡើងដែលបានស្រាវជ្រាវរកឃើញថាព្រះចៅអធិរាជហុងទី តាមពិតទៅនៅ មានព្រះជនគង់នៅនៅឡើយ រស់នៅជាបុព្វជិតសង្ឃព្រះពុទ្ធសាសនាមួយអង្គ។ ព្រះចៅ អធិរាជដ៏ចាស់ជរាម្នាក់នេះ ត្រូវបានអញ្ជើញអោយត្រឡប់ទៅកាន់រាជធានីវិញ ហើយទ្រង់ បានរស់នៅក្នុង រាជធានីវិញដោយប្រារព្ធពិធីបុណ្យធំអបអរសាទរ ហើយទ្រង់បានរស់នៅក្នុង នាមជាភ្ញៀវម្នាក់ នៅថ្ងៃចុងក្រោយរបស់ទ្រង់នៅក្នុងព្រះបរមរាជវាំង។ ទោះបីជាយ៉ាងណាក៏ ដោយ ក៏ទ្រង់ត្រូវបានយកចិត្តទុកដាក់មើលថែទាំយ៉ាងប្រុងប្រយ័ត្ន។

# សិល្បៈសង្គ្រាមរបស់លោកស៊ុនជួ

# Sun Tzu on the Art of War

## ជាអភិប្រាយោធាដ៏ចាស់បំផុតក្នុងលោក

## The oldest military treatise in the world

### បកប្រែជាភាសាអង់គ្លេសដោយលោកលីយ៉ុងណោលហ្សិលឆ្នាំ១៩១០

### Translated in English by Mr.Lionel Giles, M.A. (1910)

១.ការធ្វើផែនការឬការគណនាគន់គូរ ( Laying Plans or Culculation )

១)-លោកស៊ុនជួបានមានប្រសាសន៍ថា«សិល្បៈសង្គ្រាមគឺមានសារៈសំខាន់បំផុតសំរាប់ប្រទេសជាតិ រដ្ឋ និងនគរទាំងមូល។

២)-វាជាបញ្ហាស្លាប់រស់មួយគឺជាកត្តាសុវត្ថិភាព ជាកន្លែងសុខសាន្ត ហើយក៏ជាកន្លែងស្លាប់រស់ គ្រោះថ្នាក់ និងវិនាសកម្មដល់យើងផងដែរ។ ហេតុនេះវាជាកម្មវត្ថុមួយនៃការសើបអង្កេត តាមដានសើបយកពត៌មានអោយច្បាសអំពីមាគ៌ាផ្លូវដែលយើងត្រូវធ្វើរឺត្រូវដើរ ព្រោះមិនមែនជារឿងធ្វេសប្រហែសទេប៉ុន្តែវាជាកត្តាស្លាប់រស់ ជាអាយុជីវិតរបស់យើង។

៣)-ហេតុដូច្នេះសិល្បៈសង្គ្រាមត្រូវបានគ្រប់គ្រងដោយកត្តាខ្ជាប់ខ្ជួន៥យ៉ាងដែលទទួលខុសត្រូវក្នុងការពិភាក្សា ពិចារណាដោយប្រុងប្រយ័ត្នរបស់ឧត្តមសេនីយ ឬមេទ័ពនិមួយៗនៅក្នុងការស្វែងរកលក្ខ័ខណ្ឌ័ជ័យជំនះនៅក្នុងសមរភូមិ វាកំណត់នៅលក្ខ័ខណ្ឌ័ជោគជ័យនិងបរាជ័យ។

៨)-កត្តានីវន្តទាំង៥គឺៈ

(១)-ច្បាប់សីលធម៌

(២)-ឋានសួគ៌

(៣)-ផែនដី

(៤)-មេបញ្ជាការ មេទ័ព និងឧត្តមសេនីយ

(៥)-វិធីសាស្រ្ត និងវិន័យបទបញ្ជា

**(១)-ច្បាប់សីមធម៌ (Moral Law):** ច្បាប់សីលធម៌បង្ករអោយប្រជាជនទទួលយកយើងយល់ព្រមទាំងស្រុងទទួលយកអ្នកគ្រប់គ្រងរបស់យើង ដើម្បីអោយគេពួកគេដើរតាមយើងដោយមិនគិតពីអាយុជីវិតរបស់ពួកគេ មិនតក់ស្លុត មិនស្រងាកចិត្តនៅក្នុងគ្រោះថ្នាក់។

**(២)-ឋានសួគ៌ (Heaven) :**ឋានសួគ៌មានន័យថាជាអ្វីដែលកើតមកពីមេឃដូចជាយប់ថ្ងៃ ក្តៅត្រជាក់ពេលវេលា ម៉ោង រដូវកាលនានា ច័ន្ទគ្រាស សូរ្យគ្រាស ទេពសយុត្តិ ផ្កាយដុះកន្ទុយ ខ្យល់ព្យុះ គ្រោះធម្មជាតិ-------។ល។

**(៣)-ផែនដី (Earth) :**ផែនដីមានចំងាយ ទំហំធំតូច គ្រោះថ្នាក់ សុវត្ថិភាព មូលដ្ឋានដែនដីបើកចំហរ និងច្រកតូចចង្អៀត ភ័ព្វសំណាង ឱកាសនៃការរស់ និងការស្លាប់។

**(៤)-មេបញ្ជាការមេទ័ព និងឧត្តមសេនីយ (General and Commanders) :**គឺឈរលើគុណធម៌នៃគតិបណ្ឌិត ភាពស្មោះត្រង់ ភក្តីភាពនឹងជាតិទឹកដី ទឹកចិត្តមេត្តាករុណា ភាពម៉ត់ចត់ ភាពក្លៀវក្លា ភាពមុតមាំ ភាពក្លាហ៊ានមុះមុត------។ល។

**(៥)-វិធីសាស្រ្ត និងវិន័យបទបញ្ជា (Methods and Disciplines):** អ្នកត្រូវយល់ដឹងពីការត្រៀមរៀបចំវិន័យ បទបញ្ជា និង ប្រព័ន្ធអង្គការចាត់តាំងរបស់កងទ័ពនៅក្នុងការបែងភាគកូនទាហ៊ាន និងចែករំលែកបែងចែកបន្តនៅចំនួនកងកំលាំងកងទ័ពអោយបានសមរម្យនៅក្នុងប្រព័ន្ធអង្គការចាត់តាំងរបស់ខ្លួន ការតែងតាំងតាមឋានានុក្រម កំរិតចាត់តាំង ការឡើងសន្ទឹមៗនៅឋានៈបុណ្យសក្តិក្នុងចំណោមនាយទាហ៊ាន ការថៃរក្សាផ្លូវនានាសំរាប់ជា

មធ្យោបាយនានា ការផ្គត់ផ្គង់ស្បៀង សព្វាវុធ បរិក្ខាសឹកអោយបានដល់កងទ័ព ត្រួតពិនិត្យធ្វើសវនកម្មដល់ការចំណាយខាងផ្នែកយោធា។

កត្តានាំមុខទាំង៥ទាំងនេះ ឧត្តមសេនីយ មេទ័ពគ្រប់រូបៗគួរតែដឹងអោយច្បាស់លាស់។ ឧត្តមសេនីយដែលយល់ដឹងពីកត្តាទាំង៥នេះនឹងទទួលបរាជ័យ។

**៥)**-ហេតុដូច្នេះនៅក្នុងកិច្ចពិភាក្សាសំរេចពិចារណាថ្លឹងថ្លែងរបស់អ្នក សូមយកកត្តានីវន្តទាំង៥នេះមកធ្វើជាមូលដ្ឋាននៅក្នុងការប្រៀបធៀបមួយ នៅពេលអ្នកគណនាគន់គូរស្វែងរកមធ្យោបាយកំណត់នៅលក្ខ័ខណ្ឌ័យោធាប្រកបដោយជោគជ័យ។ភាពឆ្លាតវៃនេះគឺៈ

(១)-តើអ្នកគ្រប់គ្រង ឬមហាក្សត្រណាមួយក្នុងចំណោមមហាក្សត្រទាំងពីរត្រូវបានធ្វើអោយមហាជន កងទ័ពជ្រួតជ្រាបនៅច្បាប់សីលធម៌?

(២)-តើឧត្តមសេនីយណាមួយក្នុងចំណោមឧត្តមសេនីយទាំងពីរមានសមត្ថភាពខ្លាំងបំផុត។

(៣)-តើឧត្តមសេនីយណាមួយក្នុងចំណោមឧត្តមសេនីយខាងណា មួយណាដែលចេះទាញយកផលប្រយោជន៍ចេញពីមេឃ និងដី។

(៤)-តើកងទ័ពណាមួយឬកងកំលាំងណាមួយដែលគោរពវិន័យ និងពង្រឹងការអនុវត្តន៍វិន័យបានតឹងរឹងបំផុត។

(៥)-កងទ័ពណាមួយដែលមានកំលាំងខ្លាំងជាង?

(៦)-តើទ័ពណាមួយដែលមានមេទ័ពនិងកូនទាហ៊ាន ហ្វឹកហាត់ស្ទាត់ជំនាញ។

(៧)-តើទ័ពណាមួយអនុវត្តន៍បានមធ្យ័តទាំងវិន័យ និងទណ្ឌកម្ម?

តាមមធ្យោបាយនៃការពិចារណា៧យ៉ាងទាំងនេះ អាចទោះទាយបាននៅជ័យជំនះនិងការបរាជ័យជាមុនបាន។

**៦)**-ឧត្តមសេនីយដែលស្តាប់ដំបូន្មានរបស់ខ្ញុំ ហើយអនុវត្តន៍តាមដំបូន្មាននោះ នឹងមានប្រៀបនៅក្នុងសង្គ្រាម មានជ័យជំនះក្នុងសមរភូមិ ដោយរក្សានៅកត្តានីវន្តទាំង៥នៅក្នុងការបញ្ជាទ័ព តែអ្នកដែលមិនស្តាប់តាមដំបូន្មានរបស់ខ្ញុំ និងមិនអនុវត្តន៍តាមកត្តានិវន្ត

ទាំង៥នេះ នឹងបរាជ័យ បាត់បង់ឱកាសជោគជ័យ។ ខណៈពេលដែលចេះទាញយកផល ប្រយោជន៍សំរាប់ខ្លួនឯង ថែមទាំងក្តាប់បាននៅឱកាសកាលៈទេសៈពិសេសជួយដល់អ្នក ទៅលើគ្រប់ក្បួនច្បាប់ បទបញ្ជាធម្មតារបស់អ្នក។ បើឱកាសកាលៈទេសៈអំណោយ ផលដល់អ្នកហើយ គួរតែអនុវត្តន៍ផែនការរបស់អ្នកជាបន្ទាន់។

**៧)**-រាល់គ្រប់សង្គ្រាមទាំងអស់ត្រូវបានពឹងផ្អែកលើកលយុទ្ធ ការបោកបញ្ឆោត ការ បោកប្រាស់។ ហេតុដូច្នេះ នៅពេលអ្នកវាយប្រហារបាន អ្នកត្រូវតែធ្វើហាក់បីដូចជា មិនអាចវាយប្រហារបាន នៅពេលអ្នកកំពុងបានប្រើប្រាស់កំលាំងទ័ពរបស់អ្នក អ្នកត្រូវ តែធ្វើហាក់បីដូចជាធ្វេសប្រហែស ព្រងើយកន្តើយ អសកម្ម។ នៅពេលអ្នកនៅជិត អ្នកត្រូវតែធ្វើអោយសត្រូវជឿថាអ្នកនៅឆ្ងាយខ្លាំងណាស់ ហើយបើអ្នកនៅឆ្ងាយ អ្នកត្រូវ តែធ្វើអោយសត្រូវរបស់អ្នកជឿថាអ្នកនៅជិតៗហ្នឹង។

អ្នកត្រូវតែបន្តដាក់នុយ បញ្ឆុះបញ្ឆូលសត្រូវ បញ្ឆោតសត្រូវរបស់អ្នកអោយចូល អន្ទាក់របស់អ្នក អ្នកត្រូវធ្វើពុតជាច្របូកច្របល់កើតកលយុគផ្ទៃក្នុង ចលាចល ហើយ វាយកំទេចសត្រូវតែម្តង។ បើសត្រូវរបស់អ្នកមានសន្តិសុខ សុវត្ថិភាពរឹងមាំគ្រប់ចំណុច អ្នកត្រូវតែត្រៀមរៀបចំទុកជាមុនរងចាំឱកាសអំណោយផល ចាំវាយសត្រូវ។បើសត្រូវអ្នក មានកំលាំងខ្លាំងលើសលុបមានប្រៀបខ្លាំងក្លាលើអ្នក អ្នកត្រូវតែគេចវេសចេញពីខ្មាំង។បើ គូរសត្រូវរបស់អ្នកមានអារម្មណ៍ឆេវឆាវងាយខឹងក្រោធ ត្រូវតែស្វែងរកមធ្យោបាយផ្សេងៗធ្វើ អោយសត្រូវរបស់អ្នកខឹងក្តៅក្រហាយកាន់តែខ្លាំងទៅៗ។អ្នកត្រូវធ្វើពុតជាទន់ខ្សោយ នោះ សត្រូវរបស់អ្នកនឹងអួតក្អេងក្អាងបង្កើនភាពក្រអឺតក្រទម។បើសត្រូវរបស់អ្នកមានការសំរាកនិង មានសភាពសុខដុមរម្យនា អ្នកត្រូវតែរំខានកុំអោយមានពេលឈប់សំរាក។ បើសត្រូវរបស់ អ្នកឯកភាពគ្នា រួបរួមគ្នាជាផ្លុងមួយ អ្នកត្រូវបំបែកបំបាក់ពួកគេ។ អ្នកត្រូវវាយប្រហារ សត្រូវរបស់អ្នកនៅកន្លែងខ្វះចន្លោះ ធ្វេសប្រហែសនិងមិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រាន់។ អ្នកត្រូវបង្ហាញខ្លួននៅត្រង់កន្លែងដែលខ្មាំងមិនបានរំពឹងទុកមុន ឬស្មានមិនដល់។រាល់ឧបាយ កលយោធាទាំងនេះនឹងនាំអ្នកទៅរកជ័យជំនះ អ្នកត្រូវតែលាក់រឿងសំងាត់អោយជិតកុំអោយ បែកការ កុំអោយខ្មាំងដឹងមុន។ បច្ចុប្បន្ននេះឧត្តមសេនីយដែលទទួលជោគជ័យ ឈ្នះសង្គ្រាមគឺជាឧត្តមសេនីយដែលពូកែគណនាគន់គូរនៅក្នុងអារម្មណ៍របស់គាត់ជាមុនមុន ពេលការប្រយុទ្ធ ឬចម្បាំងកើតឡើង។ ឧត្តមសេនីយដែលពូកែធ្វើចំបាំងសឹកសង្គ្រាមខុស

ពីឧត្តមសេនីយដែលចាញ់សឹកសង្គ្រាម ពីព្រោះឧត្តមសេនីយដែលចាញ់សឹកសង្គ្រាម ដោយសារតែមានការគណនាគន់គូរតិចតួចមុនពេលធ្វើសឹកសង្គ្រាម។ ហេតុដូច្នេះអ្នកត្រូវធ្វើការគណនាគន់គូអោយបានច្រើនទើបនាំទៅរកជោគជ័យ ហើយបើមានការគណនាគន់គូរតិចតួចនឹងនាំទៅរកបរាជ័យ។ ចុះបើអ្នកដែលមិនធ្វើការគណនាគន់គូរទាល់តែសោះតើលទ្ធផលនឹងទៅជាយ៉ាងណាដែរ?

## ២-ការទាញប្រយោជន៍ពីសឹកសង្គ្រាម (Waging War) :

១)-លោកស៊ុនជូបានមានប្រសាសន៍ថា«នៅក្នុងកិច្ចប្រតិបត្តិការសង្គ្រាម កន្លែងដែលមាននៅក្នុងសមរភូមិមានរទេះចំបាំងធុនលឿន១០០០រទេះ ព្រមទាំងរទេះចំបាំងធំៗធុនធ្ងន់ជាច្រើនទៀតផង ទាហ៊ានពាក់អាវក្រោះចន្ទួន១០០០០០នាក់ប្រកបដោយស្បៀងអាហារល្មមគ្រប់គ្រាន់សំរាប់ធ្វើចំបាំង១០០០យោជន៍ មានទាំងការចំណាយនៅក្នុងប្រទេសនិងការចំណាយនៅក្នុងសមរភូមិមុខ រួមមានការកំសាន្តលំហែររបស់ភ្ញៀវទាំងឡាយ វត្ថុប្រើប្រាស់សមញ្ញៗដូចជាជ័រការ ថ្នាំលាប និងរបស់ផ្សេងៗទៀតទាំងអស់បានចំណាយលើរទេះសេះចំបាំង និងអាវក្រោះ និងសរុបទឹកប្រាក់១០០០អូនស៍ក្នុង១ថ្ងៃ។ ការចំណាយបែបហ្នឹងគឺមានតំលៃកើនឡើងសំរាប់ការបង្កើនកងទ័ព១០០០០០។

២)-នៅពេលដែលយើងធ្វើសង្គ្រាមជាក់ស្តែង ប្រសិនបើជ័យជំនះក្រមកដល់ឬប្រើរយៈពេលយូរក្នុងការធ្វើសង្គ្រាម ដូច្នេះអាវុធកងទ័ពនឹងរិចរិលខូចខាត ប្រើប្រាស់អស់ច្រើនទាំងអាវុធនិងគ្រាប់រំសេវ ហើយទឹកចិត្តក្លៀវក្លារបស់កងទ័ពនឹងថយចុះឬធ្លាក់ចុះប្រសិនបើការឡោមព័ទ្ធទីក្រុងប្រើរយៈពេលយូរ អ្នកនឹងចំណាយឋាមពលច្រើន ធ្វើអោយអស់កំលាំងរបស់អ្នក។

៣)-ជាថ្មីម្តងទៀត ប្រសិនបើយុទ្ធនាការត្រូវបានពន្យាពេលយូរ ធនធានរបស់រដ្ឋនឹងចំណាយច្រើន ទ្រព្យសម្បត្តិជាតិនឹងហិចហោច។

៤)-ឥឡូវនេះ នៅពេលអាវុធរបស់អ្នករិចរិលហិចហោច ទឹកចិត្តក្លៀវក្លារបស់កងទ័ពរបស់អ្នកថយចុះ កំលាំងឋាមពលរបស់អ្នកហត់នឿយស្រកចុះ ហើយរតនសម្បត្តិរបស់ចំណាយច្រើនហួស នោះមេទ័ព ឧត្តមសេនីយនីមួយៗនឹងពុករលួយគិតតែពីផល

ប្រយោជន៍ផ្ទាល់ខ្លួន ទាញយកផលប្រយោជន៍របស់ពួកគេចេញពីភាពលំបាកលំបិនយ៉ាប់យ៉ឺនរបស់អ្នក។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានមនុស្សណាមួយមានប្រាជ្ញាវៃឆ្លាតនឹងអាចបង្វែរផលប្រយោជន៍ទាំងឡាយដោយធានាឡើងវិញនៅស្ថានភាពដូចដើមវិញទេ។

៥)-ដូច្នេះទោះបីជាយើងដឹងថាការប្រញាប់ប្រញាល់ដ៏ឆ្លួតលីលានៅក្នុងសង្គ្រាមក៏ដោយភាពឆ្លាតវៃមិនដែលចូលរួម ឬមិនដែលឃើញមាននៅការពន្យាពេលយូរឡើយ។

៦)-មិនមានឧទាហរណ៍ណាមួយកំពុងបានទាញផលប្រយោជន៍ពីសង្គ្រាមដែលបានពន្យាពេលយូរនោះឡើយ។

៧)-វាគឺជាមនុស្សម្នាក់តែប៉ុណ្ណោះដែលត្រូវបានយល់ដឹងស្គាល់យ៉ាងច្បាស់ពេញទំហឹងនៅផលអាក្រក់និងភាពឃោរឃៅនៃសង្គ្រាមដែលអាចយល់ដឹងយ៉ាងពេញទំហឹងនៅមធ្យោបាយទាញយកផលចំណេញក្នុងការអនុវត្តន៍វា។

៨)-ទាហ៊ានដែលមានជំនាញមិនបង្កើតបន្ទុកទី២នោះទេ ក៏គ្មានរទេះសេះផ្គត់ផ្គង់ស្បៀងរបស់គាត់ដឹកធូន់ហួសហេតុមួយទ្វេជាពីរនោះទេ។

៩)-ចូរនាំសំភារៈសឹកចេញពីស្រុកស្វែងរកសត្រូវ ប្រមាញ់សត្រូវ ហើយរបស់អ្នកត្រូវនាំស្បៀងអាហារទ្រព្យសម្បត្តិ ជ័យភ័ណ្ឌចូលស្រុកវិញតាមតំរូវការកងទ័ពនិងប្រជារាស្ត្រ។

១០)-ភាពក្រីក្ររបស់នគររដ្ឋ ឃ្លាំងរដ្ឋវិនាសហិនហោច បង្ករចេញពីកងទ័ពដែលត្រូវបានរក្សាដោយការផ្គត់ផ្គង់ពីចំងាយមួយ។ ការសម្បទារផ្គត់ផ្គង់ដើម្បីរក្សាកងទ័ពមួយពីចំងាយបង្ករអោយប្រជាជនធ្លាក់ចុះក្រលិចលង់ ធនធានវិចវិល។

១១)-ម្យ៉ាងវិញទៀត ការចូលកៀករបស់កងទ័ពបង្ករអោយតំលៃទំនិញឡើងថ្លៃ ហើយតំលៃដ៏ខ្ពស់បង្ករអោយធនធានទ្រព្យសម្បត្តិប្រជាជនកាន់តែហិនហោចទៅៗ។

១២)-នៅពេលធនធានទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានហិនហោច កសិករនឹងស្រពន់ចិត្តដោយសារពន្ធដារ ការទាមទារសួយសារអាករខ្ពស់ពេក។

១៣)-និង១៤)-ដោយសារការបាត់បង់ធនធានទ្រព្យសម្បត្តិនិងភាពខ្សោះអស់កំលាំង អ្នកស្រុកភូមិករត្រូវបានប្រើប្រាស់អស់នៅក្នុងសឹកសង្គ្រាម ហើយ $\frac{៣}{១០}$ នៃចំណូលរបស់ពួកគេ

នឹងត្រូវបានវិនាសហិនហោច ព្រោះថារដ្ឋាភិបាលចំណាយច្រើនលើរទេះចំបាំងដែលខូចខាត សេះចំបាំងដែលទ្រុឌទ្រោម អាវក្រោះបុរាណ និងមួកការពារ ធ្នូរ ព្រួញ ដាវលំពែង ខែល អាវក្រៅគ្របដណ្តប់ដែសំរាប់ការពារខ្លួន គោរអូសរទេះ និងរទេះធំៗ នឹងបង្កើនការចំណាយរហូតដល់$\frac{៣}{១០}$នៃផលទុនចំណូលសរុបរបស់រដ្ឋ។

**១៥)**-ហេតុដូច្នេះ ឧត្តមសេនីយ៍ឆ្លាតវៃមួយ ធ្វើការដៅចំណុចស្វែងរកសត្រូវចំគោលដៅ។ ប្លន់ស្បៀងអាហាររបស់សត្រូវមួយរទេះគឺស្មើរនឹង២០រទេះនៃស្បៀងអាហាររបស់យើង ហើយនៅពេលតំណាលគ្នានោះ បើយើងប្លន់ស្បៀងអាហារសត្រូវបាន៦០គីឡូក្រាមគឺស្មើរនឹងស្បៀងអាហាររបស់យើង២០ដងដែលបានស្តុកទុកក្នុងឃ្លាំងផ្ទាល់របស់យើង។

**១៦)**-ឥឡូវនេះដើម្បីសំលាប់សត្រូវ យើងត្រូវតែបង្កើនគំនុំសងសឹកនិងកំហឹងខឹងក្រោធទៅដល់មនុស្សរបស់យើងនិងកងទ័ពរបស់យើង ដែលធ្វើអោយមានផលប្រយោជន៍ច្រើនលើសពីការផ្ចាញ់សត្រូវ ហើយពួកគេត្រូវតែត្រូវបានផ្តល់រង្វាន់។

**១៧)**-ហេតុដូច្នេះ នៅក្នុងការវាយប្រហាររទេះចំបាំង នៅពេលរទេះចំបាំងចំនួន១០ឬច្រើនត្រូវបានកងទ័ពរបស់យើងរឹបអូសយកដណ្តើមបាន ទាំងនោះគួរតែត្រូវបានផ្តល់រង្វង់ដល់អ្នកដែលដណ្តើមបានដំបូងគេ។ ទង់ជ័យរបស់យើងគួរតែត្រូវបានបង្កើតឡើងសំរាប់បោកបន្លំសត្រូវ មានលាយឡំនឹងរទេះចំបាំងសត្រូវស្របនឹងរបស់យើង។ ពួកទាហ៊ានដែលដណ្តើមយកបាន គួរតែត្រូវបានចាត់តាំងអោយថែរក្សារបស់ទាំងអស់នោះ។

**១៨)**-នេះត្រូវបានហៅថាការប្រើប្រាស់កំលាំងសត្រូវកំលាំងទាសឹកជំនួសកំលាំងយើងផ្ទាល់។

**១៩)**-ដូច្នេះនៅក្នុងសង្គ្រាម សូមយកកម្មវត្ថុចំបងរបស់អ្នកដណ្តើមយកជ័យជំនះ មិនមែនយុទ្ធនាការរយៈពេលវែងនោះទេ។

**២០)**-ដូច្នេះវាត្រូវបានដឹងថាមេដឹកនាំកងទ័ពគឺជាអាជ្ញាកណ្តាលនៃជោគវាសនាប្រជាជនមនុស្សដែលពួកគេត្រូវបានពឹងផ្អែកលើមេទ័ពនិងឧត្តមសេនីយដែលជាកត្តាធ្វើអោយប្រជាជាតិនឹងត្រូវបាននៅក្នុងសន្តិភាព ឬនៅក្នុងគ្រោះថ្នាក់។

## ៣-ការវាយប្រហារតាមយុទ្ធោបាយសឹក (Attack By Stratagem):

១)-លោកស៊ុនជូបានមានប្រសាសន៍ថា«នៅក្នុងសិល្បៈសង្គ្រាមដែលកំពុងប្រតិបត្តិ រឿងដែលល្អបំផុតក្នុងចំណោមរឿងទាំងអស់គឺត្រូវតែយកប្រទេសសត្រូវបានទាំងមូលដោយគ្មានខូចខាតឬរក្សាអោយនៅដដែល ការធ្វើអោយប្រទេសសត្រូវខូចខាតឬក៏ត្រូវបានបំផ្លាញខ្ទិចខ្ទីរគឺមិនមែនល្អទេ។ ដូច្នេះវាជាការប្រសើរប្រពៃបំផុតគឺចាប់យកកងទ័ពទាំងមូលជាជាងបំផ្លាញកំទេចពួកគេទាំងស្រុង។ ការចាប់យកកងពលទាំងមូល ឬទលសេនាទាំងមូលឬកងវរៈសេនាធំទាំងមូល ប្រសើរជាជាងការបំផ្លិចបំផ្លាញពួកគេទាំងស្រុង។

២)-ហេតុនេះ ការវាយប្រហារនិងការឈ្លានពាននៅក្នុងគ្រប់ចំបាំងទាំងអស់មិនប្រសើរឧត្តុងឧត្តមនោះទេ ភាពប្រពៃប្រសើរឧត្តុងឧត្តមបំផុតគឺមានការកំទេចការតស៊ូរបស់សត្រូវដោយមិនបាច់វាយប្រហារ។

៣)-ដូច្នេះទំរង់ខ្ពស់បំផុតនៃភាពជាឧត្តមសេនីយត្រូវបានធ្វើអោយផែនការរបស់សត្រូវរួមតូចប្រសើរបំផុតនៅពេលបន្ទាប់គឺត្រូវតែការពារទុបស្កាត់ទីប្រសព្វរបស់កងកំលាំងសត្រូវ បន្ទាប់មកបទបញ្ជាត្រូវតែវាយប្រហារកងទ័ពសត្រូវនៅក្នុងសមរភូមិ ហើយគោលនយោបាយដ៏អាក្រក់បំផុតក្នុងចំណោមគោលនយោបាយទាំងអស់គឺត្រូវតែឡោមព័ទ្ធសត្រូវនៅតាមបណ្តារទីក្រុងដែលមានកំពែងការពាររឹងមាំ។

៤)-តាមក្បួនច្បាប់មិនមែនត្រឹមតែឡោមព័ទ្ធទីក្រុងដែលមានកំពែងការពារប៉ុណ្ណោះទេប្រសិនបើអាចទៅរួច គួរតែចៀសវាង។ ការត្រៀមរៀបចំទុកនៅឧបករណ៍ការពារខ្លួន អាវក្រោះខែលចល័ត និងឧបករណ៍ផ្សេងៗទៀតសំរាប់ប្រើប្រាស់ក្នុងសង្គ្រាមនឹងរៀបចំប្រើរយៈពេល៣ខែពេញ និងការគរពពួកខ្សាច់ថ្មជាគ្រង់សេរបាំងការពារខ្លួនប្រឆាំងនឹងកំពែងសត្រូវ និងប្រើពេលអស់រយៈពេល៣ខែទៀត។

៥)-បើឧត្តមសេនីយដែលមិនអាចគ្រប់គ្រងសេចក្តីក្រោធកំហឹងក្តៅក្រហាយរបស់ខ្លួននឹងចាប់ផ្តើមបញ្ជាកងទ័ពអោយវាយប្រហារប្រៀបបីដូចជាហ្វូងច្រមោច លទ្ធផលចុងក្រោយគឺថាកងទ័ព$\frac{៣}{១០}$របស់គាត់នឹងត្រូវបានសំលាប់ ខណៈដែលទីក្រុងនៅតែមិនទាន់កាន់កាប់បាននៅឡើយ។ បែបនេះគឺជាលទ្ធផលនៃក្តីវិនាសអន្តរាយនៃការឡោមព័ទ្ធមួយ។

៦)-ហេតុដូច្នេះ មេដឹកនាំដែលមានជំនាញច្បាស់លាស់ បង្ក្រាបកងទ័ព សត្រូវដោយគ្មានការវាយប្រយុទ្ធណាមួយឡើយ ហើយគាត់កាន់កាប់យកបណ្តារទីក្រុងនានារបស់ពួកគេដោយគ្មានការឡោមព័ទ្ធពួកគេឡើយ។ គាត់ផ្តួលរំលំយកអាណាចក្រពួកគេដោយគ្មានកិច្ចប្រតិបត្តិការសឹកវែងឡើយនៅក្នុងសមរភូមិ។

៧)-ជាមួយកងទ័ពខ្លួននៅដដែល ជាឧត្តមសេនីយដែលជំនាញធ្វើសឹកសង្គ្រាមយ៉ាងពូកែនៅក្នុងចក្រភព ហើយដូច្នេះដោយគ្មានការបាត់បង់មនុស្សម្នាក់ ជ័យជំនះរបស់គាត់នឹងទទួលបានទាំងស្រុង។ នេះគឺជាវិធីសាស្រ្តនៃការវាយប្រហារទៅតាមយុទ្ធោបាយសឹក។

៨)-វាក្យូនសឹកសង្គ្រាមប្រសិនបើកំលាំងរបស់យើង១០នាក់ទល់នឹងកំលាំងខ្មាំង១នាក់ យើងត្រូវឡោមព័ទ្ធ ប្រសិនបើកំលាំងយើង៥នាក់ទល់នឹងកំលាំងខ្មាំង១នាក់ យើងត្រូវវាយលុកខ្មាំងប្រសិនបើកំលាំងយើងច្រើនជាងសត្រូវ២ដង យើងត្រូវបែងចែកកំលាំងទ័ពយើងជា២។

៩)-បើកំលាំងទ័ពរបស់យើងមានចំនួនស្មើរគ្នានឹងខ្មាំង យើងអាចវាយប្រយុទ្ធនឹងខ្មាំងបានតែបើកំលាំងទ័ពយើងមានចំនួនតិចជាងខ្មាំង យើងអាចគេចវេសចេញពីខ្មាំងបាន ប្រសិនបើយើងចាញ់ខ្មាំងគ្រប់មធ្យោបាយ អ្វីៗទាំងអស់មានចំនួនតិចជាងខ្មាំង យើងអាចគេចចេញពីខ្មាំងតែម្តង។

១០)-ហេតុដូច្នេះ ទោះបីជាការវាយប្រហារដ៍លំបាកលំបិនក៍ដោយ អាចត្រូវបានធ្វើឡើងដោយកងទ័ពតិចតួចមួយ ក្នុងទីបញ្ចាប់វាត្រូវតែត្រូវបានចាប់យកដោយកំលាំងកងទ័ពធំដែលមានចំនួនដ៍ច្រើនមួយ។

១១)-ឥឡូវនេះ ឧត្តមសេនីយគឺជារបងការពារនគររដ្ឋ ប្រសិនបើរបងការពារត្រូវបានបំពេញនៅរាល់គ្រប់ចំណុចទាំងអស់ នោះនគររដ្ឋនឹងខ្លាំង ប្រសិនបើរបងការពារខ្វះចន្លោះ នោះនគររដ្ឋនឹងខ្សោយ។

១២)-មានមធ្យោបាយ៣ដែលអ្នកដឹកនាំម្នាក់ៗអាចនាំមកនៅជោគវាសនាអាក្រក់ដល់កងទ័ពរបស់ខ្លួនគឺ:

(១)-នៅពេលបញ្ជាកងទ័ពអោយសំរុកចូលឬដកថយ កំពុងធ្វេសប្រហែសព្រងើយកន្តើយ នឹងការពិតមួយដែលថាបញ្ជាមិនអាចគោរព ឬក៏មិនត្រូវបានគោរព នេះត្រូវបាន ហៅថាការរំខានឬភាពទន់ខ្សោយរបស់កងទ័ព។

(២)-កិច្ចប្រឹងប្រែងគ្រប់គ្រងកងទ័ពនៅក្នុងមធ្យោបាយដូចគ្នាទៅនឹងការគ្រប់គ្រងរាជាណាចក្រ មួយដែរ ការព្រងើយកន្តើយនៅលក្ខ័ខណ្ឌ័ទាំងឡាយដែលទទួលយកក្នុងកងទ័ព នេះបង្ក រអោយមានភាពអន្ទះអន្ទែងនៅក្នុងចិត្តកងទ័ព។

(៣)-ការប្រើប្រាស់នាយទាហ៊ាននៅក្នុងកងទ័ពដោយគ្មានការទទួលស្គាល់ ការទទួលខុស ត្រូវតាមរយៈការព្រងើយកន្តើយ និងការធ្វេសប្រហែសនៃគោលការណ៍យោធានៃការសំរប សំរួលតាមកាលៈទេសៈ។ នេះធ្វើអោយច្របល់ និងកំចាត់នៅជំនឿទុកចិត្តរបស់ពល ទាហ៊ាន។

ប៉ុន្តែនៅពេលកងទ័ពមានចិត្តអន្ទះអន្ទែង និងបាត់បង់សេចក្តីជឿទុកចិត្ត បញ្ហា ពិតកើតចេញពីសម្តេចសក្តិភូមិដទៃៗទៀត។ នេះគឺជារឿងសមញ្ញបំផុត នាំទៅរកភាព អាណាធិបតេយ្យក្នុងជួរទ័ព ឈានទៅរកការបរាជ័យក្នុងសមរភូមិ។

**១៣)**-ដូច្នេះយើងអាចយល់ដឹងថាមានកត្តាសំខាន់ៗ៥យ៉ាងសំរាប់ជោគជ័យគឺៈ

(១)-អ្នកនឹងឈ្នះសង្គ្រាម នៅពេលអ្នកដឹងពីពេលវេលាត្រូវវាយប្រហារ និងពេលវេលា ដែលមិនត្រូវវាយប្រហារ។

(២)-អ្នកដែលយល់ដឹងពីវិធីដោះស្រាយបញ្ហារជាមួយទាំងថ្នាក់លើ កងកំលាំងថ្នាក់លើនិង កងកំលាំងថ្នាក់ក្រោម។

(៣)-មេទ័ពឬឧត្តមសេនីយដែលកងទ័ពរបស់ពួកមានភាពសកម្មរស់រវើកដោយស្មារតីអារម្មណ៍ ដូចគ្នាពាសពេញជួរកងទ័ព និងគ្រប់ឋានៈជាន់ថ្នាក់។

(៤)-ឧត្តមសេនីយឬមេទ័ពដែលចេះត្រៀមបំរុងរៀបចំកំលាំងកងទ័ពរបស់ខ្លួនដើម្បីរង់ចាំឱកាស វាយលុកសត្រូវដែលធ្វេសប្រហែស ឬមិនបានត្រៀមបំរុង។

(៥)-ឧត្តមសេនីយឬមេទ័ពដែលមានសមត្ថភាពយោធាគ្រប់គ្រាន់ ហើយមិនត្រូវបានជ្រៀតជ្រែកដោយមហាក្សត្រ ឬអ្នកដែលមានអំណាចធំជាង។

១៥)-នៅពេលនោះ លោកស៊ុនជូនិយាយថា«បើអ្នកយល់ច្បាស់ពីសត្រូវរបស់អ្នក និងយល់ច្បាស់ពីខ្លួនអ្នក អ្នកមិនចំបាច់ភ័យបារម្ភពីលទ្ធផលនៃការធ្វើចំបាំងរាប់រយពាន់ដងនោះទេ។ បើអ្នកស្គាល់ខ្លួនឯងច្បាស់ ប៉ុន្តែស្គាល់សត្រូវមិនច្បាស់ ជ័យជំនះមិនទៀងទាត់ជូនឈ្នះជូនចាញ់។ បើអ្នកស្គាល់ខ្លួនឯងមិនច្បាស់ ស្គាល់សត្រូវមិនច្បាស់ ច្បាំង១០០ដងគឺបរាជ័យទាំង១០០ដង»។

## ៤-អាជ្ញាស័យយុទ្ធវិធី ការរៀបចំក្បួនតាមយុទ្ធសាស្ត្រតាមយុទ្ធវិធី(Tactical Dispositions):

១)-លោកស៊ុនជូបានមានប្រសាសន៍ថា«អ្នកណាក៏ដោយ មកដល់មុន ហើយរងចាំការមកដល់សត្រូវ នឹងវាយប្រហារខ្មាំងសត្រូវប្រកបដោយភាពស្វាហាប់ជោគជ័យ។អ្នកណាក៏ដោយមកដល់ទី២ ឬបន្ទាប់នៅក្នុងទីលានសមរភូមិ ហើយត្រូវតែរហ័សធ្វើសង្គ្រាមនឹងប្រើអស់កំលាំងឋាមពលច្បាំងជាមួយនឹងខ្មាំងសត្រូវ»។

២)-ហេតុដូច្នេះអ្នកធ្វើចំបាំងដ៏ឆ្លាតវៃ បានធ្វើអោយឆន្ទៈរបស់គាត់មានឥទ្ធិពលលើសត្រូវ ប៉ុន្តែមិនអនុញ្ញាតិអោយឆន្ទៈសត្រូវមានឥទ្ធិពលលើគាត់វិញទេ។ ការពារកងទ័ពរបស់យើងប្រឆាំងនឹងការផ្ចាញ់របស់សត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់យើង ប៉ុន្តែឱកាសឬកាលៈទេសៈផ្ចាញ់សត្រូវគឺត្រូវបានផ្តល់ដោយសត្រូវខ្លួនឯង។

៣)-លោកស៊ុនជូបាននិយាយទៀតថា«មេទ័ពឬឧត្តមសេនីយអាចយល់ដឹងនៅវិធីឈ្លានពានវាយលុកខ្មាំង តែមិនធ្វើវា»។

៤)-ដូច្នេះអ្នកវាយប្រហារល្អ គឺមានសមត្ថភាពការពារខ្លួនឯងប្រឆាំងនឹងការផ្ចាលរបស់សត្រូវ ប៉ុន្តែមិនអាចបង្កើតឱកាសពិតប្រាកដនៃការផ្ចាញ់សត្រូវបានទេ។

៥)-សន្តិសុខប្រឆាំងនឹងការផ្ចាញ់របស់សត្រូវ អនុវត្តន៍យុទ្ធវិធិការពារវិញ សមត្ថភាពផ្ចាញ់សត្រូវមានន័យថាប្រកាន់យកការវាយលុកប្រឆាំងសត្រូវ។

៦)-ការឈរលើជំហរការពារ បង្ហាញថាកំលាំងរបស់យើងមិនទាន់គ្រប់គ្រាន់ ប៉ុន្តែការប្រកាន់យកការវាយប្រហារ មានន័យថា កំលាំងរបស់យើងគ្រប់គ្រាន់បរិបូរណ៍ហូរហៀរមួយ។

៧)-ឧត្តមសេនីយដែលមានជំនាញនៅក្នុងកិច្ចការពារ ពួកែលាក់ខ្លួននៅក្នុងជំរកឈប់សំពាកង័អាចិកំបាំងបំផុតលើផែនដីនេះ។ ឧត្តមសេនីយដែលមានជំនាញក្នុងការវាយប្រហារលឿនដូចផ្លេកបន្ទោរ សំរុកចូលកំទេចសត្រូវចេញពីទីខ្ពស់បំផុតនៃជំរក(ភ្នំខ្ពង់រាបទួល)។ដូច្នេះផ្ទុយទៅវិញ យើងមានសមត្ថភាពការពារខ្លួនឯង នោះជ័យជំនះនឹងទទួលបានពេញលេញ។

៨)-ដើម្បីឃើញជ័យជំនះតែប៉ុណ្ណោះនៅពេលដែលវាស្ថិតនៅក្នុងការយល់ចេះដឹងរបស់ហ្វូងទ័ពរួមគឺមិនមែនភាពខ្ពស់បំផុតនៃភាពល្អប្រពៃនោះទេ។

៩)-វាគ្មានទាល់តែសោះពាក្យថាទីខ្ពស់បំផុតនៃភាពល្អប្រពៃថ្លៃថ្លានោះ ប្រសិនបើអ្នកវាយប្រហារសត្រូវនិងឈ្លានពានសត្រូវនោះ ហើយមានតែចក្រភពទាំងមូលទេនិយាយថា‹‹ប្រពៃណាស់›។

១០)-លើកសក់នៅរដូវស្លឹកឈើជ្រុះមួយគឺមិនមែនជាសញ្ញានៃមហាកំលាំងឋាមពលនោះទេបើឃើញព្រះចន្ទ័និងព្រះអាទិត្យគឺមិនមែនជាសញ្ញានៃទិដ្ឋភាពច្បាស់លាស់ទេ។ បើឮសូរសំលេងផ្គរគឺមិនមែនជាសញ្ញានៃត្រចៀករហ័សទេ។

១១)-អ្វីដែលចាស់បុរាណបានហៅថា‹‹អ្នកវាយប្រហារដ៏ឆ្លាតវៃមួយ››គឺអ្នកដែលមិនមែនឈ្នះតែប៉ុណ្ណោះទេ ប៉ុន្តែប៉ិនប្រសព្វធ្វើអោយទទួលជោគជ័យដោយងាយស្រួល។

១២)-ហេតុដូច្នេះជ័យជំនះរបស់គាត់បាននាំអោយគាត់ មិនត្រឹមតែនាំមកនូវកេរ្តិ៍ឈ្មោះសំរាប់គតិបណ្ឌិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវជំនឿជឿជាក់សំរាប់សេចក្តីក្លាហានទៀតផង។

១៣)-អ្នកដែលឈ្នះការប្រយុទ្ធដោយគ្មានកំហុស ភាពគ្មានកំហុសគឺជាអ្វីដែលបង្កើតចេញពីភាពពិតប្រាកដនៃជ័យជំនះសំរាប់ជ័យជំនះ មានន័យថា ការឈ្លានពានលុកលុយសត្រូវដែលត្រូវបានចាញ់រួចស្រេច។

១៤)-ហេតុដូច្នេះ អ្នកវាយប្រហារដ៏ប៉ិនប្រសព្វគឺដាក់ខ្លួនគាត់ចូលទៅក្នុងទីតាំងមួយឬជំហរមួយដែលមិនចេះបរាជ័យ ឬការធ្វើអោយការបរាជ័យមិនអាចកើតមានឡើង ហើយមិនដែល

បំភ្លេចឱកាសវាយផ្ចាញ់សត្រូវឡើយ ឬចេះក្ដាប់ឱកាស ឆក់ឱកាសយកឈ្នះលើស ត្រូវធ្វើអោយសត្រូវបរាជ័យគ្រប់ពេល។

**១៥)**-ដូច្នេះវាគឺថានៅក្នុងសង្គ្រាម អ្នកយុទ្ធសាស្ត្រដែលប្រកបដោយជោគជ័យ គ្រាន់តែស្វែងរកចំណុចខ្សោយនិងចំណុចខ្លាំងនៅក្នុងការប្រយុទ្ធ បន្ទាប់ពីជោគជ័យបានឈ្នះ នៅពេលនោះដែរ អ្នកដែលចេះរៀបចំជោគវាសនា តំរង់ទិស កែតំរូវឡើងវិញ កែប្រែវាសនាឡើងវិញ ពីការផ្ចាញ់របស់សត្រូវ ការវាយប្រហារលើកទី១ ហើយបន្ទាប់មកចេះស្វែងរកជោគជ័យ និងយកឈ្នះសង្គ្រាមលើកក្រោយជាបន្តបន្ទាប់។

**១៦)**-មេដឹកនាំដែលមានជំនាញទេពកោសល្យពេញខ្លួន មានសមត្ថភាពពេញបរិបូរណ៍ចេះដាំបណ្ដុះឬបង្កើតច្បាប់សីលធម៌ ហើយប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនៅវិធីសាស្ត្រនិងបទវិន័យ។ ដូច្នេះវាស្ថិតនៅក្នុងអំណាចរបស់គាត់ដើម្បីគ្រប់គ្រងត្រួតត្រាជ័យជំនះ។

**១៧)**-ដោយគោរពទៅតាមវិធីសាស្ត្រកងទ័ព យើងត្រូវតែប្រកាន់យក៖

_ទី១៖ ការគណនាវាស់ស្ទង់វិធានការជាប់ជំពាក់វាក់វិននឹងអត្ថិភាពរបស់វាទៅនឹងផែនដី។

_ទី២៖ ការប៉ាន់ស្មានបរិមាណ ចំពោះការវាស់ស្ទង់។

_ទី៣៖ ការគណនាគន់គូរ ចំពោះការប៉ាន់ប្រមាណបរិមាណ។

_ទី៤៖ ការថ្លឹងថ្លែងនៅឱកាសភ័ព្វសំណាង ចំពោះការគណនាគន់គូរ។

_ទី៥៖ ជ័យជំនះ បានដោយសារការថ្លឹងថ្លែងឱកាសពេលវេលា។

កងទ័ពដែលទទួលជ័យជំនះគឺជាអ្នកដែលចេះលើកយកមធ្យោបាយដែលបានដើរលើផ្លូវមួយដែលថាប្រៀបបីដូចជាទំងន់មួយផោនដាក់ថ្លឹងលើជញ្ជីង ដើម្បីដឹងពីទំងន់គ្រាប់ធុញ្ញជាតិថាទំងន់ប៉ុន្មាន?

ការរុលទៅមុខរបស់កងកំលាំងដែលកំពុងវាយលុកឈ្លានពានមួយគឺប្រៀបបីដូចផ្ទុះចេញរបស់ទឹកដែលទប់នៅក្នុងជ្រោះជ្រៅមួយដែលមានជំរៅ១០០០ព្យាង្គ(៦០០០ហ្វីត)។

**៥-កំលាំងឋាមពល (Energy):**

១)-លោកស៊ុនជូបានមានប្រសាសន៍ថា«ការគ្រប់គ្រងត្រួតត្រាលើកងកំលាំងទ័ពមួយគឺប្រៀបបីដូចជាគោលការណ៍ដូចគ្នាទៅនឹងការគ្រប់គ្រងត្រួតត្រាលើមនុស្សពីរបីនាក់ ឬមួយចំនួនតូច វាគ្រាន់តែស្ថិតនៅលើបញ្ហាមួយត្រង់ថាការបែងចែងចំនួនកងទ័ពរបស់ពួកគេតែប៉ុណ្ណោះ»។

២)-ការវាយប្រហារដោយប្រើកំលាំងទ័ពធំមួយរបស់អ្នកក្រោមបញ្ជារបស់អ្នកគឺមិនខុសគ្នាទាល់តែសោះពីការវាយប្រហារដោយប្រើកំលាំងទ័ពតូចមួយ វាគ្រាន់តែស្ថិតលើបញ្ហាមួយត្រង់ថាការបង្កើតនៅសញ្ញាសំគាល់ សញ្ញាសំងាត់ និងម៉ូសំងាត់ ពាក្យសំងាត់តែប៉ុណ្ណោះ។

៣)-ដើម្បីធានាថា កំលាំងទ័ពសម្ព័ន្ធមិត្តទាំងមូលរបស់អ្នកអាចទប់ទល់បានទៅនឹងភាពភ្លៀវក្លានៃកំលាំងវាយប្រហាររបស់សត្រូវ ហើយនៅតែរក្សាជំហរហ្នឹងថ្កល់នោះគឺមានន័យថានេះត្រូវបានមានឥទ្ធិពល ប្រសិទ្ធភាពទៅបាន ដោយសារតែកលឧបាយប៉ិនប្រសព្វដោយផ្ទាល់ ឬដោយប្រយោល។

៤)-ឥទ្ធិពលកំលាំងទ័ពរបស់អ្នកអាចមានប្រៀបបីដូចថ្មត្បាល់កិនដែលវិលរុញប្រានកិនស៊ុតមួយគឺថា នេះត្រូវបានមានប្រសិទ្ធិភាពដោយសារតែវិទ្យាសាស្រ្តនៃចំណុចខ្លាំង និងចំណុចខ្សោយ។

៥)-នៅរាល់គ្រប់ការវាយប្រហារទាំងអស់ វិធីសាស្រ្តផ្ទាល់អាចត្រូវបានប្រើសំរាប់ការចូលរួមប្រយុទ្ធ ឬធ្វើចំបាំង ប៉ុន្តែវិធីសាស្រ្តប្រយោលនឹងត្រូវបានប្រើដើម្បីការពារសុវត្ថិភាពជ័យជំនះ។

៦)-យុទ្ធវិធីតិចនិចមិនផ្ទាល់ត្រូវបានប្រើប្រកបដោយប្រសិទ្ធិភាពខ្ពស់ ត្រូវបានប្រើមិនចេះអស់មិនចេះហើយ ទាំងផែនដីនិងឋានសួគ៌គ្មានទីបញ្ចប់ ប្រៀបបីដូចជាការហូរនៃទឹកទន្លេនានា និងទឹកស្ទឹងនានាដូចគ្នាទៅនឹងព្រះអាទិត្យនិងព្រះច័ន្ទ ទោះបីពួកគេមានទីបញ្ចប់ ប៉ុន្តែពួកគេចាប់ផ្តើមសារជាថ្មីឡើងវិញ មិនខុសពីរដូវកាលទាំង៤វិលចុះឡើងបន្ទាប់ពីរដូវកាលមួយកន្លងផុតទៅ រដូវកាលមួយទៀតមកដល់ ហើយរដូវកាលមួយទៀតវិលត្រឡប់មកវិញជាច្រើនលើកច្រើនសារ គ្មានទីបញ្ចប់។

៧)-មិនលើសពីគ្រឿងប្រគុំតន្ត្រីទាំង៥នោះទេ ចងផ្គុំគ្នានៃវត្ថុទាំង៥នេះ បង្កើតចេញនៅបទភ្លេងយ៉ាំពិរោះរណ្ដំ លើសពីអ្វីៗដែលធ្លាប់បានឮកន្លងមក។

៨)-គ្មានអ្វីលើសពីពណ៌ធម្មជាតិចំបងៗទាំង៥នោះទេ(មានពណ៌ខៀវ ក្រហម លឿង សនិងខ្មៅ)ទាំង៥ចងផ្គុំគ្នានោះ ពួកគេបង្កើតបានជាពណ៌ធម្មជាតិច្រើនរាប់មិនអស់ច្រើនជាងពណ៌ធម្មជាតិដែលយើងធ្លាប់ឃើញ។

៩)-គ្មានអ្វីប្រពៃជាងរសជាតិសំខាន់ៗទាំង៥ទេ(រសជាតិជូរ ប្រៃ ហាងហិរឆ្ងល ផ្អែម ល្វីង)ឱជារសទាំង៥ចងផ្គុំគ្នានោះ ផ្សំគ្នាបង្កើតចេញជាលទ្ធផលរសជាតិច្រើន ឱជារសច្រើនរាប់មិនអស់ប្រសើរជាងយើងធ្លាប់ភ្លក់សាកកន្លងមក។

១០)-នៅក្នុងការវាយប្រយុទ្ធ មានមិនលើសពីវិធីសាស្ត្រពីរនៃការវាយប្រហារនោះទេគឺដោយផ្ទាល់និងដោយប្រយោល ហើយការវាយប្រហារទាំង២នឹងចងផ្គុំគ្នា ផ្គុំលាយគ្នា ផ្តល់បង្កើតចេញនៅការកើនឡើងជាសេរីលំដាប់កលឧបាយគ្មានទីបញ្ចប់មួយ។

១១)-ការវាយប្រហារផ្ទាល់និងមិនផ្ទាល់នាំមុខគ្នាទៅវិញទៅមក ប្រើត្រឡប់ទៅត្រឡប់មក។វាហាក់បីដូចជាធ្វើចលនា ធ្វើដំណើរនៅក្នុងរង្វង់មួយ វិវត្តន៍នៅក្នុងវាលវដ្តសង្សារមួយគឺអ្នកមិនអាចមកដល់ទីបញ្ចប់បានទេ ហើយមិនអាចរកទីបញ្ចប់ឃើញទេ។ តើនរណាអាចប្រើអស់លទ្ធភាពនៃការចងផ្គុំពួកគេនោះ។

១២)-ការវាយប្រយុទ្ធរបស់កងទ័ពគឺហាក់បីដូចជាការស្ទុះទៅមុខរបស់ក្រសែទឹកហូរខ្លាំងដែលនឹងវិលក្បួចនៅជំវិញថ្ម បង្កើតជាខ្សែទឹកគួចទៅតាមចរន្តទឹក។

១៣)-គុណសម្បត្តិនៃការសំរេចចិត្តគឺប្រៀបបានទៅនឹងការឆាបដណ្តើមយកអ្វីមួយរហ័សទាន់ពេលរបស់សត្វស្ទាំងមួយដែលធ្វើអោយវាកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពឡើងលើការវាយប្រហារ និងការកំទេចជនរងគ្រោះ ឬសត្វប្រមាញ់របស់វា។

១៤)-ហេតុដូច្នេះ អ្នកវាយប្រហារដ៏ពូកែនឹងធ្វើអោយរន្ធត់ញាប់ញ័រ នៅក្នុងការចាប់ផ្តើមរបស់គាត់ ហើយធ្វើអោយសំរេចគោលដៅតាមការសំរេចចិត្តរបស់គាត់។

១៥)-ឋាមពលកំលាំងអាចត្រូវបានប្រៀបបីដូចជាការបង្ហោងឬបន្ទន់តាមរបស់ដងធ្នូរ ហើយធាក់ទាញកន្ទ្រាក់ទៅវិញទៅតាមការព្រលែងនៃគន្លឹះនៃព្រួញធ្នូ បង្កើតកំលាំងយ៉ាងរហ័សបាញ់ឆ្ពោះទៅមុខទៅតាមគោលដៅដែលបានសំរេចចិត្តរួចស្រេច។

១៦)-ក្នុងចំណោមភាពចលាចល និងច្របូកច្របល់នៃការវាយប្រយុទ្ធគ្នាច្បាំងគ្នា ហាក់បីដូចជាមានភាពចលាចលរឹករវរផង និងមិនមាពចលាចលរឹករវរទាល់តែសោះ គ្មានភាពចលាចលច្របូកច្របល់ពិតប្រាកដនោះទេ ហើយការធ្វើសម្មតិកម្មរបស់អ្នកប្រហែលជាគ្មានក្បាលឬគ្មានកន្ទុយទាល់តែសោះ ក្នុងចំណោមភាពច្របូកច្របល់ចលាចល និងភាពរឹករវរជ្រួលច្របល់ ហើយវាជាតឹកតាងមួយបញ្ជាក់ថា គ្មានភាពប្រាកដក្នុងការផ្ចាញ់សត្រូវឬជាភស្តុតាងប្រឆាំងនឹងការផ្ចាញ់សត្រូវ។

១៧)-ការធ្វើពុតក្លែងភេទជាច្របូកច្របល់រឹករវរជ្រួលច្របល់ ទាមទារតំរូវអោយមានវិន័យយ៉ាងល្អសុក្រឹត្យបំផុត។ ការក្លែងភេទពុតធ្វើជាភ័យខ្លាច ទាមទារតំរូវអោយមានភាពក្លាហានមុះមុតក្លៀវក្លាបំផុតក្នុងជួរកងទ័ព។ការធ្វើពុតក្លែងធ្វើជាទន់ខ្សោយអន់ថយ ទាមទារតំរូវអោយមានភាពរឹងមាំខ្លាំងពូកែ ប្រកបដោយឋាមពលក្នុងជួរកងទ័ព។

១៨)-ការលាក់ទុកសណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងអាវដណ្តប់នៃភាពចលាចលច្របូកច្របល់គឺជាបញ្ហាមួយដ៏សមញ្ញនៃការបែងចែកបន្ត។ ការលាក់បំពួនភាពក្លាហានមុះមុតនៅក្រោយឆាកផុតនៃភាពខ្វះមុខកំសាកញី ជាបុរេសន្និដ្ឋាននៅមូលនិធិមួយនៃឋាមពលកំលាំងអាថ៌កំបាំង។ ការពាក់មុខឬស្រោមមុខខ្សោយលើភាពខ្លាំងក្លា ត្រូវតែមានប្រសិទ្ធិភាពដល់សម្បទារយុទ្ធវិធិឬការរៀបចំយុទ្ធវិធីធ្វើសឹកសង្រ្គាម។

១៩)-ដូច្នេះឧត្តមសេនីយដែលមានជំនាញក្នុងការរក្សាសត្រូវអោយវិលវល់ក្នុងការសំដែងចេញនៅអាក្ការៈបោកប្រាស់ ល្បិចបោកបញ្ឆោតដ៏កំពូលរបស់ខ្លួនដែលដូរផ្លាស់ជានិច្ចនោះដោយយោងទៅតាមសត្រូវធ្វើសកម្មភាព។ ឧត្តមសេនីយជំនាញកលយុទ្ធ ពលិកម្មលះបង់អ្វីមួយដែលសត្រូវអាចដណ្តើមយកវា។

២០)-ការជ្រើសរើសយកវិធីដាក់នុយបញ្ឆោត ឧត្តមសេនីយឬមេទ័ពបញ្ឆោតអោយសត្រូវដេញតាមកងទ័ពជំរើសឬកងទ័ពពិសេស បន្ទាប់ពីគាត់បានរៀបក្បួនពួនស្ទាក់ស្ទាត់ចាំវាយប្រហារសត្រូវនៅពេលពួកគេមកដល់។

២១)-អ្នកវាយប្រហារដ៏ឆ្លាតវៃ ត្រូវចេះសំលឹងមើលប្រសិទ្ធភាពឥទ្ធិពលនៃឋាមពលកំលាំងចងផ្តុំ ហើយមិនត្រូវការមនុស្សច្រើនទេចេញពីបុគ្គលកងទ័ពទាំងឡាយ។ ហេតុដូច្នេះលទ្ធភាព សមត្ថភាពរបស់គាត់ត្រូវតែជ្រើសរើសមនុស្សខ្លាំងពូកែ និងប្រសប់ប្រើប្រាស់ឋាមពលចងផ្តុំ។

២២)-នៅពេលដែលគាត់ពូកែខាងប្រើប្រាស់ឋាមពលកំលាំងចងផ្តុំឬការផ្តុំកំលាំង ទ័ពវាយប្រយុទ្ធរបស់គាត់នឹងក្លាយទៅជាដូចឈើហុបរមៀលចុះពីលើភ្នំ ឬក៏ដុំថ្មធំរមៀលចុះលើភ្នំ។សំរាប់ការប្រើកំលាំងឋាមពលចងផ្តុំ ឬឋាមពលប្រមូលផ្តុំគឺជាលក្ខណៈធម្មជាតិរបស់ឈើហុបនិងដុំថ្មធំមួយនៅស្ងៀមឥតកំរើក ហើយកំរើកនៅពេលនៅទីជំរាល ឬទីតាំងចោទខ្លាំង។ ប្រសិនបើរាង៤ជ្រុង ក្លាយជានៅស្ងៀមហ្នឹងថ្កល់ ប៉ុន្តែប្រសិនបើរាងមូលគឺស្ទុះរមៀលចុះក្រោម។

២៣)-ដូច្នេះកំលាំងឋាមពលបានរីកចំរើនដោយសារអ្នកវាយប្រហារដ៏ចំណាន គឺហាក់បីដូចជាកំលាំងសន្ទុះរុញច្រានថ្មមូលមួយអោយរមៀលចុះពីលើភ្នំមួយមានកំពស់របស់ពាន់ហ្វីត។ច្រើនបំផុតលើប្រធានបទនៃឋាមពល។

## ៦-ចំណុចខ្សោយ និងចំណុចខ្លាំង(Weak Points and Strong Points):

១)-លោកស៊ុនជូបានមានប្រសាសន៍ថា ‹‹អ្នកណាក៏ដោយដែលជាអ្នកទី១ទៅដល់សមរភូមិមុនហើយរងចាំការមកដល់របស់សត្រូវ នឹងក្លាយទៅជាអ្នកវាយប្រហារដ៏ក្លៀវក្លាមុះមុត ហើយអ្នកណាក៏ដោយជាអ្នកទៅដល់ទី២ទៅដល់សមរភូមិ ត្រូវតែប្រញាប់ធ្វើចំបាំងដោយប្រើអស់កំលាំងកាយ។

២)-ហេតុដូច្នេះ អ្នកវាយប្រហារដ៏ឆ្លាតវៃធ្វើអោយឆន្ទះរបស់ខ្លួន មានឥទ្ធិពលលើសត្រូវ ប៉ុន្តែមិនអនុញ្ញាតិអោយឆន្ទះរបស់សត្រូវមានឥទ្ធិពលលើខ្លួនឡើយ។

៣)-ឧត្តមសេនីយដែលចេះទាញផលប្រយោជន៍ពីសង្គ្រាម អាចបង្ករអោយសត្រូវឈានដល់ធ្វើអោយកិច្ចព្រមព្រៀមមិនផ្តល់លទ្ធភាពអោយសត្រូវចូលជិតគាត់ ដោយការបង្ខិតបង្ខំបំផ្លិចបំផ្លាញ។

៤)-ប្រសិនបើសត្រូវរបស់គាត់ប្រកាន់យកកន្លែងសុខស្រួលរបស់ខ្លួន គាត់អាចរំខានសត្រូវ បើសត្រូវសម្បូរស្បៀងហូរហៀរ គាត់អាចធ្វើអោយសត្រូវជួបគ្រោះទុរភិក្ស បើសត្រូវបោះជំរំនៅយ៉ាងស្ងៀមស្ងាត់ គាត់អាចបង្ខំអោយសត្រូវផ្លាស់ប្តូរទីកន្លែង។

៥)-ការលិចឡើងនៅច្រើនចំណុចដែលសត្រូវត្រូវតែប្រញាប់ការពារយាត្រាទ័ពយ៉ាងប្រញាប់ទៅកន្លែងនានាដែលអ្នកមិនត្រូវបានគិតទុកជាមុន។

៦)-កងទ័ពរបស់អ្នកយាត្រាទ័ពទៅទីកន្លែងដ៏សែនឆ្ងាយដោយគ្មានវិបត្តិ ប្រសិនបើកងទ័ពអ្នករំកិលទ័ពតាមជនបទស្រុកស្រែដែលគ្មានសត្រូវ។

៧)-អ្នកអាចប្រាកដច្បាស់ក្នុងការបន្តការវាយប្រហាររបស់អ្នក ប្រសិនបើអ្នកគ្រាន់តែវាយប្រហារតាមទីកន្លែងដែលពុំមានការការពារ។ អ្នកអាចធានាសុវត្ថិភាពនៃការការពាររបស់អ្នកប្រសិនបើអ្នកគ្រាន់តែប្រកាន់យកទីតាំងទាំងឡាយដែលមិនអាចត្រូវបានវាយប្រហារ។

៨)-ហេតុដូច្នេះ ឧត្តមសេនីយដែលប៉ិនប្រសព្វក្នុងការវាយប្រហារសត្រូវរបស់គាត់ដែលមិនដឹងថាអ្វីដែលត្រូវការពារ ហើយគាត់មានជំនាញច្បាស់លាស់ក្នុងកិច្ចការពារដែលគូរសត្រូវរបស់គាត់មិនយល់ពីអ្វីដែលត្រូវវាយប្រហារ។

៩)-អូរ! អាទិទេពនៃសិល្បៈប្រើល្បិចយ៉ាងប្រសប់ និងកិច្ចការសំងាត់លាក់ការណ៍សំងាត់បានល្អ! តាមរយៈអ្នក យើងរៀនដឹងនៅអ្វីដែលមើលមិនឃើញ និងអ្វីដែលស្តាប់មិនឮហើយហេតុដូច្នេះ យើងអាចប្រកាន់យកភ័ព្វវាសនាសត្រូវ ឬក្តាប់កាន់ធ្វើម្ចាស់លើវាសនារបស់សត្រូវ ក្តោបក្នុងដៃរបស់យើង។

១០)-អ្នកអាចឈានទៅមកវាយសំរុកចូលទីតាំងរបស់ត្រូវ ហើយសត្រូវមិនអាចទប់អ្នកបានទាល់តែសោះ ប្រសិនបើអ្នកវាយប្រហារចំណុចខ្សោយរបស់សត្រូវ។ អ្នកអាចឈប់សំរាកនិងតាំងទីដោយសុវត្ថិភាពពីការដេញតាមសត្រូវ ប្រសិនបើចលនាទ័ពរបស់អ្នកលឿនជាងចលនារបស់សត្រូវ។

១១)-ប្រសិនបើអ្នកចង់វាយប្រហារសត្រូវ ហើយសត្រូវរបស់អ្នកត្រូវបានដាក់កំលាំងការពាររឹងមាំមួយដោយមានជំរកនៅខាងក្រោយកំពែងខ្ពស់ និងប្រឡាយជ្រៅមួយ រាល់

ចំណុចទាំងយើងត្រូវការធ្វើគឺការវាយប្រហារតែកន្លែងខ្លះៗដែលសត្រូវខ្វះចន្លោះ ឬធ្វេសប្រហែស។

១២)-ប្រសិនបើយើងមិនចង់វាយប្រហារទេ យើងអាចការពារសត្រូវពីចំណុចខ្សែត្រៀមនៃជំរុំរបស់យើង ឬខ្សែត្រៀមនៃកន្លែងបោះជំរុំរបស់យើងគ្រាន់តែផ្អែកទៅតាមមូលដ្ឋានទីតាំងជាក់ស្តែង។រឿងទាំងអស់ដែលយើងត្រូវធ្វើគឺបោះបង់ចោលកន្លែងប្លែកៗ ហើយទទួលខុសត្រូវតែក្នុងមាគ៌ារបស់យើង។

១៣)-ដោយការរុករកអោយឃើញនៅការរៀបចំផ្លាស់ប្តូរទីតាំងរបស់សត្រូវ និងរកអោយឃើញកន្លែងសេសសល់ដែលមិនអាចមើលឃើញដោយខ្លួនយើងយើងអាចរក្សាកងកំលាំងរបស់យើង ប្រមូលផ្តុំគ្នាខណ:ដែលកំលាំងទ័ពសត្រូវត្រូវតែត្រូវបានបែងចែករំលែក។

១៤)-យើងអាចបង្កើតកងកំលាំងឯកភាពតែមួយ ខណ:ដែលសត្រូវត្រូវតែបំបែកកំលាំងបែងភាគកំលាំង។ ហេតុដូច្នេះនៅទីនោះនឹងក្លាយជាកងកំលាំងប្រមូលផ្តុំដ៏ធំមួយប្រឆាំងនឹងកំលាំងជាផ្នែកៗរបស់សត្រូវ ដែលមានន័យថាយើងនឹងមានកងទ័ពច្រើន វាយប្រហារកងទ័ពសត្រូវតិចតួច។

១៥)-ហើយដូច្នេះ ប្រសិនបើយើងអាចវាយប្រហារកងកំលាំងទ័ពដែលទន់ខ្សោយ អន់ខ្សោយជាងប្រើកំលាំងទ័ពច្រើនលើសលុបមួយនោះ សត្រូវរបស់យើងនឹងស្ថិតនៅក្នុងបញ្ហាលំបាកធ្ងន់ធ្ងរ។

១៦)-ចំណុចកន្លែងដែលយើងចង់ ឬមានចេតនាវាយប្រហារ ត្រូវតែលាក់ការណ៍សំងាត់កុំអោយគេដឹង បន្ទាប់មក សត្រូវរបស់អ្នកនឹងត្រូវតែត្រៀមរៀបចំទប់ទល់ការវាយប្រហាររបស់អ្នកដែលអាចទៅរួចមួយនៅរាល់គ្រប់ចំណុចផ្សេងៗគ្នាជាច្រើន ហើយកងកំលាំងរបស់អ្នកកំពុងត្រូវបានចូលរួមនៅក្នុងទិសដៅជាច្រើន ហើយចំនួនកងទ័ពរបស់សត្រូវដែលយើងនឹងត្រូវតែប្រឈមមុខនៅចំណុចគោលដៅវាយប្រហារ នឹងមានចំនួនសមាមាត្រតិចតួចគឺទ័ពច្រើនវាយកំទេចទ័ពតិច។

១៧)-កន្លែងដែលសត្រូវរបស់អ្នកគួរតែពង្រឹងភ័ណ្ឌរថរបស់ខ្លួនគឺ៖

_បើសត្រូវអ្នកនឹងខ្សោយផ្នែកខាងក្រោយ គាត់គួរតែពង្រឹងនៅផ្នែកខាងក្រោយអោយរឹងមាំ។

_បើសត្រូវរបស់អ្នកខ្សោយផ្នែកខាងឆ្វេង សត្រូវរបស់អ្នកគួរតែពង្រឹងផ្នែកខាងឆ្វេង។

_បើសត្រូវរបស់អ្នកខ្សោយផ្នែកខាងស្តាំ ពួកគេគួតែពង្រឹងផ្នែកខាងស្តាំ។

_បើសត្រូវខ្សោយគ្រប់ទីកន្លែង ប្រសិនបើសត្រូវរបស់អ្នកនឹងពង្រឹងកំលាំងទ័ពគ្រប់ទីកន្លែងសត្រូវរបស់អ្នកនឹងខ្សោយគ្រប់ទីកន្លែង។

១៨)-ភាពទន់ខ្សោយជាលំដាប់លំដោយកើតចេញពីការត្រៀមរៀបចំទប់ទល់នឹងការវាយប្រហារដែលអាចកើតមានឡើង។ ចំណែកឯភាពខ្លាំងពូកែជាលំដាប់លំដោយកើតចេញពីការបង្ខិតបង្ខំរបស់សត្រូវរបស់យើងធ្វើការត្រៀមរៀបចំទប់ទល់នឹងយើងឥតឈប់ឈរ។

១៩)-ការយល់ដឹងពីទីកន្លែង និងពេលវេលានៃការប្រយុទ្ធដែលនឹងមកដល់ យើងអាចប្រមូលផ្តុំចេញពីរយៈចំងាយដ៏ឆ្ងាយបំផុតដើម្បីវាយប្រយុទ្ធ។

២០)-ប៉ុន្តែប្រសិនបើមិនដឹងពីពេលវេលា ថែមទាំងមិនស្គាល់ពីទីកន្លែងនោះទេ នោះស្លាបឆ្វេងនឹងគ្មានសក្តានុពលជួយស្លាបស្តាំ រីឯស្លាបស្តាំក៏គ្មានសក្តានុពលស្មើរគ្នាដើម្បីជួយស្លាបឆ្វេងនោះទេ។ ភ័ណ្ឌរថមិនអាចបន្ទូរផ្នែកខាងក្រោយ ឬយកផ្នែកខាងក្រោយទៅជួយគាំទ្រផ្នែកខាងមុខបានទេ។ តើចំងាយឆ្ងាយប៉ុន្មានដើម្បីធ្វើដូច្នេះ ប្រសិនបើមួយផ្នែកៗនៃកងទ័ពឆ្ងាយដាច់ពីគ្នាបំផុតគឺជាបញ្ហាដែលស្ថិតនៅក្នុងចំងាយ១០០យោជន៍ ហើយសូម្បីតែផ្នែកជិតបំផុតត្រូវបានបំបែកដាច់ពីគ្នាដោយចំងាយជាច្រើនយោជន៍។

២១)-ទោះបីជាយោងទៅតាមការប៉ាន់ប្រមាណរបស់ខ្ញុំអំពីពលទាហ៊ានរបស់យូអិ មានចំនួនលើសលុបលើកំលាំងទាហ៊ានផ្ទាល់របស់យើងក៏ដោយ នោះនឹងទាញយកផលប្រយោជន៍មិនបានអ្វីទាំងអស់នៅក្នុងបញ្ហាជ័យជំនះ។ ដូច្នេះខ្ញុំនិយាយថាជ័យជំនះអាចត្រូវបានសំរេចផល។

២២)-ទោះបីសត្រូវខ្លាំងជាងយើង និងមានចំនួនច្រើនជាងយើង យើងអាចទប់ស្កាត់ពួកគេពីការវាយប្រហារបាន។ គំរោងការដូច្នេះគឺធ្វើយ៉ាងណារកអោយឃើញផែនការរបស់ខ្មាំង និងកត្តាសំខាន់ៗដែលនាំអោយខ្មាំងទទួលជោគជ័យ។

២៣)-ត្រូវធ្វើអោយសត្រូវកក្រើកឡើង ហើយសិក្សារៀនសូត្រពីសកម្មភាពរបស់សត្រូវនិងភាពធ្វេសប្រហែស អសកម្មរបស់សត្រូវ។ បង្ខំអោយសត្រូវបង្ហាញខ្លួនឯង ដូច្នេះយើងអាចរកឃើញចំណុចខ្សោយរបស់សត្រូវ។

២៤)-ត្រូវប្រៀបធៀបយ៉ាងប្រុងប្រយ័ត្ននៅកងទ័ពកំលាំងទ័ពរបស់សត្រូវជាមួយនឹងកំលាំងទ័ពផ្ទាល់របស់អ្នក ដូច្នេះអ្នកអាចដឹងពីទីកន្លែងដែលកំលាំងសត្រូវខ្លាំងលើសលុប និងកន្លែងដែលកំលាំងសត្រូវទន់ខ្សោយមិនគ្រប់គាន់ ខ្វះចន្លោះ។

២៥)-នៅក្នុងការរៀបចំយុទ្ធវិធីល្បិចដ៍ខ្ពស់បំផុតដែលអ្នកអាចទទួលបានគឺលាក់បំពួនផែនការសំងាត់របស់អ្នក លាក់បំពួនការរៀបចំយុទ្ធរបស់អ្នក ហើយអ្នកអាចរស់នៅប្រកបដោយសុវត្ថិភាព រួចពីការឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នពីពួកចារបុរសដែលប៉ិនប្រសប់ខាងប្រើល្បិចកល ពីឧបាយកលទុច្ចរិតរបស់អ្នកដែលមានប្រាជ្ញាឆ្លាតវៃបំផុត។

២៦)-តើជ័យជំនះដូចម្តេចអាចត្រូវបានបង្កើតសំរាប់ពួកគេ ក្រៅពីបណ្តារយុទ្ធវិធីផ្ទាល់របស់សត្រូវគឺថាជាអ្វីដែលហ្វូងមនុស្សធម្មតាមិនអាចយល់ច្បាស់ មិនអាចដឹងបាន។

២៧)-មនុស្សទាំងអស់អាចមើលឃើញនៅយុទ្ធវិធីទាំងឡាយកន្លែងដែលខ្ញុំធ្លាប់ឈ្លានពានលុកលុយ ប៉ុន្តែអ្វីៗដែលគ្មាននរណាម្នាក់អាចយល់បាននោះគឺយុទ្ធសាស្រ្ត ក្រៅពីជ័យជំនះណាមួយត្រូវបានវិវត្តន៍។

២៨)-កុំយកបណ្តារយុទ្ធវិធីនានាមកប្រើដដែលៗ ជាពិសេសយុទ្ធវិធីដែលអ្នកប្រើធ្លាប់បានទទួលជ័យជំនះមួយ ប៉ុន្តែសូមយកយុទ្ធវិធី វិធីសាស្រ្តរបស់អ្នកត្រូវបានប្រើប្រាស់ទៀងទាត់ទៅតាមកាលៈទេសៈផ្សេងៗគ្នា គ្មានកំណត់ច្បាស់លាស់។

២៩)-យុទ្ធវិធីកងទ័ព យុទ្ធវិធីយោធាគឺប្រៀបបីដូចជាទឹក ចំពោះទឹកនៅក្នុងវគ្គចរន្តរបស់ទឹកតាមធម្មជាតិ ហូរចេញពីទីកន្លែងខ្ពស់និងធ្វើដំណើរស្ទុះយ៉ាងលឿនបុកទៅរកទីកន្លែងទាប។

៣០)-ដូច្នេះនៅក្នុងសង្គ្រាម ត្រូវប្រកាន់មាគ៌ាដែលថា យើងត្រូវតែប្រើមធ្យោបាយគេចវេសចៀសចេញពីអ្វីដែលខ្លាំង ហើយត្រូវតែវាយប្រហារវាយលុកលើអ្វីដែលខ្សោយ។

៣១)-ទឹកបង្កើតរូបរាងទៅតាមចរន្តខ្សែទឹករបស់វា ដោយយោងទៅតាមលក្ខណៈធម្មជាតិនៃមូលដ្ឋានធម្មជាតិ នៃមូលដ្ឋានទីតាំងជាក់ស្តែង ទៅលើទីកន្លែងណាមួយដែលវាហូរទៅកាន់ ហើយទាហ៊ានធ្វើចំបាំងបានជោគជ័យ អាស្រ័យលើសត្រូវដែលប្រឈមមុខនឹងពួកគេ។

៣២)-ហេតុដូច្នេះ គ្រាន់តែធ្វើអោយដូចទឹករក្សានៅរូបរាងទំរង់មិនពិតប្រាកដមួយ។ ដូច្នេះនៅក្នុងសឹកសង្គ្រាមគឺគ្មានលក្ខ័ខណ្ឌ៍ឋិតថេរពិតប្រាកដជានិរន្តនោះទេ។

៣៣)-ឧត្តមសេនីយដែលអាចផ្លាស់ប្តូរប្រែប្រួលនៅយុទ្ធវិធីរបស់ខ្លួននៅក្នុងការទំនាក់ទំនងទៅនឹងសត្រូវរបស់ខ្លួន ហើយបន្ទាប់នោះបន្តជោគជ័យជ័យជនះ បានន័យថាផ្លាស់ប្តូរយុទ្ធវិធីច្បាំងតាមស្ថានភាពជាក់ស្តែងរបស់សត្រូវ នឹងទទួលបានជ័យជំនះជាបន្តបន្ទាប់ អាចត្រូវបានហៅថាអ្នកបើកបរឬតៃកុងដែលបានកើតចេញពីឋានសួគ៌មួយ។

៣៤)-មានធាតុ៥(ទឹក ភ្លើង ឈើ លោហៈធាតុ ដី)ជានិច្ចកាលមិនមានសមភាពលុបលើគ្នាទេឬមិនមានប្រៀបលើគ្នាទេគឺដូចជា៤រដូវកាល បង្កើតមាតិអោយគ្នាឬត្រួសត្រាយផ្លូវអោយគ្នាទៅវិញទៅមក ត្រឡប់សារចុះសារឡើង។ មានថ្ងៃរដូវខ្លី និងវែង ព្រះចន្ទមានកំឡុងពេលវេលារបស់វាត្រូវរះចេញ លិបចូល លិចបាត់ ឬបង្ហាញខ្លួនធំតូចតាមពេលវេលា។

## ៧-ការប្រើកលឧបាយដ៏ប៉ិនប្រសប់ក្នុងសឹកសង្គ្រាម (Maneuvering) ៖

១)-លោកស៊ុន-ជូបានមានប្រសាសន៍ថា«នៅក្នុងសឹកសង្គ្រាម ឧត្តមសេនីយទទួលបញ្ជាពីព្រះមហាក្សត្រ ឬមេដឹកនាំនគរ»។

២)-ការប្រមូលកងទ័ពមួយ និងការប្រមូលផ្តុំកងកំលាំងប្រដាប់អាវុធ ឧត្តមសេនីយត្រូវតែចេះបត់បែន ទន់ភ្លន់ និងចុះសំរុងគ្នាទៅនឹងធាតុខុសគ្នាផ្សេងៗទាំង៥សិន មុនពេលបោះជំរុំរបស់ខ្លួន។

៣)-បន្ទាប់ពីនោះ នៅក្នុងការធ្វើសឹកសង្គ្រាម គ្មានអ្វីដែលលំបាកជាងការបង្កើតចេញនៅការប្រើកលល្បិចដ៏ប៉ិប្រសប់តាមយុទ្ធវិធី មានលក្ខណៈបត់បែនវៀចវេរទៅតាមទិសដៅការដឹកនាំដោយផ្ទាល់ និងភព្វ័វាសនាអាក្រក់ដែលទទួលបានក្នុងសង្គ្រាម។

៤)-ដូច្នេះដើម្បីប្រកាន់យកផ្លូវវែងនិងបត់បែនវេចវេរមួយ បន្ទាប់ពីការបញ្ចុះបញ្ចូលបញ្ឆោតសត្រូវអោយដើរខុសផ្លូវ ត្រូវគិតគូរច្នៃប្រឌិតរកមធ្យោបាយអោយឈានទៅដល់គោលដៅអោយបានមុនខ្មាំង ហើយទោះបីជាការចាប់ផ្តើមបន្ទាប់ពីខ្មាំងក៏ដោយ ត្រូវបង្ហាញនៅចំណេះដឹងនៃកលឧបាយ រហស្សបាយ អោយមានគំលាតបត់បែនទន់ភ្លន់។

៥)-ការប្រើកលឧបាយដ៏ប៉ិនប្រសប់ជាមួយកងទ័ពមួយប្រកបទៅដោយសារៈប្រយោជន៍មានប្រយោជន៍ក្រៃលែង ប៉ុន្តែបើការប្រើកងទ័ពច្រើនដែលគ្មានវិន័យមួយនោះ នឹងផ្តល់គ្រោះថ្នាក់បំផុតដល់អ្នក។

៦)-ប្រសិនបើអ្នកបង្កើតរៀបចំកងទ័ពដែលបំពាក់បរិក្ខារសឹកគ្រប់គ្រាន់មួយនៅក្នុងការរំកិលទ័ពដើម្បីកញ្ឆក់យកប្រយោជន៍ត្រង់នេះបន្តិច ត្រង់នោះបន្តិច ឱកាសនិងភ័ព្វសំណាងត្រង់ថាអ្នកនឹងយឺតយ៉ាវ ឬយឺតពេលវេលាខ្លាំងណាស់។ ម្យ៉ាងវិញទៀត អ្នកត្រូវតែវាយលុក វាយប្រហារ ដោយប្រើកងទ័ពជំនាញ ឬទ័ពពិសេសរៀបក្បួនជាជួរត្រង់មួយក្នុងគោលបំណងធ្វើពលិកម្មប្តូរផ្តាច់ដាច់ខាតដើម្បីវាយប្លន់ដណ្តើមយកស្បៀង ឃ្លាំងស្តុកបរិក្ខារសឹកទំនិញ និងក្បួនឡានរថយន្ត យន្តហោះ កប៉ាល់ទឹកដឹកទំនិញអាវុធ និងស្បៀងរបស់ខ្មាំង។

៧)-ដូច្នេះប្រសិនបើអ្នកបញ្ជាអោយមនុស្សរបស់អ្នកពាក់អាវធំធ្វើពីស្បែកគោព្រៃរុំជុំវិញ ហើយបានបង្ខំអោយរំកិលទ័ពដោយគ្មានឈប់ឈរទាំងយប់ថ្ងៃ លាក់បាំងចំងាយធម្មតាទ្វេដងដែលលាតសន្ធឹងមួយធ្វើដំណើរ១០០យោជន៍ ដើម្បីយកប្រយោជន៍ និងស្វែងរកផលប្រយោជន៍មួយនោះ មេដឹកនាំទាំងឡាយនៅផ្នែកទាំងអស់របស់អ្នកនឹងធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់សត្រូវ។

៨)-កងទ័ពខ្លាំងស្ទាត់ជំនាញនឹងដាក់នៅពីមុខឬជួរមុខ រីឯកងទ័ពដែលទន់ខ្សោយមានជំនាញមិនច្បាស់លាស់ត្រូវដាក់នៅពីខាងក្រោយ ហើយរៀបចំផែនការនេះគឺ មានតែ១ភាគ១០តែប៉ុណ្ណោះនៃកងទ័ពរបស់អ្នកនឹងទៅដល់គោលដៅទិសដៅរបស់ខ្លួន។

៩)-ប្រសិនបើអ្នករំកិលកងទ័ព៥០យោជន៍ ដើម្បីទៅវាយលុកសត្រូវដែលមានកលឧបាយខ្ពស់ជាងអ្នក នោះអ្នកនឹងបាត់បង់មេដឹកនាំនៃកងពលទី១របស់អ្នកហើយមានតែកងកំលាំងពាក់កណ្តាលរបស់អ្នកតែប៉ុណ្ណោះនឹងឈានទៅដល់គោលដៅ។

១០)-ប្រសិនបើអ្នករំកិលទ័ព៣០យោជន៍ទៅក្នុងគោលដៅឬកម្មវត្ថុដូចគ្នា កងទ័ព២ភាគ ៣របស់អ្នកតែប៉ុណ្ណោះនឹងទៅដល់ទីដៅឬគោលដៅដែលអ្នកចង់បាន។

១១)-យើងត្រូវតែវាយដណ្តើមយកទីកន្លែងណាមួយជាបន្ទាប់នោះ ដោយធ្វើអោយកងទ័ពរបស់អ្នកគ្មានបាត់បង់យានដឹកទំនិញបរិក្ខាសឹក គ្មានបាត់បង់ស្បៀងអាហារ និងគ្មានបាត់បង់មូលដ្ឋានផ្គត់ផ្គង់បរិក្ខាសឹក សព្វាវុធ ព្រមទាំងកំលាំងទ័ព នោះជាជោគជ័យមហាជោគជ័យ។

១២)-យើងមិនអាចចូលទៅក្នុងសម្ព័នមិត្តបានទេ រហូតដល់យើងត្រូវបានជ្រាបច្បាស់នៅការរៀបចំប្លង់គំរោងរបស់ពួកអ្នកជិតខាងរបស់យើង។

១៣)-យើងមិនអាចធ្វើអោយសមរម្យបានទេដើម្បីដឹកនាំកងទ័ពរំកិលទៅកន្លែងណាមួយឬទៅវាយលុកខ្មាំង លុះត្រាតែយើងស្គាល់ឬធ្លាប់ដឹងច្បាស់ពីតាំងភូមិសាស្ត្រផ្ទៃក្នុងនៃដែនដីខ្មាំងដូចជាទីខ្ពស់ខ្ពង់រាប ភ្នំនានានៅក្នុងដែនដីខ្មាំង អន្លង់អន្ទាក់ ទីតាំងគ្រោះថ្នាក់ ទីជំរាលទីចោទ វាលភក់ល្បាប់ ទីទំនាប និងទីលិចទឹកនៃដែនដីរបស់ខ្មាំង។

១៤)-យើងនឹងមិនអាចទាញយកផលប្រយោជន៍ពីលក្ខណ:ធម្មជាតិ លក្ខណ:ភូមិសាស្ត្ររបស់ខ្មាំងមកធ្វើជាប្រយោជន៍អោយខ្លួនឯងបានទេលុះត្រាតែយើងធ្វើការប្រើប្រាស់មគ្គុទេសផ្ទៃក្នុង ឬមគ្គុទេសន៍របស់អ្នកនាំផ្លូវនៅក្នុងទឹកដីខ្មាំង។

១៥)-នៅក្នុងសង្គ្រាម ត្រូវប្រតិបត្តិប្រកបដោយការបិតបាំង ការលាក់គំនិតអាថិកំបាំងរបស់យើង ហើយយើងនឹងបន្តការងារប្រកបដោយជោគជ័យជាបន្តបន្ទាប់។

១៦)-ថាតើការប្រមូលផ្តុំកងទ័ពរបស់អ្នក និងការបែងចែកទ័ពរបស់អ្នកត្រូវតែបានសំរេចចិត្តទៅតាមកាលៈទេសៈជាក់ស្តែង។

១៧)-បង្កើតភាពរហ័សរហួនរបស់អ្នកអោយលឿនដូចខ្យល់ ហើយបង្កើតភាពតឹងតែងរបស់អ្នកអោយចង្អៀតដូចជាព្រៃ។

១៨)-នៅក្នុងការវាយសន្ទប់ភ្លាមៗ និងការវាយប្លន់ដណ្តើមយកគឺធ្វើឡើងអោយដូចជាភ្លើងឆេះសន្ធោសន្ធៅ ប្រកាន់ភាពរឹងមាំ ហ្មឹងថ្កល់មិនប្រែប្រួលអោយដូចជាភ្នំមួយ។

១៩)-សូមរក្សាទុកផែនការរបស់អ្នកនៅក្នុងទីងងឹត ទីអាចិកំបាំង ហើយខ្មាំងមិនអាចយល់ជ្រាបពីយើងបានដូចពិភពយប់ងងឹតហើយនៅពេលដែលអ្នកផ្លាស់ប្តូរវាយលុក ធ្វើអោយបានលឿនលាន់ដូចរន្ទះផ្គរបាញ់ចុះមកក្រោម។

២០)-នៅពេលអ្នកវាយប្លន់នៅតាមជនបទមួយ សូមយករបស់ទ្រព្យដែលលួចប្លន់បានមកយកទៅបែងចែកក្នុងចំណោមកងទ័ពរបស់អ្នក។ នៅពេលអ្នកវាយដណ្តើមយកដែនដីថ្មីៗ សូមកាត់ផ្តាច់ដែនដីនោះជាចំណែកៗផ្តល់អោយកូនទាហ៊ាន មេទ័ពជាប្រយោជន៍។

២១)-សញ្ជឹងគិត និងពិគ្រោះពិចារណាពិភាក្សាអោយបានល្អិតល្អន់មុនពេលអ្នកធ្វើការរំកិលទ័ព។

២២)-ឧត្តមសេនីយឆ្លាតវៃនឹងឈ្លានពានវាយលុកខ្មាំងនៅពេលដឹងថាខ្មាំងមានឧបាយកលរំកិលទ័ពងាកចេញ។ ការធ្វើបែបហ្នឹងគឺជាសិល្បៈនៃការប្រើល្បិចកលដ៏ប៉ិនប្រសប់។

២៣)-នៅក្នុងក្បួនតម្រាសឹកពីជ័យសង្គ្រាមនៃការគ្រប់គ្រងកងទ័ពបានចែងថា‹‹នៅលើទីលានសមរភូមិ ពាក្យសម្តីដែលត្រូវបាននិយាយចេញ មិនអាចយកជាការ១០០%ទេឬមិនទាន់គ្រប់គ្រាន់ល្មមនោះទេ ដូច្នេះត្រូវមានការលើកដាក់ឆ្លុះបញ្ចាំងពីសំលេងស្គរនិងគងផងដែរហើយបើប្រើក្នុងគោលដៅកម្មវត្ថុពិសេស មិនទាន់គ្រប់គ្រាន់ទេ ត្រូវមានការបង្ហាញចេញអោយបានច្បាស់លាស់តាមរយៈការមើលឃើញច្បាស់នៅការលើកដាក់ទុងជ័យ បដារ និងទុងសញ្ញាថែមទៀតផង ព្រមទាំងមានការបាញ់អំផ្ទុងភ្លើងកាំជ្រួចធ្វើសញ្ញា ឬសំលេងទាក់ទងសំងាត់ធ្វើជាសញ្ញា........ទើបជាការគ្រប់គ្រាន់››។

២៤)-បណ្តារស្គរនិងគង ទុងសញ្ញា បដារ និងទុងជ័យគឺជាមធ្យោបាយនៅទីជិតៗក្បែរៗកន្លែងដែលភ្នែកនិងត្រចៀករបស់កងទ័ពអាចត្រូវបានផ្តោតសំឡឹងលើចំណុចពិសេសមួយ។

២៥)-ដូច្នេះមេទ័ពដែលបង្កើតនៅកងឯកភាពមួយ គឺវាមិនមាននៅលទ្ធភាពបង្កើតនៅភាពក្លាហ៊ានក្លៀវក្លាមុះមុតសំរាប់សំរុកទៅមុខតែម្នាក់ឯងនោះទេ ឬសំរាប់ភាពកំសាកញីដកថយតែម្នាក់ឯងនោះទេ។ នេះគឺជាសិល្បៈនៃការដោះស្រាយនៅហ្វូងមនុស្សដ៏ធំនៅក្នុងកងទ័ព។

២៦)-ហេតុដូច្នេះ នៅក្នុងការវាយប្រហារពេលយប់ ត្រូវតែបង្កើតនៅការប្រើប្រាស់ភ្លើងសញ្ញាអោយបានច្រើន ព្រមទាំងស្គរផងដែរ ហើយនៅក្នុងការវាយប្រហារពេលថ្ងៃការ

ប្រើទុងជ័យ បដារ និងទុងសញ្ញាធ្វើជាមធ្យោបាយមួយដែលមានឥទ្ធិពលនៅលើភ្នែកនិងត្រចៀករបស់កងទ័ពរបស់អ្នក។

២៧)-កងទ័ពទាំងមូលមួយ អាចត្រូវបានប្លន់យកនៅព្រលឹងវិញ្ញាណស្មារតីរបស់ខ្លួន ហើយអគ្គមេបញ្ជាការកងទ័ពម្នាក់អាចត្រូវបានប្លន់យកនៅវត្តមានផ្លូវចិត្តរបស់ខ្លួន។

២៨)-ឥឡូវនេះ ព្រលឹងវិញ្ញាណស្មារតីទាហ៊ានម្នាក់មានភាពខ្លាំងក្លាឆ្លាតវាងវៃបំផុតនៅពេលព្រឹក នៅពេលថ្ងៃវាចាប់ផ្តើមរាវែក ហើយនៅពេលព្រលប់ឬយប់ចិត្តរបស់ទាហ៊ានស្រយុតចុះលែងចង់ច្បាំង ចង់តែត្រឡប់ទៅកាន់ជំរុំតែប៉ុណ្ណោះ។

២៩)-ហេតុដូច្នេះ ឧត្តមសេនីយដ៏ឆ្លាតវៃម្នាក់ ត្រូវតែចៀសវាងគេចចេញពីកងទ័ពមួយនៅពេលដែលព្រលឹងវិញ្ញាណស្មារតីរបស់ពួកគេមានភាពក្លៀវក្លា ប៉ុន្តែត្រូវតែវាយប្រហារនៅពេលកងទ័ពមួយមានព្រលឹងវិញ្ញាណស្មារតីរាវែក ស្រយុតចុះ និងធ្លាក់ទឹកចិត្តចង់ត្រឡប់ទៅកាន់ជំរុំវិញ។ នេះជាសិល្បៈនៃការសិក្សាបទមាលាពីជ័យសង្គ្រាម។

៣០)-កងទ័ពដែលប្រកបដោយវិន័យ និងភាពស្ងប់ស្ងៀម ត្រូវរងចាំនៅការលិចឡើងនៃភាពច្របូកច្របល់ និងស្វរកងរំពងរបស់សត្រូវ ឬក្នុងចំណោមសត្រូវ នេះគឺជាសិល្បៈនៃការរក្សាទុកទ្រព្យកម្មសិទ្ធិខ្លួនឯង។

៣១)-ត្រូវតែទៅជិត ឬអោយដល់គោលដៅ ខណ:ដែលសត្រូវនៅ តែនៅឆ្ងាយពីគោលដៅនៅឡើយ ហើយស្ថិតក្នុងសភាពរងចាំនៅស្ងៀមប្រកបដោយភាពសុខស្រួលខណ:ដែលសត្រូវកំពុងតែហត់នឿយធ្វើការធ្ងន់ធ្ងរ និងកំពុងតស៊ូដ៏លំបាកលំបិន។ យើងត្រូវតែថែបំប៉នកងទ័ព ផ្តល់ចំណីអាហារគ្រប់គ្រាន់ល្អខណ:ដែលសត្រូវអត់ឃ្លានខ្វះខាតស្បៀង។ នេះគឺជាសិល្បៈនៃការគិតគូរសំចៃកំលាំងរបស់ខ្លួន។

៣២)-សូមកុំស្ទុះវាយរំខានស្កាត់ផ្លូវដំណើររបស់សត្រូវមួយដែលទុងជ័យ ទុងសញ្ញានិងបដាររបស់សត្រូវមានសណ្តាប់ធ្នាប់របៀបរៀបរយល្អឥតខ្ចោះ ហើយទប់ចិត្តមិនវាយប្រហារលើកងទ័ពដែលរំកិលប្រកបដោយភាពស្ងប់ស្ងាត់និងមានលំដាប់ជួររបៀបរៀបរយល្អប្រកបដោយជំនឿទុកចិត្តមុតមាំ។ នេះគឺជាសិល្បៈនៃការសិក្សាកាល:ទេស:ពេលវេលា។

៣៣)-វាគឺជាស្ទ័យស័ត្យខាងយោធាមួយដោយមិនវាយសំរុកលើទីខ្ពស់ប្រឆាំងនឹងសត្រូវឬមិនវាយសត្រូវនៅលើទីខ្ពស់ទីទួល ហើយក៏មិនវាយសត្រូវនៅពេលដែលកំពុងវាយបុកសំរុកពីទីខ្ពស់ចុះមកក្រោមសំរុកមករកយើង។

៣៤)-មិនបន្តដេញតាមសត្រូវមួយដែលធ្វើពុតក្លែងជាភៀសខ្លួនគេចចេញដកថយ ហើយក៏មិនវាយប្រហារទាហ៊ានឬកងទ័ពដែលអារម្មណ៍ទឹកចិត្តរបស់ពួកគេកំពុងតែក្លៀវក្លាមុះមុត។

៣៥)-មិនសីនុយបញ្ឆោត ឬត្របាក់លេបនុយបញ្ឆោតដែលបានផ្តល់ដោយសត្រូវ។ មិនវាយប្រហារ ឬរំខានកងទ័ពមួយដែលកំពុងតែធ្វើដំណើរត្រឡប់មកកាន់ជំរុំ ឬផ្ទះសំបែងភូមិកំណើតរបស់ខ្លួន។

៣៦)-នៅពេលដែលអ្នកធ្វើការឡោមព័ទ្ធកងទ័ពមួយរបស់សត្រូវ ចូរទុកច្រកចេញមួយសំរាប់អោយសត្រូវភៀសខ្លួនេចញ កុំវាយខ្ទប់បិទច្រកខ្ទប់សត្រូវដែលអស់សង្ឃឹមស្ថិតក្នុងសភាពដ៏លំបាកលំបិនមួយនោះ ចៀសវាងការវាយបើកផ្លូវឈាមរបស់សត្រូវ។

៣៧)-ការធ្វើបែបហ្នឹងគឺជាសិល្បៈសង្គ្រាមនៃការធ្វើសឹកសង្គ្រាម។

## ៨-ការផ្លាស់ប្តូរប្រែប្រួលយុទ្ធវិធីសឹកសង្គ្រាម (Variation in Tactics):

១)-លោកស៊ុន-ជូបានមានប្រសាសន៍ថា«នៅក្នុងសង្គ្រាម ឧត្តមសេនីយទទួលបញ្ជាពីព្រះមហាក្សត្ររបស់ខ្លួនដើម្បីកែណ្ឌប្រមូលកងទ័ពរបស់ខ្លួន»។

២)-នៅពេលស្ថិតនៅក្នុងប្រទេសឬដែនដីលំបាកៗ សូមកុំបោះជំរុំអោយសោះ។ នៅក្នុងប្រទេសឬដែនដីកន្លែងដែលមានផ្លូវខ្ពស់ៗធំៗប្រសព្វគ្នា ចូរចាប់ដៃរួមដៃសហការជាមួយនឹងសម្ព័ន្ធមិត្តរបស់អ្នក។ សូមកុំបោះជំរុំទីតាំងឈរជើង ឬរងចាំនៅកន្លែង ឬទីតាំងដាច់ស្រយាលដ៏សែនគ្រោះថ្នាក់។ នៅក្នុងស្ថានភាពឬស្ថានការណ៍ដែលស្ថិតក្នុងការហ៊ុំព័ទ្ធ អ្នកត្រូវតែប្រើយុទ្ធោបាយចុងក្រោយដោះស្រាយនៅស្ថានការណ៍នោះ។ នៅក្នុងទីតាំងអស់សង្ឃឹម អ្នកត្រូវតែវាយប្រហារ។

៣)-មានផ្លូវជាច្រើនដែលអ្នកមិនត្រូវដើរ កងទ័ពជាច្រើនដែលអ្នកមិនត្រូវវាយប្រហារនិង មានទីក្រុងជាច្រើនដែលអ្នកមិនត្រូវឡោមព័ទ្ធ មានទីតាំងជាច្រើនអ្នកមិនត្រូវដណ្តើមយក ហើយមានបញ្ហាជាច្រើនរបស់ព្រះមហាក្សត្រដែលអ្នកមិនត្រូវគោរព។

៤)-ឧត្តមសេនីយដែលយល់ដឹងទាំងស្រុងនៅសារៈប្រយោជន៍នៃការប្រើល្បិចយុទ្ធសាស្រ្តត្រូវ ចេះប្រែប្រួលផ្លាស់ប្តូរយុទ្ធវិធីរបស់ខ្លួនគឺយល់ដឹងនៅវិធីសាស្រ្តដោះស្រាយកងទ័ពរបស់ខ្លួន។

៥)-ឧត្តមសេនីយដែលមិនយល់ដឹងនៅបញ្ហាអស់ទាំងនេះ ប្រហែលជាគាត់ស្គាល់ច្បាស់ពីអ្វី ដែលត្រូវបញ្ហាលើប្រទេសឬដែនដីមូលដ្ឋានមួយ ប៉ុន្តែមិនអាចប្រើចំណេះដឹងរបស់គាត់បត់ បែនទៅតាមហេតុការណ៍ស្ថានការណ៍ប្រតិបត្តិជាក់ស្តែងទៅតាមកាលៈទេសៈជាក់ស្តែង។

៦)-ដូច្នេះរាល់គ្រប់សិស្សសិល្បៈសង្គ្រាមដែលមិនមានបទពិសោធន៍នៅក្នុងសិល្បៈសង្គ្រាមស្តីពី ការប្រែប្រួលផ្លាស់ប្តូរផែនការរបស់ខ្លួននោះ នឹងបរាជ័យក្នុងការប្រើប្រាស់មនុស្សរបស់ គាត់អោយបានប្រសើរបំផុត ទោះបីជាគាត់ជ្រាបច្បាស់នៅសារៈប្រយោជន៍នៅទាំង៥ក៏ដោយ។

៧)-ហេតុដូច្នេះនៅក្នុងផែនការណ៍របស់អ្នកដឹកនាំដ៏ឆ្លាតវៃ ត្រូវតែគិតពិចារណាអំពីផល ប្រយោជន៍គុណសម្បត្តិ និងគុណវិបត្តិ ការខាតបង់ដែលនឹងមានលាយឡំបញ្ចូលគ្នាឬដើរ ទន្ទឹមគ្នាផងនោះ។

៨)-ប្រសិនបើការរំពឹងទុកជាមុន សង្ឃឹមទុកជាមុនរបស់យើងអំពីផលប្រយោជន៍គុណ សម្បត្តិត្រូវបានសម្រួលនៅក្នុងមធ្យោបាយនេះ យើងអាចបន្តនៅក្នុងការសំរេចស្នាដៃសមិទ្ធិ ផលដោយសំរេចបាននៅផ្នែកសំខាន់ៗនៃគំរោងផែនការរបស់យើងបាន។

៩)-ម្យ៉ាងវិញទៀត ប្រសិនបើយើងស្ថិតក្នុងចំណោមការលំបាកលំបិនជាច្រើនជានិច្ចកាល យើងត្រូវតែរៀបចំត្រៀមជាស្រេចដើម្បីដណ្តើមយកនៅសារៈប្រយោជន៍ផលប្រយោជន៍មួយ បានហើយយើងក៏អាចបញ្ចៀសខ្លួនយើងចេញពីវាសនាអាក្រក់ ឬគ្រោះថ្នាក់ផងដែរ។

១០)-កាត់បន្ថយសត្រូវធំៗសំខាន់ៗ ដោយប្រើការបំផ្លិចបំផ្លាញបង្ខិតបង្ខំសត្រូវ និងបង្ករ បញ្ហាអោយសត្រូវ ហើយរក្សាឬទុកអោយសត្រូវស្ថិតក្នុងគ្រោះថ្នាក់ជានិច្ចដោយជ្រើសរើស យកការវាយជន្លបញ្ឆោត ប្រើល្បិចបំភាន់ភ្នែករំខានសត្រូវអោយព្រួយបារម្ភពីសភាពគ្រោះ

ថ្នាក់ជានិច្ច ហើយធ្វើអោយសត្រូវប្រញាប់ស្ទុះទៅរកចំណុចដែលយើងដៅអោយឬចំណុចអន្ទាក់របស់យើង។

**១១)**-សិល្បៈសង្គ្រាមបង្រៀនយើងមិនអោយពឹងផ្អែកលើសត្រូវដែលបោះទីតាំងក្បែរៗខាងជិតយើងថាមិនមកអោយសោះ ប៉ុន្តែយើងត្រូវពឹងផ្អែកលើការត្រៀមរៀបចំបំរុងទុកជាស្រេចផ្ទាល់ខ្លួនរបស់ពួកយើង ដើម្បីរងចាំទទួលសត្រូវវិញ គឺយើងកុំរំពឹងលើសំណាង ឬឱកាសដែលថាកងទ័ពសត្រូវមិនវាយប្រហារអោយសោះ ប៉ុន្តែប្រសើរប្រពៃបំផុត យើងត្រូវពឹងផ្អែកលើការពិតដែលថាយើងបានបង្កើតរៀបចំនៅទីតាំងរបស់យើង មិនអោយសត្រូវចូលចុះឬវាយប្រហារយើងបាន។

**១២)**-មានកំហុសដែលនាំអោយគ្រោះថ្នាក់៥យ៉ាងដែលអាចមានផលប្រយោជន៍ឬឥទ្ធិពលចេញពីឧត្តមសេនីយម្នាក់ ឬកំហុសកើតចេញពីឧត្តមសេនីយ៖

(១)-ភាពធ្វេសប្រហែស ព្រងើយកន្តើយដែលនាំទៅរកការបំផ្លិចបំផ្លាញ។

(២)-ភាពកំសាកញីដែលនាំអោយសត្រូវចាប់ខ្លួនបាន។

(៣)-អារម្មណ៍ប្រញាប់ប្រញាល់ ចិត្តអន្ទះសារដែលអាចត្រូវបានបង្ករដោយការជេរប្រទិចរបស់សត្រូវ ឬការញុះញុងលើកដាក់ផ្គួរផ្គងរបស់សត្រូវ(ចិត្តឆេវឆាវនាំអោយវិនាស)។

(៤)-ការស្រឡាញ់ងុបងល់នឹងកិត្តិយសហួសហេតុដែលមិនអាចទប់នឹងការអាម៉ាស់មុខ។

(៥)-ការយកចិត្តទុកដាក់ខ្វល់ខ្វាយហួសហេតុអំពីកងទ័ពមនុស្សរបស់ខ្លួនដែលនាំអោយខ្វល់ខ្វាយនិងបារម្ភឥតឈប់ឈរ បង្កើតចេញជាបញ្ហានៅក្នុងជួរទ័ព។

**១៣)**-ទាំងនេះគឺជាកំហុសទាំង៥ដែលឧត្តមសេនីយមាន ហើយនាំទៅរកការបំផ្លិចបំផ្លាញខ្លួននៅក្នុងការធ្វើសង្គ្រាម។

**១៤)**-នៅពេលកងទ័ពមួយត្រូវបានដួលរលំ ហើយមេដឹកនាំត្រូវបានសំលាប់ បុព្វហេតុពិតជារកឃើញក្នុងចំណោមកំហុសដ៍គ្រោះថ្នាក់ទាំង៥នេះ។ សូមយកកំហុសទាំង៥ធ្វើជាប្រធានបទនៃការសញ្ជឹងគិតសំរបសំរួលទៅរកជ័យជំនះវិញ។

## ៩-ការរំកិលទ័ព (The Army on the Move):

១)-លោកស៊ុន-ជូបានមានប្រសាសន៍ថា«ឥឡូវនេះ យើងឈានមកដល់ការបោះជំរុំកង ទ័ពនិងសើបអង្កេតមើលសញ្ញាសំងាត់របស់សត្រូវ។ សូមឆ្លងភ្នំអោយបានលឿនបំផុត ហើយបោះជំរុំទីតាំងនៅក្បែរៗជិតមាត់ជ្រោះជ្រលង»។

២)-បោះជំរុំនៅលើទីតាំងកន្លែងខ្ពស់ៗប្រឈមនឹងព្រះអាទិត្យ។ សូមកុំឡើងលើទីខ្ពស់ៗដើម្បី ធ្វើការភៀសខ្លួនគេចចេញ។ ច្រើនបំផុតសង្គ្រាមនៅតាមភ្នំ លើភ្នំ............។ល។

៣)-បន្ទាប់ពីឆ្លងទន្លេមួយ អ្នកគួរតែទៅអោយឆ្ងាយពីទន្លេមួយនោះ។

៤)-នៅពេលអ្នកឃើញកងទ័ពរបស់សត្រូវលុកលុយលើទីតាំងមួយ ឬឆ្លងទន្លេមួយនៅមុខ នៃការរំកិលទ័ព សូមកុំសំរុកវាយនៅកណ្តាលស្ទឹង។ វានឹងប្រសើរប្រពៃបំផុតទុក អោយកងទ័ពពាក់កណ្តាលឆ្លងផុតសិន ហើយបន្ទាប់មកទើបចាប់ផ្តើមវាយសំរុកលើកងទ័ព សត្រូវឈ្លានពាន។

៥)-ប្រសិនបើអ្នកអន្ទះសារវាយប្រហារ អ្នកគួរតែកុំវាយប្រហារកងទ័ពខ្លាំង ឬទ័ពលុកលុយ នៅក្បែរទន្លេមួយដែលសត្រូវត្រូវតែឆ្លង។

៦)-សូមចងទូករបស់អ្នកអោយខ្ពស់ផុតពីផ្ទៃទឹក ខ្ពស់ជាងសត្រូវនិងប្រឈមមុខនឹងព្រះ អាទិត្យកុំរំកិលទ័ពរបស់អ្នកទៅលើខ្សែទឹកស្ទឹងដើម្បីវាយលុកសត្រូវ។ ធ្វើដូច្នេះគឺច្រើនបំផុត សំរាប់សង្គ្រាមតាមទន្លេ។

៧)-នៅក្នុងការឆ្លងវាលភក់ទឹកប្រៃ ការព្រួយបារម្ភតែមួយគត់របស់អ្នក គួរតែធ្វើការបញ្ជារំកិល ទ័ពអោយបានលឿនបំផុតដោយគ្មានការពន្យាពេលណាមួយទេ។

៨)-ប្រសិនបើកងកំលាំងរបស់អ្នកត្រូវបានបង្ខំចិត្តវាយប្រយុទ្ធនៅក្នុងវាលភក់ទឹកប្រៃមួយអ្នកគួរ តែមានទឹកនិងស្មៅនៅក្បែរខ្លួនអ្នក ត្រូវបែរទៅរកដោមឈើ ដង្ហុំឈើនានា។ ការធ្វើ បែបនេះ ច្រើនបំផុតសំរាប់ការប្រតិបត្តិការសឹកនៅក្នុងវាលភក់ទឹកប្រៃ។

៩)-នៅរដូវប្រាំងស្ងួត ប្រទេសទំនាបគឺដណ្ដើមយកទីតាំងដែលងាយចូលទៅដល់យ៉ាងងាយ មួយជាមួយទីតាំងខ្ពស់ៗនៅខាងស្ដាំរបស់អ្នក សុវត្ថិភាពនៅខាងក្រោយរបស់អ្នក។ធ្វើបែបហ្នឹង ច្រើនបំផុតសំរាប់យុទ្ធនាការនៅបណ្ដារប្រទេសទំនាប។

១០)-ទាំងនេះគឺជាមែកធាងដ៏មានប្រយោជន៍៤នៃចំណេះដឹងខាងយោធាដែលធ្វើអោយប្រសើរឡើងដល់ព្រះចៅអធិរាជទន្លេលឿង ដើម្បីដណ្ដើមយកក្សត្របុរី៤ទៀត។

១១)-កងទ័ពទាំងអស់ពេញចិត្តទីតាំងមូលដ្ឋានខ្ពស់ៗទៅកាន់ទីទំនាប និងទីតាំងមានពន្លឺព្រះអាទិត្យទៅកាន់ទីងងឹត។

១២)-ប្រសិនបើអ្នកប្រយ័ត្នមនុស្សរបស់អ្នក ហើយបោះជំរុំលើមូលដ្ឋានលំបាក កងទ័ពអាចនឹងគេចផុតពីជំងឺនៃរាល់គ្រប់ប្រភេទ ហើយនេះនឹងមានន័យថាទទួលជោគជ័យ។

១៣)-នៅពេលអ្នកមកដល់ទីខ្ពស់មួយ ឬមាត់ច្រាំងមួយ ត្រូវកាន់កាប់ផ្នែកដែលមានពន្លឺព្រះអាទិត្យ ជាមួយជំរាលនៅផ្នែកខាងក្រោយខាងស្ដាំរបស់អ្នក។ ដូច្នេះនៅពេលភ្លាមៗនោះ អ្នកនឹងធ្វើការទាញផលប្រយោជន៍នៃកងទ័ពរបស់អ្នក ហើយប្រើប្រាស់ផលប្រយោជន៍ធម្មជាតិ លក្ខណៈសម្បត្តិរបស់មូលដ្ឋាន។

១៤)-នៅពេលអ្នកស្ថិតនៅក្នុងការលំបាកលំបិន ជួបផលវិបាកដោយសារស្ថិតនៅក្នុងប្រទេសដែលមានភ្លៀងជោគជាំច្រើនភ្លៀងខ្លាំង ឬមូលដ្ឋានដែនដីដែលមានភ្លៀងច្រើនទន្លេមួយដែលអ្នកប្រាថ្នាចង់ឆ្លងមាននីវោទឹកខ្ពស់ អត្រានីវោទឹកខ្ពស់ជ្រៅខ្លាំង ហើយមានពពុះស្ពុលពាសពេញ ពពុះផ្ទុំៗសព្វទីកន្លែង នោះអ្នកត្រូវតែរងចាំរហូតដល់ទឹកទន្លេស្រកចុះអត្រានីវោទឹកថយចុះ ហើយពពុះទឹកថយចុះតិចទៅៗ ទើបឆ្លងទន្លេ។

១៥)-ប្រទេសដែនដីស្ថិតក្នុងកន្លែងដែលមានជំរាលចោទខ្លាំង ដីចោទខ្លាំង និងភ្នំទេរចោទខ្លាំង មានចរន្តទឹកហូររវាងច្រកក្រហូងធម្មជាតិជ្រៅៗ ព្រៃគម្ពោធក្រាស់ៗច្រើន ទីកន្លែងទឹកហូរច្រោះរិចៗ វាលភក់និងទីជំរាលនានា គួរតែត្រូវបានចាកចេញដោយល្បឿនលឿនបំផុតតាមដែលអាចធ្វើទៅបាន ហើយកុំទៅជិតៗកៀកកន្លែងអស់ទាំងនេះអោយសោះ។

១៦)-ក្នុងខណៈដែលយើងចាកចេញពីកន្លែងបែបហ្នឹង យើងគួរតែរងចាំទុកអោយសត្រូវមកដល់បណ្តារទីតាំងកន្លែងបែបហ្នឹងសិន។ ខណៈដែលយើងប្រឈមមុខនឹងបណ្តារទីតាំងបែបហ្នឹង យើងគួរតែទុកអោយសត្រូវយកទីតាំងបែបហ្នឹងហើយយើងនៅពីខាងក្រោយសត្រូវ។

១៧)-ប្រសិនបើស្ថិតនៅជិតៗក្បែរៗខាងនៃជំរុំរបស់អ្នក គួរតែមានដែនដីមូលដ្ឋានទីទួលឬទីខ្ពស់ខ្លះៗ មានត្រពាំងទាំងឡាយ បានឡោមព័ទ្ធដោយស្មៅស្បូវបំពង់ខ្ពស់ ឬព្រៃឈើដែលមានដើមរុក្ខជាតិតូចៗដុះក្រាស់ឃ្មឹក ពួកគេត្រូវតែប្រុងប្រយ័ត្នដោយធ្វើដំណើរតាមផ្លូវវាង និងបានរុករកផ្លូវឬត្រួសត្រាយផ្លូវផ្សេងទៀតដើរ សំរាប់កន្លែងអស់ទាំងនេះគឺជាកន្លែងនានាដែលយើងទុកកងទ័ពសំរាប់ពួនស្ទាក់វាយប្រហារ ឬបង្កប់ចារជននានារងចាំពួនស្ទាក់វាយប្រហារខ្មាំង។

១៨)-នៅពេលដែលសត្រូវនៅកៀកនៅក្បែរដៃ ហើយនៅតែរក្សាភាពស្ងប់ស្ងៀម គឺសត្រូវកំពុងតែពឹងផ្អែកលើកំលាំងធម្មជាតិនៃទីតាំងរបស់សត្រូវ។

១៩)-នៅពេលដែលសត្រូវនៅដាច់តែឯង ដាច់សង្វែក ហើយព្យាយាមបង្ករលក្ខណៈវាយប្រយុទ្ធឬធ្វើចំបាំងមួយគឺ សត្រូវអន្ទះសារដើម្បីសំរុកទៅមុខទៅផ្នែកម្ខាងទៀត។

២០)-ប្រសិនបើកន្លែងបោះជំរុំរបស់សត្រូវដែលងាយស្រួលចូលគឺសត្រូវកំពុងតែដាក់អន្ទាក់ដាក់នុយបញ្ឆោតយើងហើយ។

២១)-ចលនាក្នុងចំណោមដើមឈើនានានៃព្រៃឈើមួយ បង្ហាញអោយឃើញថាសត្រូវកំពុងតែសំរុកចូល។ បើមានការស្តែងបង្ហាញឡើងនៃឆាកទិដ្ឋភាពច្រើនបែបបនៅក្នុងចំណោមស្មៅក្រាស់ៗ មានន័យថាសត្រូវចង់ឬត្រូវការធ្វើអោយយើងមានការសង្ស័យ។

២២)-ការស្ទុះហើរឡើងរបស់បក្សីនានានៅក្នុងការហើរគៀសខ្លួនគេចចេញឬហើរគ្មានសណ្តាប់ធ្នាប់របស់ហ្វូងបក្សីគឺជាសញ្ញានៃការពួនស្ទាក់វាយឆ្មក់មួយរបស់ខ្មាំង។ សត្វតិរច្ឆានសត្វព្រៃដែលបានផ្អើលឬភ្ញាក់ផ្អើលរត់ចេញ បង្ហាញថាការវាយប្រហារដ៏ឆាប់ៗមួយនឹងមកដល់។

២៣)-នៅពេលដែលធូលីដីហុយត្រឡោមឡើងនៅក្នុងជួរឈរខ្ពស់ឡើងមួយ វាគឺជាសញ្ញាបញ្ជាក់ថារទេះចំបាំង ឬយានជំនិះកងទ័ពកំពុងសំរុកចូលឬកំពុងឈានទៅមុខ។ នៅពេលដែលធូលីដីទាបៗ ប៉ុន្តែបាចសាចរីកសាយក្នុងផ្ទៃតំបន់ធំទូលាយមួយ វាបង្ហាញនៅ

សញ្ញាមួយនៃការចូលរួមចំណែករបស់កងទ័ពថ្មើរជើងកំពុងឈានមកជិតដល់ ឬការមកដល់ឬឈានមករបស់កងទ័ពថ្មើរជើង។ នៅពេលមែកឈើនានាបែកចេញ និងយកចេញនៅក្នុងបណ្តារទិសដៅឬគោលដៅផ្សេងៗគ្នា វាបង្ហាញថាបក្សពួកសត្រូវត្រូវបានបញ្ជូនមកប្រមូលអុសដុត។ បើមានពពកធូលីដ៏តិចតួចមួយផ្លាស់ប្តូរ ឬកពុងមានចលនាទៅមកៗ វាជាសញ្ញាបង្ហាញអោយឃើញថាកងទ័ពរបស់សត្រូវកពូងតែបោះជំរុំ។

២៤)-នៅពេលដែលសត្រូវប្រើពាក្យសម្តីទន់ភ្លន់រាបសារ បន្ទាបខ្លួន ដាក់ខ្លួន ហើយបានបង្កើនការត្រៀមរៀបបំរុងរួចស្រេច ឬបង្កើនការត្រៀមលក្ខណៈត្រៀមខ្លួនជាស្រេចមានន័យថាវាជាសញ្ញាបញ្ជាក់ថាសត្រូវប្រហែលជាឈានទៅមុខ សំរុកទ័ពចូល។ បើសត្រូវប្រើភាសាគំរោះគំរើយ ប្រើពាក្យសម្តីសាហ៊ារឃោរឃៅហើយបែរជាសំរុកទ័ពចូលទៅមុខទោះបីជាសត្រូវធ្វើការវាយប្រហារក៏ដោយ វាជាសញ្ញាបញ្ជាក់ថាសត្រូវនឹងដកថយ។

២៥)-នៅពេលដែលរទេះចំបាំងធុនស្រាលបង្ហាញខ្លួនជាលើកដំបូង ហើយប្រកាន់យកទីតាំងមួយ ឬឃើញដាក់នៅតាមស្លាបនានា វាជាសញ្ញាមួយបញ្ជាក់ថាសត្រូវនឹងបង្កើតសង្គ្រាមឬការវាយប្រយុទ្ធ។

២៦)-នៅពេលដែលសត្រូវធ្វើសំណើរ(ឬកិច្ចព្រមព្រៀង)សន្តិភាពដោយមិនបានអមដោយកិច្ចព្រមព្រៀងដែលមានសច្ចាប្រណិធានមួយ ឬក៏មិនមានសន្ធិសញ្ញាកិច្ចសន្យាដែលមានការស្បថស្បែរមួយ បង្ហាញថាសត្រូវមានផែនការក្បត់មួយ ឬផែនការប្រកបដោយល្បិចខ្មៅក្រខ្វក់មួយ។

២៧)-នៅពេលដែលសត្រូវមានការៀបចំចាត់ចែងច្រើនឥតឈប់ឈរ ហើយពួកកូនទាហ៊ានតំឡើងបុណ្យសក្តិតំណែងអោយ វាមានន័យថាពេលវេលាសំខាន់មកដល់ហើយ។

២៨)-នៅពេលដែលទាហ៊ានរបស់សត្រូវមានខ្លះត្រូវបានឃើញថាកំពុងសំរុកទៅមុខ ហើយខ្លះទៀតកំពុងដកថយ វាគឺជាការដាក់អន្ទាក់បោកបញ្ឆោតមួយ ឬជាការបញ្ឆោតមួយ។

២៩)-នៅពេលដែលកងទ័ពសត្រូវឈរផ្អែកទៅលើលំពែង ឬអាវុធរបស់ពួកគេមានន័យថាទាហ៊ានរបស់ខ្មាំងកំពុងបានហត់នឿយហេវហត់ខ្លាំងដោយត្រូវការស្បៀង ឬស្រេកឃ្លានអាហារ។

៣០)-ប្រសិនបើពួកទាហ៊ានខ្មាំងទាំងនោះ ត្រូវបានបញ្ជូនអោយទៅដងទឹក ដោយចាប់ផ្តើមផឹកទឹកមុនដងទឹក មានន័យថាទាហ៊ានខ្មាំងកំពុងរងទុកទោសពីការស្រេចទឹក ឬក៏ស្រេកទឹកខ្លាំង។

៣១)-ប្រសិនបើសត្រូវមើលឃើញនៅផលប្រយោជន៍មួយដែលត្រូវតែចាប់យក ហើយបែរជាមិនប្រឹងប្រែងព្យាយាមរក្សាការពារវា ឬដណ្តើមយកផលប្រយោជន៍នោះ មានន័យថាពួកទាហ៊ានរបស់ខ្មាំងត្រូវបានហត់នឿយអស់កំលាំងខ្លាំង។

៣២)-ប្រសិនបើបក្សីទាំងឡាយប្រមូលផ្តុំគ្នានៅតាមចំណុចមួយចំនួន មានន័យថាទីតាំងនោះមិនទាន់ត្រូវបានកាន់កាប់នៅឡើយទេ ឬក៏ទ័ពខ្មាំងមកកាន់កាប់ដោយមិនដឹងខ្លួននៅពេលយប់ ឬក៏ទ័ពខ្មាំងនឹងមកនៅពេលយប់។

៣៣)-ប្រសិនបើមានការរំខាននៅក្នុងជំរុំគឺសិទ្ធិអំណាចរបស់ឧត្តមសេនីយឬមេទ័ពខ្សោយ។ ប្រសិនបើមានបដារ ទុងសញ្ញា និងទុងជ័យត្រូវបានផ្លាស់ប្តូរទៅមកតែពីសតែពាសឬក៏គ្មានរបៀបរៀបរយ មានន័យថាការបះបោរចលាចលក្នុងកងទ័ពខ្មាំងកំពុងកើតមានឡើងឬក៏ខ្មាំងកំពុងមានការបែកបាក់គ្នាទំនាស់ខ្វែងគំនិតគ្នា។ ប្រសិនបើបណ្តារពួកនាយទាហ៊ានឬមេទ័ពខឹងសម្បារ វាមានន័យថាពួកកូនទាហ៊ាននឿយហត់ខ្លាំង អស់សង្ឃឹមខ្លាំង។

៣៤)-នៅពេលកងទ័ពសត្រូវផ្តល់ចំណីអាហារគ្រាប់ធុញ្ញជាតិអោយសេះរបស់ខ្លួនសី ហើយសំលាប់គោរក្របីសត្វពាហណៈរបស់ខ្លួនធ្វើជាចំណីអាហារ ហើយនៅពេលដែលកងទ័ពខ្មាំងមិនព្យួរឆ្នាំងចំអិនអាហាររបស់ពួកគេនៅចង្ក្រានផ្ទះបាយនៃជំរុំ បង្ហាញអោយឃើញថាកងទ័ពរបស់ខ្មាំងនឹងមិនវិលត្រឡប់ទៅកាន់កន្លែងបោះតង់បោះជំរុំរបស់ពួកគេវិញទេ អ្នកអាចដឹងថាកងទ័ពរបស់ខ្មាំងសត្រូវ ត្រូវបានកំណត់ឬសំរេចចិត្តវាយប្រហារច្បាំងស្លាប់រស់។

៣៥)-បើឃើញសញ្ញាឬទិដ្ឋភាពសភាពរបស់កងទ័ពខ្មាំងខ្សឹបខ្សៀវគ្នាតាមក្រុមតូចៗពីមួយទៅមួយ ឬក៏កំពុងនិយាយគ្នាតាមចំណុចដែលមានសំលេងខ្សាវៗប្រកបដោយភាពលាក់លៀមគឺពួកគេមិនសប្បាយចិត្តនឹងតំណែងបុណ្យសក្តិឋានន្តរសក្តិពីតូចទៅធំឬតូចចិត្តក្នុងចំណោមពលទាហ៊ានគ្រប់ជាន់ថ្នាក់ ឬការបំរុងដកថយ ឬក៏មានគ្រោះថ្នាក់ ឬអ្នកស្លាប់នៅក្នុងចំណោមពួកគេ។

៣៦)-ការផ្តល់រង្វាន់ញឹកញាប់ពេក ជាសញ្ញាបង្ហាញថា សត្រូវជិតអស់ស្បៀងហើយ ឬក៍ធនធានរបស់សត្រូវដល់ទីបញ្ចប់ហើយ បើសត្រូវដាក់ទណ្ឌកម្មច្រើនញឹកញាប់ពេក មានន័យថាមានអ្នកក្បត់ក្នុងជួរទាហ៊ានសត្រូវ ហើយសត្រូវកំពុងស្ថិតនៅក្នុងវិបត្តិធ្ងន់ធ្ងរ។

៣៧)-សត្រូវចាប់ផ្តើមកដោយអាកប្បកិរិយាអួតអាងក្អេងក្អាង ប៉ុន្តែនៅពេលបន្ទាប់មកបែរជាភ័យខ្លាចភ្ញាក់ផ្អើលនៅក្នុងចំណោមសត្រូវភាគច្រើន បង្ហាញថាសត្រូវខ្វះខាតពត៌មានសំខាន់ៗ ឬទទួលពត៌មានអាក្រក់ពីអ្នកសើបអង្កេត។

៣៨)-នៅពេលដែលបណ្តារបេសកកជនសត្រូវ ត្រូវបានបញ្ជូនអោយមករាយការណ៍ជូនដំណឹងដល់យើងដោយផ្ទាល់មាត់ វាជាសញ្ញាមួយបញ្ជាក់ថាសត្រូវប្រាថ្នាចង់ផ្អាកសង្គ្រាមឬបញ្ឈប់សង្គ្រាមជាបណ្តោះអាសន្នមួយ។

៣៩)-ប្រសិនបើកងទ័ពសត្រូវយាត្រាទ័ពចូលមកប្រកបដោយកំហឹងខឹងក្រោធ ហើយនៅតែប្រឈមមុខនឹងកងទ័ពរបស់របស់អ្នកអស់រយៈពេលយូឬវែងមួយ ដោយគ្មានចូលរួមធ្វើចម្បាំងវាយប្រយុទ្ធឬក៏ដកកងទ័ពចេញម្តងទៀត គឺជាស្ថានការណ៍មួយដែលទាមទារអោយយើងរក្សាការប្រុងប្រយ័ត្នខ្ពស់ និងក្លំមើលយ៉ាងប្រុងប្រយ័ត្នប្រយែងបំផុត។

៤០)-ប្រសិនបើកងទ័ពរបស់យើងមានចំនួនតិចជាងកងទ័ពរបស់ខ្មាំងដែលមានចំនួនកងទ័ពច្រើនសន្ធឹកសន្ធាប់ វាមានន័យថាកុំធ្វើការវាយប្រហារសត្រូវដោយផ្ទាល់អោយសោះ ហើយអ្នកមិនអាចវាយប្រយុទ្ធដោយផ្ទាល់បានទេ។អ្វីដែលយើងអាចធ្វើបានគឺជារឿយៗសមញ្ញបំផុតគ្រាន់តែយើងប្រមូលផ្តុំនៅរាល់គ្រប់កងទ័ព កងកំលាំងទាំងអស់របស់យើងតាមលទ្ធភាពដែលអាចធ្វើទៅកើត រួចហើយរក្សាការក្លំមើលយ៉ាងប្រកិត សង្កេតសត្រូវយ៉ាងប្រុងប្រយ័ត្នបំផុតហើយពង្រឹងកងកំលាំងកងទ័ពរបស់យើងអោយបានរឹងមាំ មុនអនុវត្តន៍ការវាយប្រហារ ពេលសត្រូវខ្សោះល្វើយ។

៤១)-ប្រសិនបើសត្រូវដែលធ្វើសមយុទ្ធមិនបានគិតប្រមើលទុកជាមុន ប៉ុន្តែបានបំភ្លឺបង្ហាញដល់គូរទំនាស់របស់ខ្លួន គឺប្រាកដណាស់ត្រូវតែត្រូវតែចាប់ខ្លួនដោយពួកគេ(គូរទំនាស់)។

៤២)-ប្រសិនបើពួកកងទ័ពទាហ៊ានរបស់ខ្មាំងត្រូវបានដាក់ទណ្ឌកម្មមុនពេលពួកគេបានកែឈ្នួឬបានលើកទ័ពមកវាយប្រហារអ្នក ពួកគេនឹងបង្ហាញនៅភស្តុតាងថាមិនចុះចូលជាមួយអ្នកទេ

ហើយបើចុះចូលនឹងអ្នកវិញនោះ លុះត្រាតែកងទ័ពរបស់សត្រូវធ្វើសឹកសង្គ្រាមដោយគ្មានប្រយោជន៍ក្នុងពេលប្រតិបត្តិការជាក់ស្តែង។ ប្រសិនបើនៅពេលកងទ័ពរបស់ខ្មាំងចង់វាយប្រហារលុកលុយអ្នក ទណ្ឌកម្មទាំងឡាយមិនត្រូវបានអនុវត្តន៍ទេនោះ ពួកគេនឹងនៅស្ងៀមជាដរាប។

**៤៣)**-ហេតុដូច្នេះ នៅពេលទាហ៊ានរបស់ខ្មាំងត្រូវបានយកចិត្តទុកដាក់លើបញ្ហាមនុស្សជាតិជាលើកតំបូងជាគំរូដំបូងនោះ ប៉ុន្តែបែរជាត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹងដោយប្រើមធ្យោបាយវិន័យដែកថែបនៅពេលបន្ទាប់នោះ។ នេះគឺពិតជាមាគ៌ាដ៏ពិតប្រាកដមួយឈានទៅរកជ័យជំនះ។

**៤៤)**-ប្រសិនបើនៅក្នុងរាល់បទបញ្ជាទាំងឡាយត្រូវបានអនុវត្តន៍តាម គោរពតាមតាមទំលាប់ដោយពួកទាហ៊ានដែលមានការហ្វឹកហាត់កងទ័ពឬទាហ៊ានទាំងនោះនឹងរក្សាវិន័យគោរពវិន័យគោរពវិន័យបានល្អបំផុត ឬជាកងទ័ពមានវិន័យល្អ តែប្រសិនបើរាល់គ្រប់បញ្ហាមិនត្រូវបានកងទ័ពគោរពទេ គឺវិន័យរបស់កងទ័ពនោះអាក្រក់ឬគ្មានវិន័យ។

**៤៥)**-ប្រសិនបើឧត្តមសេនីយម្នាក់បង្ហាញសំដែងនៅជំនឿជឿជាក់ទុកចិត្តលើកងទ័ពរបស់គាត់ប៉ុន្តែជានិច្ចកាលមានការទទូចសុំលើរាល់បទបញ្ជារបស់គាត់ត្រូវបានគោរព ផលប្រយោជន៍ដែលទទួលបាននឹងកើតមានទៅវិញទៅមក។

## ១០-ដែនដី (Terrain):

**១)**-លោកស៊ុន-ជូ បានមានប្រសាសន៍ថា ‹‹យើងអាចដឹងនៅភាពខុសគ្នានៅប្រភេទដែនដីទាំង៦បានគឺមាន៖

(១)-មូលដ្ឋានដែនដីបើកចំហរ (Accessible Ground)

(២)-តំបន់ពលិកម្មឬតំបន់លះបង់ (Entangling Ground)

(៣)-តំបន់តោងទាញ (Temporizing Ground)

(៤)-តំបន់ច្រកចូលចង្អៀត (Narrow Pass Ground)

(៥)-តំបន់ចោទខ្លាំង (Precipitous Heights Ground)

(៦)-តំបន់ឆ្ងាយដាច់ស្រយាលពីសត្រូវ (Positions at a great distance from the enemy)

២)-មូលដ្ឋានដែនដីបើកចំហរជាតំបន់ដែលត្រូវបានឆ្លងកាត់ដោយសេរីដោយភាគីទាំង២ភាគីទាំងសងខាងត្រូវបានហៅថា**មូលដ្ឋានដែនដីបើកចំហរ**(Accessible Ground)។

៣)-ដោយគោរពទៅតាម ឬយោងទៅតាមមូលដ្ឋានដែនដីនៃលក្ខណៈធម្មជាតិនេះគឺមុនពេលសត្រូវចូលកាន់កាប់ចំណុចទីតាំងដែលមានពន្លឺព្រះអាទិត្យ និទីតាំងខ្ពស់ៗ នោះអ្នកត្រូវតែការពារយ៉ាងប្រុងប្រយ័ត្ននៅខ្សែត្រៀមផ្គត់ផ្គង់របស់អ្នក។ ដូច្នេះអ្នកនឹងអាចនឹងវាយប្រហារប្រកបដោយសារៈប្រយោជន៍ ឬប្រកបដោយផលចំណេញ។

៤)-មូលដ្ឋានដែនដីដែលអាចត្រូវបានបោះបង់ចោល ប៉ុន្តែពិបាកដណ្តើមកាន់កាប់ជាថ្មីឡើងវិញនោះ ត្រូវបានហៅថា **តំបន់ពលិកម្មឬមូលដ្ឋានតំបន់លះបង់ (Entangling Ground)**។

៥)-ពីមូលដ្ឋានទីតាំងមួយនៃប្រភេទមូលដ្ឋាននេះ ប្រសិនបើសត្រូវមិនត្រូវបានត្រៀមទុកជាមុនឬមិនបានរៀបចំត្រៀមទុកជាមុនទេនោះ អ្នកអាចវាយប្រហារ វាយលុកសំរុកចូលទៅមុខផ្ចាញ់សត្រូវ ធ្វើអោយសត្រូវបរាជ័យ។ ប៉ុន្តែប្រសិនបើសត្រូវបានរៀបចំខ្លួនរួចជាស្រេច ឬត្រូវបានត្រៀមលក្ខណៈទុកជាមុនសំរាប់ការមកដល់របស់អ្នក នោះអ្នកមិនអាចឈ្នះសត្រូវបានទេ ឬក៏មិនអាចផ្ចាញ់សត្រូវបានទេ ហេតុដូច្នេះបើអ្នកចង់ត្រឡប់ថយក្រោយវិញក៏មិនអាចធ្វើទៅរួច មហន្តរាយនឹងកើតមានយ៉ាងពិតប្រាកដ។

៦)-នៅពេលទីតាំងមានលក្ខណៈមួយបែបដែលគ្មានភាគីណាមួយនឹងទទួលបានផលប្រយោជន៍នោះទេ បើធ្វើការរំកិលទ័ពជាមុននោះ ឬធ្វើចលនាដំបូងនោះ វាត្រូវបានហៅថា**តំបន់គោងទាញ (Temporizing Ground)**។

៧)-នៅក្នុងទីតាំងមួយបែបប្រភេទនេះ ទោះបីជាសត្រូវគួរតែផ្តល់អោយយើងនៅនុយបញ្ឆោតដែលគួរអោយទាក់ទាញចិត្តចាប់អារម្មណ៍មួយក៏ដោយ វានឹងត្រូវបានផ្តល់ដំបូន្មានថាមិនអោយជ្រួលច្របល់ចិត្ត កុំសំរុកចូលអោយសោះ ប៉ុន្តែដកថយប្រសើរប្រពៃជាងដូច្នេះបញ្ចុះបញ្ចូលសត្រូវអោយចូលវិញ បញ្ឆោតសត្រូវអោយចូលវិញ បន្ទាប់មកនៅពេលដែលមួយផ្នែកនៃកងទ័ពរបស់សត្រូវមកដល់ យើងអាចបើកយុទ្ធនាការវាយប្រហាររបស់យើងទៅលើសត្រូវប្រកបដោយផលចំណេញ ទទួលបានផលប្រយោជន៍ជាទីពេញចិត្ត។

៨)-ដោយយោងទៅតាមទីតាំងច្រកចូលចង្អៀត ប្រសិនបើអ្នកអាចកាន់កាប់តំបន់ទាំងនេះបានមុន សូមពង្រឹងតំបន់មូលដ្ឋានទាំងនេះអោយបានរឹងមាំខ្លាំងក្លា ដោយបោះជំរុំទ័ពអោយបានរឹងមាំ ហើយរងចាំការមកដល់របស់សត្រូវ។

៩)-អ្នកគួរតែចាត់កងទ័ពរបស់អ្នកអោយបង្ការជាមុន នៅពេលអ្នកចូលទៅកាន់កាប់តំបន់មូលដ្ឋានច្រកតូចចង្អៀតមួយនោះ កុំដេញតាមសត្រូវអោយសោះ ប្រសិនបើមូលដ្ឋានច្រកតូចចង្អៀតត្រូវបានបោះជំរុំទ័ពដោយសត្រូវយ៉ាងពេញលេញនោះ ប៉ុន្តែដេញតាមបានក្នុងករណីដែលសត្រូវត្រូវបានបោះជំរុំទ័ពមិនទាន់រឹងមាំនៅឡើយ។

១០)-ដោយយោងទៅតាមទីតាំងមូលដ្ឋានខ្ពស់ៗចោទខ្លាំង ប្រសិនបើអ្នកទៅដល់និងកាន់កាប់បានមុនសត្រូវរបស់អ្នក អ្នកគួរតែកាន់កាប់នៅទីតាំងខ្ពស់ៗមានពន្លឺព្រះអាទិត្យ ហើយបោះទ័ពនៅទីនោះរងចាំសត្រូវអ្នកមកដល់។

១១)-ប្រសិនបើសត្រូវរបស់អ្នកបានកាន់កាប់ទីតាំងមូលដ្ឋានទាំងនោះបានមុនអ្នក សូមកុំដេញតាមវាយសត្រុវរបស់អ្នកអោយសោះ ប៉ុន្តែចូរអ្នកដកទ័ពថយហើយព្យាយាមបញ្ចុះបញ្ចូលសត្រូវរបស់អ្នក បោកបញ្ឆោតសត្រូវរបស់អ្នកអោយចេញពីទីតាំងមូលដ្ឋាននោះសិន។

១២)-ប្រសិនបើអ្នកត្រូវបានបោះទ័ពនៅចំងាយឆ្ងាយដាច់ច្រយាលពីសត្រូវ ហើយកំលាំងកងទ័ពអ្នកនិងសត្រូវមានចំនួនស្មើរគ្នាគឺកងកំលាំងទាំង២ប៉ុនគ្នាស្មើរគ្នា វាមិនមែនជាការងាយស្រួលនោះទេ ហើយការវាយប្រហាររបស់អ្នកនឹងធ្វើអោយអ្នកខាតបង់ផលប្រយោជន៍ច្រើនជួបគុណវិបត្តិច្រើន។

**១៣)**-មូលដ្ឋានដែនដីទាំង៦ទាំងនេះគឺជាគោលកាណ៍ចំបងៗដែលបានជាប់ពាក់ព័ន្ធនឹងផែនដី។ឧត្តមសេនីយដែលបានទទួលបានទីតាំងប៉ុស្តបោះបន្ទាយទទួលខុសត្រូវនៅទីតាំងមូលដ្ឋានទាំងនេះ ត្រូវតែមានការប្រុងប្រយ័ត្ន សិក្សាស្វែងយល់តំបន់ទាំងនេះអោយបានច្បាស់។

**១៤)**-ឥឡូវនេះ កងកំលាំងកងទ័ពរបស់អ្នកមិនត្រូវបានបង្ហាញត្រដាងស្តែងចេញនៅគ្រោះមហន្តរាយលើទីតាំងមូលដ្ឋានធម្មជាតិនោះទេ ប៉ុន្តែកើតចេញពីកំហុសរបស់ឧត្តមសេនីយដែលទទួលខុសត្រូវលើតំបន់អស់ទាំងអស់នេះ។ រាល់កំហុសឆ្គងរបស់ឧត្តមសេនីយឬរាល់គ្រប់កំហុសឆ្គងទាំងអស់នេះគឺមាន៖

(១)-ការគេចភៀសខ្លួន(Flight)។

(២)-ការមិនស្តាប់បង្គាប់(Insubordination)។

(៣)-ការដួររលំ(Collapse)។

(៤)-ការបំផ្លិចបំផ្លាញ(Ruin)។

(៥)-ការគ្មានអង្គការចាត់តាំងច្បាស់លាស់(Disorganization)។

(៦)-ការបាក់ទ័ពរត់ខ្ចាត់ខ្ចាយ(Rout)។

**១៥)**-មូលដ្ឋានដែនដីដែលស្ថិតក្នុងលក្ខ័ខណ្ឌដទៃៗស្រដៀងគ្នានឹងមូលដ្ឋានដែនដីដូចរៀបរាប់ខាងលើ ប្រសិនបើកងកំលាំងទ័ពមួយ ត្រូវបានវាយប្រហារប្រឆាំងនឹងកងកំលាំងទ័ពដទៃទៀតដែលមានទំហំធំជាង១០ដងនោះគឺលទ្ធផលនឹងធ្វើការភៀសខ្លួនដូចទ័ពមុនៗដែរឬដូចអតីតទ័ពមុនៗដែរ។

**១៦)**-នៅពេលដែលទាហ៊ានសមញ្ញក្លាយជាទាហ៊ានដ៏ខ្លាំងក្លា ហើយបណ្តារមេទ័ពរបស់គេទន់ខ្សោយ លទ្ធផលគឺកើតចេញពីការមិនស្តាប់បង្គាប់។ នៅពេលដែលបណ្តារមេទ័ពនាយទាហ៊ានខ្សោយ លទ្ធផលគឺកើតចេញជាការដួលរលំ។

**១៧)**-នៅពេលនាយទាហ៊ានជានខ្ពស់ខឹងសម្បារ និងមិនស្តាប់បង្គាប់ ហើយនៅពេលជួបប្រយុទ្ធច្បាំងជាមួយសត្រូវ នោះកើតមានរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេនៅអារម្មណ៍តូចចិត្តនឹង

អ្វីមួយ មុនពេលអគ្គមេបញ្ជាការអាចប្រាប់ថាតើគាត់ត្រូវស្ថិតនៅក្នុងទីតាំងមួយឬអត់ ដើម្បីវាយប្រហារខ្មាំង លទ្ធផលគឺការវិនាសអន្តរាយ។

១៨)-នៅពេលឧត្តមសេនីយខ្សោយ ហើយគ្មានសិទ្ធិអំណាច នៅពេលដែលរាល់បញ្ជារបស់គាត់មិនច្បាស់លាស់ និងខុសប្លែកគ្នា នៅពេលគ្មានកាតព្វកិច្ចច្បាស់លាស់ជាក់លាក់ចាត់តាំងបណ្តារមេទ័ពនិងពលទាហ៊ាន ហើយរាល់មុខតំណែងឋានន្តរសក្កិទាំងឡាយត្រូវបានបង្កើតនៅក្នុងរបៀបបែបបទលក្ខណៈឥតរបៀប មិនទៀងទាត់មួយ។ លទ្ធផលគឺកើតចេញជាការចលាចលច្របូកច្របល់ឥតមានអង្គការចាត់តាំងច្បាស់លាស់ (Utter disorganization)។

១៩)-នៅពេលដែលឧត្តមសេនីយម្នាក់មិនអាចប៉ាន់ប្រមាណនៅកងកំលាំងកងទ័ពរបស់សត្រូវបញ្ជាអោយកងកំលាំងកងទ័ពអន់ខ្សោយតូចតាចមួយទៅវាយប្រហារកងកំលាំងដ៏ធំមួយរបស់សត្រូវ ឬក៏យកកងទលសេនាខ្សោយមួយទៅវាយប្រហារប្រឆាំងកងកំលាំងសត្រូវដ៏មានសក្តានុពលមួយនោះ ហើយធ្វេសប្រហែសមិនយកចិត្តទុកដាក់ជ្រើសរើសយកទាហ៊ានជំរើស ឬទាហ៊ានពិសេសទៅដាក់នៅឯជួរទ័ពមុខ ឬខ្សែត្រៀមជួរមុខ លទ្ធផលត្រូវបាក់ទ័ពរត់ខ្ចាត់ខ្ចាយ។

២០)-ទាំងនេះគឺជាមាគ៌ាទាំង៦នាំទៅរកបរាជ័យដែលឧត្តមសេនីយត្រូវតែប្រុងប្រយ័ត្នអោយមែនទែន ជាពិសេសឧត្តមសេនីយដែលកាន់មុខតំណែងមានតួនាទីទទួលខុសត្រូវមួយត្រូវតែកត់ចំណាំ។

២១)-ការរៀបចំក្បួន ឬការបង្កើតប្រឌិតក្បួនទ័ពទៅតាមធម្មជាតិនៃមូលដ្ឋានទីតាំងដែនដីគឺជាសម្ព័ន្ធភាពដ៏ប្រសើរបំផុតរបស់កងទ័ព ប៉ុន្តែត្រូវតែមានអំណាចសក្តានុពលមួយខាងការប៉ាន់ប្រមណសត្រូវ ការប៉ាន់ស្មាននៅការត្រួតពិនិត្យកំលាំងទ័ព យកជ័យជំនះលើខ្មាំងសត្រូវ និងចេះគណនាគន់គូរយ៉ាងឆ្លាតវៃនៅរាល់ការលំបាកលំបិនទាំងឡាយគ្រោះថ្នាក់នានា និងរយៈចំងាយទាំងឡាយបង្កើតចេញនៅការសាកល្បងនឹងសត្រូវរបស់ឧត្តមសេនីយធំមួយ។

២២)-ឧត្តមសេនីយដែលយល់នៅរាល់រឿងរ៉ាវទាំងនេះ ហើយធ្វើការវាយប្រហារដោយប្រើចំណេះដឹងនៅក្នុងចម្បាំង ឬការវាយប្រយុទ្ធរបស់គាត់។ នៅរាល់ឧត្តមសេនីយដែល

មិនយល់ដឹងនៅរាល់រឿងរ៉ាវអស់ទាំងនេះ មិនចេះយកទ្រឹស្តីប្ញកនិងការអនុវត្តន៍មកប្រើប្រាស់ នោះនឹងទទួលបរាជ័យយ៉ាងជាក់ប្រាកដ។

២៣)-នៅក្នុងការវាយប្រហារគឺប្រាកដជាទទួលលទ្ធផលជ័យជំនះ ដូច្នេះគឺអ្នកត្រូវតែវាយប្រហារ សូម្បីតែមេដឹកនាំបានហាមឃាត់មិនអោយវាយក៏ដោយ។ ប្រសិនបើការវាយប្រហារនឹងមិនមានលទ្ធផលជោគជ័យទេ គឺអ្នកមិនត្រូវវាយទេ ខណៈដែលមេដឹកនាំរបស់អ្នកបញ្ជាបង្ខំអោយអ្នកវាយលុកខ្លាំង។

២៤)-ឧត្តមសេនីយដែលសំរុកទៅមុខដោយគ្មានចង់បានកេរ្តិ៍ឈ្មោះ និងដកថយក្រោយដោយគ្មានភ័យខ្លាចពីភាពអាម៉ាស់មុខ ឧត្តមសេនីយមានលក្ខណៈចរិតបែបហ្នឹង ត្រូវបានគិតតែប៉ុណ្ណោះថាជាឧត្តមសេនីយដែលមានគំនិតកិច្ចកលដើម្បីការពារប្រទេសទឹកដី ដែនដីមូលដ្ឋានរបស់ខ្លួន ហើយបំរើការងារយ៉ាងល្អប្រពៃបំផុតថ្វាយព្រះមហាក្សត្ររបស់គាត់ឬជាសេវាដ៍ប្រសើរសំរាប់ព្រះមហាក្សត្ររបស់គាត់ គឺជាគ្រឿងអលង្ការឬជាអាយុជីវិតជាតិអាយុជីវិតរបស់ព្រះរាជាណាចក្រ ឬប្រទេសជាតិទាំងមូល ឬជាភ័ព្វសំណាងរបស់ជាតិ។

២៥)-ដោយចាត់ទុកកូនទាហ៊ានរបស់អ្នកដូចជាកូនៗរបស់អ្នក ហើយពួកគេនឹងដើរតាមអ្នកចូលទៅក្នុងជ្រោះយ៉ាងជ្រៅបំផុត ប៉ុន្តែបើអ្នកមើលថែរក្សាកូនទាហ៊ានរបស់អ្នកដូចជាកូនប្រុសសំណប់ចិត្តជាទីស្រឡាញ់របស់អ្នកផ្ទាល់ ហើយពួកគេឈរក្បែរអ្នក គាំទ្រដល់អ្នករហូតដល់ក្ស័ជីវ៉ា។

២៦)-ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកធ្វើអ្វីមួយ ប៉ុន្តែមិនអាចធ្វើការប្រើប្រាស់សិទ្ធិអំណាចរបស់អ្នកតាមចិត្តចង់ និងប្រកបដោយចិត្តសប្បុរសធម៌ ប៉ុន្តែមិនអាចបង្ខំអោយពលទាហ៊ានអនុវត្តន៍តាមបញ្ជារបស់អ្នក ហើយអ្នកអសមត្ថភាព លើសពីនេះទៅទៀត អ្នកមិនមានសមត្ថភាពលទ្ធភាពបង្ក្រាបភាពចលាចលវឹកវរជ្រួលច្របល់បាន នោះហើយជាហេតុធ្វើអោយកូនទាហ៊ានរបស់អ្នកត្រូវតែត្រូវបានប្រៀបធៀបប្រដូចទៅនឹងក្មេងបៀមដៃ លីលាអត់ដឹងអី។ ពលទាហ៊ានកូនទាហ៊ានទាំងអស់របស់អ្នក ក៏គ្មានបានការក្នុងការប្រតិបត្តិការសឹកសង្គ្រាមដើម្បីសំរេចតាមគោលដៅគោលបំណងរបស់អ្នក។

២៧)-ប្រសិនបើអ្នកដឹងថាមនុស្សឬកូនទាហ៊ានរបស់អ្នកផ្ទាល់ស្ថិតនៅក្នុងលក្ខ័ខណ្ឌមួយដើម្បីវាយប្រហារសត្រូវ ប៉ុន្តែអ្នកមិនដឹងថាសត្រូវរបស់អ្នកប្រុងប្រយ័ត្ន មិនធ្វេសប្រហែសមិន

បើកចំហរអោយកងទ័ពរបស់អ្នកវាយប្រហារ អ្នកគ្រាន់តែទៅដល់ពាក់កណ្ដាលផ្លូវតែប៉ុណ្ណោះឆ្ពោះទៅកាន់ជ័យជំនះ។

២៨)-ប្រសិនបើយើងដឹងថា សត្រូវរបស់យើងបើកចំហរធ្វេសប្រហែសសំរាប់យើងវាយប្រហារ ប៉ុន្តែយើងមិនដឹងថាកងទ័ពឬមនុស្សផ្ទាល់របស់យើងមិនស្ថិតនៅក្នុងលក្ខ័ខណ្ឌមួយសំរាប់វាយប្រហារនោះទេយើងគ្រាន់តែទៅដល់ពាក់កណ្ដាលផ្លូវតែប៉ុណ្ណោះឆ្ពោះទៅកាន់ជ័យជំនះ។

២៩)-ប្រសិនបើយើងដឹងថា សត្រូវបើកចំហរធ្វេសប្រហែសសំរាប់អោយយើងវាយប្រហារ ហើយយើងដឹងផងដែរថា កងទ័ពរបស់យើងស្ថិតក្នុងលក្ខ័ខណ្ឌមួយដែលត្រូវតែវាយប្រហារសត្រូវប៉ុន្តែយើងពុំដឹងថាលក្ខណៈធម្មជាតិរបស់ដែនដីមូលដ្ឋាននោះថាតើអាចធ្វើការវាយប្រយុទ្ធបានឬអត់? ការវាយប្រហារមិនអាចប្រតិបត្តិទៅបាននោះទេ យើងនៅតែទៅដល់ពាក់កណ្ដាលផ្លូវតែប៉ុណ្ណោះឆ្ពោះទៅរកជ័យជំនះ។

៣០)-ហេតុដូច្នេះទាហ៊ានដែលមានបទពិសោធន៍ស្ទាត់ជំនាញនៅពេលធ្វើសឹកសង្គ្រាមម្តងៗមិនដែលត្រូវបានធ្វើអោយសុញ្ញគំនិតម្តងណាឡើយ ទោះបីមានម្តងម្កាលជំរុំរបស់គាត់បែបបាក់ខូចខាតក៏ដោយ ក៏គាត់នៅតែមិនដែលបាត់បង់អាយុជីវិតឬខូចខាតធំដុំឡើយ។

៣១)-ហេតុដូច្នេះ ទើបលោកស៊ុន-ជូបានមានប្រសាសន៍ថា«ប្រសិនបើអ្នកស្គាល់សត្រូវច្បាស់និងស្គាល់ខ្លួនឯងច្បាស់ ជ័យជំនះរបស់អ្នកនឹងមានជារៀងរហូតដោយគ្មានការមន្ទិលសង្ស័យ។ ប្រសិនបើអ្នកស្គាល់ឋានសួគ៌និងផែនដីច្បាស់ អ្នកអាចធ្វើអោយជ័យជំនះរបស់អ្នកទទួលបានទាំងស្រុង។

## ១១-ស្ថានភាពទាំង៩(The Nine Situations):

១)-លោកស៊ុន-ជូ មានប្រសាសន៍ថា«សិល្បៈសង្គ្រាមទទួលស្គាល់នៅភាពខុសប្លែកគ្នា៩យ៉ាងនៃមូលដ្ឋានដែនដីគឺ៖

(១)-មូលដ្ឋានបែកខ្ញែកគ្មានទំរង់ច្បាស់លាស់ឬស្រពិចស្រពិល(Dispersive Ground)។

(២)-មូលដ្ឋានងាយស្រួល(Facile Ground)។

(៣)-មូលដ្ឋានជំល្លោះវិវាទ(Contentious Ground)។

(៤)-មូលដ្ឋានបើកចំហរ(Open Ground)។

(៥)-មូលដ្ឋានភពប្រសព្វ(Ground of Intersecting Highways)។

(៦)-មូលដ្ឋានពិតប្រាកដ(Serious Ground)។

(៧)-មូលដ្ឋានលំបាក(Difficult Ground)។

(៨)-មូលដ្ឋានហ៊ុំព័ទ្ធ(Hemmed-in Ground)។

(៩)-មូលដ្ឋានអស់សង្ឃឹម(Desperate Ground)។

**២)**-នៅពេលដែលមេដឹកនាំម្នាក់កំពុងតែវាយប្រហារនៅក្នុងដែនដីផ្ទាល់របស់គាត់ វាគឺជាមូលដ្ឋានស្រពិចស្រពិលមួយ(Dispersive Ground)។

**៣)**-នៅពេលដែលគាត់បានជ្រៀតចូលទៅក្នុងដែនដីសត្រូវ ប៉ុន្តែទៅមិនឆ្ងាយប៉ុន្មាននោះទេវាគឺជាមូលដ្ឋានងាយស្រួល(Facile Ground)។

**៤)**-មូលដ្ឋានដែលជាតំបន់ជ័យភូមិសំបូរស្តុកស្តម្ភដែលនាំចូលនៅផលប្រយោជន៍គុណសម្បត្តិអំណោយផលដល់ភាគីទាំងសងខាងគឺត្រូវបានហៅថាមូលដ្ឋានតោងទាញ ឬហៅថាមូលដ្ឋានជំល្លោះវិវាទ (Contentious Ground) ។

**(៥)**-មូលដ្ឋានដែលភាគីនីមួយៗមានសេរីភាពដើរហើរចេញចូលបានគឺត្រូវបានហៅថាមូលដ្ឋានបើកចំហរ(Open Ground)។

**៦)**-មូលដ្ឋានដែលបង្កើតគន្លឹះទៅកាន់រដ្ឋជាប់គ្នា៣ ដូច្នេះចំណុចនោះគឺថាឧត្តមសេនីយដែលកាន់កាប់វាបានមុន មានប្រៀបជាងគេបំផុតនៅក្នុងចក្រភព ហើយអាចបញ្ជាលើចក្រភពទាំងមូលបាន និងមានឥទ្ធិពលក្នុងការចេញបញ្ជាគ្រប់យ៉ាង នេះគឺត្រូវបានហៅថាមូលដ្ឋានផ្លូវធំប្រសព្វគ្នា(Ground of Intersecting Highways)។

៧)-នៅពេលកងទ័ពមួយបានជ្រាបចូលទៅក្នុងបេះដូងនៃប្រទេសដែនដីសត្រូវមួយ កំពុងទុកចោលនៅបណ្តាលទីក្រុងដែលមានបន្ទាយការពារជាច្រើននៅក្នុងផ្នែកខាងក្រោយរបស់ខ្លួន វាត្រូវបានហៅថា‹‹មូលដ្ឋានពិតប្រាកដ(Serious Ground)››។

៨)-បណ្តារតំបន់មូលដ្ឋានដែលមានព្រៃឈើច្រើនតាមភ្នំ ភ្នំច្រើន តំបន់ទីទួលរម៉ាំងរម៉ោកតំបន់ចោទខ្ពស់យ៉ាប់យ៉ឺន តំបន់ជំរាល តំបន់វាលភក់ល្បាប់ច្រើន និងតំបន់ដែលមានរបងកំពែងការពារគឺថារាល់គ្រប់តំបន់ដែនដីទាំងអស់បែបហ្នឹងដែលពិបាកឆ្លងកាត់ពិតប្រាកដឬហៅថាមូលដ្ឋានយ៉ាប់យ៉ឺន(Difficult Ground)។

៩)-មូលដ្ឋានដែលត្រូវបានទៅដល់តាមរយៈបណ្តារជ្រោះជ្រលងតូចចង្អៀតទាំងឡាយដែលយើងធ្វើដំណើរឆ្លងកាត់យ៉ាងហត់នឿយបំផុតតាមរយៈផ្លូវដ៏សែនលំបាកលំបិនបំផុតតែប៉ុណ្ណោះឬផ្លូវលំបាកផ្លូវទារុណតែប៉ុណ្ណោះ ហេតុដូច្នេះមូលដ្ឋាននោះ ទោះបីជាសត្រូវមានចំនួនកងទ័ពតិចតួច ក៏ល្មមគ្រប់គ្រាន់សំរាប់វាយរុញច្រានកងកំលាំងអង្គភាពកងទ័ពដ៏ធំមួយរបស់យើងបានដែរ។ នេះត្រូវបានហៅថា ‹‹មូលដ្ឋានហ៊ុំព័ទ្ធ(Hemmed-in Ground)››។

១០)-មូលដ្ឋានដែលយើងអាចគ្រាន់តែត្រូវបានសង្គ្រោះប៉ុណ្ណោះ ស្រោចស្រង់ចេញពីការបំផ្លិចបំផ្លាញដោយការវាយប្រហារដោយគ្មានការពន្យាពេល នេះហៅថា‹‹មូលដ្ឋានអស់សង្ឃឹម›› (Desperate Ground)។

១១)-ហេតុដូច្នេះហើយ នៅតាមមូលដ្ឋានស្រពិចស្រពិលមិនច្បាស់លាស់ ចូរអ្នកកុំវាយប្រយុទ្ធ។ តាមមូលដ្ឋានងាយស្រួល បន្តការវាយលុក។ នៅលើមូលដ្ឋានតោងទាញកុំវាយប្រយុទ្ធឬកុំវាយប្រហារ។

១២)-នៅតាមមូលដ្ឋានបើកចំហរ កុំព្យាយាមរាំងផ្ទុកវាយបង្អាក់ផ្លូវសត្រូវ។ នៅតាមមូលដ្ឋានមានផ្លូវធំៗប្រសព្វគ្នា ចូរចាប់ដៃសហការឬចងសម្ព័ន្ធមិត្តជាមួយអ្នកជិតខាង ឬចូលរួមជាមួយនឹងសម្ព័ន្ធមិត្តរបស់អ្នក។

១៣)-នៅតាមមូលដ្ឋានពិតប្រាកដប្រមូលកងទ័ពធ្វើការវាយឆក់ប្លន់។នៅលើមូលដ្ឋានលំបាកៗ សូមនៅស្ងប់ស្ងៀមបញ្ឈប់សកម្មភាពរំកិលទ័ព ឬរក្សាការរំកិលទ័ពដោយស្ងៀមស្ងាត់។

១៤)-នៅក្នុងមូលដ្ឋានហ៊ុំព័ទ្ធ ត្រូវប្រើរាល់គ្រប់យុទ្ធោបាយសឹកធ្វើជាមធ្យោបាយដោះស្រាយចុងក្រោយបំផុត។ នៅលើមូលដ្ឋានអស់សង្ឃឹម ត្រូវតែវាយប្រយុទ្ធ ឬវាយលុក វាយបើកផ្លូវឈាម។

១៥)-អ្នកទាំងនោះដែលត្រូវបានហៅថាពួកមេដឹកនាំស្ទាត់ជំនាញជើងចាស់នោះ បានយល់ដឹងនៅវិធីបោះស្នៀតក្បួនទ័ពមួយ(ឬដឹកនាំទ័ពអោយញែកចេញពីគ្នា)រវាងផ្នែកខាងមុខនិងផ្នែកខាងក្រោយរបស់សត្រូវ ដើម្បីទុបស្កាត់រារាំងកិច្ចសហប្រតិបត្តិការសឹករវាងកងពលធំនិងកងពលតូចរបស់សត្រូវ និងទប់ស្កាត់រារាំងកងទ័ពជំនាញរបស់សត្រូវដែលមកសង្គ្រោះស្ថានការណ៍អាក្រក់ និងទប់ទល់មេទ័ពនានារបស់សត្រូវមិនអោយដេញតាមវាយប្រហារកងទ័ពរបស់ពួកគេទាន់។

១៦)-នៅពេលដែលកងទ័ពរបស់សត្រូវត្រូវបានរួបរួមគ្នាល្អមានឯកភាពជាធ្លុងមួយ អ្នកត្រូវតែធ្វើអោយពួកគេកើតចលាលាចលវឹកវរផ្ទៃក្នុង ឬក៏អ្នកត្រូវតែរងចាំកងទ័ពសត្រូវកើតមានភាពចលាចលវឹកវរកាលាហាលផ្ទៃក្នុងសិន។

១៧)-នៅពេលមូលដ្ឋានផ្តល់ផលចំណេញផលប្រយោជន៍ដល់កងទ័ពរបស់យើង យើងត្រូវតែធ្វើការរំកិលទ័ពទៅមុខ ហើយនៅពេលគ្មានផលចំណេញនោះទេ យើងត្រូវបញ្ឈប់ការរំកិលកងទ័ព។

១៨)-ប្រសិនបើអ្នកត្រូវបានសួរពីវិធីសាស្រ្តប្រឈមមុខជាមួយមហាសត្រូវដ៏ធំមួយនោះអ្នកត្រូវតែរៀបចំចំណុចរំកិលកងទ័ពទៅវាយប្រយុទ្ធប្រកបដោយសណ្តាប់ធ្នាប់វិន័យល្អ ហើយដៅចំណុចរំកិលទ័ពទៅវាយប្រហារអោយបានច្បាស់លាស់។ លោកស៊ុន-ជូ បានមានប្រសាសន៍ថា«អ្នកត្រូវតែចាប់ផ្តើមវាយប្រហារដណ្តើមកាន់កាប់យកអ្វីមួយដែលសត្រូវរបស់អ្នកពេញចិត្តបំផុតឬជាដង្ហើមស្លាប់រស់ ជាអាយុជីវិតរបស់សត្រូវរបស់អ្នក បន្ទាប់មកសត្រូវរបស់អ្នកនឹងសាកល្បងដណ្តើមយកអ្វីដែលជាបំណងឆន្ទះរបស់អ្នកវិញ»។

១៩)-ការបង្កើនល្បឿនអោយលឿនបំផុតគឺមានសារៈសំខាន់ណាស់នៅក្នុងសង្គ្រាម ដណ្តើមយកផលប្រយោជន៍ ទាញយកផលចំណេញពីអ្វីដែលសត្រូវពុំបានត្រៀមរៀបចំទុកជាមុនឬពីអ្វីដែលសត្រូវធ្វេសប្រហែសខ្វះចន្លោះ រំកិលទ័ពទៅតាមផ្លូវដែលសត្រូវអ្នកស្មានមិនដល់ ហើយអ្នកត្រូវរំពឹងទុកជាមុន ឬរំកិលទ័ពទៅតាមផ្លូវដែលសត្រូវអ្នកស្មានមិនដល់ ហើយអ្នកត្រូវតែវាយប្រហារនៅរាល់ចំណុចទីតាំងដែលសត្រូវអ្នកពុំបានការពារ មិនប្រុងប្រយ័ត្នត្រៀមលក្ខណៈជាមុន។

២០)-ដូចខាងក្រោមនេះគឺជាគោលការណ៍ទាំងឡាយត្រូវតែត្រូវបានសង្កេតដោយកងកំលាំងវាយលុកឈ្លានពានមួយគឺ មុនពេលវាយជ្រៀតជ្រាបចូលទៅក្នុងដែនដីប្រទេសខ្មាំងតទៅទៀត កិច្ចការដ៏សំខាន់បំផុតដើម្បីសំរេចនៅគោលបំណងឆន្ទះដ៏ធំបំផុតរបស់អ្នកគឺអ្នកត្រូវតែធ្វើអោយមានភាពសាមគ្គីគ្នានៅក្នុងកងទ័ពរបស់អ្នក ចងបាច់ជាធ្លុងមួយ ហើយបើកងទ័ពកងកំលាំងដ៏ធំរបស់អ្នកមានភាពសាមគ្គីគ្នារឹងមាំដូចដុំថ្មធំមួយដុំរមៀលចុះពីលើភ្នំចុះមកក្រោម ហេតុដូច្នេះពួកអ្នកការពារប្រឆាំងការវាយលុករបស់អ្នកនឹងមិនហ៊ានបង្ហាញលាតត្រដាងនៅអាក្ការៈប្រឆាំងនឹងអ្នកឡើយ សត្រូវអ្នកមិនអាចទប់ទល់អ្នក ឬធ្វើអោយឆន្ទៈសត្រូវការពារទឹកដីមិនអាចទុបទល់នឹងអ្នកបានឡើយ។

២១)-ត្រូវតែធ្វើការលុកលុយប្លន់រឹបអូសដណ្តើមយកប្រទេសដែនដីដ៏មានជីវជាតិសំបូរស្តុកស្តមយកទៅផ្គត់ផ្គង់ស្បៀងអាហារទៅដល់កងទ័ពកងកំលាំងរបស់អ្នក។

២២)-អ្នកត្រូវតែសិក្សាស្វែងយល់យ៉ាងប្រុងប្រយ័ត្នអំពីសុខមាលភាព សុវត្តិភាពនៃមនុស្សរបស់អ្នក ហើយកុំហួតផាសីឬយកពន្ធដារច្រើនជ្រុលពេកពីពួកគេ។អ្នកត្រូវតែប្រមូលផ្តុំនៅរាល់គ្រប់កំលាំងឋាមពលបញ្ញាញាណឬកលឧបាយដែលលាក់ទុកកំលាំងកងទ័ពដែលបំរុងទុកយកមកប្រើប្រាស់ពេលវាយលុក។ ចូរអ្នករក្សាកងកំលាំងកងទ័ពរបស់អ្នកជានិច្ចទុកសំរាប់ធ្វើការរំកិលទ័ព ឬវាយប្រហារខ្មាំង ហើយអ្នកត្រូវតែប្រឌិតកែច្នៃបង្កើតផែនការថ្មីៗដែលគ្មាននរណាដឹងឬយល់បាននិងគំរោងអាថិកំបាំងសំរាប់បំរើយុទ្ធសាស្ត្រយកឈ្នះលើខ្មាំងសត្រូវ។

២៣)-ចូរអ្នកបោះពលទាហ៊ានរបស់អ្នកទៅក្នុងបណ្តារទីតាំងទាំងឡាយណាដែលជាកន្លែងចំណុចគ្មានការភៀសខ្លួនចេញ ឬមិនអាចរត់ចោលជួរបាន ប្រើវិន័យតឹងរឹងពេលវាយប្រយុទ្ធព្រមទាំងពង្រឹងជំហរទឹកចិត្តស្មារតីក្លាហ៊ានរឹងមាំ សុខចិត្តស្លាប់ មិនសុខចិត្តចាញ់ព្រម

ទាំងបញ្ជូនទ័ពច្បាំងជាមួយខ្មាំងសត្រូវដោយរៀបក្បួនទ័ពក្នុងទីតាំងមិនអោយភៀសខ្លួនរត់ចោលជួរបានគឺបើរត់គេចខ្លួន រត់ចោលជួរមានតែផ្លូវស្លាប់។ប្រសិនបើកងទ័ពកងកំលាំងទាហ៊ានរបស់យើងនឹងប្រឈមមុខនឹងក្តីមរណៈ ពួកគេមិនគេចភៀសចេញពីទីលានសមរភូមិឡើយហើយពួកគេគ្មានមធ្យោបាយណាមួយជ្រើសរើសក្រៅពីច្បាំងស្លាប់រស់យកជ័យជំនះលើខ្មាំងឡើយ។ បណ្តាពួកមេទ័ព និងកូនទាហ៊ានទាំងឡាយរបស់អ្នក នឹងក្លាយទៅជាកំលាំងឈានមុខដ៏ប្រពៃបំផុត វាយប្រហារសំរុកទៅមុខកំទេចខ្មាំងដោយប្រើអស់កំលាំងឋាមពលពីខ្លួនរបស់ពួកគេប្រៀបបីដូចជាដុំថ្មមូលដ៏ធំមួយរមៀលធ្លាក់ចុះពីលើកំពូលភ្នំចុះមកក្រោម។

២៤)-ទាហ៊ានទាំងឡាយនៅពេលស្ថិតនៅក្នុងការលំបាក ស្ថានភាពអស់សង្ឃឹមបានបោះបង់ហេតុផលឬអារម្មណ៍ភ័យខ្លាច។ ប្រសិនបើគ្មានកន្លែងគេចខ្លួនភៀសចេញទេ ពួកគេនឹងឈរជើងយ៉ាងរឹងមាំប្រយុទ្ធវាយខ្មាំង។ ប្រសិនបើពួកគេស្ថិតក្នុងប្រទេសដែនដីរបស់សត្រូវពួកគេនឹងបង្ហាញនៅការប្រឈមមុខយ៉ាងរឹងរូសមួយឬវាយប្រហារតទល់ខ្មាំងយ៉ាងចចេសប្រសិនបើគ្មានជំនួយសំរាប់កងកំលាំងដែលកំពុងវាយប្រយុទ្ធនោះទេ នោះពួកគេនឹងវាយប្រហារវាយប្រយុទ្ធយ៉ាងខ្លាំងក្លា។

២៥)-ដូច្នេះ ដោយគ្មានការរងចាំដើម្បីរៀបចំប្រមូលកងទ័ព ពលទាហ៊ានទាំងឡាយនឹងឈរជើងយ៉ាងរស់រវើកជានិរន្ត។ ដោយគ្មានការរងចាំដើម្បីត្រូវបានស្នើរសុំ ពួកគេនឹងធ្វើអ្វីៗទៅតាមឆន្ទះរបស់ពួកគេ។ ដោយគ្មានការរឹតបន្តឹងការដាក់កំហិតព្រំដែន ពួកគេនឹងប្រកបដោយភាពស្មោះត្រង់។ ដោយគ្មានការផ្តល់បទបញ្ជា ឬការបញ្ជា ពួកគេអាចត្រូវបានជឿទុកចិត្ត។

២៦)-ត្រូវហាមឃាត់ហាមប្រាមមិនអោយប្រកាន់យកប្រផ្នូលនានា ហើយត្រូវកំចាត់ចោលអោយអស់នៅក្តីមន្ទិលសង្ស័យដែលមានជំនឿជឿលើរឿងនិទានចាស់បុរាណឬរឿងអច្ឆរិយៈ។ ហេតុដូច្នេះ រហូតដល់ក្តីមរណៈកើតឡើងដោយខ្លួនវា គ្មានកាលាហល់ ឬក្តីមហន្តរាយណាមួយតំរូវអោយត្រូវតែភ័យខ្លាចឡើយ។

២៧)-ប្រសិនបើកូនទាហ៊ានរបស់យើងត្រូវបានដាក់កំរិតមិនអោយមានចិត្តលោភលន់ស្រឡាញ់លុយហួសហេតុឡើយ វាមិនមែនពីព្រោះតែហេតុផលដោយសារពួកគេស្អប់ខ្ពើមមួយ

ចំពោះពួកអ្នកមាននោះទេ ប្រសិនបើអាយុជីវិតរបស់ពួកគេមិនមានតទៅទៀតទេនោះតើលុយមានន័យអ្វី? ហើយវាក៏មិនមែនដោយសារហេតុផលថាពួកគេមិនត្រូវបានធ្លាក់ទឹកចិត្តស្រយុត្តិចុះចំពោះភាពមានអាយុវែងឡើយ ប៉ុន្តែដើម្បីជាតិទឹកដី។

២៨)-នៅថ្ងៃដែលពួកគេត្រូវបានបញ្ជាអោយចេញប្រយុទ្ធក្នុងសមរភូមិ បណ្តារទាហ៊ានរបស់អ្នកអាចយំ ទាំងនោះកំពុងអង្គុយលើសាក់ការដូរដាក់សំលៀកបំពាក់របស់ពួកគេ ហើយទាំងនោះកំពុងដេកផ្អែកចុះ ធ្វើអោយទឹកភ្នែកបានហូរស្រក់ចុះលើថ្ពាល់របស់ពួកគេ។ ប៉ុន្តែភ្លាមនោះសូមនាំពួកគេទៅកាន់ឆកសមុទ្រ ហើយពួកគេនឹងសំដែងចេញនៅភាពក្លាហ៊ាន។

២៩)-អ្នករៀបឬប្រើយុទ្ធវិធីដ៏ជំនាញប៉ិនប្រសប់ អាចត្រូវបានប្រៀបប្រដូចទៅនឹងសត្វពស់សួយជាង។ ឥឡូវពស់សួយជាងគឺជាពស់មួយដែលត្រូវបានប្រទះឃើញនៅភ្នំឈុង។បើអ្នកវាយប្រហារក្បាលសត្វពស់ ហើយអ្នកនឹងត្រូវបានវាយវ៉ាត់សង្គ្រាប់ដោយកន្ទុយពស់ បើអ្នកវាយកន្ទុយសត្វពស់ អ្នកនឹងត្រូវបានវាយប្រហារដោយក្បាលសត្វពស់ ប៉ុន្តែបើអ្នកវាយប្រហារនៅចំកណ្តាលខ្លួនសត្វពស់ ហើយអ្នកនឹងត្រូវបានវាយសង្គ្រាប់ដោយទាំងក្បាលនិងទាំងកន្ទុយសត្វពស់។

៣០)-សួរថាប្រសិនបើកងទ័ពមួយអាចត្រូវបានធ្វើគំរូត្រាប់តាមពស់សួយជាង ខ្ញុំគួតែឆ្លើយថាបាទ! ធ្វើត្រាប់តាមបាន។ ចំពោះកងទ័ពនគរវូ និងកងទ័ពនគរយូគឺជាសត្រូវនឹងគ្នា ប្រសិនបើពួកគេកំពុងតែឆ្លងទន្លេមួយនៅឡើយដោយជិះទូកតែមួយដូចគ្នា ហើយត្រូវបានបោកបក់បំផ្លិចបំផ្លាញដោយខ្យល់ព្យុះមួយ ពួកគេនឹងមកជួយគ្នាទៅវិញទៅមក គ្រាន់តែយកដៃឆ្វេងជួយដៃខាងស្តាំតែប៉ុណ្ណោះ។

៣១)-ហេតុដូច្នេះ វាមិនទាន់គ្រប់គ្រាន់ទេ ដើម្បីដាក់សេចក្តីទុកចិត្តលើនរណាម្នាក់ដោយការយកសេះរបស់គេចងទុកក្នុងខ្សែចំណង ហើយកប់រទេះសេះចំបាំងឬកង់រទេះសេះចំបាំងរបស់ពួកគេទុកនៅក្នុងដីឬមូលដ្ឋានដែនដី។

៣២)-តាមគោលការណ៍ ដើម្បីរៀបចំចាត់ចែងកងទ័ពមួយគឺត្រូវតែបង្កើតចេញនៅស្តង់ដារមួយ ឬកំរិតស្តង់ដារមួយនៃសេចក្តីក្លាហានដែលកងទ័ពទាហ៊ានទាំងអស់ ត្រូវតែឈានដល់កំរិតស្តង់ដារសេចក្តីក្លាហានមួយនោះ។

៣៣)-វិធីដើម្បីធ្វើអោយប្រសើរបំផុតទាំងកងទ័ពខ្លាំងនិងទាំងកងទ័ពខ្សោយគឺថាជាបញ្ហាមួយដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់អោយបានសមស្របនៅមូលដ្ឋាននីមួយៗ។

៣៤)-ដូច្នេះឧត្តមសេនីយដែលប្រកបដោយជំនាញដឹកនាំកងទ័ពរបស់គាត់ គ្រាន់តែចាត់ទុកគាត់បីដូចបានកំពុងដឹកនាំមនុស្សតែម្នាក់ទៅគ្រប់ទីកន្លែងដោយដៃរបស់គាត់។

៣៥)-វាគឺជាកិច្ចការជំនួញរបស់ឧត្តមសេនីយម្នាក់គ្រាន់តែនៅស្ងប់ស្ងៀមហើយរក្សាការណ៍សំងាត់ក្នុងការអនុវត្តន៍ផែនការជាយុទ្ធសាស្រ្តស្របតាមយុទ្ធវិធីដ៏ប៉ិនប្រសប់ហើយចេញបញ្ជាអោយបានត្រឹមត្រូវទៀងទាត់។

៣៦)-ឧត្តមសេនីយត្រូវតែមានលទ្ធភាពសមត្ថភាពប្រើប្រាស់កលល្បិចសំងាត់ដាក់ពួកមេទ័ពនិងកូនទាហ៊ានរបស់គាត់អនុវត្តន៍នៅផែនការសំងាត់ទៅតាមយុទ្ធវិធីអាថិកំបាំងរបស់គាត់ដោយប្រើរបាយការណ៍ខុស សេចក្តីរាយការណ៍ក្លែងក្លាយនិងការសំដែងបង្ហាញពត៌មានក្លែងក្លាយ ហើយបើគាត់ធ្វើដូច្នេះ គាត់អាចធ្វើអោយពួកមេទ័ពនិងកូនទាហ៊ានរបស់គាត់ស្ថិតក្នុងសភាពមិនដឹងអីទាល់តែសោះ ឬមិនដឹងមិនឮរឿងគ្រប់យ៉ាងទាំងមូល។

៣៧)-ដោយការផ្លាស់ប្តូរនៅការរៀបចំចាត់ចែងរបស់គាត់ និងការផ្លាស់ប្តូរផែនការទាំងឡាយរបស់គាត់ គាត់នៅតែធ្វើអោយសត្រូវរបស់គាត់ស្ថិតនៅក្នុងសភាពអត់ដឹងអីសត្រូវរបស់គាត់គឺទទួលបានតែចំណេះដឹងពត៌មានមិនច្បាស់លាស់។ ដោយការដោះដូរអើរុះនៅជំរុំរបស់គាត់ ហើយប្រកាន់យកឬបង្កើតនៅផ្លូវបត់បែនវៀរវេរជាច្រើន គាត់អាចទុបស្កាត់ពីការគិតរំពឹងទុកឬសង្ឃឹមទុកជាមុននៅគោលបំណងរបស់គាត់ ឬធ្វើអោយខ្មាំងសត្រូវរបស់គាត់មិនអាចគិតស្មានទុកឬប្រមើលមើលនៅគោលដៅរបស់គាត់ទុកជាមុនបានឡើយ។

៣៨)-នៅក្នុងពេលវេលាចាំបាច់ ឱកាសហុចអោយ មេដឹកនាំនៃកងទ័ពមួយ ធ្វើសកម្មភាពដូចជាមនុស្សម្នាក់ដែលបានឡើងដើមឈើ ឬទីដ៏ខ្ពស់មួយហើយបន្ទាប់មកទាត់ជណ្តើរចេញពីខាងក្រោយអ្នក។ គាត់ដឹកនាំមនុស្សរបស់គាត់ចូលទៅក្នុងដែនដីសត្រូវយ៉ាងជ្រៅមុនពេលគាត់ព្រលែងដៃរបស់គាត់។

៣៩)-គាត់ដុតទូកនានារបស់គាត់ ហើយវាយបំបែកឆ្នាំងខ្ទះចំអិនបាយម្ហូបរបស់គាត់ ដូចអ្នកគង្វាលម្នាក់ដឹកនាំហ្វូងចៀមមួយហ្វូង គាត់ដឹកនាំមនុស្សរបស់គាត់តាមមធ្យោបាយនេះ ហើយគ្មានអ្នកណាម្នាក់ដឹងថាតើគាត់នឹងទៅណា?

៤០)-ការដឹកនាំកងទ័ពរបស់ខ្លួន ហើយនាំទៅកាន់គ្រោះថ្នាក់មួយ គឺនេះមានន័យថាពាណិជ្ជកម្ម ឬការធ្វើជំនួញរបស់ឧត្តមសេនីយ។

៤១)-វិធានការផ្សេងៗគ្នាត្រូវបានធ្វើអោយសមស្របទៅនឹងភាពខុសប្លែកគ្នានៃមូលដ្ឋានទាំង៩ ។ភាពសក្ដិសិទ្ធិនៃយុទ្ធវិធីវាយលុក ឬយុទ្ធវិធីការពារហើយច្បាប់ជាមូលដ្ឋានគ្រឹះនៃលក្ខណៈធម្មជាតិរបស់មនុស្សជាតិទាំងនោះគឺជារឿងរ៉ាវបញ្ហាសំខាន់ចាំបាច់ដែលត្រូវតែត្រូវបានសិក្សាស្វែងយល់អោយបានច្រើនបំផុត ច្បាស់លាស់បំផុត។

៤២)-នៅពេលដែលអ្នកធ្វើការវាយលុកឈ្លានពានដែនដីសត្រូវនោះគោលការណ៍ឧត្តមសេនីយគឺថានាំទ័ពជ្រៀតជ្រាបចូលទៅក្នុងដែនដីសត្រូវ ប៉ុន្តែសរុបអោយខ្លីគឺប្រើមធ្យោបាយបំបែកកងទ័ពរបស់អ្នកអោយបែកញែកពីគ្នាទៅតាមផ្លូវខ្លីៗមួយ បន្ទាប់ពីជ្រៀតជ្រាបចូលយ៉ាងជ្រៅទៅក្នុងទឹកដីរបស់ខ្មាំងឬដែនដីខ្មាំង ត្រូវតែប្រមូលបង្រួមកងឯកភាពអោយមានភាពស្អិតជាប់គ្នា។

៤៣)-នៅពេលដែលអ្នកចាកចេញពីដែនដីផ្ទាល់របស់អ្នកឆ្លងផុតទៅហើយ នាំកងទ័ពរបស់អ្នកឆ្លងកាត់ដែនដីជិតខាង អ្នកនឹងបានកាន់កាប់មូលដ្ឋានខ្លាំងដោយខ្លួនឯង។នៅពេលមានមធ្យោបាយគមនាគមន៍ទំនាក់ទំនងសព្វទិសទីគ្រប់ច្រកល្ហកទាំង៤ផ្នែក មូលដ្ឋាននេះគឺជាមូលដ្ឋានមួយនៃផ្លូវធំៗប្រសព្វគ្នា។

៤៤)-នៅពេលដែលអ្នកជ្រៀតជ្រាបចូលយ៉ាងជ្រៅទៅក្នុងដែនដីប្រទេសមួយ វាគឺជាតំបន់ពិតប្រាកដ។ នៅពេលអ្នកជ្រៀតជ្រាបចូលទៅក្នុងដែនដីមួយ ប៉ុន្តែទើបតែធ្វើដំណើរតាមផ្លូវបានបន្តិចបន្តួចមួយ វាគឺជាមូលដ្ឋានងាយស្រួលមួយ។

៤៥)-នៅពេលដែលអ្នកទៅជុំវិញមូលដ្ឋានសឹករបស់សត្រូវរហូតដល់ផ្នែកខាងក្រោយបន្ទាយ ហើយមានច្រកចូលតូចចង្អៀតនៅផ្នែកខាងមុខ វាគឺជាមូលដ្ឋានហ៊ុំព័ទ្ធ។ នៅពេលគ្មានកន្លែងភៀសខ្លួនរត់គេចចេញទាល់តែសោះវាជាមូលដ្ឋានអស់សង្ឃឹម។

៤៦)-ហេតុដូច្នេះ នៅតាមមូលដ្ឋានស្រពិចស្រពិល ខ្ញុំត្រូវតែជំរុញញ៉ាំងអោយមនុស្សរបស់អ្នកមានការឯកភាពគ្នាជាផ្លូវមួយជាមួយកងអង្គភាពឯកភាពប្រតិបត្តិតាមគោលបំណងឬគោលដៅរបស់ខ្ញុំ។ នៅតាមមូលដ្ឋានងាយស្រួល ខ្ញុំដឹងថាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតរវាងផ្នែកទាំងអស់នៃកងទ័ពរបស់ខ្ញុំ។

៤៧)-នៅតាមតំបន់មូលដ្ឋានតោងទាញខ្ញុំប្រញាប់រូសរាន់ទៅកាន់កាប់នៅផ្នែកខាងក្រោយ។

៤៨)-នៅលើមូលដ្ឋានបើកចំហរ ខ្ញុំត្រូវតែរក្សាការក្លំមើលយ៉ាងប្រុងប្រយ័ត្នមួយនៅលើកិច្ចការពាររបស់ខ្ញុំ។ នៅតាមមូលដ្ឋាននៃផ្លូវធំៗប្រសព្វគ្នា ខ្ញុំត្រូវតែចងមិត្ត និងពង្រឹងសម្ព័ន្ធមិត្តរបស់ខ្ញុំអោយបានរឹងមាំ។

៤៩)-នៅតាមមូលដ្ឋានពិតប្រាកដ ខ្ញុំត្រូវតែព្យាយាមធានាកិច្ចការពារលើបណ្តាញផ្គត់ផ្គង់ជាខ្សែសង្វាក់មួយ។ នៅលើមូលដ្ឋានលំបាកៗ ខ្ញុំត្រូវតែរក្សាការរុញច្រាននៅតាមបណ្តោយផ្លូវ ឬវាយទំលុះរកផ្លូវចេញ។

៥០)-នៅតាមមូលដ្ឋានហ៊ុំព័ទ្ធខ្ញុំត្រូវតែវាយរាំងខ្ទប់តាមផ្លូវណាមួយដើម្បីរកច្រកដកថយ។នៅលើមូលដ្ឋានអស់សង្ឃឹម ខ្ញុំត្រូវតែប្រកាសអះអាងប្រាប់ដល់ពួកទាហ៊ានរបស់ខ្ញុំនៅភាពអស់សង្ឃឹមដើម្បីវាយបើកផ្លូវឈាមស្រោចស្រង់អាយុជីវិតរបស់ពួកគេ។

៥១)-រីឯមូលដ្ឋាននានា វាអាស្រ័យលើការរៀបចំបែងចែកទាហ៊ានដើម្បីផ្តល់ការតស៊ូដ៏ចចេសរឹងរូសមួយនៅពេលខ្មាំងបានឡោមព័ទ្ធ ដើម្បីប្រយុទ្ធយ៉ាងសស្រាក់សស្រាំ នៅពេលគាត់មិនអាចជួយខ្លួនឯងបាន ហើយដើម្បីគោរពទៅតាមស្ថានការណ៍បត់បែនតាមកាលៈទេសៈយ៉ាងសមស្របនៅពេលដែលគាត់បានធ្លាក់ទៅក្នុងគ្រោះថ្នាក់។

៥២)-យើងមិនអាចចូលទៅក្នុងដែនដីសម្ព័ន្ធនៅជិតក្បែរខាងជាមួយស្តេចព្រះអង្គម្ចាស់ដែលនៅជិតខាងបានទេ រហូតដល់យើងដឹងថាមានការរៀបចំគំរោងផែនការដ៏ល្អរបស់ពួកគេ។ យើងមិនអាចដឹងនាំកងទ័ពមួយរំកិលទ័ពចូលទាំងទទឹងទិសគ្មានហេតុផលបានទេ លុះត្រាតែយើងស្គាល់ច្បាស់នៅរបៀបប្រឈមមុខនៅលើផ្ទៃនៃដែនដីប្រទេសមួយគឺ យើងស្គាល់អំពីព្រៃឈើនិងភ្នំនានារបស់វាអន្លង់អន្ទាក់របស់វា និងទីចោទខ្ពស់របស់វា វាលភក់និងល្បាប់តំបន់លិចទឹករបស់វា។ យើងនឹងមិនអាចទាញយកផលប្រយោជន៍ផលចំណេញពី

លក្ខណៈធម្មជាតិរបស់ដែនដីប្រទេសមួយជាមួយស្ថានភាពហេតុការណ៍មួយបានទេ លុះត្រាតែយើងធ្វើការប្រើប្រាស់នៅពួកមគ្គុទេសន៍ ពួកអ្នកនាំផ្លូវនៅក្នុងដែនដីប្រទេសនោះ។

៥៣)-ត្រូវតែធ្វើមិនដឹងមិនឮនៅគោលការណ៍ណាមួយក្នុងចំណោមគោលការណ៍៤ឬ៥ខាងក្រោមនេះដែលមិនសមស្របនឹងស្តេចល្មោភសង្គ្រាមមួយ។

៥៤)-នៅពេលស្តេចល្មោភសង្គ្រាមមួយអង្គវាយប្រហារលើរដ្ឋនគរដ៏មានអំណាចមួយ ក្រុមឧត្តមសេនីយរបស់ទ្រង់បង្ហាញសំដែងយោបល់ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងការទប់ស្កាត់មិនអោយមានការប្រមូលផ្តុំកងកំលាំងទ័ពរបស់សត្រូវ។ ទ្រង់ស្តាប់ឱវាទរាល់អ្នកជំទាស់នឹងព្រះរាជតំរិះរបស់ទ្រង់ហើយនិងសម្ព័ន្ធមិត្តទាំងឡាយរបស់ពួកគេដែលត្រូវបានជំទាស់រារាំងពីការចូលរួមប្រឆាំងនឹងទ្រង់។

៥៥)-ហេតុដូច្នេះព្រះអង្គមិនវាយប្រហារសម្ព័ន្ធមិត្តដោយខ្លួនឯងពេញមួយរដូវប្រាំង ហើយទ្រង់ក៏មិនចិញ្ចឹមចិត្តក្តោបអំណាចលើរដ្ឋនគរដទៃៗទៀតដែរ។ប៉ុន្តែព្រះអង្គទ្រង់អនុវត្តន៍គំរោងផែនការដែលបានរៀបចំរួចជាស្រេចដោយសំងាត់របស់ទ្រង់ផ្ទាល់ដោយរក្សាការស្ញើចសរសើរដល់អ្នកប្រឆាំងជំទាស់របស់ទ្រង់។ដូច្នេះទ្រង់មានសមត្ថភាពអាចវាយដណ្តើមកាន់កាប់បណ្តារទីក្រុងទាំងឡាយរបស់ពួកគេ ហើយផ្តួលរំលំរាជាណាចក្រទាំងឡាយរបស់ពួកគេ។

៥៦)-ការផ្តល់រង្វាន់ដោយមិនគិតពីក្បួនច្បាប់បទបញ្ជាក្បួនខ្នាតត្រឹមត្រូវ ចេញបទបញ្ជាដោយមិនគិតពីការរៀបចំចាត់ចែងពីមុនៗមក ហើយអ្នកនឹងអាចដោះស្រាយបញ្ហាកងទ័ពទាំងមូលដូចជាអ្នកដោះស្រាយជាមនុស្សតែម្នាក់គត់។

៥៧)-ប្រឈមមុខទៅនឹងទាហ៊ានរបស់អ្នកជាមួយការងារពិតប្រាកដដោយខ្លួនវាដោយមិនដែលអោយពួកគេដឹងនៅគំរោងផែនការរបស់អ្នកឡើយ នៅពេលអ្នកមានទស្សនៈវិស័យភ្លឺស្វាងនាំវាយកមកដាក់ពីមុខភ្នែករបស់ពួកគេ ប៉ុន្តែមិនប្រាប់ពួកគេអំពីអ្វីទាំងអស់ នៅពេលដែលមានស្ថានការណ៍អាប់អួរ។

៥៨)-យកទាហ៊ានរបស់អ្នកដាក់នៅក្នុងគ្រោះថ្នាក់ស្លាប់រស់ឬក្នុងភ័យន្តរាយលើជ្រោះមរណៈ ហើយទាហ៊ានកងទ័ពរបស់អ្នកនឹងស្តារស្ថានការណ៍អោយរស់ឡើងវិញ។ បោះកងទ័ព

របស់អ្នកទៅក្នុងបញ្ហាលំបាកទាល់ច្រកដែលអស់សង្ឃឹម ហើយកងទ័ពរបស់អ្នកនឹងវាយទំលុះបុកចេញប្រកបដោយសុវត្ថិភាព។

៥៩)-សំរាប់វាគឺមានតំលៃបំផុតនៅពេលដែលកងទ័ពមួយបានធ្លាក់ទៅក្នុងមាគ៌ាដ៏គ្រោះថ្នាក់ ហើយដែលអាចវាយសំរុកបុកប្រហារសត្រូវដូចខ្យល់ព្យុះសង្ឃរា សំរេចបានជោគជ័យឬជ័យជំនះ។

៦០)-ជ័យជំនះនៅក្នុងសង្គ្រាមត្រូវបានទទួលបានការបោះជំរកឬជំរុំយ៉ាងប្រុងប្រយត្ន័ដោយពួកយើងខ្លួនឯង ដើម្បីវាយប្រហារនៅគោលដៅឬគោលបំណងរបស់សត្រូវ។

៦១)-ដោយការកំទេចកងទ័ពសត្រូវជាបន្តបន្ទាប់ យើងនឹងបន្តរត់ដេញតាមសំលាប់អគ្គមេបញ្ជាការរបស់សត្រូវរហូតដល់តែបាន។

៦២)-នេះត្រូវបានហៅថាសមត្ថភាពដើម្បីសំរេចជោគជ័យនៅរឿងមួយដោយគ្រាន់តែប្រើល្បិចបន្តិចបន្តួច។

៦៣)-នៅថ្ងៃដែលអ្នកចេញបញ្ជារបស់អ្នកអោយវាយលុកខ្មាំងសត្រូវ ត្រូវបញ្ជាអោយរាំងខ្ទប់ច្រកឆ្លងកាត់តាមព្រំដែន បិទច្រកព្រំដែនបំផ្លិចបំផ្លាញបញ្ជីចំណាយចំណូលផ្លូវការចំនួនសរុបរបស់មន្ត្រីកងទ័ព និងបញ្ឈប់ការឆ្លងកាត់ទៅមករបស់ពួកបេសកកជន ពួកអ្នកនាំសារទាំងអស់។

៦៤)-ត្រូវតែតឹងតែងនៅក្នុងជួរសភាក្រុមប្រឹក្សានៅក្នុងបន្ទាប់សាលប្រជុំពិភាក្សាប្រឹក្សាយោបល់ដើម្បីអោយអ្នកអាចត្រួតត្រាសភាពការណ៍សឹកបាន។

៦៥)-ប្រសិនបើសត្រូវទុកចោលទ្វារអោយបើកចំហរមួយ អ្នកត្រូវតែប្រញាប់ប្រញាល់ស្ទុះចូលទៅក្នុង។

៦៦)-បង្ការខ្មាំងសត្រូវរបស់អ្នកមិនអោយដណ្តើមយកអ្វីដែលអ្នកត្រូវការចាំបាច់ជាអាយុជីវិតទេ ហើយអ្នកដណ្តើមយកអ្វីដេលសត្រូវអ្នកចង់បាន អ្វីដែលជាអាយុជីវិតរបស់សត្រូវរបស់អ្នក ដោយអ្នកចេះប្រើគំរោងសំងាត់គិតគូរផែនការក្បត់ប្រកបដោយល្បិចកលដ៏ប៉ិនប្រសប់ស្រប ទៅតាមពេលវេលាឱកាសហុចអោយនៅពេលសត្រូវអ្នកដល់មូលដ្ឋានមួយ។

៦៧)-សូមអ្នកដើរលើផ្លូវដែលបានកំណត់ដោយក្បួនច្បាប់ ហើយធ្វើជាគួរសមដោយខ្លួនឯង ចំពោះសត្រូវរហូតដល់អ្នកអាចវាយប្រហារនៅក្នុងសមរភូមិដែលបានកំណត់ទុកមួយឬក្នុងការប្រយុទ្ធដែលសំរេចទុកមួយ។

៦៨)-ដូច្នេះនៅពេលដំបូងសំដែងបង្ហាញចេញនៅភាពអៀនខ្មាស់ដូចស្រីក្រមុំម្នាក់រហូតដល់សត្រូវរបស់អ្នក ផ្តល់អោយអ្នកនៅការបើកចំហរមួយ បន្ទាប់មកស្ទុះដណ្តើមជើងយ៉ាងឆាប់រហ័សបំផុត សង្គ្រប់សត្រូវដូចជាទន្សាយគល់កំពុងរត់មួយ ហើយវានឹងយឺតពេលទៅហើយសំរាប់សត្រូវដើម្បីវាយទុបទល់ប្រឆាំងនឹងអ្នកវិញនោះ។

## ១២-ការវាយប្រហារដោយប្រើភ្លើង(The Attack By Fire):

១)-លោកស៊ុន-ជូបានមានប្រសាសន៍ថា«មាននមធ្យោបាយ៥យ៉ាងសំរាប់ធ្វើការវាយប្រហារដោយប្រើភ្លើង។

_ទីមួយគឺដុតបំផ្លាញកងទ័ពទាហ៊ានរបស់ខ្មាំងនៅក្នុងជំរុំរបស់ពួកគេ។

_ទីពីរគឺដុតបំផ្លាញឃ្លាំងស្តុកនានា។

_ទីបីគឺដុតបំផ្លាញមធ្យោបាយដឹកជញ្ជូន រថយន្ត និងយានជំនិះ។

_ទី៤គឺដុតបំផ្លាញឃ្លាំងអាវុធ បរិក្ខាសឹក គ្រាប់រំសេវ និងអាវុធយុទ្ធភ័ណ្ឌនានា។

_ទី៥គឺការវាយចោលភ្លើងដុតភ្លើង ទំលាក់ភ្លើងក្នុងចំណោមសត្រូវ។

២)-ដើម្បីអនុវត្តន៍ការវាយប្រហារមួយ យើងត្រូវតែមានមធ្យោបាយដែលអាចប្រើប្រាស់ធ្វើទៅបាន។ សំភារៈសំរាប់បង្កើនការវាយប្រហារដោយភ្លើង គួរតែជានិច្ចកាលត្រូវបានរក្សាទុកក្នុងការត្រៀមទុកមុនជាស្រេច។

៣)-មានរដូវកាលដ៏សមស្របមួយសំរាប់ធ្វើការវាយប្រហារដោយភ្លើង និងថ្ងៃពិសេសៗសំរាប់ចាប់ផ្តើមមហាអគ្គីសភ័យមួយ។

៤)-រដូវកាលសមរម្យគឺនៅពេលអាកាសធាតុស្ងួតហែងខ្លាំង ហើយមានថ្ងៃពិសេសៗគឺទាំងនោះមានក្រុមផ្កាយដែលមានរាងកន្ត្រក រាងជញ្ជាំង រាងស្លាបបក្សី ឬរាងឈើទទឹងឈើរបារសំរាប់រាងផ្កាយទាំង៤នេះគឺគ្រប់ថ្ងៃទាំងអស់កើតមានខ្យល់ខ្លាំងក្លាឥតឈប់ឈរ។

៥)-ការវាយប្រហារដោយភ្លើងជាការវាយប្រហារមួយគួរតែត្រូវបានរៀបចំត្រៀមទុកសំរាប់ជួបប្រយុទ្ធដោយការអភិវឌ្ឍន៍ដែលអាចធ្វើទៅបាន៥យ៉ាងគឺ៖

៦)-(១)-នៅពេលដែលភ្លើងផ្ទុះឆេះឡើងនៅក្នុងជំរុំសត្រូវ ការឆ្លើយតបភ្លាមៗជាមួយការវាយប្រហារមួយចេញពីខាងក្រៅ។

៧)-(២)-ប្រសិនបើមានការផ្ទុះឆេះភ្លើងមួយ ប៉ុន្តែទាហ៊ានរបស់ខ្មាំងនៅតែនៅស្ងប់ស្ងៀម រងចំឱកាសល្អ ប្រើពេលវេលារងចាំសិន ហើយកុំធ្វើការវាយប្រហារ។

៨)-(៣)-នៅពេលដែលកំលាំងអណ្តាតភ្លើងឆេះសន្ធោសន្ធៅរីករាលដាលឈានទៅដល់ទីខ្ពស់របស់វា សូមដេញតាមវាឡើងទៅវាយប្រហារមួយ ប្រសិនបើបែបនោះគឺអាចប្រតិបត្តិទៅបាន ប្រសិនបើមិនអាច សូមអ្នកស្នាក់នៅតែមួយកន្លែងបានហើយ។

៩)-(៤)-ប្រសិនបើវាអាចធ្វើទៅកើតដើម្បីធ្វើការវាយប្រហារមួយជាមួយភ្លើងពីខាងក្រៅ កុំរងចាំភ្លើងឆេះផ្ទះចេញពីខាងក្នុង ហើយបែងចែកការវាយប្រហាររបស់អ្នកតាមពេលវេលាជាទីពេញចិត្តមួយ។

១០)-(៥)-នៅពេលដែលអ្នកចាប់ផ្តើមវាយប្រហារដោយភ្លើងឆេះមួយ អ្នកត្រូវតែនៅផ្នែកខាងលើខ្យល់ កុំវាយប្រហារចេញពីខាងក្រោមខ្យល់។

១១)-នៅពេលដែលខ្យល់មួយដែលកើតមាននៅពេលថ្ងៃជាប់រហូតអស់រយៈពេលដ៏យូរ ប៉ុន្តែនៅពេលយប់មានខ្យល់រំភើយមួយធ្លាក់មកក្នុងពេលឆាប់ៗ។

១២)-រាល់គ្រប់កងទ័ពការអភិវឌ្ឍន៍ទាំង៥បានជាប់ទាក់ទងគ្នាជាមួយភ្លើង ត្រូវតែត្រូវបានយល់ដឹងជាពិសេសគឺចលនាទាំងឡាយរបស់ក្រុមផ្កាយដែលត្រូវបានគណនាគន់គូរហើយការក្លំមើលតាមដានមួយត្រូវបានរក្សាធ្វើជាប្រចាំរហូដល់មានថ្ងៃសមរម្យ។

១៣)-ហេតុដូច្នេះយុទ្ធវិធីទាំងនោះដែលប្រើប្រាស់ភ្លើងជាជំនួយមួយសំរាប់ការវាយប្រហារ បង្ហាញអោយឃើញនៅភាពឆ្លាតវៃ បញ្ញាភ្លៀវភ្លា ហើយអ្នកទាំងនោះដែលប្រើទឹកជាជំនួយមួយសំរាប់ការវាយប្រហារ ទទួលបានការចូលដល់ការត្រួតត្រាកងកំលាំងទ័ពមួយ។

១៤)-ដោយឫតាមមធ្យោបាយទឹក សត្រូវមួយអាចត្រូវបានពួនស្ទាក់វាយ ប៉ុន្តែមិនត្រូវបានប្លន់នៅរាល់របស់របរទ្រព្យកម្មសិទ្ធិរបស់គាត់ទាំងអស់ទេ។

១៥)-ការមិនសប្បាយចិត្តគឺជាភ័ព្វវាសនារបស់មនុស្សម្នាក់ដែលព្យាយាមយកឈ្នះការប្រយុទ្ធរបស់គាត់ ហើយបន្តនៅក្នុងការវាយប្រហាររបស់គាត់ដោយគ្មានការដាំបណ្តុះនៅព្រលឹងស្មារតីនៃការត្រិះរិះពិចារណាអោយបានច្រើនសន្ទឹកសន្ធាប់ សំរាប់លទ្ធផលគឺខាតបង់ពេលវេលាឥតប្រយោជន៍ ហើយកើតការឈប់ស្ងៀមទូទៅ។

១៦)-ហេតុដូច្នេះលោកស៊ុនជួបាននិយាយថា «មេដឹកនាំឬអ្នកគ្រប់គ្រងដែលមានសតិបញ្ញាលើសលុប ធ្វើផែនការគំរោងការសំងាត់របស់គាត់ទុកជាមុនរួចជាស្រេចយ៉ាងល្អប្រពៃ ឧត្តមសេនីយល្អដាំបណ្តុះធនធានមនុស្សរបស់គាត់។

១៧)-កុំធ្វើការរំកិលទ័ព លុះត្រាតែអ្នកមើលឃើញពីផលចំណេញឬសារៈប្រយោជន៍មួយ។ កុំប្រើប្រាស់ទាហ៊ានរបស់អ្នក លុះត្រាតែមានអ្វីមួយត្រូវបានទទួលបាន។ កុំវាយប្រហារលុះត្រាតែទីតាំងសំខាន់ចាំបាច់។

១៨)-គ្មានមេដឹកនាំណាមួយគួរតែដាក់កងទ័ពទៅក្នុងសមរភូមិដោយគ្រាន់តែដើម្បីធ្វើអោយសប្បាយពេញចិត្ត បន្សាយកំហឹងផ្ទាល់ខ្លួនរបស់គាត់ទេ ហើយក៏គ្មានឧត្តមសេនីយណាមួយវាយប្រយុទ្ធក្នុងចំបាំងមួយយ៉ាងសមញ្ញ។

១៩)-ប្រសិនបើវាមានផលប្រយោជន៍ដល់អ្នកឬជាផលចំណេញរបស់អ្នកចូរធ្វើការរំកិលទ័ពទៅមុខ។ ប្រសិនបើគ្មានផលចំណេញនោះទេ សូមកុំរំកិលទ័ព រក្សាកងទ័ពនៅមួយកន្លែង។

២០)-នៅពេលដែលយើងខឹង ចូរធ្វើពុតជាសប្បាយរីករាយ ហើយនៅពេលដែលអ្នកកើតចិត្តមួរម៉ៅក្តៅក្រហាយមួយ ចូរធ្វើជាសប្បាចិត្ត។

២១)-ប៉ុន្តែរាជាណាចក្រមួយដែលនៅពេលមួយត្រូវបានបំផ្លិចបំផ្លាញ អាចមិនដែលត្រឡប់មកម្តងទៀតដោយរស់រានមានជីវិតដូចមុននោះទេ ឬក៏ការស្លាប់ មរណៈភាព មិនដែលអាចត្រឡប់ជារស់រានមានជីវិតឡើងវិញបាននោះទេ។

២២)-ហេតុដូច្នេះ មេដឹកនាំដែលមានសតិបញ្ញាវឆ្លាតវៃ ត្រូវមានការប្រុងប្រយ័ត្នគ្រប់ជំហ៊ាន ហើយឧត្តមសេនីយល្អត្រូវពោរពេញទៅដោយបុព្វហេតុ ការព្រមាននិងប្រុងស្មារតីជានិច្ច។ នេះគឺជាមាគ៌ាដើម្បីរក្សាប្រទេសមួយអោយមានសន្តិភាព ហើយរក្សាកងទ័ពមួយដែលនៅគង់វង់ដដែល។

## ១៣-ការប្រើប្រាស់ចារបុរស( The Use of Spies ):

១)-លោកស៊ុន-ជូ បានមានប្រសាសន៍ថា«ការដឹកនាំទ័ព១០០០០០នាក់រំកិលចូលទៅក្នុងដែនដីរបស់សត្រូវក្នុងចំងាយដ៏ឆ្ងាយនោះ តំរូវអោយបាត់បង់យ៉ាងធ្ងន់ធ្ងរនៅជីវិតមនុស្ស ហើយតំរូវអោយបង្ហូរចេញនៅធនធានរបស់រដ្ឋអស់ជាច្រើនសន្ធឹកសន្ធាប់។ ការចំណាយប្រចាំថ្ងៃនឹងបង្កើនទឹកប្រាក់អស់រាប់ពាន់តម្លឹង នឹងកើតមានការរំជើបរំជួលជាខ្លាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស ហើយកងទ័ពនឹងធ្លាក់ទឹកចិត្តហេវហត់អស់កំលាំងឋាមពលនៅតាមផ្លូវធំៗ។ ហើយមានប្រជាជនប្រមាណជា៧០០០គ្រួសារ នឹងត្រូវបានបង្អាក់ឬបាត់បង់នៅកំលាំងពលកម្មរបស់ពួកគេ។

២)-កងទ័ពសត្រូវអាចប្រឈមមុខគ្នាអស់រយៈពេលជាច្រើនឆ្នាំតស៊ូវាយប្រយុទ្ធដើម្បីជ័យជំនះដែលត្រូវបានសំរេចចិត្តនៅក្នុងថ្ងៃតែមួយ ឬមួយថ្ងៃគត់។ នេះជាការប្រព្រឹត្តដូច្នេះនៅតែធ្វើមិនដឹងមិនឮនៅលក្ខខណ្ឌឬស្ថានភាពដ៏សមញ្ញរបស់សត្រូវពីព្រោះដំណើរចេងកំហឹងគំគួនមួយដើម្បីឈ្នានីសសត្រូវ ធ្វើអោយសត្រូវចាយវាយធនធានប្រាក់របស់រយតំលឹង ដើម្បីការពារកិត្តយសនិងការចំណាយលើប្រាក់បៀវត្ស ហើយធ្វើអោយឈានដល់កំរិតខ្ពស់នៃអំពើអមនុស្សធម៌។

៣)-អ្នកដែលធ្វើដូច្នេះគឺមិនមែនជាមេដឹកនាំមនុស្សទេគ្មានអំណោយជួយដល់ព្រះមហាក្សត្ររបស់គាត់ទេ គ្មានម្ចាស់លើជ័យជំនះទេ។

៤)-ដូច្នេះអ្វីដែលធ្វើអោយប្រសើរឡើងដល់ព្រះមហាក្សត្រដ៏ឆ្លាតវៃ និងឧត្តមសេនីយល្អៗ ដើម្បីធ្វើការវាយប្រហារ និងវាយលុកលុយឈ្លានពាន ហើយសំរេចបានកិច្ចការ ទាំងឡាយហួសពីការឈានដល់របស់មនុស្សធម្មតាគឺជាការដឹងមុន ពូកែគណនាគន់គូរ ប៉ាន់ប្រមាណនៅស្ថានការណ៍។

៥)-ឥឡូវនេះ អ្នកដែលពូកែគណនាគន់គូរប៉ាន់ប្រមាណស្ថានការណ៍ ដឹងរាល់រឿងហេតុជា មុនបែបនេះ មិនអាចត្រូវបានទាញចេញ ឬចំរាញ់ចេញពីស្មារតីព្រលឹងវិញ្ញាណបានឡើយវា ក៏មិនអាចត្រូវបានទទួលបានបទពិសោធន៍ដោយចាំស្គាល់នោះទេ ហើយក៏មិនមែនបាន មកពីការគណនាគន់គូរដែលទាញផលចេញពីវិចារណញ្ញាណណាមួយបានទេ។

៦)-ចំណេះដឹងនៃការរៀបចំបែងចែកកងទ័ពរបស់សត្រូវ អាចត្រូវបានទទួលបានតែប៉ុណ្ណោះពី មនុស្សដទៃៗទៀត។

៧)-ហេតុដូច្នេះ ការប្រើប្រាស់ចារបុរសដែលមាន៥ចំណាត់ថ្នាក់គឺៈ

(១)-ចារបុរសមនុស្សក្នុង( The Local Spies )។

(២)-ចារបុរសរនុកក្នុង( The Inward Spies = Internal Spies ) ។

(៣)-ប្រតិចារបុរស( The Converted Spies = The Double Spies ) ។

(៤)-មរណៈចារបុរស( The Doomed Spies = The Dead Spies )។

(៥)-ចារបុរសមនុស្សរស់( The Surviving Spies = The Living Spies )។

៨)-នៅពេលដែលប្រភេទចារបុរសទាំង៥ទាំងអស់នេះ ធ្វើការទាំងអស់គ្នា គ្មាននរណា ម្នាក់អាចរកឃើញប្រព័ន្ធសំងាត់បានទេ។ នេះត្រូវបានហៅថា«ការប្រើប្រាស់ប្រព័ន្ធបណ្ដាញ សំងាត់យ៉ាងប៉ិនប្រសប់បែបអច្ឆរិយៈ»។វាគឺអាស្រ័យលើក្រុមទីប្រឹក្សាមុនៗរបស់ព្រះមហាក្សត្រ ដ៏ច្រើនបំផុត ឬក៏មនុស្សជំនិតៗ បញ្ញាជនរបស់ទ្រង់។

៩)-ការមានចារបុរសមនុស្សក្នុងមានន័យថាជាការប្រើប្រាស់នៅបណ្ដារសេវាកម្មផ្ទៃក្នុងរបស់ ពួកអ្នកស្រុកនៅក្នុងស្រុកឬក៏នៅប្រទេសខ្មាំងតែម្ដង ឬប្រើប្រាស់មនុស្សជនជាតិខ្មាំងនៅ ក្នុងទឹកដីខ្មាំងអោយធ្វើការសើបយកកាណ៍ពតិមានសំងាត់ៗពីខ្មាំង។

១០)-ការមានចារបុរសនុកក្នុងមានន័យថាជាការធ្វើការប្រើប្រាស់បណ្តារមន្ត្រីជាន់ខ្ពស់របស់ខ្មាំង ឬមនុស្សជំនិតៗរបស់ខ្មាំងបំរើការសំងាត់អោយយើង ព្រមទាំងសើបការណ៍សំងាត់ពីខ្មាំងមកអោយយើង។

១១)-ការមានប្រតិចារបុរសគឺការចាប់យកឬទិញទឹកចិត្តបណ្តារពល់ពួកចារបុរសរបស់ខ្មាំង ហើយប្រើប្រាស់ពួកគេសំរាប់បំរើការ ធ្វើការងារសំងាត់ទៅតាមគោលបំណងគោលដៅរបស់យើង។

១២)-ការមានមរណៈចារបុរសគឺជាកាបង្កើតរឿងរ៉ាវហេតុការណ៍ពិតប្រាកដផ្សេងៗជាច្រើនជាចំហរសំរាប់បំរើអោយគោលបំណងនៃការបោកប្រាស់ បោកបញ្ឆោតខ្មាំង ហើយអនុញ្ញាតិអោយឬក៏បញ្ជាអោយចារបុរសរបស់យើង ធ្វើជាយល់ដឹងហេតុការណ៍រឿងរ៉ាវទាំងនោះហើយធ្វើក្លែងពុតជាថ្លោះធ្លោយភ្លាត់មាត់រ៉ាយរ៉ាប់រៀបរាប់ឬនិយាយរាយការណ៍ឬបែកធ្លាយពត៌មានសំងាត់អោយសត្រូវដឹង។

១៣)-ទីបញ្ចប់គឺចារបុរសមនុស្សរស់គឺ បណ្តារអ្នកទាំងអស់នោះដែលនាំពត៌មាននានាពីខ្មាំងត្រឡប់យកមកអោយយើង ឬក៏បញ្ជូនភ្នាក់ងារសើបការសំងាត់ទៅយកពត៌មានឬដំណឹងផ្សេងៗពីជំរុំខ្មាំងត្រឡប់យកមកអោយយើងវិញ។

១៤)-ហេតុដូច្នេះ គ្មាននរណានៅក្នុងកងទ័ពទាំងមូលមានទំនាក់ទំនងជិតស្និតជាមួយសត្រូវច្រើនជាចារបុរសដែលត្រូវបានរក្សាទុកនោះទេ។ គ្មាននរណាមួយគួរតែត្រូវបានផ្តល់រង្វាន់ច្រើនដោយសេរីនោះទេ ហើយគ្មានជំនួញដទៃទៀតៗគួរតែត្រូវបានរក្សារឿងសំងាត់ផែនការសំងាត់អាថិកំបាំងធំៗនោះទេ។

១៥)-ពួកចារបុរសមិនអាចត្រូវបានប្រើប្រកបដោយប្រយោជន៍ដោយគ្មានសុខុមញ្ញាណដែលធ្វើដោយអំណាចអព្ភន្តរញ្ញាណពិតប្រាកដមួយនោះទេ។

១៦)-ពួកចារបុរសមិនអាចត្រូវបានរៀបចំចាត់ចែងដោយសមរម្យដោយគ្មានក្តីមេត្តាករុណានិងក្តីស្មោះត្រង់នោះទេ។

១៧)-ដោយគ្មានភាពប៉ិនប្រសប់ឆ្លាតវៃប្រកបដោយល្បិចកលខាងផ្លូវចិត្តចារបុរសម្នាក់មិនអាចធ្វើអោយពិតប្រាកដនៃការពិត ឬរឿងពិតនៃរបាយការណ៍ ឬសេចក្តីរាយការណ៍របស់ពួកគេនោះទេ។

១៨)-ជាល្បិចកលប៉ិនប្រសប់! ជាល្បិចកលប៉ិនប្រសប់! ហើយប្រើប្រាស់នៅចារបុរសរបស់អ្នកសំរាប់រាល់គ្រប់ប្រភេទនៃមុខជំនួញទាំងឡាយ។

១៩)-ប្រសិនបើផ្នែកសំងាត់មួយនៃពត៌មានត្រូវបានបកអាក្រាតដោយចារបុរសម្នាក់មុនពេលវេលាទុំជោរ គាត់ត្រូវតែត្រូវបានកាត់ទោសប្រហារជីវិតរួមគ្នាជាមួយមនុស្សដែលជាបណ្តាញសំងាត់របស់គាត់ និងមនុស្សដែលត្រូវបានគាត់ប្រាប់ពត៌មាននោះ។

២០)-ថាតើកម្មវត្ថុគោលដៅគឺដើម្បីវាយកំទេច វាយរុញច្រានកងទ័ពមួយ ដើម្បីធ្វើព្យុះភ្លៀងនៅក្នុងទីក្រុងមួយ ឬដើម្បីធ្វើឃាតឬធ្វើឃាតកម្មនយោបាយលើបុគ្គលមួយ វាជានិច្ចកាលមានសារៈសំខាន់ណាស់សំរាប់ចាប់ផ្តើមដោយការរកអោយឃើញនៅបណ្តារឈ្មោះអ្នកចូលរួមទាំងឡាយ មន្ត្រីជំនួយការឬជំនិតទីប្រឹក្សាយោបល់ អ្នកយាមទ្វារនិងអ្នកការពារអ្នកយាមល្បាតរបស់អគ្គមេបញ្ជាការឬឧត្តមសេនីយ.........។ ពួកចារបុរសរបស់យើងត្រូវតែត្រូវបានប្រគល់អំណាចអោយដើម្បីធ្វើអោយបានដឹងជាប្រាកដនៅអ្នកទាំងនេះ។

២១)-ចារបុរសរបស់សត្រូវដែលបានមកបង្កប់ឈ្លបការណ៍ពីយើងត្រូវតែត្រូវបានរកអោយឃើញស្រាវជ្រាវរកខ្សែបណ្តាញជនបង្កប់ ហើយព្យាយាមល្បួងបញ្ចុះបញ្ចូលដោយសូកប៉ាន់ទិញទឹកចិត្តអោយធ្វើជាជនបង្កប់របស់យើងប្រើប្រាស់តាមគោលបំណងផែនការយកពត៌មានពីខ្មាំងមកអោយយើង និងនាំពត៌មានបំពុលទៅអោយខ្មាំងវិញ និងត្រូវបានផ្តល់ជំរកយ៉ាងមានផាសុកភាពដល់គេវិញ។ ដូច្នេះពួកគេនឹងក្លាយទៅជាប្រតិចារបុរសរបស់យើងហើយអាចប្រើប្រាស់បានតាមសេចក្តីត្រូវការដើម្បីបំរើសេវារបស់យើង។

២២)-វាគឺតាមរយៈពត៌មានដែលត្រូវបាននាំយកដោយចារបុរស ប្រតិចារបុរសដែលយើងអាចយកជាការបានឬយើងអាចត្រូវការចាំបាច់ ហើយបំរើអោយឬជួយដល់បណ្តារពួកចារបុរសមនុស្សក្នុង និងចារបុរសមនុស្សវនុករបស់យើង។

២៣)-ជាថ្មីម្តងទៀត វាកំពុងជាប់ជំពាក់ទៅនឹងពត៌មានរបស់គាត់ដែលផ្តល់លក្ខណៈងាយស្រួលដល់មរណៈចារបុរសរបស់យើង នាំយកចរន្តពត៌មានក្លែងក្លាយ ទៅផ្សព្វផ្សាយអោយសត្រូវដឹងឮ។

២៤)-ជាទីបញ្ចប់ វាគឺដោយសារពត៌មានរបស់ប្រតិចារបុរសដែលធ្វើអោយចារបុរសមនុស្សរស់អាចត្រូវបានប្រើប្រាស់ទៅតាមឱកាសពេលវេលាដែលត្រូវបានចាត់តាំងអោយទៅយកការណ៍សំងាត់។

២៥)-គោលដៅនិងគោលបំណងទិសដៅនៃការប្រើប្រាស់ចារបុរសនៅក្នុងផ្នែកខុសប្លែកគ្នាទាំង៥របស់វាទាំងអស់គឺជាការយល់ដឹងឬជាចំណេះដឹងពត៌មានរបស់សត្រូវ ហើយចំណេះដឹងពត៌មាននេះអាចត្រូវបានមានប្រភពតែប៉ុណ្ណោះចេញពីប្រតិចារបុរសដូចក្នុងឧទាហរណ៍ដំបូងៗ។ ហេតុដូច្នេះ វាមានសារៈសំខាន់ណាស់ដែលថាប្រតិចារបុរស ត្រូវបានចាត់ទុកជាភាពឃើញវែងឆ្ងាយបំផុតសំរាប់ជាទុនវិភាគប្រៀបធៀប និងសន្និដ្ឋានស្ថានភាពពត៌មាន។

២៦)-ដូចសម័យបុរាណតំណាលថា«ការកើតមានឡើងនៃរាជវង្សយីនគឺដោយសារតែលោកអីឈិដែលបានបំរើជាជនបង្កប់នៅនគរសៀ។ ដូចគ្នានេះដែរ ការកើតមានឡើងនៃរាជវង្សជូគឺដោយសារតែលោកឡុយ៉ាដែលបានបំរើការជាជនបង្កប់អោយរាជវង្សយីន។

២៧)-ហេតុដូច្នេះ វាគ្រាន់តែត្រូវបានបំភ្លឺតែប៉ុណ្ណោះនៅរបៀបប្រើប្រាស់ប្រព័ន្ធចារៈបុរសទាំង៥ហើយមានតែមេដឹកនាំដែលមានសតិបញ្ញាភ្លឺស្វាងឈ្លាសវៃលើសលុបនិងឧត្តមសេនីយវៃឆ្លាតតែប៉ុណ្ណោះដែលនឹងប្រើបញ្ញាដ៏ខ្ពស់បំផុតនៅក្នុងកងទ័ពដោយប្រើផ្នែកសើបការណ៍យកពត៌មានហើយនៅពេលបន្តទៀត ពួកគេសំរេចបានលទ្ធផលដ៏ធំធេង។ ពួកចារបុរសគឺជាសមាសភាពឬកត្តាដ៏សំខាន់បំផុតមួយប្រៀបបានទៅនឹងទឹក ពីព្រោះដោយសារពួកគេទើបកងទ័ពមានសមត្ថភាពផ្លាស់ប្តូរក្បួនប្រយុទ្ធ យុទ្ធសាស្ត្រ និងយុទ្ធវិធីបានទាន់ពេលវេលាស្របទៅតាមស្ថានការណ៍ជាក់ស្តែង។ សមត្ថភាពកងទ័ពគ្រប់យ៉ាងដើម្បីធ្វើការរំកិលទ័ព ប្តូរក្បួនយុទ្ធសាស្ត្រ បត់បែនយុទ្ធវិធី ប្រែប្រួលយុទ្ធសាស្ត្រទៅតាមឱកាសហុចអោយ នាំទៅរកជោគជ័យ ក៏ពឹងផ្អែកអាស្រ័យលើប្រព័ន្ធចារៈបុរសទាំង៥នេះឯង។

# សូមអរគុណដល់ជនរួមជាតិខ្មែរដែលបានអានឯកសារអស់ទាំងនេះ!